ក្រសួងអប់រំ យុវជន និងកីឡា

វិទ្យាស្ថានជាតិអប់រំ

# ឯកសារសិក្សាស្រាវជ្រាវ

# ភាគ ១

គម្រោងលើកកម្ពស់គុណភាពអប់រំ ( EEQP-2011 )

# បុព្វកថា

ការបណ្តុះបណ្តាលធនធានមនុស្ស មិនអាចផ្តោតទៅលើតែការបង្រៀនមួយមុខបានទេ វាត្រូវមានកត្តារួមផ្សំជាច្រើនទៀត ដើម្បីឱ្យការបង្រៀន និងរៀនប្រកបដោយប្រសិទ្ធភាព ជាពិសេសបើគ្រូ ខ្វះការសិក្សាស្រាវជ្រាវ ពួកគេមិនអាចសម្រេចបានជោគជ័យពីអាជីព របស់ខ្លួនឡើយ។ ដូច្នេះការសិក្សាស្រាវជ្រាវជាការចាំបាច់របស់មន្ត្រីអប់រំ អ្នកគ្រប់គ្រង និងសាស្ត្រាចារ្យ ក្នុងការអភិវឌ្ឍជំនាញវិជ្ជាជីវៈឱ្យកាន់តែល្អប្រសើរឡើង។

ដើម្បីសម្រេចបេសកកម្មដ៏ថ្លាថ្លៃនេះ វិទ្យាស្ថានជាតិអប់រំ ដែលជាសេនាធិការរបស់ក្រសួងអប់រំ យុវជន និងកីឡា បានខំយកចិត្តទុកដាក់ធ្វើការសិក្សាស្រាវជ្រាវ ស្វែងរកចំណុចវិជ្ជមាន ចំណុចគួរកែលម្អ ព្រមទាំងបញ្ហាប្រឈមដែលកំពុងជួបប្រទះនៅតាមវិទ្យាល័យនានា និងវិធានការមួយចំនួន សម្រាប់ការអនុវត្តការងារ និងការបណ្តុះបណ្តាលគ្រូបង្រៀនឱ្យបានកាន់តែល្អប្រសើរឡើង។

កិច្ចការស្រាវជ្រាវនេះ ជាមូលដ្ឋានសម្រាប់ការអនុវត្តប្រកបដោយប្រសិទ្ធភាព ក្នុងការបង្រៀន និងរៀនរបស់គ្រូ និងសិស្ស ដើម្បីឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែងនៃសង្គមសកលភាវូបនីយកម្ម និងការធ្វើសមាហរណកម្មអាស៊ាននាឆ្នាំ២០១៥ ។

នៅទីបញ្ចប់ វិទ្យាស្ថានជាតិអប់រំ សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់ដៃគូអភិវឌ្ឍនានា ជាពិសេសធនាគារអភិវឌ្ឍអាស៊ី (ADB) ដែលបានជួយឧបត្ថម្ភជាបច្ចេកទេស និងថវិកាតាមរយៈគម្រោងលើកកម្ពស់គុណភាពអប់រំ (EEQP) និងសូមកោតសរសើរដល់ក្រុមសិក្សាស្រាវជ្រាវ របស់វិទ្យាស្ថានជាតិអប់រំ ដែលបានចំណាយពេលវេលា កម្លាំងកាយ កម្លាំងចិត្ត និងស្មារតី ដើម្បីឱ្យការងារស្រាវជ្រាវនេះទទួលបានលទ្ធផលល្អ។

រាជធានីភ្នំពេញ ថ្ងៃទី២១ ខែសីហា ឆ្នាំ២០១៦

**នាយកវិទ្យាស្ថានជាតិអប់រំ**

**បណ្ឌិត. សៀង សុចន្ធា**

# មាតិកាក្រុមសិក្សាស្រាវជ្រាវ

## ប្រធានបទស្រាវជ្រាវ

១. ការអភិវឌ្ឍកម្មវិធីសិក្សានៅវិទ្យាស្ថានជាតិអប់រំ

២. ការវាយតម្លៃអប់រំរបស់គរុនិស្សិត និងគ្រូឧទ្ទេស
នៅវិទ្យាស្ថានជាតិអប់រំ

៣. វិធីសាស្រ្តបង្រៀនបែបសិស្សមជ្ឈមណ្ឌលសម្រាប់មុខវិជ្ជា
វិទ្យាសាស្រ្តសង្គមនៅវិទ្យាស្ថានជាតិអប់រំ

៤. សមត្ថភាពដឹកនាំរបស់នាយកវិទ្យាល័យ

៥. គោលវិធីសិស្សមជ្ឈមណ្ឌលមុខវិជ្ជាសិក្សាសង្គមនៅវិទ្យាល័យ

# វិទ្យាស្ថានជាតិអប់រំ

## ប្រធានបទ

# ការអភិវឌ្ឍកម្មវិធីសិក្សានៅវិទ្យាស្ថានជាតិអប់រំ


**ក្រុមសិក្សាស្រាវជ្រាវ**

១. លោក ស៊ិន ដារ៉ា

២. លោកស្រី សេង សច្ចា

៣. លោកស្រី ហង់ ស្រីម៉ាច

៤. លោកស្រី នូ ចន្ទី

# មាតិកា


| ខ្លឹមសារ | ទំព័រ |
|---|---|
| មូលបទ ........................................ | ៣ |
| ថ្លែងអំណរគុណ ........................................ | ៣-៤ |
| 1. សេចក្តីផ្តើម ........................................ | ៤ |
| 2. សារៈតានៃការស្រាវជ្រាវ ........................................ | ៥-៦ |
| 3. គោលបំណងស្រាវជ្រាវ ........................................ | ៦ |
| 4. សំណួរស្រាវជ្រាវ ........................................ | ៦ |
| 5. ការរំលឹកទ្រឹស្តី ........................................ | ៦ |
| 6. វិធីសាស្ត្រស្រាវជ្រាវ ........................................ | ៨-៩ |
| 6.1 ការប្រមូលទិន្នន័យ | |
| 6.2 ការវិភាគទិន្នន័យ | |
| 7 លទ្ធផលដែលរំពឹងទុកសម្រាប់ការសិក្សាស្រាវជ្រាវ.................. | ៩ |
| 8 លទ្ធផល ........................................ | ១០-១៧ |
| 8.1 កម្មវិធីសិក្សាបច្ចុប្បន្ន | |
| 8.2 បញ្ហាប្រឈម ក្នុងការអនុវត្តកម្មវិធីសិក្សា | |
| 8.3 ការចូលរួមក្នុងការអនុវត្តកម្មវិធីសិក្សា | |
| 8.4 ការយល់ឃើញ ពីដំណើរការអភិវឌ្ឍកម្មវិធីសិក្សា | |
| 8.5 ការធ្វើកំណែទម្រង់ | |
| 8.6 ការចូលរួមការធ្វើកំណែទម្រង់ | |
| 8.7 ដំណោះស្រាយ | |
| 9. លទ្ធផល និង ការវិភាគ ........................................ | ១៧-១៨ |
| 9.1 បំណកស្រាយលទ្ធផល | |
| 9.2 ដែនកំណត់ និងបញ្ហាដែលជួបប្រទះក្នុងការសិក្សាស្រាវជ្រាវ | |

9.3 ប្រធានបទដែលពាក់ព័ន្ធសម្រាប់ការសិក្សាស្រាវជ្រាវបន្ត
10. សន្និដ្ឋាន ........ ១៨
11. អនុសាសន៍ ........ ១៩
12. ឯកសារយោង ........ ២០

## តំណាងសម្រួលអក្សរកាត់

| | |
|---|---|
| EEQP | គម្រោងពង្រឹងគុណភាពអប់រំ<br>Enhancing Education Quality Project |
| EFA | ការអប់រំសម្រាប់ទាំងអស់គ្នា<br>Education for All |
| ICT | បច្ចេកទេស ទំនាក់ទំនង និងព័ត៌មាន<br>Information Communication Technology |
| MoEYS | ក្រសួងអប់រំ យុវជន និង កីឡា<br>Ministry of Education, Youth and Sport |
| MoP | ក្រសួងផែនការ<br>Ministry of Planning |
| NIE | វិទ្យាស្ថានជាតិអប់រំ<br>National Institute of Education |
| RGoC | រាជរដ្ឋាភិបាលកម្ពុជា<br>Royal Government of Cambodia |

## មូលបទ

ការសិក្សាស្រាវជ្រាវនេះធ្វើឡើងដើម្បីសិក្សាពីកម្រិតយល់ដឹងរបស់សាស្ត្រាចារ្យ ប្រធានផ្នែកនីមួយៗពីដំណើរការនៃការអភិវឌ្ឍកម្មវិធីសិក្សានៅវិទ្យាស្ថានជាតិអប់រំ។

គោលបំណងក្នុងការសិក្សានេះផ្តោតលើការអភិវឌ្ឍកម្មវិធីសិក្សានៅវិទ្យាស្ថានជាតិអប់រំ ។ ក្រុមគោលដៅដែលត្រូវសម្ភាសន៍មានគណៈគ្រប់គ្រង ប្រធានផ្នែក និងសាស្ត្រាចារ្យនៃវិទ្យាស្ថានជាតិអប់រំ។វិធីសាស្ត្រដែលត្រូវបានប្រើប្រាស់ក្នុងការសិក្សាស្រាវជ្រាវតាមគឺបែបបរិមាណ និងគុណភាព។

លទ្ធផលដែលបានរកឃើញបង្ហាញថា គណៈគ្រប់គ្រង និងមន្ត្រីសាស្ត្រាចារ្យមានការយល់ដឹងផ្សេងគ្នាពីកម្មវិធីសិក្សា។ ក្នុងនោះ 93,75% នៃមន្ត្រីសាស្ត្រាចារ្យដែលត្រូវបានសម្ភាសន៍ឆ្លើយថា មិនបានយល់ដឹងពីការអភិវឌ្ឍកម្មវិធីសិក្សានោះទេ។

ក្នុងនោះដែរ 84,38% នៃមន្ត្រីសាស្ត្រាចារ្យក៏មិនបានបន្តចូលរួមក្នុងការធ្វើកម្មវិធីសិក្សានៅវិទ្យាស្ថានជាតិអប់រំ តែបង្ហាញពីបំណងក្នុងការចូលរួមធ្វើកម្មវិធីសិក្សានេះ ។ តាមការសិក្សានេះក៏បានរកឃើញ មន្ត្រី សាស្ត្រាចារ្យភាគច្រើនមិនបានចូលរួមក្នុងការធ្វើកម្មវិធីសិក្សាប៉ុន្តែមានឆន្ទះចង់ចូលរួមក្នុងដំណើរការធ្វើកម្មវិធីសិក្សាដែរ។ អ្វីដែលគួរឱ្យកត់សម្គាល់តាមរយៈការសម្ភាសន៍ឆ្លើយថាគាត់ក៏មិនបានដឹងដែរថាមន្ត្រីណាខ្លះដែលបានចូលរួមក្នុងការធ្វើកំណែទម្រង់ ឬផ្លាស់ប្តូរកម្មវិធីសិក្សាកន្លងមកនេះ ដោយគិតថាប្រហែលជាគណៈគ្រប់គ្រងជាអ្នកសម្រេចចិត្តធ្វើការងារទាំងអស់នេះ។ ៨0% (ប៉ែតសិបភាគរយ)នៃអ្នកអនុវត្តកម្មវិធីសិក្សាមិនបានដឹងពីការធ្វើកម្មវិធីសិក្សា ។ ទោះជាយ៉ាងណាក៏ដោយអ្នកចូលរួមរហូតដល់ជាង៩0%(កៅសិបភាគរយ) នៅតែចង់ចូលរួមក្នុងការធ្វើកំណែទម្រង់និងការផ្លាស់ប្តូរកម្មវិធីសិក្សានេះដែរ។

អនុសាសន៍សំខាន់និងចាំបាច់មួយចំនួនត្រូវបានធ្វើឡើងសម្រាប់វិទ្យាស្ថានជាតិអប់រំ កម្មវិធីសិក្សាគួរត្រូវផ្សព្វផ្សាយឱ្យបានទូលំទូលាយដល់ការិយាល័យដែលពាក់ព័ន្ធ។ ក្រៅពីនេះក៏មានសំណូមពរ ឱ្យសាស្ត្រាចារ្យត្រូវមានការយល់ដឹងពីគោលនយោបាយទាក់ទង និងការអភិវឌ្ឍក៏ដូចជាការកែទម្រង់កម្មវិធីសិក្សា ។ អ្វីដែលសំខាន់ក៏គួរផ្តល់ឱកាសអោយអ្នកពាក់ព័ន្ធបានចូលរួមក្នុងការធ្វើកម្មវិធីសិក្សា។

## ការថ្លែងអំណរគុណ

ជាបឋមក្រុមស្រាវជ្រាវសូមសំដែងនូវការដឹងគុណយ៉ាងជ្រាលជ្រៅចំពោះលោកស្រីបណ្ឌិត Ann Glover ចំពោះការផ្តល់ដំបូន្មាន និងការណែនាំដ៏ល្អព្រមទាំងផ្តល់នូវកម្លាំងចិត្ត និងការលើកទឹកចិត្តដល់ក្រុមការងារគ្រប់ពេលវេលា។ពិសេសលោកបណ្ឌិតNgin Chanrith ចំពោះការ

ផ្ដល់នូវការពិគ្រោះយោបល់ និងការសម្រួលជាប់លាប់ក្នុងពេលប្រមូលទិន្នន័យ ក៏ដូចជាការវិភាគសម្រាប់ការស្រាវជ្រាវនេះ។ ពិសេសអរគុណអ្នកទាំងពីរដែលបានចំណាយពេលវេលាដ៏មានតម្លៃក្នុងការគាំទ្រ និងលើកទឹកចិត្តធ្វើឱ្យការស្រាវជ្រាវនេះបានរីកចម្រើនទៅមុខ ទោះក្នុងខណៈដែលមានភារកិច្ចមមាញឹកក៏ដោយ។
សូមថ្លែងអំណរគុណដល់សមាជិកក្រុមស្រាវជ្រាវទាំងអស់ដែលបានចំណាយពេលវេលាដ៏មានតម្លៃ និងការប្រឹងប្រែងគាំទ្រគ្រប់ស្ថានភាពលំបាករហូតធ្វើឱ្យការស្រាវជ្រាវនេះបានកើតឡើង។ សូមសំដែងនូវការដឹងគុណយ៉ាងជ្រាលជ្រៅដល់ក្រសួងអប់រំ យុវជន និងកីឡា និងគម្រោងពង្រឹងគុណភាពអប់រំដែលបានផ្ដល់ឱកាស ក៏ដូចជាការគាំទ្រចំពោះការងារស្រាវជ្រាវនេះ។ អរគុណយ៉ាងខ្លាំងចំពោះប្រធានផ្នែក ប្រធានមុខវិជ្ជា និងមន្ត្រីសាស្ត្រាចារ្យទាំងអស់ចំពោះការអត់ធ្មត់សហការ និងចូលរួមឆ្លើយសំណួរ និងសូមសំដែងនូវការអរគុណចំពោះមិត្តភក្ដិដែលបានចូលរួមក្នុងដំណើរការស្រាវជ្រាវនេះ។ ការអរគុណនិងដឹងគុណ ក៏សូមជូនចំពោះលោកស្រី ម៉ៅ សុធារី ចំពោះការ ផ្ដល់ប្រឹក្សាផ្នែកបច្ចេកទេសក្នុងការជួយវិភាគ និងបកស្រាយទិន្នន័យ។

## ១. សេចក្ដីផ្ដើម

ការអប់រំគឺជាសកម្មភាពចម្បងដែលគ្រប់ប្រទេសត្រូវធ្វើការអភិវឌ្ឍ ដើម្បីបំពេញតម្រូវការសង្គម។ ដោយផ្អែកលើគោលនយោបាយអប់រំសម្រាប់ទាំងអស់គ្នា ការអប់រំនៅកម្ពុជាបានដាក់ចេញនូវបេសកកម្មដើម្បីធានាថា កុមារទាំងអស់ត្រូវតែបញ្ចប់ការសិក្សាមូលដ្ឋាននៅឆ្នាំ២០១៥។ បញ្ហានេះនាំឱ្យមានការកើនឡើងនូវចំនួនសិស្សនៅវិទ្យាល័យ។ ដូច្នេះសាលានីមួយៗនឹងត្រូវការគ្រូបន្ថែមទៀតនៅគ្រប់កម្រិតសិក្សា។

ដើម្បីបំពេញតម្រូវការ ការបណ្ដុះបណ្ដាលគ្រូគឺជាសកម្មភាពគន្លឹះចម្បងក្នុងការផលិតធនធានមនុស្ស។ ដូច្នេះការបណ្ដុះបណ្ដាលគ្រូជាកូនសោរគន្លឹះក្នុងការផលិតនូវធនធានមនុស្សដើម្បីឆ្លើយតបទៅតម្រូវការរបស់សង្គមជាតិ។

ការផ្ដោតបច្ចុប្បន្នលើការបណ្ដុះបណ្ដាលគ្រូទូទាំងពិភពលោកគឺការអភិវឌ្ឍនូវកម្មវិធីសិក្សាពិសេសគឺការផ្ដោតលើតួនាទីគ្រូក្នុងការអភិវឌ្ឍកម្មវិធីសិក្សា។

យោងតាមលោកAhmet Saban (1995), ការចូលរួមរបស់គ្រូក្នុងការអភិវឌ្ឍន៍កម្មវិធីសិក្សាគឺជាបញ្ហាមួយរវាងទស្សនៈពីរក្នុងវិស័យអប់រំ។

ការព្យាយាមដើម្បីឱ្យគ្រូបានចូលរួមក្នុងការអភិវឌ្ឍន៍កម្មវិធីសិក្សារបស់សាលារៀននៅក្រៅថ្នាក់រៀនត្រូវទទួលបាននូវចំណាប់អារម្មណ៍។ Hawthome 1990, បានលើកជាឧទាហរណ៍ ការធ្វើ

អត្ថាធិប្បាយចំពោះស្ថានភាពអាមេរិកថា ក្នុងចំណោមស្រុក ឬតំបន់ជាច្រើនការបង្កើតកម្មវិធីសិក្សាគឺសម្រេចទៅតាមសាលានីមួយៗ ។ គ្រូ និងនាយកសាលាក្លាយជាអ្នកសម្រេចចិត្តយ៉ាងសំខាន់ (p279)។ ការលើកឡើងនេះវាស្របទៅនឹង គំនិតរបស់ Martin, Saif and Thiel's(1986/1987) ជានាយក និងជាអ្នកគ្រប់គ្រង ការស្ទង់មតិនៃកម្មវិធីសិក្សាជាតិ។

ក្នុងស្ថាប័នអប់រំឧត្តមសិក្សា បុគ្គលិក សាស្ត្រាចារ្យតម្រូវឱ្យចូលរួមកាន់តែសកម្មក្នុងការអភិវឌ្ឍកម្មវិធីសិក្សាដើម្បីជាសក្ខីកម្មបញ្ជាក់ថា មន្ត្រី សាស្ត្រាចារ្យជាអ្នកដែលមានការទទួលខុសត្រូវយ៉ាងសំខាន់ក្នុងការអនុវត្តនូវកម្មវិធីដែលសបញ្ជាក់ថាការបង្រៀនរបស់គេជោគជ័យអាស្រ័យលើគុណភាពនៃកម្មវិធីសិក្សានេះបើតាមការលើកឡើងរបស់ Wolfe & Hughes, 207 ។

### ២. *សាវតានៃការស្រាវជ្រាវ និងបញ្ហា*

អនុក្រឹត្យលេខ៣៥ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ១៩៩៣ អតីតមហាវិទ្យាល័យគរុកោសល្យជាកន្លែងបណ្តុះបណ្តាលគ្រូបង្រៀនមួយកន្លែងដ៏ធំនៅប្រទេសកម្ពុជា ។ យោងតាមប្រកាសចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០០៤ មហាវិទ្យាល័យគរុកោសល្យបានប្រែក្លាយជាវិទ្យាស្ថានជាតិអប់រំ ។ ដូចនេះវិទ្យាស្ថានជាតិអប់រំមានចក្ខុវិស័យបង្កើនសមត្ថភាពធនធានមនុស្សសម្រាប់បម្រើសេចក្តីត្រូវការនៅក្នុងការអភិវឌ្ឍវិស័យអប់រំ។ ដើម្បីទទួលបានលទ្ធផលជាផ្លែផ្កា វិទ្យាស្ថានជាតិអប់រំមានបេសកកម្មផ្តល់ការបណ្តុះបណ្តាលគ្រូបង្រៀន ក្នុងនោះរាប់បញ្ចូលទាំងការបណ្តុះបណ្តាលផែនការ គ្រប់គ្រង និងភាពជាអ្នកដឹកនាំសម្រាប់មន្ត្រីការិយាល័យ មន្ត្រី សាស្ត្រាចារ្យ អធិការ និងនាយកសាលាជាពិសេស ដែលទាក់ទងនិងការបណ្តុះបណ្តាលគ្រូទុតិយភូមិដើម្បីឱ្យឆ្លើយតបទៅនឹងតម្រូវការនៅក្នុងក្រសួងអប់រំ យុវជន និងកីឡា។

ដើម្បីធ្វើឱ្យសម្រេចនូវចក្ខុវិស័យ បេសកកម្ម តម្លៃ និងបំពេញតម្រូវការបង្កើនគុណភាពនៃការបណ្តុះបណ្តាលវិទ្យាស្ថានជាតិអប់រំត្រូវមានផែនការ និងកម្មវិធីសិក្សា ដែលមានខ្លឹមសារលម្អិត ។ កម្មវិធីសិក្សាជាក់ស្តែងរបស់វិទ្យាស្ថានអប់រំត្រូវតែទូលំទូលាយ មានចំណេះដឹងទំនើបទាន់សម័យសម្រាប់បម្រើសេចក្តីត្រូវការរបស់គ្រូ និងសិស្សនៅវិទ្យាល័យ ដែលធានាបាននូវគុណភាពនៃការបង្រៀន និងរៀន។ កម្មវិធីសិក្សាគួរត្រូវបានធ្វើការសិក្សានិងវាយតម្លៃថាមានលក្ខណៈគ្រប់គ្រាន់ ដើម្បីឈានទៅបំពេញតម្រូវការគ្រូ និងសិស្ស។

តាំងពីឆ្នាំ២០០៤ កម្មវិធីសិក្សានៅវិទ្យាស្ថានជាតិអប់រំធ្លាប់បានផ្លាស់ប្តូរជាញឹកញាប់ ។ ក្នុងន័យបំលាស់ប្តូរកម្មវិធីសិក្សានេះគួរតែសមស្របតាមតម្រូវការ និងមានភាពប្រសើរឡើងដើម្បីបង្កើនគុណភាពនៃការបង្រៀន និងតម្រង់ទិសឱ្យអ្នករៀននៅពេលអនាគត។ ជាងនេះទៅទៀតគ្មានការប៉ាន់ស្មាន ឬ ការវាយតម្លៃណាមួយ ដែលត្រូវបានបង្កើតឡើងដើម្បីធានាថាកម្មវិធីសិក្សាមិនចាំបាច់មានកំណែទម្រង់នោះទេ។ នៅក្នុងឱកាសចែកសញ្ញាបត្រដល់គរុនិស្សិតជំនាន់ទី១៣ នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាក៏បានគូសបញ្ជាក់យ៉ាងច្បាស់ថា«គុណភាពនៃការអប់រំ

ពឹងផ្អែកយ៉ាងខ្លាំងលើការបណ្តុះបណ្តាលគ្រូ ដែលជាអ្នកផ្តល់ការអប់រំ ដូច្នេះគ្រូត្រូវមានចំណេះដឹងខ្ពស់ មានជំនាញច្បាស់លាស់ប្រកបដោយសេចក្តីថ្លៃថ្នូរ សុចរិតយុត្តិធម៌ និងក្លាយជាគ្រូដែលមានមនសិការវិជ្ជាជីវៈខ្ពស់»។

ដើម្បីធានានូវគុណភាពនៃការបណ្តុះបណ្តាលគ្រូវិទ្យាស្ថានជាតិអប់រំបានធ្វើពង្រាងផែនការអភិវឌ្ឍវិទ្យាស្ថានជាតិអប់រំដែលក្នុងនោះរួមបញ្ចូលទាំងគោលនយោបាយរដ្ឋបាលសំខាន់ៗចាំបាច់ដើម្បីអនុវត្តន៍នូវកម្មវិធីសិក្សាប្រកបដោយប្រសិទ្ធភាព ។ ទោះជាយ៉ាងណាក៏ដោយ ស្ថាប័នត្រូវបញ្ចូលមន្ត្រីសាស្ត្រាចារ្យ សិស្សរួមទាំងការប្រឹងប្រែងរកការគាំទ្រ ពីបណ្តាភាគីដែលពាក់ព័ន្ធដទៃទៀត។ ដោយប្រឈមនិងស្ថានភាពបច្ចុប្បន្ន វិទ្យាស្ថានបានដើរតួនាទីយ៉ាងសំខាន់ក្នុងការផ្តល់ឱ្យនូវការបណ្តុះបណ្តាលទៅដល់គ្រូទុតិយភូមិនៅកម្ពុជា ។ ហើយការផ្តល់នេះត្រូវតែជាការផ្តល់នូវការបណ្តុះបណ្តាលប្រកបដោយគុណភាព។ អាស្រ័យហេតុនេះ ទើបត្រូវការចាំបាច់ក្នុងការសិក្សាតាមដាន និងវាយតម្លៃជាលក្ខណៈវិទ្យាសាស្ត្រដើម្បីធានាថា តើពេលណា ឬ ហេតុអ្វីបានជាកម្មវិធីសិក្សាគួរត្រូវបានផ្លាស់ប្តូរ ។ យោងតាម Howard (2007), ភាពចាំបាច់សម្រាប់គ្រឹះស្ថានក្រោយឧត្តមសិក្សា គឺត្រូវអនុវត្តនូវការអភិវឌ្ឍកម្មវិធីសិក្សា ដែលមានកម្មវិធីជាប់ទាក់ទងគ្នា នោះមានន័យថា ការរៀបចំកម្មវិធីដ៏ល្អផ្តល់ឱ្យសិស្សនូវការយល់ដឹងដ៏ទូលំទូលាយ និងស៊ីជម្រៅ ពេលពួកគេឆ្លងកាត់កម្មវិធីសិក្សារួចមក។

*៣. គោលបំណងនៃការស្រាវជ្រាវ*

ការសិក្សានេះមានគោលបំណង ដើម្បីស្វែងយល់ពីដំណើរការនៃការអភិវឌ្ឍកម្មវិធីសិក្សានៅវិទ្យាស្ថានជាតិអប់រំ។

*៤. សំណួរស្រាវជ្រាវ*

ដើម្បីសម្រេចគោលបំណងខាងលើ ការសិក្សាស្រាវជ្រាវនឹងឆ្លើយសំណួរខាងក្រោម ៖

តើវិទ្យាស្ថានជាតិអប់រំ ធ្វើកំណែទម្រង់ និងអភិវឌ្ឍកម្មវិធីសិក្សាយ៉ាងដូចម្តេច ?

*៥. ការរំលឹកទ្រឹស្តី*

*ប្រសិទ្ធភាពនៃការបណ្តុះបណ្តាល*

រាជរដ្ឋាភិបាលកម្ពុជាបានទទួលស្គាល់ថាដំណើរការនៃការធ្វើកំណែទម្រង់ស្ថិតនៅលើកំណាត់ផ្លូវដ៏វែងឆ្ងាយដែលទាមទារនូវការប្រឹងប្រែងបន្ថែមទៀត។ រដ្ឋាភិបាលបានកំណត់ការអប់រំជាវិស័យអាទិភាពដែលតម្រូវឱ្យមានការអភិវឌ្ឍ។ ថវិកាជាតិ ចំនួន២២,២៥%ត្រូវបានអនុម័តសម្រាប់ប្រើប្រាស់លើវិស័យអប់រំក្នុងឆ្នាំ២០០៨។ គោលដៅ នៃការធ្វើកំណែទម្រង់កម្មវិធីសិក្សាគឺ ដើម្បីធ្វើឱ្យប្រសើរឡើងនៅគុណភាពអប់រំតាមរយៈ ការពង្រឹងនូវ

ប្រសិទ្ធិភាពនៃការបង្រៀន និងការបណ្តុះបណ្តាល ។ ប្រសិនបើគោលដៅ នៃការធ្វើកំណែទម្រង់នេះប្រព្រឹត្តទៅបានល្អ វានឹងចូលរួមចំណែកដល់គោលនយោបាយ រដ្ឋាភិបាលសម្រាប់ការអភិវឌ្ឍប្រទេសកម្ពុជា។

ប្រសិទ្ធភាពនៃការបណ្តុះបណ្តាលគឺការវាស់វែងពីការរៀនសូត្រ។ ដើម្បីសម្រេចស្តង់ដារគោលដៅអប់រំជាតិ វិទ្យាស្ថានជាតិអប់រំត្រូវតែធានានូវប្រសិទ្ធភាពកម្មវិធីសិក្សាមាន ការតាំងចិត្ត មានវិន័យ និងត្រូវលើកកម្ពស់គុណភាពគ្រូបង្រៀន ដែលជាអ្នកដើរតួនាទីយ៉ាងសំខាន់ក្នុងការសម្រេចប្រសិទ្ធភាពនៃការបណ្តុះបណ្តាល។

*ការអភិវឌ្ឍកម្មវិធីសិក្សា*

នៅប្រទេសកម្ពុជា ការអភិវឌ្ឍកម្មវិធីសិក្សាគឺជាចំណុចសំខាន់នៃការខំប្រឹងប្រែងដើម្បីបង្កើនគុណភាព និងប្រសិទ្ធភាពនៃការអប់រំ។ ការបង្កើតគោលការណ៍សម្រាប់ការអភិវឌ្ឍកម្មវិធីសិក្សា គឺជាកិច្ចការចាំបាច់ក្នុងការផ្តល់ជាមគ្គុទេសន៍ដល់ការអភិវឌ្ឍកម្មវិធីសិក្សានីមួយៗ។

កម្មវិធីសិក្សា គឺជាការប្រមូលផ្តុំនូវខ្លឹមសារនៃមុខវិជ្ជា បទពិសោធន៍ និងជំនាញ ដែលត្រូវយកទៅបង្រៀនសិស្ស។ មុខវិជ្ជាទាំងអស់នោះត្រូវបានរៀបចំ និងដាក់បញ្ចូលឱ្យសមស្របទៅនឹងកម្រិតសិក្សារបស់សិស្ស។ ដូច្នេះកម្មវិធីសិក្សា គឺជាធនធានដ៏សំខាន់សម្រាប់គ្រូ នាយកសាលា អ្នកអប់រំ អ្នកវិទ្យាសាស្ត្រ អ្នកស្រាវជ្រាវ ព្រមទាំងអ្នកដែលពាក់ព័ន្ធជាមួយការអប់រំ។

គោលបំណងរបស់កម្មវិធីសិក្សា គឺជួយអភិវឌ្ឍគរុនិស្សិតទាំងអស់ឱ្យមានសមត្ថភាពពេញលេញ ជំនាញច្បាស់លាស់ និងបំណិនក្នុងការយកចំណេះដឹងទៅប្រើប្រាស់ក្នុងការបង្រៀនប្រចាំថ្ងៃ។ ដូច្នេះកម្មវិធីសិក្សាត្រូវបង្កើតជាប្រព័ន្ធតាមផែនការបង្រៀន និងរៀនព្រមទាំងការអភិវឌ្ឍដែលឆ្លុះបញ្ចាំងពីវគ្គបណ្តុះបណ្តាលគ្រូឧត្តមសិក្សា។

*គ្រូទុតិយភូមិ*

គ្រូទុតិយភូមិដើរតួនាទីយ៉ាងសំខាន់ក្នុងការអភិវឌ្ឍវិស័យអប់រំនៅកម្ពុជា។ជាងនេះទៅទៀត វិស័យអប់រំត្រូវបានគេចាត់ទុកជាសរសរស្តម្ភ ដែលជួយក្រសួងអប់រំ យុវជន និងកីឡា ឱ្យសម្រេចបាននូវគោលដៅអប់រំសម្រាប់ទាំងអស់គ្នា ។ មន្ត្រីអប់រំត្រូវបានជ្រើសរើស និងបណ្តុះបណ្តាលដោយគ្រឹះស្ថានសាធារណៈ។ មាត្រា២០ នៃច្បាប់អប់រំបានចែងថា៖ ដើម្បីក្លាយជាមន្ត្រីអប់រំលុះត្រាបានបញ្ចប់ការ សិក្សាថ្នាក់បរិញ្ញាបត្រនៅគ្រឹះស្ថានសាកលវិទ្យាល័យណាមួយក្នុងនោះដែរ មន្ត្រីនោះត្រូវឆ្លងកាត់ នូវការបណ្តុះបណ្តាលរយៈពេលមួយឆ្នាំលើផ្នែកទ្រឹស្តីរួមទាំងការអនុវត្តនូវការបង្រៀនជាក់ស្តែង ។ ដូច្នេះវិទ្យាស្ថានជាតិអប់រំក្លាយជាសេនាធិការមួយដ៏សំខាន់ទទួលភារកិច្ចក្នុងការបណ្តុះបណ្តាលគ្រូទុតិយភូមិតាមគោលនយោបាយរបស់ក្រសួងអប់រំ យុវជន និងកីឡា។

នៅទូទាំងពិភពលោកគ្រូទុតិយភូមិទទួលនូវភារៈដ៏លំបាក។ ក្រៅពីសកម្មភាពក្នុងថ្នាក់រៀនជារឿយៗគ្រូត្រូវទទួលភារៈធ្វើការជាមួយសិស្ស ដូចជាក្លឹប ការបង្ហាត់ល្ខោន អត្តពលកម្ម ការគ្រប់គ្រងនានា ឆាកសម្តែង ការតុបតែងបន្ទប់។ យោងតាមការសិក្សាស្រាវជ្រាវរបស់ NEP and VSO(2008), សិស្សទុតិយភូមិត្រូវត្រៀមខ្លួនទទួលយកការងារដែលស្ថិតនៅកន្លែងមានស្ថានភាពលំបាក ។ នៅវិទ្យាស្ថានជាតិអប់រំ គ្រូតម្រូវឱ្យមានជំនាញក្នុងការធ្វើកម្មវិធីសិក្សា កិច្ចតែងការបង្រៀន និងធ្វើមេរៀនសម្រាប់បង្រៀន។

## ៦. *វិធីសាស្ត្រស្រាវជ្រាវ*

### ៦.១. *វិធីសាស្ត្រ ប្រមូលទិន្នន័យ*

ក្នុងការសិក្សាស្រាវជ្រាវនេះ យើងជ្រើសរើសយកវិធីសិក្សាស្រាវជ្រាវបែបគុណភាពមកសិក្សាស្វែងយល់អំពីទស្សនៈ និងការអនុវត្ត ការធ្វើកំណែទម្រង់ និងអភិវឌ្ឍន៍កម្មវិធីសិក្សា។

ការជ្រើសរើសយកការសិក្សាស្រាវជ្រាវបែបគុណភាពនេះ ព្រោះដំណើរការនៃការប្រមូលទិន្នន័យត្រូវឆ្លងកាត់ការសម្ភាសន៍មានលក្ខណៈស៊ីជម្រៅ។ សំណួរភាគច្រើនត្រូវយកទៅប្រើប្រាស់ក្នុងការសម្ភាសន៍ជាសំណួរបើក ដើម្បីប្រមូលព័ត៌មានទាក់ទងនឹងដំណើរការអភិវឌ្ឍន៍កម្មវិធីសិក្សា។

ការសិក្សាស្រាវជ្រាវនេះអាចធ្វើទៅបានក្រោយពីមានការអនុញ្ញាតពីក្រសួងអប់រំ យុវជន និង កីឡា។ នាយក នាយករង និងក្រុមគោលដៅផ្សេងទៀត គឺជាមុខសញ្ញាដែលត្រូវធ្វើសម្ភាសន៍ ។

នៅក្នុងការសិក្សានេះក្រុមអ្នកសិក្សាប្រើប្រាស់ទិន្នន័យបន្ទាប់បន្សំ ឬ ទិន្នន័យមានស្រាប់ និងទិន្នន័យបឋមដូចខាងក្រោម៖

**ក. ទិន្នន័យជាឯកសារ:** សៀវភៅ របាយការណ៍ ព្រឹត្តប័ត្រអប់រំ និងឯកសារផ្សេងៗ។

**ខ. ទិន្នន័យបឋម:** ក្រុមអ្នកសិក្សាប្រើប្រាស់វិធីសាស្រ្តពីរគឺ៖

- ការសម្ភាសន៍លក្ខណៈស៊ីជម្រៅមួយទល់នឹងមួយជាមួយគណៈគ្រប់គ្រង ក្នុងនោះមាននាយក នាយករង និងប្រធានផ្នែកវិទ្យាស្ថានជាតិអប់រំទាំងអស់ចំនួន៨នាក់។
- ការពិភាក្សាជាក្រុមជាមួយក្រុមគោលដៅជាសាស្រ្តាចារ្យនៃវិទ្យាស្ថានជាតិអប់រំចំនួន២០%គឺស្មើនឹង២៨នាក់នៃសាស្រ្តាចារ្យសរុប១៩៦នាក់។ ការប្រមូលទិន្នន័យប្រើរយៈពេល៣០ថ្ងៃ គឺ ចាប់ពីខែសីហា ដល់ ខែកញ្ញា ឆ្នាំ២០១០។

### ៦.២. *ការវិភាគទិន្នន័យ*

ទម្រង់នៃការវិភាគទិន្នន័យមានពីរបែប៖

- ការវិភាគបែបបរិមាណៈ ទិន្នន័យនឹងត្រូវវិភាគតាមបែបស្ថិតិពណ៌នាដោយប្រើភាគរយ។ ទិន្នន័យបែបបរិមាណនឹងបង្ហាញជាតារាង និងក្រាហ្វិក។

- ការវិភាគបែបគុណភាព: ទិន្នន័យនឹងត្រូវវិភាគតាមបែបខ្លឹមសារដោយដាក់ទិន្នន័យជាក្រុមរៀបតាមលំដាប់នៃសំណួរ ។ ទិន្នន័យបែបគុណវិស័យនឹងត្រូវបកស្រាយតាមនិទ្ទាការ ឬ ចំណុចរួមនៃចម្លើយ។ ទិន្នន័យបែបនេះនឹងត្រូវបង្ហាញជាលក្ខណៈបរិយាយ។

*គម្រោងនៃការសិក្សាស្រាវជ្រាវ*

គម្រោងនៃការសិក្សាស្រាវជ្រាវត្រូវបានសង្ខេបនៅក្នុងដ្យាក្រាមខាងក្រោម។

## គម្រោងផែនការគោល




*៧.លទ្ធផលដែលរំពឹងទុកសម្រាប់ការសិក្សាស្រាវជ្រាវ*

ការសិក្សាស្រាវជ្រាវនេះត្រូវបានរំពឹងទុកថានិងអាចផ្តល់នូវការយល់ដឹងយ៉ាងស៊ីជម្រៅអំពីដំណើរការអភិវឌ្ឍន៍កម្មវិធីសិក្សានៃវិទ្យាស្ថានជាតិអប់រំ(NIE) ហើយការងារនេះអាចជួយបង្ហាញអំពីរបៀបធ្វើយ៉ាងណាដើម្បីឱ្យដំណើរការកំណែទម្រង់ និងការអភិវឌ្ឍអាចមានភាពរឹងមាំ។

## ៨. លទ្ធផល

### ៨.១ កម្មវិធីសិក្សានាពេលបច្ចុប្បន្ន

សាស្ត្រាចារ្យដែលចូលរួមបានកត់សម្គាល់ពីចំនួនកំហុសឆ្គងដែលកើតមាននៅក្នុងកម្មវិធីសិក្សារួមមាន : កម្មវិធីសិក្សាជាទូទៅមានលក្ខណៈជាទ្រឹស្តី( Theory- centered) កម្មវិធីសិក្សាបែបនេះមិនទាន់អាចឆ្លើយតបទៅនឹងសេចក្តីត្រូវការនៃការអប់រំថ្នាក់មធ្យមសិក្សានៅកម្ពុជា ហើយក៏ពុំមានលក្ខណៈស៊ីជម្រៅ។ សាស្ត្រាចារ្យបានមើលឃើញពីភាពខ្វះខាតនៃទំនាក់ទំនងនៅក្នុងកម្មវិធីសិក្សា ដែលកម្មវិធីសិក្សានោះពុំមានលក្ខណៈដូចគ្នា ហើយត្រូវបានធ្វើការពិចារណាទៅលើការចែកចាយ ឯកសារនៃកម្មវិធីសិក្សាផងដែរ។ មតិយោបល់ដ៏ទៃទៀតរួមមាន ដូចជាពេលវេលាក្នុងការសិក្សាសម្រាប់មុខវិជ្ជាវិធីសាស្ត្រក្នុងការបង្រៀន(Teaching Methodology) គឺមិនទាន់មានភាពគ្រប់គ្រាន់នៅឡើយ(សាស្ត្រាចារ្យមិនអាចបញ្ចប់កម្មវិធីសិក្សាតាមពេលកំណត់) ហើយពេលវេលាសម្រាប់ការធ្វើកម្មសិក្សា(practicum) មានលក្ខណៈខ្លីពេក ដែលពុំអាចធ្វើឱ្យកម្មសិក្សានិងកម្មសិក្សាការីទទួលបាននូវការអនុវត្តគ្រប់គ្រាន់មុននឹងចូលទៅកាន់អាជីពជាគ្រូបង្រៀន។ មាតិកានៅក្នុងមេរៀនក៏ពុំទាន់រៀបចំឲ្យសមស្របទៅនឹងពេលវេលាក្នុងការបង្រៀនផងដែរ។ គណៈគ្រប់គ្រងបានលើកឡើងថាកម្មវិធីសិក្សានូវពុំទាន់សមស្របទៅនឹងតម្រូវការរបស់សាលារដ្ឋនូវឡើយ។ ជាពិសេសគឺមុខវិជ្ជាឯកទេសទីពីរ ។ ពួកគាត់បានកត់សម្គាល់ថាពេលវេលា ក្នុងការសិក្សាមុខវិជ្ជាឯកទេសទី២ នឹងការសិក្សាមុខវិជ្ជាវិធីសាស្ត្របង្រៀនមានលក្ខណៈខ្លីពេក។ គណៈគ្រប់គ្រងមួយចំនួនបានលើកឡើង ថាគួរឱ្យមានកម្មវិធីសិក្សាដូចទៅនឹងសេរីលង្កា និងសឹង្ហបុរី ដោយលើកឡើងថាកម្មវិធីសិក្សាគួរតែផ្តោតទៅលើការផ្ទេរជំនាញ។ សាស្ត្រាចារ្យបានធ្វើការចែករំលែកនូវយោបល់ ដោយធ្វើយ៉ាងណាឱ្យកម្មវិធីសិក្សាមានភាពប្រសើរឡើង ដែលយោបល់ទាំងនោះភាគច្រើនទាក់ទងនឹងមុខវិជ្ជាថ្មី ICT(មុខវិជ្ជាជំនាញទីពីរ) ។ ពួកគេបានរៀបរាប់ថា មុខវិជ្ជានេះពិបាកសម្រាប់គរុនិស្សិតយកទៅធ្វើការអនុវត្តនៅឯមធ្យមសិក្សា ហើយសាស្ត្រាចារ្យក៏ត្រូវការឯកសារសម្រាប់ការបង្រៀនមុខវិជ្ជាថ្មីម្យ៉ាងវិញទៀត មុខវិជ្ជានេះក៏ពុំជាប់ទាក់ទងទៅនឹងមុខវិជ្ជាឯកទេសទីមួយផងដែរ។

## ៨.២ បញ្ហាប្រឈម ក្នុងការអនុវត្តកម្មវិធីសិក្សា




គណៈគ្រប់គ្រងនិងបុគ្គលិកមួយចំនួនបានបញ្ជាក់ពីភាពចាំបាច់នៃការអនុវត្តកម្មវិធីសិក្សាថ្មីខណៈភាគច្រើននៃបុគ្គលិកពុំមានការរំពឹងទុកពីការអនុវត្តកម្មវិធីថ្មី

គ្រូឧទ្ទេសផ្នែកវិទ្យាសាស្ត្របានលើកឡើងថា កម្មវិធីសិក្សានោះពិតជាមានការលំបាក ក្នុងការបង្រៀន ហើយពុំអាចបញ្ចប់បានតាមពេលវេលាកំណត់ ។ ហេតុផលក្នុងបញ្ហានេះគឺ រួមបញ្ចូលទាំងការខ្វះខាតឯកសារ ថ្នាក់រៀនមានសិស្សច្រើន និងការអវត្តមានច្រើនរបស់គរុនិស្សិត ។ គ្រូឧទ្ទេសបានលើកឡើងថា ពេលវេលាសម្រាប់ការបង្រៀន និងកម្មវិធីសិក្សាមិនស៊ីគ្នាទេ ឯការបង្រៀនសម្រាប់ឯកទេសទី២មានតែ៤ម៉ោងនោះ វាពុំគ្រប់គ្រាន់ឡើយ។

ម្យ៉ាងវិញទៀត វាពុំមានការឯកភាពគ្នាលើមាតិកានៅឡើយ ហើយកម្មវិធីសិក្សានោះពុំបានឆ្លើយតបយ៉ាងត្រឹមត្រូវទៅតាមតម្រូវការនៅតាមវិទ្យាល័យនានា ហើយសិស្សជួបប្រទះបញ្ហាជាច្រើន គឺការលំបាកក្នុងការយល់ដឹងអំពីឯកទេសទី២ ។ ផ្ទុយទៅវិញ គ្រូឧទ្ទេសផ្នែក Computer និង គ្រូឧទ្ទេសផ្នែកគណិតវិទ្យាបានបញ្ជាក់ថាពួកគាត់មានបញ្ហាខ្លះៗក្នុងការអនុវត្តកម្មវិធីសិក្សា។

## ៨.៣ ការចូលរួមក្នុងការអនុវត្តកម្មវិធីសិក្សា

នៅពេលដែលត្រូវបានសួរអំពីការចូលរួមក្នុងការអភិវឌ្ឍកម្មវិធីសិក្សា គ្រូឧទ្ទេសភាគច្រើនបានឆ្លើយថាពួកគាត់ពុំបានចូលរួមក្នុងការធ្វើកម្មវិធីសិក្សានៅវិទ្យាស្ថានទេ គ្រាន់តែបានចូលរួមអនុវត្តកម្មវិធីបង្រៀនប្រចាំឆ្នាំប៉ុណ្ណោះ ។ គ្រូឧទ្ទេសខ្លះបានចូលរួមក្នុងការធ្វើកម្មវិធីសិក្សាសម្រាប់តែមុខវិជ្ជាវិទ្យាសាស្ត្រតែប៉ុណ្ណោះ។

លោកនាយករងម្នាក់បានមានប្រសាសន៍ថា កាលពីមុនមានតែគ្នា២ឬ៣នាក់ ត្រូវបានចូលរួមក្នុងការអភិវឌ្ឍន៍កម្មវិធីសិក្សា នៅពេលដែលធ្វើកម្មវិធីសិក្សា គ្រូឧទ្ទេសមានពេលត្រឹមតែ២ ឬ៣ថ្ងៃតែប៉ុណ្ណោះ សម្រាប់រៀបចំការបង្រៀន ហើយពុំមានការត្រួតពិនិត្យ ឬក៏ការធានានូវប្រសិទ្ធភាព ឬដំណើរការច្បាស់លាស់ឡើយ។

ក្រុមគ្រូផ្នែកមុខវិជ្ជាវិទ្យាសាស្ត្រ ត្រូវបានចូលរួមនៅចន្លោះពី ២០០០-២០០៤ ប៉ុន្តែលោក នាយករងបានមានប្រសាសន៍ផ្សេងពីនេះ បន្ទាប់ពីឆ្នាំនោះមក គ្រូឧទ្ទេសដែលបានចូលរួម គឺគាត់ពុំបាន ដឹងទេ ។ ក្រោយមកទៀតគ្រូឧទ្ទេសគ្រប់មុខវិជ្ជាទាំងអស់ត្រូវបានអនុញ្ញាតឲ្យបញ្ចេញទស្សនៈ និងបង្ហាញពីកម្មវិធីសិក្សារបស់ពួកគាត់។

## ៨.៤ ការយល់ឃើញ ពីដំណើរការអភិវឌ្ឍកម្មវិធីសិក្សា




គណៈគ្រប់គ្រងយល់ដឹងពីដំណើរការអភិវឌ្ឍកម្មវិធីសិក្សាក្នុងដែរមានបុគ្គលិកសាស្ត្រាចារ្យតិចតួចបានចូលរួមក្នុងការធ្វើកម្មវិធីសិក្សា

គ្រូឧទ្ទេសស្ទើរតែទាំងអស់ពុំបានដឹងថា តើកម្មសិក្សានៅវិទ្យាស្ថានជាតិអប់រំត្រូវបានធ្វើឡើងដោយរបៀបណា ហើយក៏ពុំបានដឹងថា នរណាខ្លះបានចូលរួមដែរ។ អ្នកខ្លះបានលើកឡើងថាអ្នកធ្វើកម្មវិធីសិក្សា គឺជាគណៈគ្រប់គ្រង ឬក៏ជាប្រធានការិយាល័យរបស់ក្រសួងអប់រំយុវជន និងកីឡា ។ លោកនាយករងបានមានប្រសាសន៍ថាគឺមានតែ១ឬ២ នាក់ទេ ត្រូវបានចូលរួម នាយករង ឬក៏ប្រធានផ្នែក។ ចំណុចសំខាន់គឺផ្តោតលើវិធីសាស្ត្រ។

## ៨.៥ ការធ្វើកំណែទម្រង់កម្មវិធីសិក្សា




បុគ្គលិកចូលរួមសម្ភាសន៍ទាំងអស់បានដឹងពីការធ្វើកំណែទម្រង់កម្មវិធីសិក្សាតែ ភាគច្រើនមិនបានដឹងថាតើកំណែទម្រង់ធ្វើឡើងពេលណាឬមានការសិក្សាដែរឬទេ មុនពេលធ្វើកំណែទម្រង់

*ភាពញឹកញាប់នៃកំណែទម្រង់* - គ្រូបង្រៀនមួយចំនួនយល់ឃើញថា វិទ្យាស្ថានជាតិអប់រំបានធ្វើកំណែទម្រង់កម្មវិធីសិក្សារបស់ខ្លួនជារៀងរាល់ឆ្នាំ។ គ្រូឧទ្ទេសផ្សេងទៀតលើកឡើងថា កំណែទម្រង់កម្មវិធីសិក្សាមុខវិជ្ជាវិទ្យាសាស្ត្របានធ្វើឡើងរវាងឆ្នាំ២០០០ និងឆ្នាំ២០០៣ ហើយពួកគេបញ្ជាក់ទៀត ថាមុខវិជ្ជាឯកទេសទី២ត្រូវបានដាក់បញ្ចូលបន្ថែមក្នុងកម្មវិធីសិក្សាក្នុងឆ្នាំ២០០២ ហើយមុខវិជ្ជាឯក ទេសទី២នេះឯងដែលបន្តធ្វើកំណែទម្រង់ជារៀងរាល់ឆ្នាំ។

លោកនាយករងបានដឹងច្រើនអំពីកំណែទម្រង់កម្មវិធីសិក្សាកន្លងមក។ នាយករងម្នាក់បានលើកឡើងថាតាំង ពីឆ្នាំ១៩៩៧ មានកំណែទម្រង់កម្មវិធីសិក្សារហូតមក។ ក្នុងឆ្នាំ២០០០ JICA បានរៀបចំកម្មវិធីសិក្សា មូលដ្ឋានឡើងវិញ បន្ទាប់មកគ្រូឧទ្ទេសរៀបចំអភិវឌ្ឍវិធីសាស្ត្របង្រៀន និងខ្លឹមសារមេរៀន ជា ពិសេសមុខវិជ្ជាវិទ្យាសាស្ត្រ។ ក្នុងឆ្នាំ២០០៥ កម្មវិធីសិក្សាមានការផ្លាស់ប្តូរ ប៉ុន្តែនៅតែមិនឆ្លើយតប នឹងតម្រូវការរបស់សាលារៀន ។ *ការតាមដាន ឬវាយតម្លៃមុនធ្វើកំណែទម្រង់កម្មវិធីសិក្សា* - គ្រូ ឧទ្ទេសមិនប្រាកដថា តើការវាយតម្លៃត្រូវបានគេធ្វើឡើងដែរឬទេ មុនកំណែទម្រង់កម្មវិធីសិក្សា ហើយក៏មិនបានដឹងថា មានការស្រាវជ្រាវវាយតម្លៃត្រូវបានធ្វើឡើងនោះដែរ។

ទោះជាយ៉ាងណា សម្រាបមុខវិជ្ជាវិទ្យាសាស្ត្រគ្រូបានលើកឡើងថាពិតជាបានធ្វើការវាយតម្លៃប្រាកដមែន។

*កត្តាជំរុញឱ្យមានកំណែទម្រង់* - គ្រូបង្រៀនយល់ឃើញថាមានកត្តាជាច្រើន ដែលធ្វើឱ្យមាន កំណែទម្រង់រួមមានតម្រូវការចាំបាច់ជាក់ស្តែងរបស់គ្រូ (នៅវិទ្យាល័យ និងសាលាផ្សេងៗទៀតរួម ទាំងក្រសួងអប់រំ យុវជន និងកីឡាផងដែរ) ទីផ្សារការងារ ស្ថានភាពនយោបាយ ការរីកចម្រើនផ្នែកវិទ្យាសាស្ត្រ និងតម្រូវការបង្កើតថ្មី។

*គោលនយោបាយ* - គ្រូឧទ្ទេសមិនបានដឹងច្បាស់ថាតើវិទ្យាស្ថានជាតិអប់រំមានគោលនយោបាយសម្រាប់ការធ្វើកំណែទម្រង់កម្មវិធីសិក្សាឬទេ គ្រូឧទ្ទេសខ្លះបានឆ្លើយថា *មិនដឹងទេ ប្រហែលជាគ្មានគោលនយោបាយទេ មិនច្បាស់ទេ គ្មានការណែនាំច្បាស់លាស់* ឬ ថាវិទ្យាស្ថានជាតិអប់រំធ្វើ ការកែទម្រង់តាមការចង្អុលបង្ហាញផ្ទាល់ពីក្រសួងអប់រំ យុវជន និងកីឡា។

*ការចូលរួមក្នុងការធ្វើកំណែទម្រង់* - គ្រូឧទ្ទេសក៏មិនបានដឹងច្បាស់ថាតើនរណាបានចូលរួមកែទម្រង់កម្មវិធីសិក្សាដោយឆ្លើយថា *មិន ដឹង ប្រហែលជាក្រុមគណៈគ្រប់គ្រង ក្រសួងអប់រំ នាយកដ្ឋានឧត្តមសិក្សា និងប្រធានផ្នែក*។

ការបង្រៀនគួរសមរម្យជាមួយពេលវេលា។ សាស្ត្រាចារ្យគួរតែរៀបចំមេរៀនរបស់ខ្លួន(មេរៀនដែលយើងរៀបចំមានភាពងាយស្រួលក្នុងការបង្រៀនជាង)មេរៀនគួរតែមានភាពទាក់ទង ដែលអាចឱ្យសិស្សយល់ពីវិធីស្វែងរកដំណោះស្រាយ ។ កំណែទម្រង់កម្មវិធីសិក្សាធ្វើឡើងដោយផ្អែកទៅលើកម្មវិធីអប់រំថ្នាក់មធ្យមសិក្សា ។ នៅក្នុងអំឡុងពេលនៃការបង្កើតកម្មវិធីសិក្សាថ្មី សាស្ត្រាចារ្យមួយចំនួនបានរកឃើញនូវផលលំបាក ដែលកើតមានឡើងដោយសារតែសម្ភារៈក្នុងការបង្រៀនមិនឆ្លើយតបទៅនឹងតម្រូវការ ។ កម្មវិធីសិក្សាថ្មីដែលបានបន្ថែមមុខវិជ្ជាថ្មីតួយ៉ាងICTគឺពុំបានឆ្លើយតបទៅនឹងតម្រូវការមូលដ្ឋានពិតឡើយ។

## ៨.៦ ការចូលរួមកំណែទម្រង់កម្មវិធីសិក្សា




គណៈគ្រប់គ្រងដឹងពីគោលនយោបាយនិងដំណើការនៃការធ្វើកំណែទម្រង់កម្មវិធីសិក្សា ខណៈភាគច្រើននៃអ្នកចូលរួមសម្ភាស៍ថា មិនដឹង និងមិនបានទទួលព័ត៌មានពីគោលនយោបាយនៃការធ្វើកំណែទម្រង់ តែមតិភាគច្រើនលើសលប់បង្ហាញឆន្ទៈក្នុងការចូលរួមធ្វើកំណែទម្រង់មានតែម្នាក់ដែលបានសម្ភាសន៍លើកឡើងគួរតែប្រធានផ្នែកតាមមុខវិជ្ជាដែលត្រូវចូលរួម

គ្រូឧទ្ទេសបញ្ចេញចំណាប់អារម្មណ៍ក្នុងការចូលរួមធ្វើកំណែទម្រង់កម្មវិធីសិក្សានៅវិទ្យាស្ថានជាតិអប់រំ ព្រោះថាការចូលរួមនឹងជួយពួកគាត់យល់ដឹងពីដំណើរការអភិវឌ្ឍកម្មវិធីសិក្សា ។ ពួកគេបញ្ជាក់ថា ប្រសិនបើពួកគេចូលរួម ពួកគេនឹងមានភាពងាយស្រួលអនុវត្តកម្មវិធីសិក្សានោះ។ ផ្ទុយទៅវិញ ប្រសិនបើពួកគេមិនបានចូលរួមទេនោះ ពួកគេនឹងមានការលំបាកច្រើនក្នុងការអនុវត្តវា។ ពួកគេទំពឹងទុកថា នឹងយល់ដឹងច្រើនអំពីខ្លឹមសារមេរៀន និងបានយល់ដឹងទូលំទូលាយអំពី កម្មវិធីសិក្សា ប្រសិនបើពួកគេជួយអភិវឌ្ឍវា។ប្រសិនបើពួកគេចូលរួមពួកគេអាចជួយបង្កើតកម្មវិធីសិក្សាឱ្យសមស្របទៅនឹងតម្រូវការរបស់សាលារដ្ឋនិងការផ្លាស់ប្តូរដទៃទៀត។ គ្រូបង្រៀនភាគច្រើនចង់ជួយក្នុងការធ្វើឱ្យប្រសើរឡើងកម្មវិធីសិក្សា និងចង់ជួយធ្វើឱ្យកម្មវិធីសិក្សាកាន់តែស្របគ្នានិង មានកម្មវិធីសិក្សាមួយដែលផ្តល់ឱ្យសិស្សនូវបំណិន និងចំណេះដឹងចាំបាច់សម្រាប់ពួកគេ។

*កម្មវិធីសិក្សាដែលត្រូវបានកែរូច* - គ្រូបង្រៀនយល់ឃើញថា កម្មវិធីសិក្សាដែលត្រូវបានធ្វើកំណែទម្រង់គួរផ្តល់ឱ្យសិស្សនូវឱកាសបង្រៀនគ្នា (មិត្តបង្រៀនមិត្ត)និងស្វ័យសិក្សាដោយខ្លួនឯង។

## ៨.៧ ដំណោះស្រាយ

ដើម្បីជាការចូលរួមចំណែកនិងជាម្ចាស់កម្មសិទ្ធនោះសាស្ត្រាចារ្យចង់ចូលរួមចំណែកក្នុងការកែប្រែកម្មវិធីសិក្សា(គ្រប់មុខវិជ្ជា) និងធ្វើការពិនិត្យមើលនៅពេលដែលពួកគាត់ (អ្នករៀបរៀង) ចូលរួម ហើយពួកគាត់នឹងអាចយល់កាន់តែច្បាស់ថាតើគួរតែបង្រៀនអ្វី។ ពួកគេបានមើលឃើញពីតម្រូវការក៏ដូចជាការចូលរួមជាភ្នាក់ងារដែលជាប់ពាក់ព័ន្ធផងដែរ ។ នាយករងបាននិយាយថាគឺត្រូវតែមានការចូលរួមពីគ្រប់មជ្ឈដ្ឋានទាំងអស់ អ្នករៀបចំបង្កើតកម្មវិធីសិក្សាត្រូវមានគុកោសល្យច្បាស់លាស់ ព្រមទាំងមានជំនាញបច្ចេកទេសផងដែរ។

ការធ្វើគម្រោងផែនការ ៖ ក្រុមសាស្ត្រាចារ្យបានលើកឡើងថា NIE គួរតែមានផែនការកំណែទម្រង់មួយច្បាស់លាស់។ ទោះបីជាយ៉ាងណាក៏ដោយ ការសិក្សាស្រាវជ្រាវគួរតែធ្វើឡើង ហើយស្វែងរកយោបល់ពីអ្នកជំនាញមុននឹងធ្វើការផ្លាស់ប្តូរ។

ការត្រួតពិនិត្យនិងការវាយតម្លៃ៖ ក្រុមសាស្ត្រាចារ្យសង្កេតឃើញពីតម្រូវការនៃការត្រួតពិនិត្យទៅលើសកម្មភាពរបស់គ្រូបង្រៀនសម្រាប់បរិបទនៃកំណែទម្រង់កម្មវិធីសិក្សា ដើម្បីឆ្លើយតបទៅនឹងតម្រូវការ ។ ការទទួលយកនូវប្រតិកម្មពីនាយកនៅសាលារដ្ឋក៏មានសារៈសំខាន់ផងដែរក្នុងការប្រមូលព័ត៌មានពីក្រុមអ្នកធ្វើអធិការកិច្ច។ ក្រុមនាយករងបាននិយាយថាវាពិតជាមានសារៈសំខាន់ក្នុងការកំណត់ភាពខ្លាំងនិងភាពខ្សោយរបស់កម្មវិធីសិក្សាមុននឹងធ្វើការកែទម្រង់ ហើយក៏ទាមទារឱ្យមានការអះអាងថា កម្មវិធីសិក្សាមានភាពសមស្របទៅនឹងកម្រិតចំណេះដឹងរបស់សិស្ស ។ ពួកគេបានស្នើសុំធ្វើការសិក្សាអំពីបញ្ហានានា ដែលកើតឡើងនៅពេលមានការរៀបចំកម្មវិធីសិក្សាកាលពីមុន ហើយនៅតែបន្តប្រើប្រាស់។

សរុបសេចក្តីមកសាស្ត្រាចារ្យមិនអាចដឹងថាតើនរណាជាអ្នករៀបចំការអភិវឌ្ឍកម្មវិធីសិក្សានៅ NIEទេ ប៉ុន្តែពួកគេពិតជាមានចំណាប់អារម្មណ៍ក្នុងការចូលរួមក្នុងដំណើរការនេះ។ ពួកគេបានដឹងថា សាស្ត្រាចារ្យដ៏ទៃទៀតភាគច្រើនមិនបានយល់អំពីដំណើរការនៃកំណែទម្រង់កម្មវិធីសិក្សានៅ NIE ហើយពួកគេសង្កេតឃើញថាកម្មវិធីសិក្សានាពេលបច្ចុប្បន្នមិនមានភាពច្បាស់លាស់ ។ នាយករងបានគូសបញ្ជាក់អំពីតម្រូវការអភិវឌ្ឍន៍គុណភាពនៃកម្មវិធីសិក្សាឱ្យកាន់តែល្អប្រសើរ ហើយគាត់ជឿជាក់ថា ក្រុមសាស្ត្រាចារ្យគួរតែចូលរួមក្នុងការអភិវឌ្ឍកម្មវិធីសិក្សា។ ទោះបីជាយ៉ាងណាក៏ដោយពួកគាត់ត្រូវធ្វើការពិចារណាថា តើនរណាជាអ្នករៀបចំ នរណាដែលគួរតែចូលរួម?។ តែបើមានចំនួនអ្នកចូលរួមច្រើនលើសលប់ពេក ពេលវេលាក៏ត្រូវចំណាយដោយឥតប្រយោជន៍ដែរ។

គណៈគ្រប់គ្រងបានលើកឡើងថាNIEក្នុងពេលថ្មីៗនេះបានធ្វើការអភិវឌ្ឍផែនការរយៈពេល៥ឆ្នាំ (ផែនការអភិវឌ្ឍរបស់NIEឆ្នាំ២០១០-២០១៤) ។ គម្រោងការនេះ ត្រូវបានអភិវឌ្ឍដោយថ្នាក់ដឹកនាំដោយមានការចូលរួមពីសំណាក់សាស្ត្រាចារ្យមួយចំនួនផងដែរ។

*៩. លទ្ធផល និង ការវិភាគ*

*៩.១ បំណកស្រាយ*

ទស្សនៈវិស័យនៃកម្មវិធីសិក្សានាពេលបច្ចុប្បន្ន សាស្ត្រាចារ្យ និងថ្នាក់ដឹកនាំមានទស្សនៈខុសគ្នា បើទោះបីជារឿងនេះត្រូវបានទទួលស្គាល់ក៏ដោយក៏ពុំទាន់មានការឆ្លើយតបឱ្យស្របទៅនឹងតម្រូវការនៃថ្នាក់មធ្យមសិក្សានៅឡើយ ។ សាស្ត្រាចារ្យបានបញ្ជាក់យ៉ាងច្បាស់អំពីបញ្ហានៃកម្មវិធីសិក្សា ហើយបញ្ហាទាំងនោះភាគច្រើនជាប់ទាក់ទងទៅនឹងមុខវិជ្ជាឯកទេសទី២។ សំខាន់ជាងនេះទៅទៀត សាស្ត្រាចារ្យបានបង្ហាញពីការព្រួយបារម្ភថាNIEពុំបានធ្វើការផ្សព្វផ្សាយអំពីមូលដ្ឋាននៃកម្មវិធីសិក្សាបានទូលំទូលាយទៅកាន់បុគ្គលិកដែលជាហេតុនាំឱ្យបុគ្គលិកដែលជាសមាជិកមិនបានយល់ ឬ ដឹងអំពីមូលដ្ឋាននៃកម្មវិធីសិក្សាទាំងនោះ។

ការចូលរួមក្នុងដំណើរការអភិវឌ្ឍកម្មវិធីសិក្សា សាស្ត្រាចារ្យភាគច្រើនមិនទាន់បានចូលរួមក្នុងការអភិវឌ្ឍនៅឡើយ ប៉ុន្តែពួកគេពិតជាមានបំណងចង់ចូលរួមក្នុងដំណើរការនេះ។ ពួកគាត់ចង់ទទួលបានឱកាសក្នុងការចូលរួមកែលម្អកម្មវិធីសិក្សា ដែលអាចធ្វើឱ្យពួកគាត់បានយល់កាន់តែច្បាស់ពីដំណើរការអភិវឌ្ឍកម្មវិធីសិក្សា និងកត្តាដែលចាំបាច់សម្រាប់ប្រើប្រាស់ដើម្បីឱ្យការអនុវត្តទទួលបានភាពជោគជ័យ។

ថ្នាក់ដឹកនាំបានដឹងហើយថាការបង្កើតឬការផ្លាស់ប្តូរកម្មវិធីសិក្សាដោយពុំមានការចូលរួម ពីបុគ្គលិកសំខាន់ដូចជា សាស្ត្រាចារ្យ និងអ្នកតំណាងនៃផ្នែកនីមួយៗ គឺមិនអាចធ្វើឲ្យកម្មវិធីសិក្សាមានគុណភាពខ្ពស់ឡើយ។ ហេតុនេះពួកគាត់គាំទ្រឱ្យមានការចូលរួមច្រើន ប៉ុន្តែអ្នកចូលរួមគួរតែកំណត់ឱ្យបានត្រឹមត្រូវជៀសវាងការចំណាយពេលវេលាឥតប្រយោជន៍ ។ គណៈគ្រប់គ្រងក៏បានលើកឡើងដែរថា ប្រសិនបើកម្មវិធីសិក្សាគ្មានប្រសិទ្ធភាព នោះបុគ្គលដែលជាប់ទាក់ទងតាមផ្នែកនីមួយៗនៃNIE និង ស្ថាប័នពាក់ព័ន្ធនានាមកពី MoEYs ត្រូវតែធ្វើការជាមួយគ្នា។

មូលដ្ឋានគ្រឹះក្នុងការកែទម្រង់កម្មវិធីសិក្សាកន្លងទៅគឺ NIEតែងតែមានការកែទម្រង់កម្មវិធីសិក្សារបស់ខ្លួនដោយពុំមានការចូលរួមពីសាស្ត្រាចារ្យបានគ្រប់គ្នា។ កំណែទម្រង់បានធ្វើឡើងដោយគ្មានការសិក្សាស្រាវជ្រាវនៅNIE ឬ ក៏ពុំមានការវាយតម្លៃថា តើការផ្លាស់ប្តូរឬការកែទម្រង់មានប្រសិទ្ធភាពដែរឬទេ? បើប្រៀបធៀបទៅនឹងកម្មវិធីសិក្សាដែលពុំទាន់ធ្វើ កម្មវិធីសិក្សាថ្មីនេះត្រូវបានដាក់

បញ្ចូលឱ្យប្រើប្រាស់ ដោយសាស្ត្រាចារ្យមានការខ្វះខាតឯកសារ និងសម្ភារក្នុងការបង្រៀន។ មេរៀនមួយចំនួនក៏ពុំទាន់រៀបចំបានសមស្របទៅនឹងពេលវេលាក្នុងការបង្រៀន។

*៩.២ ដែនកំណត់នៃការសិក្សា*

ការបង្រៀនគួរតែមានហេតុផលសមរម្យតាមពេលវេលាក្នុងការបង្រៀន គួរតែកាត់បន្ថយសាស្ត្រាចារ្យ គួរតែរៀបចំមេរៀនរបស់ខ្លួន(មេរៀនដែលយើងរៀបចំមានភាពងាយស្រួលក្នុងការបង្រៀនជាង)មេរៀនគួរតែមានភាពទាក់ទងដែលអាចឲ្យសិស្សយល់ពីវិធីស្វែងរកដំណោះស្រាយបាន។ កំណែទម្រង់កម្មវិធីសិក្សាធ្វើឡើងដោយផ្អែកទៅលើកម្មវិធីអប់រំថ្នាក់មធ្យមសិក្សា។ នៅក្នុងអំឡុងពេលនៃការបង្កើតកម្មវិធីសិក្សាថ្មីសាស្ត្រាចារ្យមួយចំនួនបានរកឃើញនូវផលលំបាកដែលកើតមានឡើងដោយសារតែសម្ភារក្នុងការបង្រៀនមិនឆ្លើយតបទៅនឹងតម្រូវការ។ កម្មវិធីសិក្សាថ្មីបានបន្ថែមមុខវិជ្ជាថ្មីមានICT គឺពុំបានឆ្លើយតបទៅនឹងតម្រូវការមូលដ្ឋានពិតជាក់ស្តែង។

*៩.៣ យោបល់សម្រាប់ការសិក្សាស្រាវជ្រាវនាពេលអនាគត*

សម្រាប់ការសិក្សាលើកក្រោយគួរតែរៀបចំពេលវេលាឲ្យបានច្រើនជាងនេះក្នុងការប្រមូលទិន្នន័យ ដើម្បីឲ្យការរៀបចំកាលវិភាគក្នុងការសម្ភាសន៍មានភាពងាយស្រួលជាងមុន។

គួរតែរៀបចំឡើងនៅការសិក្សាស្រាវជ្រាវប្រហាក់ប្រហែលគ្នានេះដើម្បីស្វែងរកឲ្យឃើញថាតើកត្តាអ្វី ដែលរារាំងការចូលរួមរបស់សាស្ត្រាចារ្យក្នុងការអភិវឌ្ឍកម្មវិធីសិក្សានៅNIE។

## សន្និដ្ឋាន

តាមរយៈលទ្ធផលនៃការសិក្សាស្រាវជ្រាវនេះមានសាស្ត្រាចារ្យតិចតួចប្រហែល(៦,៥ភាគរយ)បានយល់ដឹងពីការធ្វើកម្មវិធីសិក្សារីឯ*អ្នកបានចូលរួមក្នុងការធ្វើកម្មវិធីសិក្សា*នេះឲ្យកាន់តែមានប្រសិទ្ធភាព ក៏មានចំនួនតិចនៅឡើយ*(ប្រហែល ១៥,៦៣ភាគរយ)*ប៉ុណ្ណោះ ។ ដោយសារតែកម្មវិធីសិក្សាមានការផ្លាស់ប្តូរញឹកញាប់យើងក៏បានសិក្សាថាតើវិទ្យាស្ថានមានគោលនយោបាយក្នុងការធ្វើកំណែទម្រង់ដែរឬទេ*? ៦២,៥ភាគរយ មិនបានដឹងថាមានគោលនយោបាយទេ*។ ដោយឡែកមាន*បុគ្គលិក៣១,២៥ភាគរយ* គិតថាការផ្លាស់ប្តូរកម្មវិធីសិក្សានេះ*ប្រហែលជាមានគោលនយោបាយ* ក្នុងនោះ*៦,២៥ភាគរយ* លើកឡើងថាការផ្លាស់ប្តូរនេះ*មានក្នុងគោលនយោបាយត្រឹមត្រូវ*។

លទ្ធផលដូចដែលបានបកស្រាយជូនខាងលើនេះបានបង្ហាញយ៉ាងច្បាស់ថា ៖ វិទ្យាស្ថានអប់រំបានធ្វើកំណែទម្រង់ជាញឹកញាប់ពិតប្រាកដមែន តែការធ្វើនោះពុំទាន់បង្កលទ្ធភាពឱ្យមានការចូលរួមទូលំទូលាយនៅឡើយទេ ជាពិសេសពីសំណាក់ សាស្ត្រាចារ្យ ដែលជាអ្នកអនុវត្តកម្មវិធីសិក្សានេះ ។ កង្វះខាតព័ត៌មានពីគោលនយោបាយក្នុងការអភិវឌ្ឍកម្មវិធីសិក្សាក៏ដូចជាការ

ចូលរួមមិនបានទូលំទូលាយនេះ នឹងមិនអាចធានាបានថា កម្មវិធីសិក្សាដែលបានផ្លាស់ប្តូរនេះមាននូវគុណភាព និងប្រសិទ្ធភាពគ្រប់គ្រាន់ អាចឆ្លើយតបទៅនឹងតម្រូវការបរិបទជាក់ស្តែងក្នុងសង្គមជាតិ។

ការធ្វើកម្មវិធីសិក្សាដែលល្អគួរមានការចូលរួមពីមន្ត្រីជំនាញ និងស្ថាប័នដែលពាក់ព័ន្ធ ទើបអាចឱ្យធ្វើកម្មវិធីសិក្សាឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែងបានល្អ។

## អនុសាសន៍ និង គោលនយោបាយ

- គួរធ្វើការផ្សព្វផ្សាយពីកម្មវិធីសិក្សាគោលដែលមានស្រាប់ឱ្យបានទូលំទូលាយដល់សាស្ត្រាចារ្យទាំងអស់ រួមទាំងការិយាល័យដែលពាក់ព័ន្ធនានាបានជ្រួតជ្រាប
- គណៈគ្រប់គ្រងគួរពិភាក្សាជាមួយការិយាល័យពាក់ព័ន្ធដើម្បីធ្វើគោលនយោបាយអប់រំជាមូលដ្ឋានរបស់វិទ្យាស្ថានជាតិអប់រំ
- គណៈគ្រប់គ្រងត្រូវមានផែនការប្រចាំឆ្នាំនិងរបៀបវារៈច្បាស់លាស់ដើម្បីកោះប្រជុំនិងតាមដានពីការងារអភិវឌ្ឍ និងកំណែទម្រង់ កម្មវិធីសិក្សានេះ
- ត្រូវផ្តល់ឱកាសឱ្យគ្រប់ផ្នែកបានចូលរួមក្នុងសកម្មភាពអភិវឌ្ឍកម្មវិធីសិក្សានេះ
- ដើម្បីធានាបាននូវគុណភាពវិទ្យាស្ថានជាតិអប់រំគួរពិចារណាពីការធ្វើកំណែទម្រង់ផងដែរចំពោះគោលនយោបាយកម្មវិធីសិក្សាចាស់របស់ខ្លួន(ធ្វើបច្ចុប្បន្នភាព)
- ដេប៉ាតឺម៉ង់ផែនការគួរផ្តួចផ្តើមនូវគំនិតក្នុងការធ្វើផែនការអភិវឌ្ឍពិសេសកម្មវិធីសិក្សាគោលសម្រាប់វិទ្យាស្ថានជាតិអប់រំ
- ការិយាល័យស្រាវជ្រាវ ដេប៉ាតឺម៉ង់អប់រំ ដេប៉ាតឺម៉ង់គ្រប់គ្រង និងផែនការ ការិយាល័យសិក្សាត្រូវធ្វើការសិក្សាស្រាវជ្រាវពីកម្មវិធីសិក្សារបស់គ្រឹះស្ថានផ្សេងៗដើម្បីពង្រឹងកម្មវិធីរបស់ខ្លួន
- សាស្ត្រាចារ្យគ្រប់ផ្នែកត្រូវពង្រឹងសមត្ថភាពផ្ទាល់ខ្លួនតាមរយៈការបង្កើននូវការស្រាវជ្រាវ៕

## ឯកសារយោង


1. Ahmet Saban (1995). Outcomes of Teacher Participation in Curriculum Development Process, vol. 115.

2. Bennell, P. & Akyeampong, K. (2007). Motivation of Teacher in Sub Saharan Africa and South Asia-Researching the Issue. London: DFID.

3. Benveniste, L., Marshall, J. & Caridad Araujo, M. (2008). Teaching in Cambodia, Human Development Sector East Asia and the Pacific Region. The World Bank and Ministry of Education, Youth and Sport, Royal Government of Cambodia.

4. Holmes, E.R. & Holmes, L.D. (1995). Other cultures, elder years. Thousand Oaks, CA: Sage.

5. Howard, J. (2007). Curriculum Development, Department of Education, Elon University, retrieved on 7th June 2010 from

6. Markel, M.H. (1992). Technical writing: Situations and Strategies (3rd ed.). New York: St. Martins. MoEF, GDP figures (2005-2007) from

7. MoEYS (2007). Education Law. Cambodia: Ministry of Education, Youth and Sport.

8. MoEYS (2004). Policy for Curriculum Development. Cambodia: Ministry of Education, Youth and Sport.

9. MoEYS (2005). Education Strategy Plan. Cambodia: Ministry of Education, Youth and Sport.

10. MoP (2007). Public Investment Program.

11. Smith, R. (1995). Successful School Management, Great Britain: Biddles Ltd, Guildford & King's Lynn.

12. NEP (2007). The Impact of Informal School Fees on Family Expenditures: Education Operational Research, Phnom Penh: Education Partnership.

13. NEP & VSO (2008). Teaching Matters: Policy Report on the Motivation and Morale of Teachers in Cambodia. Phnom Penh: NEP and VSO.

14. US Bureau of Census (1999). Statistical Abstracts of the United States 1999 (118th ed.). Washington, DC: U.S. Government Printing Offices.

15. Wolfe, P. & Hughes, J. (2007). Curriculum Develop-ment in Higher Education: Faculty-Driven Processes and Practices. New Directions for Teaching and Learning. Vol 112.


### Accessed sites


1. http://74.6.146.127/search/cache?ei=UTF
2. http://mef.gov.kh/statistics/statistics.html
3. http://www.thecanadianencyclopedia.com/index.cfm?PgNm=TCE&Params=A1ARTA0002083
4. http://www.nln.org/ce/CurrDev-day1v2/tsld003.htm
5. http://www.michigan.gov/som/0,1607,7-192-29940_23422-64670--,00.html

# វិទ្យាស្ថានជាតិអប់រំ

## ប្រធានបទ

## ការវាយតម្លៃអប់រំរបស់គរុនិស្សិត និងគ្រូឧទ្ទេស
## នៅវិទ្យាស្ថានជាតិអប់រំ


**ក្រុមសិក្សាស្រាវជ្រាវ**

១. លោក គឹម លាង

២. លោក ម៉ែន សុខសុន្ទី

៣. លោក ទី ប៉ូលីរស្មី

៤. លោក ឃាង ប៉េងលី

# មាតិកា

**ខ្លឹមសារ** **ទំព័រ**


សេចក្តីថ្លែងអំណរគុណ(Acknowlegment) .......................................... ២
១. សេចក្តីផ្តើម (Introduction)............................................................. ៣
២. សាវតានៃបញ្ហាស្រាវជ្រាវ (Background) ........................................ ៤
៣. គោលបំណងស្រាវជ្រាវ ....................................................................... ៤
៤. សំណួរស្រាវជ្រាវ (Question of research) ......................................... ៥
៥.ដំណើរការស្រាវជ្រាវ (Process) ......................................................... ៥
៥.១មូលហេតុនៃការជ្រើសរើសវិធីសាស្ត្រស្រាវជ្រាវ (Reason).................. ៥
៥.២សំណាកនិងទីកន្លែង (Sample and location) .................................. ៥
៥.៣ការសុំការអនុញ្ញាត (Permission) ...................................................... ៥
៦. វិធីសាស្ត្រស្រាវជ្រាវ (Research methodology) ................................ ៦
៦.១ការប្រមូលទិន្នន័យ (Data collection) ................................................ ៦
៦.២វិធីសាស្ត្រវិភាគទិន្នន័យ (Data analysis) .............................. ៦
៦.៣លទ្ធផលរំពឹងទុកនៃការស្រាវជ្រាវ (Respect)...................................... ៧
៧. ការរំលឹកទ្រឹស្តីនិងការសិក្សាដែលពាក់ព័ន្ធ (Review) ............................ ៧
៧.១ការវាយតម្លៃអប់រំនៅវិទ្យាស្ថានជាតិអប់រំ (Educational assessment in NIE)
៧.២បញ្ញត្តិនិងទ្រឹស្តីនៃការវាយតម្លៃអប់រំ (Concept and Review)............. ៨
៨. ទិន្នន័យរកឃើញ (Finding) ................................................................ ១០
៨.១បញ្ហាប្រឈម (Challenges) ............................................................... ១១
៨.២សំណូមពរសម្រាប់កែប្រែនិងអភិវឌ្ឍន៍ ............................................... ១២
៩. សន្និដ្ឋាន (Conclusions) ................................................................. ១២
១០. ការផ្តល់អនុសាសន៍(Recommendation) ........................................... ១២
១១. ឯកសារយោង(Reference) ................................................................ ១៣
ឧបសម្ពន្ធ (Annex)
A- ចំពោះគរុនិស្សិត
B-សម្រាប់គ្រូឧទ្ទេស

# សេចក្តីថ្លែងអំណរគុណ (Acknowledgment)

យើងខ្ញុំជាក្រុមស្រាវជ្រាវការសិក្សាប្រតិបត្តិមានកិត្តិយស សូមថ្លែងអំណរគុណចំពោះ៖

- ក្រសួងអប់រំ យុវជន និងកីឡា
- គម្រោងលើកកម្ពស់គុណភាពអប់រំ
- វិទ្យាស្ថានជាតិអប់រំ
- មន្ត្រីបុគ្គលិកសាស្ត្រាចារ្យព្រមទាំងគរុនិស្សិតនៅវិទ្យាស្ថានជាតិអប់រំ

ដែលបានបង្កលក្ខណៈងាយស្រួលចូលរួមសហការ ជួយឧបត្ថមគាំទ្រនិងផ្តល់ឱកាសឱ្យដំណើរការសិក្សាប្រតិបត្តិនេះបានទទួលលទ្ធផលចប់សព្វគ្រប់។

## ១. សេចក្តីផ្តើម

ការអប់រំមានតួនាទីយ៉ាងសំខាន់ក្នុងការបណ្តុះបណ្តាលធនធានមនុស្ស ដែលជាធនធានចាំបាច់បំផុតនិងប្រើប្រាស់មិនចេះរីងស្ងួត សម្រាប់ការអភិវឌ្ឍប្រទេសជាតិ ។ ការអប់រំត្រូវការនូវធនធាននេះជាចាំបាច់ ជាពិសេសគ្រូបង្រៀន ព្រោះគ្រូបង្រៀនគឺជាអ្នកអប់រំកូនចៅប្រជាពលរដ្ឋឱ្យក្លាយទៅជាបញ្ញវន្តប្រកបទៅដោយសីលធម៌វិជ្ជាជីវៈនិងមានចំណេះដឹងខ្ពង់ខ្ពស់តាមមុខជំនាញឯកទេសដើម្បីកសាងប្រទេសជាតិឆ្ពោះទៅរកការអភិវឌ្ឍ ហើយក៏ឱ្យពួកគេក្លាយជាមនុស្សពេញលេញ ជាពលរដ្ឋថ្លៃថ្នូរប្រកបទៅដោយពហុបច្ចេកវិទ្យាទំនើប។រាជរដ្ឋាភិបាលចាត់ទុកការអប់រំជាយុទ្ធសាស្ត្រចម្បងនៅពេលដែលប្រទេសជាតិរួចចាកផុតពីសង្គ្រាម ដើម្បីកាត់បន្ថយភាពក្រីក្រ និងលើកផែនការអភិវឌ្ឍផ្នែកសេដ្ឋកិច្ច សង្គមកិច្ច ប្រកបដោយចីរភាព និងអភិបាលកិច្ចល្អ ដែលកត្តាបំពេញឱ្យគ្នាទៅវិញទៅមក នៅក្នុងការកំណត់នូវភាពជោគជ័យ។[1]

មុខវិជ្ជាវិទ្យាសាស្ត្រគណិតវិទ្យា និងព័ត៌មានវិទ្យា គឺជាមុខវិជ្ជាមួយ ដែលទាញការពិតពីទ្រឹស្តីទូទៅ ដឹងពីហេតុការណ៍ពិសេសជាក់ស្តែងពីការអនុវត្តផ្ទាល់។ ដើម្បីបណ្តុះបណ្តាល ឬបង្រៀនគណិតវិទ្យា និងវិទ្យាសាស្ត្រឱ្យបានល្អសម្រាប់ជាគុណប្រយោជន៍ដល់គ្រូឧទ្ទេស និងគរុនិស្សិតត្រូវទាមទារឱ្យយើងយកចិត្តទុកដាក់ទៅលើបំណិននៃចំណេះដឹង បំណិននៃចំណេះធ្វើ វិធីសាស្ត្រហ្វឹកហ្វឺនក្នុងការបង្ហាត់បង្រៀន និងសិក្សាស្រាវជ្រាវ ហើយជាងនេះទៅទៀតគឺផ្តោតទៅលើសកម្មភាពបង្រៀននិងរៀនស្រាវជ្រាវ ពិសេសអំពីកិច្ចការស្រាវជ្រាវ និងការវាយតម្លៃអប់រំរបស់ពួកគេ ក្នុងការអភិវឌ្ឍសមត្ថភាពផ្នែកឯកទេសស្របតាមតម្រូវការបរិស្ថានសង្គម រីកចម្រើននាយុគសម័យបច្ចុប្បន្ន។

ចំពោះគរុនិស្សិត "បរិញ្ញា+១" មុខវិជ្ជាគណិតវិទ្យា និងវិទ្យាសាស្ត្រ ដើម្បីក្លាយខ្លួនជាគ្រូបង្រៀនម្នាក់ដែលមានទេពកោសល្យ និងសមត្ថភាពពេញលេញ ចាំបាច់ត្រូវមានការធ្វើតេស្ត និងការវាយតម្លៃអប់រំជាប្រចាំមួយ ដើម្បីបញ្ជាក់ពីសមត្ថភាពរបស់បុគ្គលម្នាក់ៗទៅលើមុខវិជ្ជាតាមឆមាសនីមួយៗ ។

ហេតុដូចបានបង្ហាញជូនខាងលើ ការសិក្សាស្រាវជ្រាវនេះ គឺផ្តោតទៅលើ"*ការវាយតម្លៃអប់រំ នៅវិទ្យាស្ថានជាតិអប់រំ៖ ការអនុវត្ត និងការយល់ឃើញរបស់គ្រូឧទ្ទេស និងគរុនិស្សិត នៃមុខវិជ្ជា វិទ្យាសាស្ត្រ និងគណិតវិទ្យា* "។

ការបណ្តុះបណ្តាលគរុនិស្សិត(បរិញ្ញា+១)មុខវិជ្ជាគណិតវិទ្យា និងវិទ្យាសាស្ត្រនៅវិទ្យាស្ថានជាតិអប់រំជាគម្រោងដ៏សំខាន់មួយ ដែលផ្តោតការយកចិត្តទុកដាក់ខ្ពស់ទៅលើការវាយតម្លៃអប់រំរបស់គ្រូឧទ្ទេស និងគរុនិស្សិត ហើយតម្រូវឱ្យមានការបណ្តុះបណ្តាលនូវធនធានមនុស្សទៅតាមសំណូមពរនៃការអភិវឌ្ឍរបស់ប្រទេសជាតិពោលគឺ ៖ គ្រូឧទ្ទេសត្រូវមានបេសកកម្មនិងបន្ទុកដ៏ធ្ងន់ធ្ងរក្នុងការបង្រៀនដឹកនាំកិច្ចការស្រាវជ្រាវ និងវាយតម្លៃអប់រំមនុស្សទៅតាមលំនាំនៃជំហានអភិវឌ្ឍរបស់វិទ្យាសាស្ត្រក្នុងសង្គមមនុស្សជាតិ ចំណែកឯគរុនិស្សិតត្រូវមានបេសកកម្ម

[1] របាយការណ៍ស្រាវជ្រាវការបណ្តុះបណ្តាលគរុនិស្សិតបរិញ្ញា+1ផ្នែកគណិតវិទ្យានៅវិទ្យាស្ថានជាតិអប់រំ២០០៩

និងភារៈកិច្ចរបស់ខ្លួនក្នុងការសិក្សាស្រាវជ្រាវឱ្យមានចំណេះដឹងខ្ពស់ ព្រោះវាជាកញ្ចក់ដើម្បីឆ្លុះសម្រាប់វាយតម្លៃការអប់រំលើមុខវិជ្ជា គណិតវិទ្យា និងវិទ្យាសាស្ត្រ។ ដូច្នេះទាមទារឱ្យគ្រូឧទ្ទេសនិងគរុនិស្សិតត្រូវតែឈ្លាសវៃមានភាពប៉ិនប្រសប់ក្នុងបេសកកម្ម និងការងាររបស់ខ្លួន។

ដើម្បីសម្រេចឱ្យបាននូវគោលដៅអប់រំជាតិ គ្រូឧទ្ទេស និងគរុនិស្សិត ត្រូវផ្សារភ្ជាប់សកម្មភាពកិច្ចការស្រាវជ្រាវរបស់ខ្លួនទៅនឹងសកម្មភាពនានាជាមួយសហគមន៍ រដ្ឋអំណាចមូលដ្ឋាន និងមជ្ឈដ្ឋានជុំវិញវិទ្យាស្ថានជាតិអប់រំ ដើម្បីអភិវឌ្ឍការវាយតម្លៃអប់រំ និងការបណ្តុះបណ្តាល។

## ២. សាវតានៃបញ្ហាស្រាវជ្រាវ (Background)

បទពិសោធន៍សម្រាប់ផ្ទេរចំណេះដឹងឱ្យមនុស្សពីជំនាន់មួយទៅជំនាន់មួយទៀត ត្រូវចងក្រងជាឯកសារសម្រាប់សិក្សាស្រាវជ្រាវពីមួយថ្ងៃទៅមួយថ្ងៃឱ្យមានលក្ខណៈកាន់តែសុក្រិត។ ទន្ទឹមនឹងនេះការអប់រំក៏កាន់តែមានលក្ខណៈវិទ្យាសាស្ត្រផងដែរ។ការអប់រំត្រូវធ្វើឱ្យបទពិសោធន៍មានតុល្យភាពទៅនឹងចំណេះដឹង ដែលមនុស្សអាចទទួលយកបាន រីឯការផ្តល់ និងទទួលចំណេះដឹង គឺទាមទារឱ្យគ្រូឧទ្ទេសនិងគរុនិស្សិត គប្បីមានលក្ខណៈវិនិច្ឆ័យច្បាស់លាស់ក្នុងការវែកញែកស្រាវជ្រាវឱ្យឃើញនូវចំណុចល្អនិងចំណុចខ្វះខាត។ ការអប់រំមនុស្សត្រូវតែដឹងឱ្យបានច្បាស់អំពីផែនការអភិវឌ្ឍសេដ្ឋកិច្ចនិងវិស័យផ្សេងៗទៀតជាមុនហើយក្រសួងអប់រំត្រូវបណ្តុះបណ្តាលធនធានមនុស្សទៅតាមកម្មវិធីដែលឆ្លើយតបបានទៅនឹងផែនការនៃការអភិវឌ្ឍនេះជាមុន។ កាលណាការបណ្តុះបណ្តាលជួបចំណុចខ្វះខាតមានដូចជាជំនាញឯកទេសកម្មវិធីនោះនាំឱ្យវិស័យអប់រំ សេដ្ឋកិច្ច និងវិស័យផ្សេងៗទៀតមិនបោះជំហានទៅមុខ ។ យ៉ាងណាមិញបើសម្ភារឋវិកាសម្រាប់បម្រើឱ្យវិស័យអប់រំ ឬការបណ្តុះបណ្តាលមិនគ្រប់គ្រាន់ទេនោះ គុណភាពអប់រំ ឬគុណភាពនៃការបណ្តុះបណ្តាលធនធានមនុស្សសម្រាប់សេដ្ឋកិច្ច និងវិស័យឯទៀត ក៏មិនអាចទទួលផលល្អដែរ ។

ដោយសារបញ្ហាទាំងនេះហើយ ទើបធ្វើឱ្យវិទ្យាស្ថានជាតិអប់រំ មានភារកិច្ចដ៏ធំធេងក្នុងការផ្តល់ចំណេះដឹង និងការស្រាវជ្រាវ ពោរពេញទៅដោយសមត្ថភាព និងគុណភាពខ្ពស់ប្រកបដោយមនសិការវិជ្ជាជីវៈ។ចំពោះគ្រូឧទ្ទេស និងគរុនិស្សិត គប្បីមានលក្ខណៈវិនិច្ឆ័យច្បាស់លាស់ក្នុងការវែកញែកដើម្បីអនុវត្តការងាររបស់ខ្លួនឱ្យបានជោគជ័យនិងមានប្រសិទ្ធភាពដោយត្រូវយល់ដឹងច្បាស់អំពីវិធីសាស្ត្រវាយតម្លៃអប់រំសម្រាប់មុខវិជ្ជាឯកទេសរបស់ខ្លួន។

## ៣. គោលបំណងស្រាវជ្រាវ (Objective of research)

ការសិក្សាស្រាវជ្រាវនេះមានគោលបំណង ដើម្បីស្វែងយល់អំពីការអនុវត្តការវាយតម្លៃអប់រំមុខវិជ្ជាគណិតវិទ្យា និងវិទ្យាសាស្ត្រនៅវិទ្យាស្ថានជាតិអប់រំ ដោយផ្តោតលើការយល់ឃើញរបស់គ្រូឧទ្ទេស និងគរុនិស្សិត អំពីការអនុវត្តរបៀបវាយតម្លៃអប់រំមុខវិជ្ជា វិទ្យាសាស្ត្រ និងគណិតវិទ្យា។

## ៤. សំណួរស្រាវជ្រាវ (Question of research)

ការសិក្សានេះ នឹងឆ្លើយសំណួរដូចខាងក្រោម ៖

ក-តើការអនុវត្តការវាយតម្លៃអប់រំមុខវិជ្ជាវិទ្យាសាស្ត្រ និងគណិតវិទ្យានៅវិទ្យាស្ថានជាតិអប់រំមានលក្ខណៈយ៉ាងដូចម្តេច?(បញ្ហាប្រឈម)

ខ- តើគ្រូឧទ្ទេស និងគរុនិស្សិតយល់ឃើញយ៉ាងដូចម្តេចអំពីការអនុវត្តការវាយតម្លៃអប់រំមុខវិជ្ជាវិទ្យាសាស្ត្រនិងគណិតវិទ្យានៅវិទ្យាស្ថានជាតិអប់រំ? (សំណូមពរ និងការកែលំអ)

## ៥. ដំណើរការស្រាវជ្រាវ (Process)

### ៥.១ មូលហេតុនៃការជ្រើសរើសវិធីសាស្ត្រស្រាវជ្រាវ (Reason)

វិទ្យាស្ថានជាតិអប់រំជាគ្រឹះស្ថានបណ្តុះបណ្តាលមួយ ដែលមានភារកិច្ចដ៏សំខាន់ក្នុងវិស័យអប់រំ។ ដើម្បីសម្រេចភារកិច្ចដ៏ធំធេងនេះ ទាមទារឱ្យគ្រូឧទ្ទេស និងគរុនិស្សិត គប្បីមានលក្ខណៈវិនិច្ឆ័យច្បាស់លាស់ក្នុងការវែកញែក ដើម្បីអនុវត្តការងាររបស់ខ្លួនឱ្យបានជោគជ័យ និងមានប្រសិទ្ធភាពដោយត្រូវយល់ដឹងច្បាស់អំពីវិធីសាស្ត្រវាយតម្លៃអប់រំសម្រាប់មុខវិជ្ជាឯកទេសរបស់ខ្លួន។

ក្នុងការសិក្សាស្រាវជ្រាវ គឺផ្តោតសំខាន់ទៅលើប្រសិទ្ធភាពនៃការវាយតម្លៃអប់រំសម្រាប់គ្រូឧទ្ទេស និងគរុនិស្សិត ដោយឱ្យពួកគេស្គាល់អំពី៖

- ភាពខ្លាំង និងភាពខ្សោយ នៃវិធីសាស្ត្រវាយតម្លៃអប់រំនីមួយៗ។
- វិធីសាស្ត្រវាយតម្លៃអប់រំ ប្រើប្រាស់សម្រាប់បង្កើនបំណិន និងសមត្ថភាពចំណេះដឹង នឹងត្រូវបានពង្រីក។
- វិធីសាស្ត្រវាយតម្លៃអប់រំ គឺការផ្ទុផ្ទង រវាងការសិក្សា និងលទ្ធផលសិក្សា។
- ការវាយតម្លៃត្រូវតែអភិវឌ្ឍសមត្ថភាពរបស់សាស្ត្រាចារ្យ និងគរុ-និស្សិត ដើម្បីធ្វើសុភវិនិច្ឆ័យទុកសម្រាប់ការបំពេញកិច្ចការឱ្យបានល្អ។
- ការវាយតម្លៃអប់រំគួរតែបង្កើតសម្រាប់ឆ្លើយតបប្រតិកម្មរបស់ពួកគេ។

### ៥.២សំណាក និងទីកន្លែង (Sample and location)

ដំណើរការស្រាវជ្រាវនេះត្រូវជ្រើសរើសសំណាកតាមបែបវិធីងាយស្រួល ។ ការប្រមូលសំណាកគឺធ្វើឡើងតាមបែបគុណភាពដោយប្រើការសម្ភាសន៍ពាក់កណ្តាលរចនាសម្ព័ន្ធជាមួយគ្រូឧទ្ទេស ។ ដោយជ្រើសរើសយកគ្រូឧទ្ទេសតាមបែបសកលស្ថិតិ (Population) ចំនួន១៨នាក់និងជាមួយគរុនិស្សិតតាមបែបចៃដន្យ (Random) ចំនួន២០នាក់ក្នុងចំណោម៦មុខវិជ្ជាដែលត្រូវបានកំណត់។

ការប្រមូលទិន្នន័យតាមបែបបរិមាណយើងនឹងប្រើកម្រងសំណួរ ។ សម្រាប់គ្រូឧទ្ទេសជ្រើសរើសតាមបែបសកលស្ថិតិ (Population) ៤០នាក់។សម្រាប់គរុនិស្សិតជ្រើសរើសយកតាមបែបចៃដន្យ(Random) ចំនួន១៨៥នាក់លើមុខវិជ្ជាចំនួន៦ដើម្បីឱ្យពួកគេបំពេញកម្រងសំណួរ

ទាំងនោះ។កិច្ចការស្រាវជ្រាវនេះនឹងធ្វើសំណាកជាមួយគ្រូឧទ្ទេសនិងគរុនិស្សិតនៅវិទ្យាស្ថានជាតិអប់រំ។

**៥.៣ការសុំការអនុញ្ញាត** (Permission)

ក្រុមស្រាវជ្រាវនឹងប្រមូលទិន្នន័យពីគណៈគ្រប់គ្រង គ្រូឧទ្ទេស និងគរុនិស្សិតនៃវិទ្យាស្ថានជាតិអប់រំបន្ទាប់ពីបានទទួលការអនុញ្ញាតពីក្រសួងអប់រំយុវជន និងកីឡា។

## ៦. វិធីសាស្ត្រស្រាវជ្រាវ (Research methodology)

### ៦.១ ការប្រមូលទិន្នន័យ (Data collection)

ការប្រមូលទិន្នន័យគឺប្រើប្រាស់វិធីសាស្ត្រតាមបែបគុណវិស័យនិងបរិមាណវិស័យដោយសម្ភាសន៍ពាក់កណ្តាលរចនាសម្ព័ន្ធជាមួយគ្រូឧទ្ទេសគរុនិស្សិត និងការប្រើប្រាស់កម្រងសំណួរ។

ការសម្ភាសន៍ពាក់កណ្តាលរចនាសម្ព័ន្ធមានចំនួន១០សំណួរ សួរសាស្ត្រាចារ្យចំនួន ១៨ នាក់ ។ រីឯគរុនិស្សិតមាន៧សំណួរ ។ គរុនិស្សិតដែលត្រូវសួរមានចំនួន ២០នាក់ ចែកចេញជា២០ក្រុមជ្រើសរើសក្នុងចំណោម៦មុខវិជ្ជារួមមានគណិតវិទ្យា(៨ក្រុម) ព័ត៌មានវិទ្យា(៣ក្រុម) រូបវិទ្យា(៣ក្រុម) គីមីវិទ្យា(២ក្រុម) ជីវវិទ្យា(២ក្រុម) និងផែនដីវិទ្យា(២ក្រុម)។ គរុនិស្សិតទាំងនោះត្រូវបានផ្តល់សំណួរសំខាន់ៗសម្រាប់ពិភាក្សាផងដែរ ដែលក្រុមពិភាក្សា ត្រូវបានបែងចែកជា៦ក្រុមក្នុងមួយក្រុមៗមានសមាជិក ២ឬ៣នាក់។

ចំណែកឯកម្រងសំណួរ គឺចែកចេញជាពីរ គឺកម្រងសំណួរសម្រាប់សាស្ត្រាចារ្យ និងកម្រងសំណួរសម្រាប់គរុនិស្សិត ។ កម្រងសំណួរសម្រាប់សាស្ត្រាចារ្យមានចំនួន ២៥សំណួរសួរទៅលើសាស្ត្រាចារ្យចំនួន ៤០នាក់ ។ រីឯកម្រងសំណួរសម្រាប់គរុនិស្សិតមាន២៧សំណួរសួរទៅលើគរុនិស្សិតចំនួន ១៨៥នាក់ ក្នុងចំណោមគរុនិស្សិត ៤៦០នាក់នៃមុខវិជ្ជាទាំង៦ ។ សំណួរសម្ភាសន៍ និងកម្រងសំណួរទាំងនោះ គឺផ្តោតទៅលើការអនុវត្តរបស់សាស្ត្រាចារ្យ និងគរុនិស្សិតនៅវិទ្យាស្ថានជាតិអប់រំ។

រយៈពេលនៃការប្រមូលទិន្នន័យគឺ ៣៣ ថ្ងៃ ចាប់ពីថ្ងៃទី ២៦ ខែ វិច្ឆិកាដល់ថ្ងៃទី២៨ ខែ ធ្នូ ឆ្នាំ ២០១០។

### ៦.២ វិធីសាស្ត្រវិភាគទិន្នន័យ (Data analysis)

ទិន្នន័យដែលប្រមូលបាន ត្រូវបញ្ចូលក្នុងកម្មវិធី SPSS និង Excel ហើយយកមកវិភាគតាមបែបបរិមាណវិស័យ និងគុណវិស័យដោយបង្កើតជាតំនូសតាង ជាក្រាហ្វិកជាប្រេកង់(ភាគរយ) និងជាមធ្យមភាគ ដើម្បីធ្វើការប្រៀបធៀប ។ ទាញសេចក្តីសន្និដ្ឋាន និងវាយតម្លៃទៅលើលទ្ធផលដែលសម្រេចបាន។

ក្នុងពេលវិភាគទិន្នន័យត្រូវប្រើរយៈពេល៣០ថ្ងៃ ពីថ្ងៃទី០១ ដល់ ថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១១។

### ៦.៣ លទ្ធផលរំពឹងទុកនៃការស្រាវជ្រាវ (Expected Out Comes)

ការស្រាវជ្រាវនេះ នឹងផ្តល់នូវការយល់ដឹងអំពីការអនុវត្តរបស់សាស្ត្រាចារ្យ និងគរុនិស្សិត សំដៅលើការញែកឱ្យច្បាស់ពីរបៀបប្រតិបត្តិការវាយតម្លៃអប់រំ ដែលមានការអភិវឌ្ឍ និងឱ្យមានការទទួលស្គាល់ថា សកម្មភាពវាយតម្លៃអប់រំអនុវត្តឡើងដើម្បីអភិវឌ្ឍការធ្វើសុក វិនិច្ឆ័យលើព័ត៌មានដែលបានសិក្សារួច និងសម្រាប់ឆ្លើយតបទៅនឹងប្រតិកម្មរបស់គរុនិស្សិត។វាជាការចាំបាច់ណាស់ ដើម្បីបំពេញកង្វះខាតចំពោះអ្នកមានមុខរបរប្រកបដោយវិជ្ជាជីវៈ និងរួមចំណែកយ៉ាងមានប្រសិទ្ធភាពក្នុងដំណើរការបង្រៀនដែលជាតម្រូវការល្អសម្រាប់គ្រូ និងពង្រឹងបន្ថែមលើសមត្ថភាពរៀនរបស់គរុនិស្សិត។

## ៧. ការរំលឹកទ្រឹស្តី និងការសិក្សាដែលពាក់ព័ន្ធ (Review)

### ៧.១ ការវាយតម្លៃអប់រំនៅវិទ្យាស្ថានជាតិអប់រំ (Educational assessment in NIE)

វិទ្យាស្ថានជាតិអប់រំ ជាគ្រឹះស្ថានបណ្តុះបណ្តាលគរុនិស្សិតឱ្យក្លាយទៅជាគ្រូបង្រៀនកម្រិតឧត្តមប្រកបដោយគុណភាព និងប្រសិទ្ធភាព ដើម្បីសម្រេចបាននូវចក្ខុវិស័យនេះ គរុនិស្សិតតឹតម្រូវឱ្យធ្វើការប្រឡងចូលរៀន ហើយនៅក្នុងរយៈពេលបណ្តុះបណ្តាលគរុនិស្សិត ត្រូវប្រឡងគ្រប់មុខវិជ្ជាទាំងអស់ ដែលមានចែងក្នុងកម្មវិធីសិក្សា។ ការវាយតម្លៃសម្រាប់គរុនិស្សិតបានចូលរៀន និងរៀន នៅវិទ្យាស្ថានជាតិអប់រំរួមមាន៖

- ការប្រឡងជ្រើសរើសចូលរៀនទៅតាមតម្រូវការ នៃផែនការរបស់ក្រសួងអប់រំយុវជន និងកីឡា។
- ការប្រឡងត្រួតពិនិត្យឆមាសលើកទីមួយទៅតាមមុខវិជ្ជាដែលបានរៀន។
- ការប្រឡងឆមាសទីមួយ ដោយបង្កើតជាសម័យប្រឡង មានន័យថាគរុនិស្សិតត្រូវប្រឡងជុំគ្នាក្នុងរយៈពេលបីថ្ងៃ។
- ការចុះទៅធ្វើកម្មសិក្សាប្រតិបត្តិគរុកោសល្យ។
- ការប្រឡងត្រួតពិនិត្យឆមាសទីពីរទៅតាមមុខវិជ្ជាដែលបានរៀន។
- កិច្ចការស្រាវជ្រាវ និងតាំងពិព័រណ៍វិទ្យាសាស្ត្រ។
- ការប្រឡងឆមាសលើកទីពីរ។
- ការប្រឡងបញ្ចប់ការបណ្តុះបណ្តាល[2]។
- ការវាយតម្លៃសីលធម៌។

ព្រមទាំងយោងតាមផែនការអនុវត្តន៍កម្មវិធីបណ្តុះបណ្តាលគរុនិស្សិតកម្រិតឧត្តម (បរិញ្ញា+១) ដែលមាននៅវិទ្យាស្ថានជាតិអប់រំ។

ក្នុងពេលដំណើរការសិក្សា ការវាយតម្លៃអប់រំទាំងនេះសំដៅលើ៖

- **មធ្យមពិន្ទុប្រចាំឆមាសទី១ ៥០%**

  មធ្យមពិន្ទុប្រឡងត្រួតពិនិត្យឆមាសទី១ + មធ្យមពិន្ទុប្រឡងឆមាសទី១ចែកនឹង២

[2]សេចក្តីជូនដំណឹងរបស់ ក្រសួងអប់រំ យុវជន និងកីឡា ឆ្នាំ ២០០៩

- **មធ្យមពិន្ទុប្រចាំឆមាសទី២ ៥០%**
  មធ្យមពិន្ទុប្រឡងត្រួតពិនិត្យឆមាសទី២ + មធ្យមពិន្ទុប្រឡងឆមាសទី២ចែកនឹង២
- កិច្ចការស្រាវជ្រាវ និងតាំងពិព័រណ៍ ២០%
- **ពិន្ទុប្រចាំឆ្នាំ**
  មធ្យមពិន្ទុប្រចាំឆមាសទី១ + មធ្យមពិន្ទុប្រចាំឆមាសទី២ +កិច្ចការស្រាវជ្រាវ និងតាំងពិព័រណ៍=១០០ % (៥០%+៥០%+២០%)ចែកនឹង៣
- **សម្រាប់មធ្យមពិន្ទុវាយតម្លៃវគ្គបណ្តុះបណ្តាលទាំងមូលគឺ ៖**
  (ពិន្ទុប្រចាំឆ្នាំ+ពិន្ទុប្រឡងបញ្ចប់+ពិន្ទុកម្មសិក្សាប្រតិបត្តិ)/៣

**៧.២ បញ្ញត្តិ និងទ្រឹស្តីនៃការវាយតម្លៃអប់រំ** (Concept and Review)

ក.យោងតាមទ្រឹស្តីប្រសិទ្ធភាពអប់រំរបស់Hornby (2003) ៖

នៅពេលដែលប្រើប្រាស់វិធីសាស្ត្រវាយតម្លៃ គឺត្រូវមានសំណួរជាច្រើនបានលេចឡើងដោយមានសេចក្តីដូចតទៅនេះ៖

តើអ្វីជាភាពខ្លាំង និងភាពខ្សោយ នៃវិធីសាស្ត្រវាយតម្លៃអប់រំនីមួយៗ?

តើការប្រើប្រាស់វិធីសាស្ត្រវាយតម្លៃអប់រំដែលអាចទទួលយកបាន ត្រូវពង្រីកទៅលើផ្នែកអ្វីខ្លះ?

តើវិធីសាស្ត្រវាយតម្លៃអប់រំ ដែលប្រើប្រាស់សម្រាប់បង្កើនបំណិនប្រសប់ និងសមត្ថភាពចំណេះដឹងត្រូវពង្រីកទៅលើផ្នែកអ្វីខ្លះ?

តើវិធីសាស្ត្រវាយតម្លៃអប់រំគឺជាការផ្ទុផ្តងរវាងការសិក្សា និងលទ្ធផលសិក្សាដែរឬទេ?

តើនិស្សិត សាស្ត្រាចារ្យ និងមន្ត្រីអប់រំដែលពាក់ព័ន្ធនឹងការងារបណ្តុះបណ្តាលទាំងអស់យល់ដឹងច្បាស់អំពីលក្ខណៈវិនិច្ឆ័យនៅក្នុងវិធីសាស្ត្រវាយតម្លៃអប់រំ និងរបៀបដែលត្រូវបង្កើតដើម្បីវាយតម្លៃដែរឬទេ?

ខ. យោងតាមទ្រឹស្តីនៃការវាយតម្លៃសម្រាប់អនាគត (Assessment Futures) របស់ University of Technology Sydney[3]៖

ការវាយតម្លៃគឺជាមូលដ្ឋាននៃសំណើមួយដែលវាយតម្លៃការអប់រំនៅឧត្តមសិក្សាដោយ មានការខ្វះចន្លោះទាក់ទិនទៅនឹងការឱ្យសញ្ញាបត្រនិងការវិនិច្ឆ័យពិន្ទុឱ្យបានត្រឹមត្រូវហើយជាគោលបំណងរួម និងជាតម្រូវការចាំបាច់ សម្រាប់ជួយដល់ការវាយតម្លៃមិនច្បាស់លាស់ការវាយតម្លៃត្រូវតែជួយគាំទ្រការសិក្សា ជាងនេះទៅទៀត វាត្រូវតែជួយគាំទ្រដំណើរការនៃការសិក្សា ដែលនិស្សិតបានបញ្ចប់ពីការសិក្សារបស់ខ្លួន។ ការវាយតម្លៃត្រូវតែលើកតម្កើងឥរិយាបថ សម្បទាចំណេះដឹង និងបំណិនទៀតផង។ អ្នកសិក្សាត្រូវការស្រាវជ្រាវកិច្ចការផ្សេងៗដែលពួកគេត្រូវប្រឈមទៅនឹងជីវភាពរស់នៅរបស់ពួកគេ។ មានន័យថាបទប្បញ្ញត្តិនៃការវាយតម្លៃរបស់យើងគឺត្រូវតែធ្វើការផ្លាស់ប្តូរ ដោយផ្តោតជាសំខាន់ទៅលើអ្វីដែលត្រូវបានបង្រៀន ឬ ផ្តោតសំខាន់

[3]Boud, D. and Associates (2010). *Assessment 2020: Seven propositions for assessment reform in higher education*. Sydney: Australian Learning and Teaching Council.

ទៅលើការវាស់លទ្ធផលសិក្សារបស់និស្សិតដើម្បីកសាងសមត្ថភាពនិងប្រសិទ្ធភាពសម្រាប់ពួកគេ និងសម្រាប់អ្នកឯទៀត។

បញ្ហានេះមិនមានន័យថាសញ្ញាបត្ររបស់គរុនិស្សិតមិនសំខាន់នោះទេវាមានន័យថាការវាយតម្លៃជាប្រធានបទ សំដៅទៅលើអ្វីដែលតម្រូវឱ្យមានការទាំទ្រដល់ការសិក្សា និងការកសាងសមត្ថភាពគរុនិស្សិត ហើយគរុនិស្សិតចាំបាច់ត្រូវធ្វើសុភវិនិច្ឆ័យ។ ហេតុនេះសំណួរដែលត្រូវបានសួរសម្រាប់ការវាយតម្លៃ មិនគួរសួរថា តើការវាយតម្លៃអាចទុកចិត្តបាន និងត្រឹមត្រូវម៉ត់ចត់ដែរឬទេ? ជំនួសសំណួរនេះ យើងគួរសួរថា តើការវាយតម្លៃ វានឹងចូលរួមចំណែកសម្រាប់ការគាំទ្រដល់ដំណើរការនៃការសិក្សាដែរឬទេ? បើមិនធ្វើដូច្នោះទេ នោះគ្មានចំណុចផ្លាស់ប្តូរចំពោះដំណើរការសិក្សាឡើយ ។

ការកសាងសមត្ថភាពគរុនិស្សិតបានផ្តល់របៀបនៃការគិតអំពីសកម្មភាពវាយតម្លៃ វាជាលំនាំថ្មីមួយ។ សកម្មភាពវាយតម្លៃជាកែវឆ្លុះថ្មីមួយ ដែលការប្រើប្រាស់អាចនាំឱ្យយើងធ្វើការកែប្រែនូវអ្វីដែលត្រូវធ្វើ។ ការវាយតម្លៃគឺអាស្រ័យទៅនឹងគោលដៅចម្បង នៃការអប់រំដើម្បីអភិវឌ្ឍការអប់រំធនធានមនុស្ស និងឱ្យមានការផ្លាស់ប្តូរសង្គម។

ការវាយតម្លៃត្រូវតែជាវិភាគទានវិជ្ជមានជួយលើការសិក្សារបស់គរុនិស្សិត។វាជាតម្រូវការចាំបាច់ដោយប្រកាន់យកទស្សនៈ និងវិធីសាស្ត្រដែលត្រូវបានសិក្សាលើមេរៀននៃមុខវិជ្ជាថ្មីៗ ។ ការវាយតម្លៃត្រូវតែអភិវឌ្ឍន៍សមត្ថភាពនិស្សិត ដើម្បីធ្វើសុភវិនិច្ឆ័យទុកសម្រាប់ការបំពេញការសិក្សាឱ្យបានល្អ ហើយរៀបចំកែប្រែនិស្សិតឱ្យក្លាយជាអ្នកសិក្សាដែលសកម្មដោយជំរុញពួកគេឱ្យមានដំណើរការពិនិត្យមើលខ្លួនឯង លើការរួមចំណែកក្នុងដំណើរការប្រព្រឹត្តទោះជាការប្រព្រឹត្តអ្វីក៏ដោយ។

ជាងនេះទៅទៀត ការវាយតម្លៃអប់រំមានទម្រង់ជាបទប្បញ្ញត្តិគន្លឹះបួនប្រភេទ ដែលជាមូលដ្ឋាននៃការសន្ទតរួមមាន៖

- ការជួយគាំទ្រ និងឧបត្ថម្ភ
- ការអភិវឌ្ឍដោយសុភវិនិច្ឆ័យលើព័ត៌មានដែលបានសិក្សា
- ការឆ្លើយតបប្រតិកម្មរបស់និស្សិត
- និងការបំពេញកង្វះខាតចំពោះអ្នកមានមុខរបរប្រកបដោយវិជ្ជាជីវៈ។

គ. យោងតាមប្រសាសន៍[4] របស់លោក Gow (ដកស្រង់នៅក្នុងHornby, 2003) នៅសាកល វិទ្យាល័យ The Robert Gordon University ៖

ការវាយតម្លៃ គឺជាការអនុញ្ញាតឱ្យនិស្សិតយល់ដឹងកិច្ចការរបស់ពួកគេនៅក្នុងថ្នាក់រៀនដែលមិនមែនជាកិច្ចការថ្មី វាជាវិធីដ៏ងាយស្រួលមួយសម្រាប់ការវាយតម្លៃក្នុងរយៈពេលខ្លីបំផុតឬក៏ជាសំណួរសរសេរដែលឆ្លើយត្រឡប់បានយ៉ាងលឿនលើសកម្មភាពប្រតិបត្តិ និងការសិក្សារបស់ពួកគេការវាយតម្លៃជាសកម្មភាពដែលមានការលើកទឹកចិត្តដ៏មានឥទ្ធិពលមួយក្នុងការ

[4] Reflections on Assessment: Volume I Page 23

សិក្សា ហើយជូនកាលការវាយតម្លៃនេះជាផលចំណេញសម្រាប់និស្សិត ពេលប្រឡងបញ្ចប់ការសិក្សារបស់ខ្លួន។

គាត់បានបន្ថែមទៀតថាការវាយតម្លៃត្រូវតែៈ អភិវឌ្ឍន៍លើអត្រានៃការចូលរួម (វត្តមានក្នុងថ្នាក់) ពីព្រោះការវាយតម្លៃសំដៅទៅលើសកម្មភាពរៀនដោយខ្លួនឯង និងមានការលើកទឹកចិត្តដើម្បីសិក្សាស្រាវជ្រាវ ។ ជាងនេះទៅទៀតការវាយតម្លៃអប់រំត្រូវតែអភិវឌ្ឍន៍ចំណេះដឹងដែលមានស្រាប់ ឱ្យរឹតតែប្រសើរដោយមានការផ្លាស់ប្តូរ និងរីកចម្រើន។

ឃ. យោងតាមទ្រឹស្តី របស់ Brandt et al. (2007) ៖

ការវាយតម្លៃអប់រំ គឺប្រើប្រាស់សម្រាប់ការសម្រេចចិត្តដោយផ្ទាល់តាមការចង្អុលបង្ហាញដ៏ល្អ ហើយអាចមានប្រយោជន៍ដ៏ជាក់លាក់ សម្រាប់លទ្ធផលសិក្សាស្រាវជ្រាវរបស់និស្សិត។ វាអាចឆ្លុះបញ្ចាំងអំពីភាពខ្លាំង និងភាពខ្សោយនៃការសិក្សាអប់រំ ហើយក៏ផ្តល់ផងដែរនូវគោលនយោបាយអប់រំសម្រាប់អនុវត្ត និងដឹកនាំវិទ្យាស្ថានឱ្យមានដំណើរការរៀន និងបង្រៀនបានល្អ។ ម៉្យាងវិញទៀតការវាយតម្លៃអប់រំត្រូវបានគេបង្កើតឡើងដើម្បីជួយដល់ការបង្ហាត់បង្រៀនរបស់គ្រូ ថែមទាំងផ្តល់ព័ត៌មានចំពោះក្រុមពិភាក្សារបស់និស្សិត និងជាការរកឱ្យឃើញនូវការវាយតម្លៃការសិក្សាស្រាវជ្រាវថ្មីៗ។ វាជាវិធីសាស្ត្រដែលមានឥទ្ធិពលយ៉ាងខ្លាំងសម្រាប់វាយតម្លៃគ្រូក្នុងគោលបំណងអភិវឌ្ឍការបំពេញភារកិច្ចរបស់គាត់ និងការសិក្សារៀនសូត្ររបស់និស្សិតព្រមទាំងប្រសិទ្ធភាពការងារបង្រៀនរបស់គ្រូក្នុងថ្នាក់រៀនទៀតផង។

ដោយផ្អែកលើបទប្បញ្ញត្តិនៅវិទ្យាស្ថានជាតិអប់រំ និងផែនការអនុវត្តន៍កម្មវិធីបណ្តុះបណ្តាលគរុនិស្សិតកម្រិតឧត្តម(បរិញ្ញា+១)បញ្ញត្តិ និងទ្រឹស្តីនៃការវាយតម្លៃអប់រំដូចមានខ្លឹមសារខាងលើ ការស្រាវជ្រាវអាចធ្វើការវិភាគ និងវាយតម្លៃឱ្យឃើញច្បាស់ពីការអនុវត្តការវាយតម្លៃអប់រំរបស់វិទ្យាស្ថានជាតិអប់រំ ដោយឆ្លុះបញ្ចាំងអំពីៈ

-ការបំពេញកិច្ចការបង្រៀន និងរៀន(Assignment or tasks)

-ព័ត៌មានត្រឡប់របស់គ្រូឧទ្ទេស និងគរុនិស្សិត(Feedback)។

## ៨ ទិន្នន័យរកឃើញ (Finding)

កិច្ចការស្រាវជ្រាវនេះ ប្រមូលទិន្នន័យដែលបានទាក់ទងនឹងការវាយតម្លៃអប់រំនៅវិទ្យាស្ថានជាតិអប់រំក៏ប៉ុន្តែរបាយការណ៍នៃការប្រមូលទិន្នន័យនោះគឺផ្តោតទៅលើទិន្នន័យសំខាន់ៗដែលត្រូវយកមកវិភាគទាក់ទងនឹងបញ្ហាប្រឈមការអនុវត្តន៍ការវាយតម្លៃអប់រំ ហើយនឹងសំណូម ពរសម្រាប់កែលម្អ និងអភិវឌ្ឍន៍វិធីសាស្ត្រវាយតម្លៃ។(មានទិន្នន័យជាច្រើនទៀតនៅក្នុងឧបសម្ព័ន្ធអាចយកទៅប្រើប្រាស់ដើម្បីវិភាគស្រាវជ្រាវទៅថ្ងៃអនាគត)

### ៨.១ បញ្ហាប្រឈម (Challenges)

**ការអនុវត្តន៍របស់គរុនិស្សិត**

- មានការឈប់ម្តងម្កាលភាគច្រើន

- មិនចាប់អារម្មណ៍ និងព័ត៌មានត្រឡប់(មិនចូលរួមទទួលយកព័ត៌មានត្រឡប់)
- ខ្វះការណែនាំពីគ្រូ
- ពុំយល់ដឹងពីព័ត៌មានត្រឡប់ដែលបានបង្ហាញឱ្យដឹងពីរបៀបសិក្សារឹតតែប្រសើរទៅថ្ងៃមុខ
- ការផ្តល់ព័ត៌មានត្រឡប់ពុំត្រូវបាន ទទួលការគាំទ្រ និងលើកទឹកចិត្ត។

**ការយល់ដឹង និងការអនុវត្តរបស់គ្រូ**

- សាស្ត្រាចារ្យមួយចំនួនមិនយល់ពីតម្លៃនៃការផ្តល់ព័ត៌មានត្រឡប់
- សាស្ត្រាចារ្យមួយចំនួនខ្វះឆន្ទៈក្នុងការផ្តល់ឬទទួលព័ត៌មានត្រឡប់ពីគរុនិស្សិត មន្ត្រីអប់រំ បុគ្គលិកនិងគណគ្រប់គ្រង
- សាស្ត្រាចារ្យមួយចំនួនខ្វះការបែងចែកពេលវេលាសម្រាប់ការអនុវត្តការតាមដាន និងផ្តល់ព័ត៌មានត្រឡប់។

**៨.២ សំណូមពរសម្រាប់កែប្រែ និងអភិវឌ្ឍន៍**

**សំណូមពររបស់គ្រូឧទ្ទេស**

- គ្រូគួរតែឱ្យគរុនិស្សិតសរសេរព័ត៌មានត្រឡប់នៅពេលបញ្ចប់មេរៀនរបស់ខ្លួន ។
- ការវាយតម្លៃអប់រំគួរតែត្រូវបានជួយគាំទ្រនិងឧបត្ថម្ភពីមន្ត្រីអប់រំ ឬគណៈគ្រប់គ្រងដែលពាក់ព័ន្ធ(ឧទាហរណ៍ដូចជា៖ការផ្តល់ការសរសើរលើកទឹកចិត្តលិខិតសរសើរ ឬជារង្វាន់។ល។
- ការវាយតម្លៃអប់រំគួរតែអភិវឌ្ឍការវិនិច្ឆ័យ(ចេះថ្លឹងថ្លែង)លើខ្លឹមសារមេរៀនដែលបានសិក្សារួច
- ការវាយតម្លៃអប់រំគួរតែបង្កើតសម្រាប់ឆ្លើយតបប្រតិកម្មរបស់គរុនិស្សិត។

**សំណូមពររបស់គរុនិស្សិត**

- គរុនិស្សិតគួរតែមកសិក្សាតាមកាលវិភាគដែលកំណត់ដោយវិទ្យាស្ថាន
- គរុនិស្សិតគួរតែសិក្សាស្រាវជ្រាវបន្ថែមឱ្យបានច្រើននៅពេលចន្លោះពីការសិក្សា
- គរុនិស្សិតគួរតែអានព័ត៌មានត្រឡប់ឱ្យបានច្រើនដើម្បីជាកញ្ចក់ឆ្លុះក្នុងការកែប្រែនូវសកម្មភាពដែលបានធ្វើ ។
- គួរធ្វើការវាយតម្លៃលើសមត្ថភាពពិត និងត្រឹមត្រូវដោយសម្តែងភាពស្មោះត្រង់ចំពោះសមត្ថភាពដែលខ្លួនមាន
- គួរគប្បីត្រួតពិនិត្យនិងតាមដាននូវរាល់សកម្មភាពដែលបានប្រព្រឹត្តទៅតាមកិច្ចការនីមួយៗឱ្យបានច្បាស់លាស់ជាក់ស្តែង និងទៀងទាត់
- គួរផ្តល់ព័ត៌មានត្រឡប់ឱ្យបានទាន់ពេលវេលា និងត្រឹមត្រូវ
- គួរចេះបង្កើតគំរូសំណួរធ្វើការវិភាគលើព័ត៌មានត្រឡប់ដែលទទួលបានរួចចេះដោះស្រាយបញ្ហានោះ
- គួរធ្វើការវាយតម្លៃក្នុងពេលកំពុងសិក្សាផ្ទាល់តាមរយៈសាស្ត្រាចារ្យបង្រៀនផ្ទាល់។

## ៩. សន្និដ្ឋាន

ផ្អែកលើការសិក្សាស្រាវជ្រាវនេះបានបង្ហាញឱ្យឃើញដូចខាងក្រោម៖

- ទាំងគរុនិស្សិត និងសាស្ត្រាចារ្យ មានការខ្វះខាតនៅក្នុងការវាយតម្លៃអប់រំពិសេសលើវិធីសាស្ត្រផ្តល់ ឬទទួលព័ត៌មានត្រឡប់សម្រាប់ការបណ្តុះបណ្តាលរបស់វិទ្យាស្ថានជាតិអប់រំ។
- ទាំងគរុនិស្សិត និងសាស្ត្រាចារ្យមិនទាន់យល់ស៊ីជម្រៅពីវិធីសាស្ត្រវាយតម្លៃអប់រំ។
- ទាំងគរុនិស្សិត និងសាស្ត្រាចារ្យ មានការខ្វះខាតនៅក្នុងការអនុវត្តន៍ផ្នែកវាយតម្លៃអប់រំ ដែលពាក់ព័ន្ធទៅនឹងការយល់ដឹងពីសារៈប្រយោជន៍នៃព័ត៌មានត្រឡប់។
- ការវាយតម្លៃអប់រំពិសេសលើវិធីសាស្ត្រផ្តល់ ឬទទួលព័ត៌មានត្រឡប់ចាំបាច់ត្រូវមានការគាំទ្របន្ថែម
- ការយល់ដឹងពីការវាយតម្លៃអប់រំដ៏មានប្រសិទ្ធភាពនោះគឺការកែប្រែគរុសិស្ស និងសាស្ត្រាចារ្យ ឱ្យក្លាយទៅជាអ្នកសិក្សានិងអ្នកបង្រៀនដ៏សកម្ម
- ការវាយតម្លៃអប់រំអាចឆ្លុះបញ្ចាំងអំពីភាពខ្លាំងនិងភាពខ្សោយនៃវិស័យអប់រំហើយវាក៏ផ្តល់ផងដែរនូវគោលនយោបាយអប់រំសម្រាប់អនុវត្តនិងដឹកនាំឱ្យមានដំណើរការរៀននិងបង្រៀនបានល្អ។

## ១០. ការផ្តល់អនុសាសន៍

- ត្រូវបើកសិក្ខាសាលាស្តីពីការផ្សព្វផ្សាយការវាយតម្លៃអប់រំ ចំពោះសាស្ត្រាចារ្យនៅវិទ្យាស្ថានជាតិអប់រំ
- បង្កើត Website សម្រាប់ផ្សព្វផ្សាយគោលការណ៍ និងការវាយតម្លៃអប់រំនៅវិទ្យាស្ថានជាតិអប់រំ
- ធ្វើយ៉ាងណាឱ្យគរុនិស្សិតយល់ដឹងពីដំណើរការវាយតម្លៃអប់រំនៅវិទ្យាស្ថានជាតិអប់រំ
- ធានាថាគរុនិស្សិតយល់ដឹងអំពីសារៈសំខាន់ នៃព័ត៌មានត្រឡប់

## ១១. ឯកសារយោង


1.ម៉ែន សុខសុន្ទី (២០០៩). របាយការណ៍ស្រាវជ្រាវស្តីពីការបណ្តុះបណ្តាលគរុនិស្សិតបរិញ្ញា+1 ផ្នែកគណិតវិទ្យានៅវិទ្យាស្ថានជាតិអប់រំ.ភ្នំពេញ:សកលវិទ្យាល័យចំរើនពហុបច្ចេកវិទ្យា

2. ក្រសួងអប់រំ យុវជននិងកីឡា (២០០៩a). បទប្បញ្ញត្តិស្តីពីការបណ្តុះបណ្តាលគរុនិស្សិតកម្រិតឧត្តម (បរិញ្ញា+១) នៅវិទ្យាស្ថានជាតិអប់រំ. ភ្នំពេញ:ក្រសួងអប់រំ យុវជន និងកីឡា.

3. ក្រសួងអប់រំ យុវជន និងកីឡា (២០០៩b). សេចក្តីជូនដំណឹងរបស់ក្រសួងអប់រំ យុវជន និងកីឡា ស្តីពីការប្រឡងជ្រើសរើសគរុនិស្សិតកម្រិតឧត្តម ឆ្នាំ ២០០៩. ភ្នំពេញ: ក្រសួងអប់រំ យុវជន និងកីឡា.

4. វិទ្យាស្ថានជាតិអប់រំ (២០០៩)។ផែនការអនុវត្តន៍កម្មវិធីបណ្តុះបណ្តាលគរុនិស្សិតកម្រិតឧត្តម (បរិញ្ញា+១)ជំនាន់ទី១៥. ភ្នំពេញ: វិទ្យាស្ថានជាតិអប់រំ.

5. Boud, D. and Associates (2010). *Assessment 2020: Seven propositions for assessment reform in higher education.* Sydney: Australian Learning and Teaching Council.

6. Boud, D. (2009). "How can practice reshape assessment?" In Joughin, G. (ed.) *Assessment, Learning and Judgement in Higher Education.* Dordrecht: Springer.

7. Mathers, C. & Oliva, M. (2008).*Improving Instruction through Effective Teacher Evaluation.*Washington, DC: National Comprehensive Center for Teacher Quality.

8. Boud, D. and Falchikov, N. (2007). "Developing assessment for informing judgement" In D. Boud and N. Falchikov (eds.). *Rethinking Assessment for Higher Education: Learning for the Longer Term.* London: Routledge.

9. Boud, D. (2007). "Reframing assessment as if learning were important" In D. Boud & N. Falchikov (eds.)*Rethinking Assessment for Higher Education: Learning for the Longer Term.* London: Routledge.

10. Boud, D. and Falchikov, N. (2006). "Aligning assessment with long-term learning" In D. Boud and N. Falchikov (eds.). *Rethinking Assessment for Higher Education: Learning for the Longer Term.* London: Routledge.

11. Hornby, W. (2004). "Dogs, Stars, Rolls Royces and Old Double-Decker Buses: Efficiency and Effectiveness in Assessment". In D.A. Ross (ed.). *Streamlining assessment-how to make assessment more efficient and more effective.* Available at

12. http://www.enhancementthemes.ac.uk/documents/events/20040113. Accessedon 8 June 2010.

13. Boud, D. (2000). "Sustainable assessment: rethinking assessment for the learning society". *Studies in Continuing Education* (22:2, 151-167).

# ឧបសម្ព័ន្ធ(Annex)

អ្នកដែលត្រូវបានសម្ភាសន៍និងបំពេញកម្រងសំណួរឆ្លើយថា៖

**A-ចំពោះគរុនិស្សិត**

**១- ក្នុងរយៈពេលបណ្តុះបណ្តាលអ្នកដែល ៖**




មិនដែលឈប់សោះមានចំនួន៤០នាក់ស្មើនឹង ២១.៦២%

ឈប់ម្តងម្កាលចំនួន១២០នាក់ស្មើនឹង ៦៤.៨៦%

ឈប់ញឹកញាប់ចំនួន២៥នាក់ស្មើនឹង ១៣.៥១%

*(ក្រាហ្វិក-០១)*

**២- ការដោះស្រាយលំហាត់បានល្អ បើមានការសិក្សាឱ្យបានច្រើន អ្នកដែលឆ្លើយថា៖**




មិនឯកភាពមានចំនួន ៦៧ នាក់ ស្មើនឹង៣៦.៤១%

ពុំមានចម្លើយមានចំនួន ៤០ នាក់ ស្មើនឹង២១.៧៤ %

ឯកភាពមានចំនួន ៧៧ នាក់ ស្មើនឹង៤១.៨៥ %

*(ក្រាហ្វិក-០២)*

**៣- ព័ត៌មានត្រឡប់មានសារៈសំខាន់ដែលអាចធ្វើឱ្យមានទំនាក់ទំនងល្អជាមួយអ្នកដទៃ អ្នកដែលឆ្លើយថា៖**




មិនឯកភាពមានចំនួន ១៤ នាក់ ស្មើនឹង៧.៥៧ %
ពុំមានចម្លើយមានចំនួន ២១ នាក់ ស្មើនឹង១១.៣៥ %
ឯកភាពមានចំនួន ១៥០ នាក់ ស្មើនឹង៨១.០៨ %

*(ក្រាហ្វិក-០៣)*

**៤- ព័ត៌មានគ្រឡប់ជួយខ្ញុំឱ្យយល់មេរៀនកាន់តែច្បាស់អ្នកដែលឆ្លើយថា៖**




មិនឯកភាពមានចំនួន ៩ នាក់ ស្មើនឹង៤.៨៦ %
ពុំមានចម្លើយមានចំនួន ១៤ នាក់ ស្មើនឹង៧.៥៧ %
ឯកភាពមានចំនួន ១៦២ នាក់ ស្មើនឹង៨៧.៥៧ %

*(ក្រាហ្វិក-០៤)*

**៥- ព័ត៌មានគ្រឡប់បានបង្ហាញឱ្យខ្ញុំដឹងពីរបៀបសិក្សារឹតតែប្រសើរទៅថ្ងៃមុខអ្នកដែលឆ្លើយថា៖**




មិនឯកភាពមានចំនួន ៦ នាក់ ស្មើនឹង៣.៣៣%
ពុំមានចម្លើយមានចំនួន ៣៨ នាក់ ស្មើនឹង២១.១១ %
ឯកភាពមានចំនួន ១៣៦ នាក់ ស្មើនឹង៧៥.៥៦ %

*(ក្រាហ្វិក-០៥)*

៦- ក្រោយពីបានអានព័ត៌មានគ្រឡប់ខ្ញុំយល់ច្បាស់ពីមូលហេតុដែលត្រូវកត់សម្គាល់នូវអ្វីដែលត្រូវធ្វើបន្តអ្នកដែលឆ្លើយថា៖




មិនឯកភាពមានចំនួន ១ នាក់ ស្មើនឹង០.៥៤%
ពុំមានចម្លើយមានចំនួន ៤២ នាក់ ស្មើនឹង២២.៨៣ %
ឯកភាពមានចំនួន ១៤១ នាក់ ស្មើនឹង៧៦.៦៣ %

*(ក្រាហ្វិក-០៦)*

៧- ពួកគេប្រើប្រាស់ព័ត៌មានគ្រឡប់ដើម្បីកែតម្រូវនូវកិច្ចតែងការដែលពួកគេបានធ្វើឬអ្នកដែលឆ្លើយថា៖




មិនឯកភាពមានចំនួន ២១ នាក់ ស្មើនឹង១១.៣៥%

ពុំមានចម្លើយមានចំនួន ៣៦ នាក់ ស្មើនឹង១៩.៤៦ %

ឯកភាពមានចំនួន ១២៨ នាក់ ស្មើនឹង៦៩.១៩ %

*(ក្រាហ្វិក-០៧)*

៨- ព័ត៌មានត្រឡប់មិនបានជួយពួកគេក្នុងកិច្ចតែងការបន្តបន្ទាប់ឬអ្នកដែលឆ្លើយថា៖




មិនឯកភាពមានចំនួន ៨៩ នាក់ ស្មើនឹង៤៨.១១%

ពុំមានចម្លើយមានចំនួន ៤៥ នាក់ ស្មើនឹង២៤.៣២ %

ឯកភាពមានចំនួន ៥១ នាក់ ស្មើនឹង២៧.៥៧ %

*(ក្រាហ្វិក-០៨)*

៩- ព័ត៌មានត្រឡប់អាចធ្វើឱ្យពួកគេបង្កើតសម្ភារៈឧបទេសមុនពេលកម្មសិក្សាអ្នកដែលឆ្លើយថា៖




មិនឯកភាពមានចំនួន ១៤ នាក់ ស្មើនឹង៧.៥៧ %

ពុំមានចម្លើយមានចំនួន ៤៦ នាក់ ស្មើនឹង២៤.៨៦ %

ឯកភាពមានចំនួន ១២៥ នាក់ ស្មើនឹង៦៧.៥៧ %

*(ក្រាហ្វិក-០៩)*

១០- ពួកគេមិនបានប្រើប្រាស់ព័ត៌មានត្រឡប់ដើម្បីកែតម្រូវកិច្ចតែងការបង្រៀនអ្នកដែលឆ្លើយថា៖




មិនឯកភាពមានចំនួន ៦២ នាក់ ស្មើនឹង៣៣.៥១%

ពុំមានចម្លើយមានចំនួន ៥៧ នាក់ ស្មើនឹង៣០.៨១ %

ឯកភាពមានចំនួន ៦៦ នាក់ ស្មើនឹង៣៥.៦៨ %

*(ក្រាហ្វិក-១០)*

១១- ពួកគេធ្វើខុសឬច្រឡំកិច្ចការស្រាវជ្រាវពួកគេមិនបានទទួលការណែនាំបានច្រើនទេ នូវអ្វីដែលត្រូវកែលម្អអ្នកដែលឆ្លើយថា៖




មិនឯកភាពមានចំនួន ៦៦ នាក់ ស្មើនឹង៣៥.៦៨%

ពុំមានចម្លើយមានចំនួន ៥៣ នាក់ ស្មើនឹង២៨.៦៥ %

ឯកភាពមានចំនួន ៦៦ នាក់ ស្មើនឹង៣៥.៦៨ %

*(ក្រាហ្វិក-១១)*

១២- ពួកគេគួរតែសិក្សាឱ្យបានច្រើនប្រសិនបើពួកគេទទួលបានព័ត៌មានត្រឡប់បានច្រើន អ្នកដែលឆ្លើយថា៖




មិនឯកភាពមានចំនួន ០ នាក់ ស្មើនឹង ០ %

ពុំមានចម្លើយមានចំនួន ២៧ នាក់ ស្មើនឹង១៤.៥៩ %

ឯកភាពមានចំនួន ១៥៨ នាក់ ស្មើនឹង៨៥.៤១ %

*(ក្រាហ្វិក-១២)*

១៣- ទោះជាព័ត៌មានត្រឡប់នោះមកយឺតយ៉ាងណាក៏ដោយក៏មានប្រយោជន៍សម្រាប់ពួកគេដែរអ្នកដែលឆ្លើយថា៖




មិនឯកភាពមានចំនួន ១៨ នាក់ ស្មើនឹង៩.៧៣%
ពុំមានចម្លើយមានចំនួន ៣៣ នាក់ ស្មើនឹង១៧.៨៤ %
ឯកភាពមានចំនួន ១៣៤ នាក់ ស្មើនឹង៧២.៤៣ %

*(ក្រាហ្វិក-១៣)*

១៤- ពួកគេប្រើប្រាស់ព័ត៌មានត្រឡប់ដើម្បីកែតម្រូវនូវកិច្ចការស្រាវជ្រាវដែលពួកគេបាន ធ្វើអ្នកដែលឆ្លើយថា៖




មិនឯកភាពមានចំនួន ១១ នាក់ ស្មើនឹង៥.៩៥%
ពុំមានចម្លើយមានចំនួន ៤៥ នាក់ ស្មើនឹង២៤.៣២ %
ឯកភាពមានចំនួន ១២៩ នាក់ ស្មើនឹង៦៩.៧៣ %

*(ក្រាហ្វិក-១៤)*

B-សម្រាប់គ្រូខ្ទុទ្ទេស

១- វិធីសាស្ត្រវាយតម្លៃដែលបានប្រើវាត្រូវបានដឹងដើម្បីជួយក្នុងការវាយតម្លៃដ៏ច្បាស់មួយ សមស្របទៅនឹងវិធីបង្រៀន អ្នកដែលឆ្លើយថា ៖




មិនឯកភាពមានចំនួន ៩ នាក់ ស្មើ ២០.៥០%
មិនមានចម្លើយមានចំនួន ៥ នាក់ ស្មើ ១១.៤០%
ឯកភាពទាំងស្រុងមានចំនួន ៣០ នាក់ ស្មើ ៦៨.២០%

*(ក្រាហ្វិក-១៥)*

២- ការបិទផ្សាយបញ្ជីពិន្ទុមានប្រយោជន៍ដល់និស្សិតអ្នកដែលឆ្លើយថា ៖




មិនឯកភាពមានចំនួន ៦ នាក់ ស្មើ ១៣.៦០%
មិនមានចម្លើយមានចំនួន ៨ នាក់ ស្មើ ១៨.២០%
ឯកភាពទាំងស្រុងមានចំនួន ៣០ នាក់ ស្មើ ៦៨.២០%

*(ក្រាហ្វិក-១៦)*

៣- ខ្ញុំត្រូវបានវាយតម្លៃដោយគរុនិស្សិតឬប្រធានក្រុម អ្នកដែលឆ្លើយថា ៖




មិនឯកភាពមានចំនួន ៥ នាក់ ស្មើ ១១.៤០%
មិនមានចម្លើយមានចំនួន ៩ នាក់ ស្មើ ២០.៥០%
ឯកភាពទាំងស្រុងមានចំនួន ៣០ នាក់ ស្មើ ៦៨.២០%

*(ក្រាហ្វិក-១៧)*

**៤- ខ្ញុំបានផ្តល់ព័ត៌មានត្រឡប់នៅពេលបញ្ចប់នៃវគ្គបណ្តុះបណ្តាលអ្នកដែលឆ្លើយថា ៖**




មិនឯកភាពមានចំនួន ៧ នាក់ ស្មើ ១៥.៩០%
មិនមានចម្លើយមានចំនួន ៧ នាក់ ស្មើ ១៥.៩០%
ឯកភាពទាំងស្រុងមានចំនួន ៣០ នាក់ ស្មើ ៦៨.២០%

*(ក្រាហ្វិក-១៨)*

**៥- គរុនិស្សិតរបស់ខ្ញុំទទួលបានការណែនាំអ្នកដែលឆ្លើយថា ៖**




មិនឯកភាពមានចំនួន ៥ នាក់ ស្មើ ១១.៤០%
មិនមានចម្លើយមានចំនួន ៧ នាក់ ស្មើ ១៥.៩០%
ឯកភាពទាំងស្រុងមានចំនួន ៣២ នាក់ ស្មើ ៧២.៧០%

*(ក្រាហ្វិក-១៩)*

==============================

# វិទ្យាស្ថានជាតិអប់រំ

## ប្រធានបទ

# វិធីសាស្ត្របង្រៀនបែបសិស្សមជ្ឈមណ្ឌល សម្រាប់មុខវិជ្ជាវិទ្យាសាស្ត្រសង្គម នៅវិទ្យាស្ថានជាតិអប់រំ

**ក្រុមសិក្សាស្រាវជ្រាវ**

*១. លោកស្រី សាំង សុចិន្តា*

*២. លោក ចេង ថុន*

*៣. លោកស្រី តូ សូភី*

*៤. លោកស្រី រុយ សុកលក្ខិណា*

# មាតិកា


ខ្លឹមសារ ទំព័រ

១. សេចក្តីផ្តើម ........ ៥

២ បញ្ហាស្រាវជ្រាវ ........ ៦

៣ .គោលបំណងនៃការស្រាវជ្រាវ ........ ៧

៤ .សំណួរស្រាវជ្រាវ ........ ៧

៥ គោលដៅនៃការស្រាវជ្រាវ ........ ៧

៦. វិធីសាស្ត្រស្រាវជ្រាវ ........ ៧

៦.១ វិធីសាស្ត្រប្រមូលទិន្នន័យ........ ៧

៦.២ វិធីសាស្ត្រវិភាគទិន្នន័យ........ ៨

៦.៣ លទ្ធផលរំពឹងទុកនៃការស្រាវជ្រាវ........ ៨

៧. រំលឹកទ្រឹស្តី និងការសិក្សាដែលពាក់ព័ន្ធ ........ ៨

៧.១ ទ្រឹស្តីអំពីការបង្រៀន និងការរៀនតាមរបៀបសិស្សមជ្ឈមណ្ឌល........ ៩

៧.២ គោលការណ៍នៃវិធីសាស្ត្របង្រៀនបែបសិស្សមជ្ឈមណ្ឌល........ ១០

៧.៣ ប្រភេទនៃសកម្មភាពសិក្សាតាមបែបសិស្សមជ្ឈមណ្ឌល........ ១១

៧.៤ យុទ្ធវិធីបង្រៀនបែបសិស្សមជ្ឈមណ្ឌល........ ១២

៧.៥ សារសំខាន់នៃវិធីសាស្ត្របង្រៀនបែបសិស្សមជ្ឈមណ្ឌល........ ១៣

៨. របកគំហើញ និងការវិភាគទិន្នន័យ........ ១៥

៨.១ ទស្សនរបស់គ្រូឧទ្ទេស និងគរុនិស្សិតនៅវិទ្យាស្ថានជាតិអប់រំ........ ១៥

៨.១.១ របកគំហើញៈទស្សនរបស់គរុនិស្សិតចំពោះការអនុវត្តគោលវិធីសិស្ស មជ្ឈមណ្ឌល........ ១៥

៨.១.២ ការវិភាគ ទស្សនគរុនិស្សិតចំពោះការអនុវត្តគោលវិធីសិស្ស មជ្ឈមណ្ឌល........ ២៣

៨.២ ទស្សនរបស់គ្រូឧទ្ទេសចំពោះការអនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌល.. ២៧

៨.២.១ របកគំហើញៈទស្សននៃការអនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌល ២៧ របស់គ្រូឧទ្ទេស........ ២៧

៨.២.២ ការវិភាគៈ ទស្សននៃការអនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌលរបស់ គ្រូឧទ្ទេស........ ៣០

៨.៣ ការសង្កេតថ្នាក់........ ៣២

៩: សេចក្តីសន្និដ្ឋាន ........ ៣៣

១០. អនុសាសន៍ ........ ៣៤

១១. ចំណុចដែលត្រូវសិក្សាបន្ត ............................................................ ៣៤
១២. ឯកសារយោង ............................................................ ៣៤

# អារម្ភកថា

២

វិទ្យាស្ថានជាតិអប់រំជាគ្រឹះស្ថានឧត្តមសិក្សារដ្ឋតែមួយគត់ ដែលមានតួនាទីក្នុងការបណ្តុះបណ្តាល គ្រូបង្រៀនកម្រិតឧត្តម អ្នកដឹកនាំស្ថាប័នអប់រំ មន្ត្រីគ្រប់គ្រងអប់រំ និងអ្នកវាយតម្លៃគុណភាពអប់រំ នៅក្នុងព្រះរាជាណាចក្រកម្ពុជា។ បច្ចុប្បន្ននេះវិទ្យាស្ថានជាតិអប់រំបាននឹងកំពុងពង្រឹងសមត្ថភាពគ្រូឧទ្ទេស ដើម្បីធានាគុណភាពបណ្តុះបណ្តាលធនធានមនុស្ស ជូនប្រទេសជាតិ ជាពិសេសបណ្តុះបណ្តាលគ្រូបង្រៀនកម្រិតឧត្តម (បរិញ្ញា+១) សម្រាប់បម្រើការនៅតាមបណ្តារាជធានីខេត្ត នៅទូទាំងប្រទេស។ ដើម្បីឆ្លើយតបទៅនឹងចក្ខុវិស័យខាងលើ របាយការណ៍ស្រាវជ្រាវដែលចងក្រងឡើងគឺមានគោលបំណងបង្ហាញពីចំណុចគន្លឹះ និងចក្ខុវិស័យទៅថ្ងៃអនាគតរបស់ វិស័យអប់រំ ដែលអ្នកអប់រំទាំងឡាយត្រូវយល់ដឹង ដើម្បីឱ្យការបង្រៀន រៀនមានលក្ខណៈស្តង់ដា និងឆ្លើយតបទៅនឹងសកលភាវូបនីយកម្មក្នុងតំបន់។ ថ្វីត្បិតតែរបាយការណ៍នេះធ្វើការស្រាវជ្រាវតែក្នុងវិទ្យាស្ថានជាតិអប់រំក៏ពិតមែន ប៉ុន្តែយើងសង្ឃឹមយ៉ាងមុតមាំថា របាយការណ៍នេះគឺជាចក្ខុវិស័យជួយដល់ការបណ្តុះបណ្តាលគ្រូបង្រៀនគ្រប់កម្រិត ហើយថែមទាំងញ៉ាំងឱ្យគរុសិស្ស គរុនិស្សិតយល់ច្បាស់ពីការអនុវត្តគោលវិធីទំនើបទៀតផង។ ការអភិវឌ្ឍគ្រូបង្រៀនជាកត្តាមួយដែលមិនអាចខ្វះបានក្នុងការអភិវឌ្ឍប្រទេសជាតិ ជាពិសេសគុណភាពអប់រំ ។

# សេចក្តីថ្លែងអំណរគុណ

ជាបឋមក្រុមស្រាវជ្រាវសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះថ្នាក់ដឹកនាំក្រសួងអប់រំ យុវជន និងកីឡា ដែលបានគាំទ្រ និងបង្កឱ្យមានលក្ខណៈងាយស្រួលដល់ការស្រាវជ្រាវ ។

យើងខ្ញុំសូមថ្លែងអំណរគុណជាអនេកចំពោះការឧបត្ថម្ភរបស់គម្រោងEEQP (TU1)ដែលបានផ្តល់ឱកាសគាំទ្រតាំងពីចាប់ផ្តើមដំណើរការស្រាវជ្រាវរហូតដល់ទីបញ្ចប់។

យើងខ្ញុំសូមថ្លែងអំណរគុណចំពោះឯកឧត្តមនាយក នាយករង នៃវិទ្យាស្ថានជាតិអប់រំ ដែលតែងតែជំរុញលើកទឹកចិត្តជួយឧបត្ថម្ភទាំងស្មារតី និងសម្ភារដល់អ្នកស្រាវជ្រាវ។ជាពិសេស បានអនុញ្ញាតឱ្យក្រុមស្រាវជ្រាវចុះអង្កេតជាមួយគរុនិស្សិត និងធ្វើបទសម្ភាសន៍ជាមួយលោក លោកស្រី ជាគ្រូ ឧទ្ទេស ក្នុងការប្រមូលទិន្នន័យ។

យើងខ្ញុំសូមថ្លែងអំណរគុណដល់គ្រូឧទ្ទេសទាំងអស់ និងគរុនិស្សិតកម្រិតឧត្តម(បរិញ្ញា+១) ជំនាន់ ទី១៦ដែលបានផ្តល់បទសម្ភាសន៍ដោយយកចិត្តទុកដាក់ដើម្បីឆ្លើយ និងចំណាយពេលវេលាដ៏មានតម្លៃចំពោះរបាយការណ៍ស្រាវជ្រាវនេះ។

យើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងខ្លាំងដល់អ្នកជំនាញការស្រាវជ្រាវជាតិ និងអន្តរជាតិគឺ លោកស្រីបណ្ឌិត Anne Glover និងលោកបណ្ឌិត ជិន ចាន់រិទ្ធដែលខិតខំបង្ហាត់បង្រៀនដល់ក្រុមស្រាវជ្រាវទាំងផ្នែកទ្រឹស្តី និងការអនុវត្តជាក់ស្តែងជួយកែលម្អផ្តល់ប្រឹក្សាស្តីពីដំណើរការស្រាវជ្រាវឱ្យមានលក្ខណៈពេញលេញ និងបញ្ចប់ត្រឹមត្រូវ។

ជាទីបញ្ចប់យើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះការជួយឧបត្ថម្ភគាំទ្ររបស់គម្រោងទាំងផ្នែកហិរញ្ញវត្ថុ និងបច្ចេកទេសដើម្បីឱ្យរបាយការណ៍នេះទទួលបានលទ្ធផលល្អ។

## ១.សេចក្ដីផ្ដើម

សាវតារនៃការស្រាវជ្រាវរយៈកាលកន្លងមករហូតដល់បច្ចុប្បន្ននេះ ទោះជាមានការខិតខំប្រឹងប្រែងលើកកម្ពស់គុណភាពយ៉ាងណាក៏ដោយក៏វិស័យអប់រំនៅព្រះរាជាណាចក្រកម្ពុជាយើងនៅតែមានការខ្វះចន្លោះនៅឡើយ។ នៅតាមសាលារៀនតាំងពីមត្តេយ្យសាលាដល់មធ្យមសិក្សាសិស្សត្រូវបានរៀបចំអង្គុយច្រើនលើសពីនិយាមគរុកោសល្យបានន័យថា បរិស្ថានថ្នាក់រៀនមិនទាន់ឆ្លើយតបទៅ នឹងវិធីបង្រៀន និងរៀនក្នុងសតវត្សទី២១នៅឡើយ (បូ១៩៩៦)។ សាស្ត្រាចារ្យគ្រូបង្រៀន និងគរុសិស្ស គរុនិស្សិតពុំសូវមានការប្រាស្រ័យទាក់ទងល្អ និងពុំទាន់មានការលើកទឹកចិត្តទាំងផ្លូវកាយ និងផ្លូវចិត្តបានប្រសើរនៅឡើយ។ ប្រការនេះ មានន័យថា គរុនិស្សិតពុំសូវមានសកម្មភាពស្មើគ្នាដែលកើតចេញ ពីខ្លួនឯងនោះទេ គឺពេលខ្លះគេធ្វើតែអ្វីៗដែលគ្រូដាក់ឱ្យតែប៉ុណ្ណោះ។ គ្រូបង្រៀនភាគច្រើនអនុវត្តគោលវិធីគ្រូមជ្ឈមណ្ឌល បង្រៀនតែអ្វីៗដែលមានក្នុងសៀវភៅមេរៀនតែប៉ុណ្ណោះ ដោយយោលទៅតាមកង្វះអាគារសិក្សា សម្ភារៈឧបទេសទំនើប ជាដើម...(បូ១៩៩៦)។

បច្ចុប្បន្នប្រសិនជាអ្នកអប់រំ គ្រូបង្រៀនចង់ឱ្យគរុសិស្ស គរុនិស្សិតខ្មែរក្លាយជាធនធានមនុស្សដែល មានប្រយោជន៍ នៅក្នុងសង្គមប្រជាធិបតេយ្យក្នុងសតវត្សទី២១នេះយើងត្រូវតែរៀបចំថ្នាក់រៀន យ៉ាងណាដើម្បីផ្ដល់ឱកាសឱ្យគរុសិស្ស និស្សិត ក្លាយទៅជាអ្នកសកម្មចេះគិត និងត្រិះរិះឱ្យបានល្អិតល្អន់មានសមត្ថភាពរឹងមាំ។ ដើម្បីសម្រេចគោលដៅនេះបានគ្រូបង្រៀនត្រូវចាប់អារម្មណ៍លើគោលការណ៍ចតុស្ដម្ភនៃការអប់រំឱ្យបានល្អពោលគឺ បណ្ដុះបណ្ដាលធនធានមនុស្សឱ្យមានបំណិនទាំងបួនគឺ៖

- រៀនស្គាល់៖ ចំណេះដឹងទូលំទូលាយគ្រប់គ្រាន់ជាមួយនិងឱកាសប្រកបការងារបានស៊ីជម្រៅ និងដើម្បីទាញយកអត្ថប្រយោជន៍ពីការអប់រំដែលបានផ្ដល់ឱ្យសម្រាប់ប្រើប្រាស់ក្នុងជីវិតរស់នៅ។
- រៀនធ្វើ៖ ដើម្បីទទួល បាន មិនត្រឹមតែ ជាបំណិនមុខរបរ ប៉ុណ្ណោះទេ ប៉ុន្តែអ្វីដែល កាន់តែទូលាយទៀតនោះគឺសមត្ថភាពដោះស្រាយស្ថានភាពផ្សេងៗច្រើន និងធ្វើជាក្រុមៗបាន ។ នេះក៏មានន័យផងដែរថាជាការរៀនធ្វើនៅក្នុងបរិបទនៃស្រទាប់សង្គមផ្សេងៗ ដែលរួមមានវគ្គសិក្សា ការសិក្សាស្រាវជ្រាវ និងការងារផ្សេងៗ ។
- រៀនរៀបចំខ្លួន៖ ដើម្បីគេអាចអភិវឌ្ឍបុគ្គលិកលក្ខណៈបានកាន់តែល្អប្រសើរហើយអាចធ្វើសកម្មភាពដោយស្វ័យភាពច្រើនជាងមុនប្រកបដោយសុភវិនិច្ឆ័យ និងប្រកបដោយការទទួលខុសត្រូវផ្ទាល់ខ្លួន។ចំពោះបញ្ហានេះ ការអប់រំមិនត្រូវមើលស្រាលទិដ្ឋភាពណាមួយនៃសក្ដានុពលរបស់បុគ្គលណាម្នាក់ឡើយដែលរួមមាន៖ ស្មារតីចងចាំ សមត្ថភាពវិភាគរកហេតុផល អារម្មណ៍

ចង់ឱ្យមានសោភ័ណ សមត្ថភាពខាងកាយសម្បទា និងបំណិនប្រាស្រ័យទាក់ទងព័ត៌មានជាដើម(គណៈកម្មការអន្តរជាតិទទួលបន្ទុកការងារអប់រំសម្រាប់សតវត្សទី២១, ១៩៩៦)។

• រៀនរស់នៅជាមួយគ្នា ៖ ដោយពង្រឹងពង្រីកការយោគយល់ដល់អ្នកដទៃ និងយល់ពីតម្លៃនៃការពឹងផ្អែកគ្នាទៅវិញទៅមកដោយអនុវត្តគម្រោងការងាររួម ហើយរៀនគ្រប់គ្រងទំនាស់ក្នុងស្មារតីគោរពតម្លៃពហុទស្សនៈការយោគយល់គ្នាទៅវិញទៅមក និងសន្តិភាព។ ដូចនេះថ្នាក់រៀនត្រូវរៀបចំសកម្មភាពបង្រៀន និងរៀនឱ្យសិស្សចូលរួមសកម្មភាពការសិក្សាឱ្យបានស្មើគ្នាចូលរួមក្នុងគ្រប់សកម្មភាពក្នុងថ្នាក់រៀនត្រូវចេះគិតដោយខ្លួនឯង និងចេះទទួលខុសត្រូវចំពោះសកម្មភាពរបស់ខ្លួនទាំងក្នុងថ្នាក់ និងក្រៅថ្នាក់ (គណកម្មការអន្តរជាតិទទួលបន្ទុកការងារអប់រំសម្រាប់សតវត្សទី២១, ១៩៩៦)។

## ២.បញ្ហាស្រាវជ្រាវ

ការលើកកម្ពស់គុណភាពអប់រំពិសេសគុណភាពនៃការបង្រៀន និងរៀនជាបញ្ហាចម្បងដែលក្រសួងអប់រំ យុវជន និងកីឡា និងអ្នកគ្រប់គ្រងអប់រំគ្រប់លំដាប់ថ្នាក់បាននឹងកំពុងយកចិត្តទុកដាក់យ៉ាងខ្លាំងក្លានិងជាប្រចាំ។ ការបណ្តុះបណ្តាលធនធានមនុស្ស(បរិញ្ញា+១)នេះវាជាការងារចាំបាច់ដែលវិទ្យាស្ថានជាតិអប់រំ(វ.ជ.អ) ត្រូវអនុវត្តឱ្យបានល្អក្នុងការជំរុញឱ្យមានការបង្រៀន និងរៀនប្រកបដោយប្រសិទ្ធភាពខ្ពស់ ពោលគឺធានាឱ្យបានការបង្រៀន និងរៀនល្អ សំដៅសម្រេចគោលដៅអប់រំជាតិដោយជោគជ័យ(នាយកដ្ឋានបណ្តុះបណ្តាល និងវិក្រិតការ ២០០១)។ ការបណ្តុះបណ្តាលធនធានមនុស្សនៅវិទ្យាស្ថានជាតិអប់រំមានការកែប្រែឈ្មោះជាច្រើនមកហើយ ប៉ុន្តែយើងធ្វើការស្រាវជ្រាវចាប់ពីឆ្នាំ១៩៩៦ ជំនាន់ទី១(បរិញ្ញា+១) រហូតដល់បច្ចុប្បន្ន ។ ក្នុងការបណ្តុះបណ្តាលបានផ្តោតទៅលើជំនាញឯកទេសទី១ បន្ថែមលើនេះមុខវិជ្ជាចិត្ត-គរុកោសល្យវិធីសាស្ត្របង្រៀនហ្វឹកហ្វឺនឱ្យចេះប្រើប្រាស់សម្ភារក្នុងការបង្រៀន ។ ឆ្លងកាត់តាមបទពិសោធន៍ក្នុងការបណ្តុះបណ្តាលគរុនិស្សិត១៦ជំនាន់មកនេះ ការបង្រៀន និងរៀននៅពុំទាន់គ្រប់ជ្រុងជ្រោយពិសេសមិនទាន់គួបផ្សំជាមួយបច្ចេកវិទ្យាទំនើប។ យើងចង់ដឹងថាវិធីបង្រៀន និងរៀនតាមកម្មវិធីសិក្សាមានឥទ្ធិពលបែបណា ហើយនៅវិទ្យាស្ថានជាតិអប់រំគ្រូឧទ្ទេសនៅតែប្រើប្រាស់ឯកសារដដែលៗដោយគ្មានការធ្វើឡើងវិញឬយ៉ាងណា ។ ជាងនេះទៅទៀតពួកគាត់មួយចំនួនមិនបានធ្វើការស្រាវជ្រាវ ដើម្បីរកវិធីសាស្ត្រដែលសមស្របទៅបង្រៀនគរុនិស្សិតទេ។ គោលវិធីសិស្សមជ្ឈមណ្ឌលមិនទាន់ត្រូវបានប្រើប្រាស់ឱ្យបានទូលំទូលាយដោយគ្រូឧទ្ទេសរបស់វិទ្យាស្ថានជាតិអប់រំនៅឡើយទេ(NIE, ២០១០)។ ដូច្នេះទាមទារឱ្យមានការសិក្សាអំពីការអនុវត្តនិងប្រសិទ្ធភាពនៃវិធីសាស្ត្របង្រៀនបែបគោលវិធីសិស្សមជ្ឈមណ្ឌលនៅវិទ្យាស្ថានជាតិអប់រំ។ សារៈសំខាន់នៃការស្រាវជ្រាវគឺរកឱ្យឃើញពីបញ្ហាដែលពាក់ព័ន្ធនឹងវិធីបង្រៀន និងរៀន ស្វែងរក

ដំណោះស្រាយបទពិសោធន៍ចំពោះតម្រូវការក្នុងការបណ្តុះបណ្តាលនូវការបង្រៀននិងរៀនតាមរយៈវិធីសាស្ត្រទំនើបៗ និងធ្វើឱ្យការបង្រៀន និងរៀនកាន់តែមានគុណភាពខ្ពស់។

## ៣.គោលបំណងស្រាវជ្រាវ

ការសិក្សានេះមានគោលបំណងស្វែងយល់អំពីការអនុវត្តវិធីបង្រៀនតាមបែបគោលវិធីសិស្សមជ្ឈមណ្ឌលនៅវិទ្យាស្ថានជាតិអប់រំដោយពិនិត្យមើលចំណុចខាងក្រោម៖

- ការអនុវត្តគោលវិធីបង្រៀនតាមបែបវិធីសិស្សមជ្ឈមណ្ឌលសម្រាប់មុខវិជ្ជាវិទ្យាសាស្ត្រសង្គម
- ការយល់ឃើញរបស់សាស្ត្រាចារ្យចំពោះវិធីសាស្ត្របង្រៀនគោលវិធីសិស្សមជ្ឈមណ្ឌល
- ការយល់ឃើញរបស់គរុនិស្សិតចំពោះវិធីសាស្ត្របង្រៀនគោលវិធីសិស្សមជ្ឈមណ្ឌល
- គោលបំណងនៃការយល់ដឹងបន្ថែមទៀតអំពីការអនុវត្ត និងប្រសិទ្ធភាពនៃគោលវិធីសិស្សមជ្ឈមណ្ឌលគឺធ្វើយ៉ាងណាឱ្យវិធីសាស្ត្រអាចត្រូវពង្រឹងបានឬផ្លាស់ប្តូរដើម្បីទទួលបានលទ្ធផលផ្នែកអប់រំ ដែលមានលក្ខណៈកាន់តែប្រសើរឡើង។

## ៤. សំណួរស្រាវជ្រាវ

ក. តើការអនុវត្តវិធីសាស្ត្របង្រៀនបែបគោលវិធីសិស្សមជ្ឈមណ្ឌលនៅវិទ្យាស្ថានជាតិអប់រំមានលក្ខណៈដូចម្តេច?

ខ. តើសាស្ត្រាចារ្យយល់ឃើញយ៉ាងដូចម្តេច អំពីការអនុវត្តវិធីសាស្ត្របង្រៀនបែបគោលវិធីសិស្សមជ្ឈមណ្ឌល?

គ. តើគរុនិស្សិតយល់ឃើញយ៉ាងដូចម្តេច អំពីការអនុវត្តវិធីសាស្ត្របង្រៀនបែបគោលវិធីសិស្សមជ្ឈមណ្ឌល?

## ៥.គោលដៅស្រាវជ្រាវ

ការសិក្សានេះមានគោលដៅដើម្បី៖

- រៀបរាប់ពីដំណើរការបង្រៀនបែបសិស្សមជ្ឈមណ្ឌលដោយផ្តោតលើមុខវិជ្ជាវិទ្យាសាស្ត្រសង្គម។
- ស្វែងយល់អំពីការយល់ឃើញរបស់គ្រូឧទ្ទេសអំពីដំណើរការ និងប្រសិទ្ធិភាពនៃវិធីសាស្ត្របង្រៀនបែបសិស្សមជ្ឈមណ្ឌល។
- ស្វែងយល់អំពីការយល់ឃើញរបស់គរុនិស្សិតអំពីដំណើរការ និងប្រសិទ្ធភាពនៃវិធីសាស្ត្របង្រៀនបែបគោលវិធីសិស្សមជ្ឈមណ្ឌល។

## ៦.វិធីសាស្ត្រស្រាវជ្រាវ

### ៦.១. វិធីសាស្ត្រប្រមូលទិន្នន័យ

ការសិក្សាស្រាវជ្រាវនេះនឹងធ្វើឡើងនៅក្នុងវិទ្យាស្ថានជាតិអប់រំដែលជាគ្រឹះស្ថានឧត្តមសិក្សាសាធារណៈតែមួយគត់របស់រាជរដ្ឋាភិបាលកម្ពុជា ដែលទទួលបន្ទុកបណ្តុះបណ្តាលគ្រូ បង្រៀន

កម្រិតឧត្តម(បរិញ្ញា+១)នៅកម្ពុជា ដែលមានទីតាំងនៅរាជធានីភ្នំពេញដោយប្រើវិធីសាស្ត្រ ៖

• បែបគុណភាពស្រាវជ្រាវពីដំណើរការអនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌល។

• បែបបរិមាណដូចជាចំនួនមនុស្ស ។ ការប្រមូលទិន្នន័យនឹងធ្វើឡើងតាមរយៈការសម្ភាសន៍ពាក់កណ្តាលរចនាសម្ព័ន្ធជាមួយគ្រូឧទ្ទេស១០នាក់ ក្នុងចំណោម៥១នាក់ ទៅលើមុខវិជ្ជាវិទ្យាសាស្ត្រសង្គមដែលនឹងជ្រើសរើសលក្ខណៈចៃដន្យ។ ការសង្កេតថ្នាក់ចំនួន៣ថ្នាក់ ដែលនឹងជ្រើសរើសឯកទេស ភូមិវិទ្យា ប្រវត្តិវិទ្យា និងអក្សរសាស្ត្រ។ កម្រងសំណួរបំពេញដោយ គរុនិស្សិតចំនួន១០០នាក់ រយៈពេល ២០ថ្ងៃលើ៥មុខវិជ្ជាឯកទេស ភូមិវិទ្យា ប្រវត្តិវិទ្យា សូនរូប អក្សរសាស្ត្រ២ក្រុម និងសីលធម៌២ក្រុមដែលនឹងជ្រើសរើសក្នុងចំណោមគរុនិស្សិត១០០០នាក់ និងការសិក្សាស្រាវជ្រាវតាមរយៈឯកសារផ្សេងៗ។

• មូលហេតុដែលជ្រើសរើសវិធីសាស្ត្រប្រមូលទិន្នន័យតាមបែប បរិមាណ និងគុណភាព គឺមានបំណងស្វែងយល់ពីទស្សនរបស់សាស្ត្រាចារ្យបង្រៀន និងគរុនិស្សិតពីវិធីបង្រៀន និងរៀនតាមបែបគោលវិធីសិស្សមជ្ឈមណ្ឌល ផ្នែកវិទ្យាសាស្ត្រសង្គមនៃវិទ្យាស្ថានជាតិអប់រំដោយជ្រើសរើសសាស្ត្រាចារ្យ គរុនិស្សិត វិទ្យាស្ថាន ជាតិអប់រំផ្ទាល់ដែលជាស្ថាប័នបណ្តុះបណ្តាលធនធានមនុស្ស។ ការស្រាវជ្រាវនេះនឹងស្នើសុំការអនុញ្ញាតពីឯកឧត្តមបណ្ឌិតនាយកវិទ្យាស្ថានជាតិអប់រំដើម្បីចុះប្រមូលទិន្នន័យ។

### ៦.២. វិធីសាស្ត្រវិភាគទិន្នន័យ

ទិន្នន័យដែលទទួលបានពីកម្រងសំណួរ នឹងត្រូវវិភាគជាប្រេកង់ ភាគរយ មធ្យមភាគ កម្រិតទាបបំផុត និងកម្រិតខ្ពស់បំផុត។ ចំណែកឯទិន្នន័យនៃការសម្ភាសន៍ពាក់កណ្តាលរចនាសម្ព័ន្ធនឹងត្រូវវិភាគជាលក្ខណៈរៀបរាប់ដែលផ្តោតទៅលើនិន្នាការ ឬលក្ខណៈរួមនៃចម្លើយ។ ការសង្កេតថ្នាក់វិភាគជាលក្ខណៈរៀបរាប់ពីសកម្មភាពសិស្ស-គ្រូ។

### ៦.៣. លទ្ធផលរំពឹងទុកនៃការស្រាវជ្រាវ

ការស្រាវជ្រាវ នឹងផ្តល់នូវការយល់ដឹងអំពីដំណើរការនៃការអនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌល ផ្នែកវិទ្យាសាស្ត្រសង្គមនិងការប្រឈមក្នុងសកម្មភាពបង្រៀន និងរៀនដើម្បីកែលម្អនិងធ្វើការអភិវឌ្ឍ។

## ៧. ការរំលឹកទ្រឹស្តី និងការសិក្សាដែលពាក់ព័ន្ធ

ក្នុងលំនាំនៃការបង្រៀន និងរៀនមានសកម្មភាពសំខាន់ពីរដែលមិនអាចផ្តាច់ចេញពីគ្នាបានគឺសកម្មភាពគ្រូ(ការបង្រៀន) និងសកម្មភាពសិស្ស (ការរៀន)ទើបដំណើរការនៃការបង្រៀនប្រព្រឹត្តទៅទទួលបានជោគជ័យ។ ដូចនេះយើងគួរស្វែងយល់ពីពាក្យគន្លឹះ វិធីបង្រៀន និងវិធីរៀន ដូចម្តេចដែលហៅថាវិធីបង្រៀន? ដូចម្តេចដែល ហៅថាវិធីរៀនរបស់គរុនិស្សិតម្នាក់ៗ?

• វិធីបង្រៀនគឺជារបៀប មធ្យោបាយ ឬល្បិច ក្នុងការបង្រៀន គ្រប់គ្រងផ្តល់ចំណេះដឹង ចំណេះធ្វើ និងបំណិនប្រសប់ ឥរិយាបថសមរម្យដល់សិស្ស ដើម្បីសម្រេចបានលទ្ធផលល្អ ។

• វិធីរៀន គឺជារបៀប ឬ មធ្យោបាយរៀនរបស់សិស្សម្នាក់ៗក្នុងការទទួលពុទ្ធិក្នុងថ្នាក់ និង ក្រៅថ្នាក់ ។

## ៧.១. ទ្រឹស្តីអំពីការបង្រៀន និងការរៀនតាមរបៀបសិស្សមជ្ឈមណ្ឌល

គោលវិធីសិស្សមជ្ឈមណ្ឌលគឺជាទ្រឹស្តីមួយឬគោលការណ៍អប់រំមួយដែលទាក់ទងទៅនឹង ការរៀន និងការបង្រៀនដោយយកសិស្សជាកត្តាសំខាន់ (នាយកដ្ឋានបណ្តុះបណ្តាល និងវិក្រិតការ ២០០១)។ ប៉ុន្តែទ្រឹស្តីគ្រូមជ្ឈមណ្ឌលត្រូវបានគ្រូបង្រៀន និងអ្នកអប់រំជាច្រើនប្រើនៅក្នុងថ្នាក់រៀន អស់រយៈពេលជាយូរមកហើយ។ ទោះជាយ៉ាងណាក៏ដោយនៅតាមតំបន់ជាច្រើន នៅលើ ពិភពលោកគ្រូបង្រៀន និងអ្នករៀបរៀងវិធីសាស្រ្តបង្រៀនជាច្រើនបានយល់ឃើញថាវិធីសាស្រ្ត បង្រៀនតាមបែបគ្រូមជ្ឈមណ្ឌលពុំសូវផ្តល់ផលប្រយោជន៍ដល់អ្នកសិក្សានោះទេ ដោយសារតែ វិធីសាស្រ្តនេះពុំឆ្លើយតបទៅ នឹងតម្រូវការរបស់អ្នកសិក្សានៅឡើយ និងពុំដាក់សិស្សឱ្យស្ថិតនៅ ចំកណ្តាលនៃដំណើរការសិក្សា។ តាមទស្សនៈរបស់គ្រូ សិស្សខ្សោយគឺជាកំហុសរបស់សិស្ស ព្រោះថាពួកគេពុំមានវិន័យល្អ ពុំធ្វើកិច្ចការផ្ទះពុំរំលឹកមេរៀន...។ល។ ប៉ុន្តែតាមការគិតរបស់ សិស្សវិញភាពខ្សោយរបស់ពួកគេគឺបណ្តាលមកពីគ្រូដែលពុំដឹងពីវិធីបង្រៀន ឬក៏គ្រូដែលពុំចេះ គរុកោសល្យក្នុងការបង្រៀន។ ចំណែកឯទស្សនៈនៃថ្នាក់ដឹកនាំនៅក្នុងសាលាវិញគុណភាពនៃ ការសិក្សាមិនទាន់ល្អគឺជាកំហុសរបស់គ្រូ និងសិស្សដែលពុំព្រមប្រតិបត្តិតាមច្បាប់ និង គោលការណ៍របស់សាលា (Rogers ២០០២)។

ដូច្នេះ គេបានបង្កើតវិធីសាស្រ្តថ្មីគឺការសិក្សាតាមបែបសិស្សមជ្ឈមណ្ឌល។ ការសិក្សាតាម បែបសិស្សមជ្ឈមណ្ឌលដាក់នូវការខុសត្រូវច្រើនទៅលើអ្នកសិក្សាសម្រាប់ការសិក្សាផ្ទាល់ខ្លួន។

ការសិក្សាបែបនេះ ធ្វើឱ្យសិស្សចូលរួមបានច្រើននៅក្នុងការសម្រេចចិត្ត ហើយពួកគេរៀន ធ្វើផ្ទាល់ជាជាងត្រឹមតែការស្តាប់ និងធ្វើតាមកិច្ចការណាដែលពុំសូវមានន័យជារឿយៗ គឺមិនមាន នៅក្នុងហេតុការណ៍ទើបធ្វើឱ្យក្លាយ ទៅជាភាពមិនពិតសម្រាប់ពួកគេ។ដោយសារតែការរៀន ទាមទារឱ្យមានការចូលរួមយ៉ាងសកម្មនៅក្នុងសកម្មភាពសិក្សា (ជាជាងស្តាប់គ្រូពន្យល់តែម្យ៉ាង) វាធ្វើឱ្យសិស្សងាយយល់ ព្រោះវិធីនេះត្រូវការសម្ភារ រីឯចំនួនសិស្សក្នុងមួយថ្នាក់មានកំណត់ និង មានប្រភពឯកសារគ្រប់គ្រាន់ (Ginsburg, 2006) ដូច្នេះ សិស្សចេះចាំបានច្រើនជាងដោយសារតែ ការចូលរួមសកម្មភាពផ្ទាល់ វា មានការជាប់ភ្ជាប់ទៅនឹងជីវិត និងបទពិសោធន៍ក្នុងការរស់នៅ របស់ពួកគេ។ ជាការពិតការសិក្សាតាមបែបសិស្សមជ្ឈមណ្ឌលពុំមែនជាអ្វីដែលថ្មីស្រឡាងនោះ ទេ។ កាលពីសម័យមុនគ្រូបង្រៀនដឹកនាំការបង្រៀនផ្ទាល់ ប៉ុន្តែដោយសារតែការរីកចម្រើនផ្នែក

អប់រំនៅក្នុងសតវត្សទី១៩ និងឥទ្ធិពលនៃអ្នកចិត្តវិទូ ធ្វើឱ្យអ្នកអប់រំបានផ្លាស់ប្តូរកម្មវិធីសិក្សាតាមទ្រឹស្តីបែបបុរាណមកធ្វើការដោយផ្ទាល់ និងធ្វើការជាក្រុមដែលសិស្សអាចសម្រេចចិត្តដោយខ្លួនឯងទៅលើអ្វីដែលពួកគេចង់បាននៅក្នុងថ្នាក់។ គន្លឹះដែលធ្វើឱ្យមានការផ្លាស់ប្តូរនេះគឺជាការសន្មតដែលសិស្សបង្កើតការរៀនដោយខ្លួនឯង។ អ្នកទ្រឹស្តីជាច្រើន ដូចជា John Dewey, Jean Piaget, and Lev Vygotsky ដែលការសិក្សារបស់ពួកគេ ផ្តោតទៅលើរបៀបដែលសិស្សរៀន គឺជាគន្លឹះឆ្ពោះទៅកាន់ការសិក្សាតាមបែបសិស្សមជ្ឈមណ្ឌល។ ចំពោះគំនិតរបស់Carl Rogers សិស្សបង្កើតការរៀនដោយខ្លួនឯងដោយផ្តោតទៅលើព័ត៌មានដែលមានទាំងនេះ គឺជាការរៀនផ្ទាល់ខ្លួនថាតាមបែបសិស្សមជ្ឈមណ្ឌល។តាមរយៈវិធីសាស្ត្រដែលបានលើកឡើងដោយលោក Piaget វាគឺជាវិធីសាស្ត្រដែលសមស្របទៅនឹងនិយមន័យនៃការសិក្សាតាមបែបសិស្សមជ្ឈមណ្ឌល ពោលគឺគ្រូបង្រៀនទុកឱកាសឱ្យសិស្សប្រាស្រ័យទាក់ទងការស្រាវជ្រាវការរៀនដោះស្រាយបញ្ហា ដោយខ្លួនឯង ដោយគ្រូដើរតួត្រឹមជាអ្នកជួយជំរុញប៉ុណ្ណោះ (អ៊ឹម ១៩៩៩)។

ចំណែកឯលោក Lev Vygotsky អ្នកចិត្តវិទូជនជាតិរុស្ស៊ីមានគំនិតខុសគ្នាខ្លះៗជាមួយនឹង Piaget ដោយ Vygotsky ផ្តោតទៅលើវិវឌ្ឍការគិតរបស់ក្មេងដោយផ្អែកលើការប្រាស្រ័យទាក់ទងគ្នារវាងក្មេង និងសង្គមដែលពួកគេរស់នៅ ធ្វើឱ្យពួកគេរៀនពីអ្វីៗដែលថ្មីតាមរយៈការទំនាក់ទំនងនេះ។ Vygotsky បានផ្តល់នូវគំនិតពីរពន្យល់ថា តើការទំនាក់ទំនងជាមួយសង្គមដែលពួកគេរស់នៅមានឥទ្ធិពលទៅលើការរៀន និងការគិតយ៉ាងណា។ Vygotsky លើកឡើងដោយប្រើប្រាស់ឧបករណ៍ពិតដូចជាកុំព្យូទ័រមាត្រាចំណែក។ល។ និងប្រព័ន្ធនិមិត្តសញ្ញាដូចជាលេខ ភាសា ក្រាបជាដើមដែលអាចឱ្យមនុស្សនៅក្នុងសង្គមទំនាក់ទំនងដោះស្រាយបញ្ហា និងបង្កើតនូវចំណេះដឹងដើរតួយ៉ាងសំខាន់នៅក្នុងការវិវត្តសមត្ថភាពនៃការគិត។ ឧទាហរណ៍នៅក្នុងការបង្រៀនគ្រូអាចដាក់ឧបករណ៍ខាងលើឱ្យសិស្សលេង ឬក៏សិក្សាធ្វើឱ្យក្មេងចូលរួមនៅក្នុងសកម្មភាពទាំងនេះ ក្មេងអាចផ្លាស់ប្តូរគំនិតរវាងគ្នា និងគ្នាដែលធ្វើឱ្យចំណេះដឹង គំនិតអាកប្បកិរិយា និងគុណតម្លៃមានការវិវត្ត។ គំនិតនេះ គឺជាគំនិតមួយដែលយើងអាចយកមកអនុវត្តនៅក្នុងការសិក្សាតាមបែបគោលវិធីសិស្សមជ្ឈមណ្ឌលទៅលើក្មេងដែលមានអាយុតិចៗ។

## ៧.២. គោលការណ៍នៃវិធីសាស្ត្របង្រៀនបែបសិស្សមជ្ឈមណ្ឌល

នៅពេលដែលរៀបរៀងមេរៀនសម្រាប់ការសិក្សាតាមបែបសិស្សមជ្ឈមណ្ឌលវាមានប្រយោជន៍សម្រាប់អ្នកបង្រៀនទាំងឡាយក្នុងការចងចាំនូវលក្ខណៈសំខាន់ៗដូចខាងក្រោម ៖

ត្រូវសួរ និងកុំប្រាប់ចម្លើយតែត្រូវព្យាយាមទាញយកព័ត៌មាន គំនិត និងចម្លើយពីសិស្សឱ្យបានច្រើន។ សិស្សរបស់យើងពុំមែនជាថូដែលរង់ចាំឱ្យគ្រូបំពេញនូវចំណេះឱ្យពួកគេនោះទេ។ ពួកគេមានចំណេះដឹង និងបទពិសោធន៍នៃជីវិតដូចគ្នា។ អ្វីដែលគេកំពុងរៀនអាចចូលរួមចំណែកបានយ៉ាងច្រើនទៅក្នុងដំណើរការនៃការរៀន។ ផ្តោតទៅលើបទពិសោធន៍ និងការចាប់អារម្មណ៍

របស់សិស្ស ប្រសិនបើគ្រូបង្រៀនជ្រើសរើសនូវប្រធានបទ ឬក៏អនុវត្តតាមសៀវភៅសិក្សា វាប្រហែលជាពុំអាចទាក់ទាញចំណាប់អារម្មណ៍របស់សិស្សនោះទេ ។ ប្រសិនបើគ្រូបង្រៀនយកសៀវភៅមេរៀនជាគោលហើយព្យាយាមរកសកម្មភាពឬក៏ឧទាហរណ៍ណាដែលផ្សារភ្ជាប់ទៅនឹងអ្វីដែលទាក់ទងនឹងជីវិតរស់នៅរបស់សិស្សនោះ ពួកគេនឹងចូលរួមយ៉ាងសកម្មក្នុងសកម្មភាពបង្រៀនព្រមទាំងការចងចាំទៀតផង ។ ការរៀនដោយឱ្យសិស្សចូលរួមក្នុងសកម្មភាពនាំឱ្យពួកគេកាន់តែចងចាំពីអ្វីដែលពួកគេបានរៀន សិស្សត្រូវមានការជ្រើសរើស ពួកគេមានជម្រើស និងធ្វើសេចក្តីសម្រេចចិត្តអំពីការសិក្សា។ ចំពោះការងារជាក្រុមទាមទារនូវការចរចា និងការសម្រេចចិត្តធ្វើការរួមគ្នា ដើម្បីឆ្ពោះទៅរកគោលដៅរួម ។ ផ្តោតលើការកសាងភាពជឿ ជាក់លើខ្លួនឯងសម្រាប់ជំនាញ ដែលយើងជ្រើសរើស។ ការលើកទឹកចិត្តឱ្យសិស្សមានការចាប់អារម្មណ៍ទៅលើមុខវិជ្ជាដែលពួកគេកំពុងសិក្សាឧទាហរណ៍ ៖ នៅក្នុងមុខវិជ្ជាភាសាអង់គ្លេសគ្រូបង្រៀនត្រូវប្រើប្រាស់នូវសម្ភារពិតៗដែលសិស្សធ្លាប់ស្គាល់ដូចជា៖ ទស្សនាវដ្តី អ៊ីនធឺណិត វីដេអូ ទូរទស្សន៍ និងសំបុត្រជាដើមដែលសិស្សត្រូវការដើម្បីបង្កើនភាពយល់ដឹងផ្នែកភាសារបស់ពួកគេ។

## ៧.៣. ប្រភេទនៃសកម្មភាពសិក្សាតាមបែបសិស្សមជ្ឈមណ្ឌល

The University of Glasgow(2004) បានចែករបៀបនៃការសិក្សារបស់សិស្សតាមគោលវិធីសិស្សមជ្ឈមណ្ឌលជាពីរគឺ ការសិក្សានៅក្នុងថ្នាក់ និងការសិក្សានៅក្រៅថ្នាក់៖

| ការសិក្សានៅក្រៅថ្នាក់ | ការសិក្សានៅក្នុងថ្នាក់ |
|---|---|
| • បង្កើតការពិភាក្សាជាក្រុម<br>• បង្ហាញណែនាំ និងជួយកែកំហុសសិស្សផ្សេងៗទៀត<br>• កិច្ចពិភាក្សាវែកញែកលើប្រធានបទអ្វីមួយ<br>• ដំណើរការសរសេរអត្ថបទកាសែតជាដើម | • សិស្សអាចធ្វើការពិភាក្សាជាដៃគូ<br>• ធ្វើឱ្យការពិភាក្សាជាដៃគូឈានទៅរកការពិភាក្សាជាក្រុម<br>• សរសេរអត្ថបទដែលឆ្លុះបញ្ចាំងទៅលើការរៀនកន្លងមក<br>• ឡើងអត្ថាធិប្បាយនៅក្នុងថ្នាក់<br>• ការសំដែងនៅក្នុងថ្នាក់ជាដើម |

សរុបមក ការសិក្សាតាមបែបសិស្សមជ្ឈមណ្ឌល គឺជាគំរូថ្មីមួយដែលផ្តោតសំខាន់ទៅលើការចូលរួមរបស់អ្នកសិក្សា ក្នុងការរៀបចំគម្រោងប្រតិបត្តិខណៈពេលដែលគ្រូបង្រៀនដើរតួជាអ្នកសម្របសម្រួលលើស្ថានភាពនៃការសិក្សា។ហើយការសិក្សាបែបនេះគឺសមស្រប ជា មួយសិស្សដែលរៀននៅកម្រិតខ្ពស់ច្រើនជាងកម្រិតទាប។អ្នកសិក្សារៀនដោយកសាងចំណេះជាជាងទទួលយកចំណេះពីអ្នកដទៃ(ពីគ្រូបង្រៀន)។យើងគួរតែជួយអ្នកសិក្សាឱ្យចូលរួម យ៉ាងសកម្មនៅក្នុងសកម្មភាពសិក្សារបស់ពួកគេ។ ជាមួយគ្នានោះដែរ យើងក៏ត្រូវរួមចំណែកអភិវឌ្ឍខ្លួនដូចគ្នា។

## ៧.៤. យុទ្ធវិធីបង្រៀនបែបសិស្សមជ្ឈមណ្ឌល

ដើម្បីសម្រេចបានផលល្អទៅតាមទស្សនៈគោលវិធីសិស្សមជ្ឈមណ្ឌលគ្រូត្រូវចេះបង្រៀន យុទ្ធវិធីសម្រាប់ការបង្រៀន និងរៀន។ ខាងក្រោមនេះ គឺជាឧទាហរណ៍ខ្លះនៃយុទ្ធវិធីដែលបម្រើឱ្យទស្សនៈគោលវិធីសិស្សមជ្ឈមណ្ឌល។

**យុទ្ធវិធីទី១ (គ្រូជាអ្នកសម្របសម្រួល-សិស្សជាអ្នកធ្វើសកម្មភាពផ្ទាល់)**

- គ្រូរៀបចំសិស្សជាក្រុមតូចៗ
- គ្រូដាក់សំណួរ ឬប្រធានបទ
- សិស្សពិភាក្សាតាមក្រុម
- តំណាងក្រុមឡើងបកស្រាយ
- គ្រូបូកសរុបក្នុងយុទ្ធវិធីនេះសិស្សរៀនដោយខ្លួនឯងនិងពិភាក្សាតាមក្រុម ហើយគ្រូចាំ តែធ្វើអន្តរាគមន៍នៅពេលសិស្សសួរ។

**យុទ្ធវិធីទី២ (គ្រូជាអ្នកដឹកនាំ-សិស្សជាអ្នកធ្វើសកម្មភាព)**




តាមគំនូសតារាងខាងលើនេះគេចែក១ម៉ោងបង្រៀនជា៤ដំណាក់កាល។សកម្មភាពគ្រូមានច្រើននៅដើមម៉ោង ហើយថយចុះបន្តិចម្តងៗ រហូតដល់ចប់ដំណាក់កាលទី៣។ សកម្មភាពសិស្សចាប់ផ្តើមពីដំណាក់កាលទី២ ហើយកើនច្រើនឡើងៗរហូតដល់ដំណាក់កាលទី៤ ដែលមានតែសិស្សប៉ុណ្ណោះធ្វើសកម្មភាព។

- នៅដំណាក់កាលទី១គ្រូជាអ្នកផ្តើមគំនិតបំផុសបញ្ហាដើម្បីបង្ហាញអំពីវត្ថុ បំណងមេរៀន(រយៈពេលប្រហែល ៣ នាទី) និងរៀបចំសកម្មភាពបន្តទៅទៀត។
- នៅដំណាក់កាលទី២ គ្រូដឹកនាំសកម្មភាពសិស្ស (អាចរៀបចំជាក្រុមតូច) និងសិស្សជាអ្នកអនុវត្តដោយផ្ទាល់រួច គ្រូចោទសំណួរឱ្យសិស្សធ្វើការអង្កេត។
- នៅដំណាក់កាលទី៣ គ្រូបំផុសបញ្ហាឱ្យសិស្សវិភាគ រួចធ្វើសំយោគដើម្បីទាញសេចក្តីសន្និដ្ឋានមួយជាច្បាប់វិធានការ ឬជាទ្រឹស្តី។
- នៅដំណាក់កាលទី៤ គ្រូដឹកដៃសិស្ស និងចង្អុលបង្ហាញផ្លូវឱ្យសិស្សរៀនដើរ ហើយចុងក្រោយគ្រូលែងដៃឱ្យសិស្ស ដើរដោយខ្លួនឯង។

កំណត់សម្គាល់ ៖ នៅដំណាក់កាលទី២គ្រូ និងសិស្សត្រូវមានសម្ភារងាយៗដែលអាចរកបានមកធ្វើពិសោធន៍ ដែលនាំឱ្យសិស្សឆាប់យល់ដោយខ្លួនឯងដោយគ្រូមិនបាច់ខិតខំពន្យល់សិស្សទេ។

**យុទ្ធវិធីទី៣ (គ្រូជាអ្នកដឹកនាំ-សិស្សធ្វើសកម្មភាព)**

គឺជាយុទ្ធវិធី "ឆ្លាស់សកម្មភាព" រវាងការបង្រៀនមេរៀន និងធ្វើការងារប្រតិបត្តិ។

- គ្រូបង្រៀនមេរៀន ១០ នាទី ឬ ៥-៧ នាទី ទៅតាមខ្លឹមសារដែលត្រូវបង្រៀន។ ការបង្រៀននេះអាចជាសកម្មភាពគ្រូ ឬជាសកម្មភាពគ្រូ និងសិស្ស។
- ចប់ផ្នែកមួយនៃមេរៀន គ្រូដាក់កិច្ចការប្រតិបត្តិឱ្យសិស្សធ្វើ២០នាទី ១៥នាទីទៅតាមសមត្ថភាពជាក់ស្តែង។
- ភាពងាយស្រួល ឬភាពលំបាកនៃការប្រតិបត្តិ គឺជាសកម្មភាពសិស្ស គ្រូអាចរៀបចំសិស្សជាក្រុម ឬរៀបចំជាសកម្មភាពបន្តបន្ទាប់ ដូចខាងក្រោម៖
  - ◆ សកម្មភាពជាបុគ្គល
  - ◆ សកម្មភាពជាក្រុមតូច
  - ◆ សកម្មភាពទូទាំងថ្នាក់

យុទ្ធវិធីទាំងបីដែលបានបង្ហាញខាងលើនេះ គ្រាន់តែជាឧទាហរណ៍ប៉ុណ្ណោះ។ គ្រូគួរស្វែងយល់អំពីយុទ្ធវិធីដែលបម្រើឱ្យគោលវិធីសិស្សមជ្ឈមណ្ឌលរួចរៀបចំយុទ្ធវិធីផ្ទាល់ខ្លួនមួយសម្រាប់ការបង្រៀនរបស់ខ្លួន។

## ៧.៥ សារៈសំខាន់នៃវិធីសាស្ត្របង្រៀនបែបសិស្សមជ្ឈមណ្ឌល

ការអនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌលគឺមានសារសំខាន់ណាស់ ពីព្រោះការស្រាវជ្រាវដោយបណ្ឌិត អ៊ុម កុច បានបង្ហាញថា ៖

- សិស្សរៀនបានលឿនជាង និងច្បាស់លាស់ជាង។
- ការរៀនសូត្រតែងតែទទួលឥទ្ធិពលពីទំនាក់ទំនងសង្គមរវាងគ្រូនិងសិស្សជាដរាប។
- ការរៀនសូត្រប្រព្រឹត្តទៅបាននៅពេលដែលគ្មានការរំខាន ឬគ្មានបញ្ហាផ្នែករាងកាយ ឬគ្មានការបង្អាប់ និងគ្មានការសើចចំអក។
- សិស្សរៀនសូត្របានពូកែ បើការបកស្រាយមេរៀនមានលក្ខណៈច្បាស់លាស់ដោយប្រើប្រាស់ពាក្យ ឬឃ្លាឃ្លោងសាមញ្ញចេះប្រើសម្ភារៈជារូបភាពជំនួយបន្ថែម និងឱ្យឧទាហរណ៍ជាក់ស្តែង។
- កម្មវិធីសិក្សា និងប្រធានបទដែលត្រូវរៀន បំពេញតាមការចង់បាន និងចំណាប់ចំណូលចិត្តរបស់សិស្ស។
- សិស្សនឹងរៀនបានល្អជាង បើ សិនជំនាញដែលត្រូវរៀននោះវាជាអ្វីដែលសិស្ស

ធ្លាប់ដឹងហើយដែលគេអាចធ្វើបានកន្លងមក។ សិស្ស ឬសិក្ខាកាមបានទទួលបទពិសោធន៍យ៉ាងច្រើននៅក្នុងជីវិតរបស់គេពីសំណាក់គ្រួសារ និងសហគមន៍ ដែលគេរស់នៅ ។ ដូចនេះវាជាការល្អដែលយើងគួរលើកទឹកចិត្តគេឱ្យផ្លាស់ប្តូរបទពិសោធន៍របស់ពួកគេជាមួយមិត្តភក្តិ។

- ការរៀនសូត្រនឹងបានលឿនជាង ប្រសិនបើជំនាញ និងព័ត៌មានត្រូវបានគេបកស្រាយតាមវិធីដែលមានគោលការណ៍ច្បាស់លាស់។
- សិស្សកំពុងតែអភិវឌ្ឍនូវអត្ថន័យនៃពាក្យចំណេះដឹង ឥរិយាបថ សេចក្តីថ្លៃថ្នូររបស់ខ្លួនផ្ទាល់។
- ដូច្នេះយើងត្រូវយកចិត្តទុកដាក់ចំពោះពួកគេដោយការយោគយល់គ្រប់ពេលវេលា។
- ពេលដែលសិស្សកាន់តែរីកចម្រើនឡើង ថាមពលនៃការចេះសង្កេត និងរិះរកហេតុផលរបស់គេក៏កាន់តែមានលក្ខណៈខ្លាំងឡើងដែរ។ ការលើកឡើងនូវបញ្ហាពិតជាអាចលើកទឹកចិត្តឱ្យមានការពិភាក្សា និងផ្លាស់ប្តូរគំនិតគ្នាទៅវិញទៅមក។
- យើងអាចចេះបានចំនួន ២០% នៃអ្វីដែលយើងឮ ៤០% នៃអ្វីដែលយើងឮ និងឃើញ៨០%នៃអ្វីដែលយើងធ្វើ និងអ្វីដែលយើងយល់ និងធ្វើដោយខ្លួនឯងពោលគឺអ្វី ដែលយើងរកឃើញដោយខ្លួនឯង (អ៊ឹម ១៩៩៩)។
- តែការអប់រំមិនមែនសុទ្ធតែអព្យាក្រឹតទាំងអស់នោះទេ។ការអប់រំត្រូវបានគេប្រើសម្រាប់រក្សាលំនឹងស្ថានភាពអ្វីមួយដែលមានស្រាប់និងការរំដោះមនុស្សឱ្យចេញផុតពីភាពល្ងង់ខ្លៅតាមរយៈការជួយពួកគេឱ្យក្លាយជាសមាជិកសង្គម ឬសហគមន៍ម្នាក់ដែលចេះច្នៃប្រឌិត គិតគូរបានហ្មត់ចត់ មានសេរីភាពពេញលេញ មានភាពក្លាហាន និងមានទំនួលខុសត្រូវពិតប្រាកដ។
- សិស្សរៀនធ្វើការជាមួយគ្នា រៀនស្តាប់មតិអ្នកដទៃ។ សិស្សចាប់ផ្តើមទទួលស្គាល់ថាមតិអ្នកដទៃអាចប្លែកពីមតិរបស់ខ្លួន ជួនកាលត្រឹមត្រូវជាងមតិរបស់ខ្លួន ឬជួនកាលអាចខុសឆ្គងក៏មាន ។ ត្រង់នេះតម្រូវឱ្យពួកគេពិភាក្សា សំយោគមតិផ្សេងទៀតដែលមានលក្ខណៈសុក្រឹតជាង។

ភាពខុសគ្នារវាងគោលវិធីសិស្សមជ្ឈមណ្ឌល និងគ្រូមជ្ឈមណ្ឌល៖

- សិស្សមជ្ឈមណ្ឌល៖ សកម្មភាពក្នុងថ្នាក់ប្រមូលផ្តុំលើសិស្ស ។
- គ្រូមជ្ឈមណ្ឌល៖ សកម្មភាពក្នុងថ្នាក់ប្រមូលផ្តុំលើគ្រូ។

ខាងក្រោមនេះជាសកម្មភាពសំខាន់ៗ នៃភាពខុសគ្នារវាងសិស្សមជ្ឈមណ្ឌល និងគ្រូមជ្ឈមណ្ឌល៖

| សិស្សមជ្ឈមណ្ឌល | គ្រូមជ្ឈមណ្ឌល |
|---|---|
| • សិស្សកសាងចំណេះដឹងតាមរយៈគ្រូណែនាំឱ្យធ្វើសកម្មភាពដោយខ្លួនឯងផ្ទាល់។<br>• សិស្សធ្វើសកម្មភាពតាមក្រុមតូចៗ<br>• គ្រូណែនាំបង្ហាញផ្លូវហើយសិស្សជាអ្នកអនុវត្ត។<br>• សិស្សយល់ហើយមានប្រតិកម្មតបវិញ។<br>• តំណាងក្រុមឡើងរាយការណ៍លទ្ធផល | • គ្រូពន្យល់ណែនាំធ្វើពិសោធន៍សរសេរលើក្តារខៀនហៅមេរៀនឱ្យសិស្សសរសេរដាក់ក្នុងសៀវភៅសរសេរ។<br>• សិស្សគ្រាន់តែជាអ្នកចាំស្តាប់ការពន្យល់ណែនាំរបស់គ្រូ ហើយចម្លងខ្លឹមសារចូលទៅក្នុងសៀវភៅ។ ការងាររបស់ក្រុមខ្លួន (ផ្ទាល់មាត់ ឬលើ ក្តារខៀន)។<br>• គ្រូសរុបលទ្ធផលវាយតម្លៃ និងសន្និដ្ឋានលើការងាររបស់សិស្ស។ |

សរុបសេចក្តីមកគោលវិធីសិស្សមជ្ឈមណ្ឌលតម្រូវឱ្យអ្នកសិក្សាប្រើប្រាស់ខួរក្បាលរបស់ពួកគេក្នុងការគិតពិចារណា និងទទួលស្គាល់អ្វីខុសអ្វីត្រូវ។ ការទុកខួរក្បាលឱ្យនៅស្ងៀមមានន័យថាការមករៀនចាំតែទទួលយកចំណេះពីគ្រូតែប៉ុណ្ណោះ។ ការរៀនបែបនេះមិនសូវមានប្រសិទ្ធភាពទេវាធ្វើឱ្យអ្នកសិក្សា ស្ពឹកស្រពន់ និងពុំសូវមានការរីកចម្រើនឡើយ។ ផ្ទុយទៅវិញការធ្វើឱ្យខួរក្បាលអ្នកសិក្សាមានចលនា គឺជាសេចក្តីត្រូវការដ៏ធំបំផុតក្នុងការអប់រំ ព្រោះថាស្តែងចេញពីចំណេះដែលសិស្សទទួលបានពីគ្រូពួកគេអាចស្វែងយល់នូវអ្វីៗដែលនៅជុំវិញខ្លួនគេបានទៀតផង (Rogers,2002)។

## ៨.របកគំហើញ និងការវិភាគទិន្នន័យ

### ៨.១ ទស្សនៈរបស់គ្រូឧទ្ទេស និងគរុនិស្សិតនៃវិទ្យាស្ថានជាតិអប់រំ

### ៨.១.១ របកគំហើញ៖ ទស្សនៈរបស់គរុនិស្សិតចំពោះការអនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌល

**គ្រូឧទ្ទេសរបស់អ្នកបានអនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌលគ្រប់មេរៀន**



ក្រាហ្វិកខាងលើបង្ហាញឱ្យឃើញថា៖មានគរុនិស្សិតចំនួន២,០៦%បានបដិសេធដាច់ខាត ថាគ្រូមិនប្រើគោលវិធីសិស្សមជ្ឈមណ្ឌលក្នុងការបង្រៀនទេ១២,៣៧%មិនបានអនុវត្ត ៣៨,០២% គ្រូប្រើធម្មតា៥៥,៣៦%យល់ស្របថាគ្រូប្រើ និង៦,១៩%ទៀតយល់ស្របថាគ្រូប្រើជាប្រចាំ។

**គ្រូឧទ្ទេសរបស់អ្នកបានអនុវត្តជំហានទាំង៥**




ក្រាហ្វិកនេះបង្ហាញថា ៖មានគរុនិស្សិតចំនួន៥,១៥% មិនយល់ស្របខ្លាំងថាគ្រូមិន បានប្រើគ្រប់៥ជំហានក្នុងការបង្រៀនតាមបែបសិស្សមជ្ឈមណ្ឌល ៨,២៥%មិនយល់ស្រប ៣៦,០៨%យល់ស្រប ៣២,៩៩%យល់ស្របជាបង្គួរ និង១៧,៥៣%ទៀតយល់ស្របខ្លាំង។

**គ្រូឧទ្ទេសរបស់អ្នកមានជំនាញសម្របសម្រួលសកម្មភាពបង្រៀនតាមបែប សិស្សមជ្ឈមណ្ឌល**




ក្រាហ្វិកបញ្ជាក់ឱ្យឃើញថា ៖ គរុនិស្សិតចំនួន៧,២២% មិនបានយល់ស្របថាគ្រូបានប្រើ វិធីសាស្ត្រលាយឡំគ្នា (គ្រូមជ្ឈមណ្ឌល+សិស្សមជ្ឈមណ្ឌល) ដើម្បីបង្រៀន ២២,៦៨% បាន យល់ស្រប ៥៦,៧០%បានយល់ស្របបង្គួរ,និង១៣,៤០%បានយល់ស្របខ្លាំង។

### គ្រូឧទ្ទេសរបស់អ្នកបានប្រើសម្ភារឧបទេសសមស្រប




ក្រាហ្វិកបង្ហាញឱ្យឃើញថា៖ក្នុងចំណោមគរុនិស្សិតចំនួន១០០នាក់ មាន៣,១៦%មិនយល់ស្របខ្លាំងថា គ្រូរបស់ពួកគាត់មិនបានប្រើប្រាស់សម្ភារឧបទេសត្រឹមត្រូវ ១៤,៧៣%មិនយល់ស្រប ៤៥,២៦%យល់ស្រប ២៦,៣១%យល់ស្របបង្គួរ និង១០,៥២%ទៀតយល់ស្របខ្លាំង។

### ថ្នាក់រៀនរបស់អ្នកមានលក្ខណៈសមស្របសម្រាប់អនុវត្តសិស្សមជ្ឈមណ្ឌល




ក្នុងការធ្វើអង្កេតលើគរុនិស្សិតចំនួន១០០នាក់បានបង្ហាញដូចក្រាហ្វិក៖ មានគរុនិស្សិតចំនួន១៧,៥២% យល់ថាបរិស្ថានបន្ទប់រៀនរបស់គាត់មិនសមស្របខ្លាំងក្នុងការអនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌល ៣១,៩៦%មិនយល់ស្រប ២៦,៨០%យល់ស្រប ១៧,៥៣%យល់ស្របបង្គួរ និង៦,១៩%ទៀតយល់ស្របខ្លាំង។

### ចំនួនសិស្សក្នុងថ្នាក់រៀនសមស្របទៅនឹងការអនុវត្តសិស្សមជ្ឈមណ្ឌល




ការធ្វើអង្កេតលើគរុនិស្សិតចំនួន១០០នាក់បានបង្ហាញថា៖ មានគរុនិស្សិតចំនួន២៧,២៧% បានយល់ថាទំហំបន្ទប់រៀនរបស់គាត់មិនសមស្របខ្លាំងក្នុងការអនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌល ២៦,២៦%មិនយល់ស្រប ២០,២០%យល់ស្រប ១៨,១៨%យល់ស្របបង្គួរ និង៨,០៨% ទៀតយល់ស្របខ្លាំង។

### តើសកម្មភាពអ្វីខ្លះដែលអ្នកធ្វើពេលគ្រូឧទ្ទេសរបស់អ្នកប្រើសិស្សមជ្ឈមណ្ឌល

### ការពិភាក្សាជាក្រុមធំ(មួយក្រុមលើសពី១០នាក់)




តាមការវិភាគខាងលើបានបង្ហាញឱ្យឃើញថា៖ គរុនិស្សិតដែលយល់ឃើញថាគ្រូបានកំណត់ក្រុមពិភាក្សាក្រុមធំ(ច្រើនជាង១០នាក់ក្នុង១ក្រុម ៗ)នោះមានគរុនិស្សិតចំនួន១២,៣៧% យល់ថាតិចបំផុត ២១,៦៥%យល់ថាតិច ៣០,៩៣%យល់ថាល្មម ២២,៦៨%យល់ថាច្រើន និង ១២,៣៧%ទៀតយល់ថាច្រើនបំផុត។

### ការពិភាក្សាក្រុមមធ្យម(៦- ១០នាក់)




តាមការវិភាគខាងលើបានបង្ហាញឱ្យឃើញថា ៖ គរុនិស្សិតដែលយល់ឃើញថាគ្រូបានកំណត់ក្រុមពិភាក្សាក្រុមមធ្យម(ពី៦ដល់១០នាក់ក្នុង១ក្រុមៗ)នោះមានគរុនិស្សិតចំនួន៧,១៤% ដែលយល់ថាតិចបំផុត ១៦,៣៣%យល់ថាតិច ៣៤,៦៩%យល់ថាល្មម ៣៤,៦៩%យល់ថាច្រើន និង៧,១៤%ទៀតយល់ថាច្រើនបំផុត។

**ការពិភាក្សាក្រុមតូច(៣-៥នាក់)**




តាមការវិភាគខាងលើបានបង្ហាញឱ្យឃើញថា ៖ គរុនិស្សិតដែលយល់ឃើញថាគ្រូបានកំណត់ក្រុមពិភាក្សាក្រុមតូច(ពី៣ដល់៥នាក់ក្នុង១ក្រុមៗ)នោះមានគរុនិស្សិតចំនួន២%យល់ថាតិចបំផុត ១២%យល់ថាតិច ៣៧%យល់ថាល្មម ៣៤ %យល់ថាច្រើន និង១៥%ទៀតយល់ថាច្រើនពេក ។

**ការពិភាក្សាជាគូ(២ នាក់)**




តាមការវិភាគខាងលើបានបង្ហាញឱ្យឃើញថា ៖ គរុនិស្សិតដែលយល់ឃើញថាគ្រូបានកំណត់ក្រុមពិភាក្សា២នាក់ក្នុង១ក្រុមៗនោះមានគរុនិស្សិតចំនួន១៩,៣៩%យល់ថាតិចបំផុត ២៤,៤៩%យល់ថាតិច ២៨,៥៧%យល់ថាល្មម ២៣,៤៧%យល់ថាច្រើន និង៤,០៨%ទៀតយល់ថាច្រើនបំផុត។

**ការសួរឆ្លើយម្នាក់ៗ**




តាមការវិភាគខាងលើបានបង្ហាញឱ្យឃើញថា ៖ គរុនិស្សិតដែលយល់ឃើញថាគ្រូបានកំណត់

ក្រុមពិភាក្សា១នាក់ក្នុងមួយក្រុមមានគរុនិស្សិតចំនួន ៦,១៩% យល់ថាតិចបំផុត ៧,២២% យល់ថាតិច ២២,៦៩%យល់ថាល្មម ៤១,២៥%យល់ថាច្រើន និង២២,៦៩% ទៀតយល់ថាច្រើនបំផុត។

**តើការបង្រៀនបែបសិស្សមជ្ឈមណ្ឌលបានជះឥទ្ធិពលដល់ការសិក្សារបស់អ្នកយ៉ាងដូចម្តេច?ធ្វើឱ្យអ្នកយល់ច្បាស់នូវខ្លឹមសារមេរៀន**




តាមការវិភាគខាងលើបានបង្ហាញឱ្យឃើញថា ៖គរុនិស្សិតដែលយល់ឃើញថាសិស្សយល់បានច្បាស់រាល់មេរៀនដែលគ្រូបានអនុវត្តតាមគោលវិធីសិស្សមជ្ឈមណ្ឌលមានគរុនិស្សិតចំនួន៣%យល់ថាតិចបំផុត ៥%យល់ថាតិច ២៤%យល់ថាល្មម ៥៥% យល់ថាច្រើន និង១៣% ទៀតយល់ថាច្រើនបំផុត ។

**បង្កើនចំណេះដឹងរបស់អ្នកតាមរយៈការពិភាក្សាផ្លាស់ប្តូរយោបល់**




តាមការវិភាគខាងលើបានបង្ហាញឱ្យឃើញថា ៖ គរុនិស្សិតដែលយល់ឃើញថាសិស្សបានទទួលចំណេះដឹងបន្ថែមតាមរយៈការពិភាក្សាក្រុមមានគរុនិស្សិតចំនួន២,០២% យល់ថាតិចបំផុត ៣,០៣%យល់ថាតិច ១៦,១៦%យល់ថាល្មម ៥៧,៥៨%យល់ថាច្រើន និង២១,២១%ទៀតយល់ថាច្រើនបំផុត។

## ធ្វើឱ្យអ្នករៀនសូត្រពីមិត្តរួមថ្នាក់




តាមការវិភាគខាងលើបានបង្ហាញឱ្យឃើញថា ៖ គរុនិស្សិតដែលយល់ឃើញថាសិស្ស បានទទួលចំណេះដឹងពីមិត្តភ័ក្តិមានគរុនិស្សិតចំនួន២%យល់ថាតិចបំផុត ៤%យល់ថាតិច ១៨% យល់ថាល្មម ៥៦%យល់ថាច្រើន និង២០,២០%ទៀតយល់ថាច្រើនបំផុត។

## ធ្វើឱ្យមិត្តរួមថ្នាក់បង្កើនចំណេះដឹង




តាមការវិភាគខាងលើបានបង្ហាញឱ្យឃើញថា ៖ គរុនិស្សិតដែលយល់ឃើញថាសិស្ស បានលើកទឹកចិត្តឱ្យជួយមិត្តភ័ក្តិមានគរុនិស្សិតចំនួន៦,០៦%យល់ថាតិច ២០,២០%យល់ថាល្មម ៥៨,៥៩%យល់ថាច្រើននិង១៥,១៥%ទៀតយល់ថាច្រើនបំផុត។

## ជួយលើកទឹកចិត្តអ្នកឱ្យមានការប្រកួតប្រជែង




តាមការវិភាគខាងលើបានបង្ហាញឱ្យឃើញថា ៖ គរុនិស្សិតដែលយល់ឃើញថាគោលវិធីសិស្សមជ្ឈមណ្ឌលបានលើកទឹកចិត្តឱ្យសិស្សមានការប្រកួតប្រជែងមានគរុនិស្សិតចំនួន៣% យល់ថាតិចបំផុត ៦,០០%យល់ថាតិច ២៤,០០%យល់ថាល្មម ៥៣,០០%យល់ថាច្រើន និង ១៤,០០%ទៀតយល់ថាច្រើនបំផុត។

## ជួយអ្នកឱ្យមានភាពម្ចាស់ការលើខ្លួនឯង




តាមការវិភាគខាងលើបានបង្ហាញឱ្យឃើញថា ៖ គរុនិស្សិតដែលយល់ឃើញថាគោលវិធីសិស្សមជ្ឈមណ្ឌលបានធ្វើឱ្យសិស្សមានភាពម្ចាស់ការ មានគរុនិស្សិតចំនួន ៨% យល់ថាតិច ២៨%យល់ថាល្មម ៥១%យល់ថាច្រើន និង១៣%ទៀតយល់ថាច្រើនបំផុត។

## ៧.ទំនុកចិត្តក្លាហានរបស់អ្នកក្នុងការចែករំលែកគំនិត




តាមការវិភាគខាងលើបានបង្ហាញឱ្យឃើញថា ៖ គរុនិស្សិតដែលយល់ឃើញថា គោលវិធីសិស្សមជ្ឈមណ្ឌលបានលើកទឹកចិត្តយើងឱ្យចែករំលែកចំណេះដឹងដល់មិត្តភ័ក្តិមានគរុនិស្សិតចំនួន២%ដែលយល់ថាតិចបំផុត ១%យល់ថាតិច ១២%យល់ថាល្មម ៥៤% យល់ថាច្រើន និង ៣១ % ទៀតយល់ថាច្រើនបំផុត ។

### ៨.១.២.ការវិភាគ ៖ ទស្សនៈរបស់គរុនិស្សិតចំពោះការអនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌល

តាមរយៈការអង្កេត គរុនិស្សិតកម្រិតឧត្តម(បរិញ្ញា+១)ជំនាន់ទី១៦ បានរកឃើញថាមានគរុនិស្សិតចំនួន ៨៥ % ឆ្លើយថា គ្រូឧទ្ទេសទាំងអស់បានអនុវត្ត គោលវិធីសិស្សមជ្ឈមណ្ឌលគ្រប់មេរៀន។ប៉ុន្តែក៏មានគរុនិស្សិតចំនួន១៥% ដែរដែលអះអាងថា គ្រូឧទ្ទេសមិនបានអនុវត្ត។ លទ្ធផលនេះ សបញ្ជាក់ឱ្យឃើញថា គរុនិស្សិតផ្នែកវិទ្យាសាស្ត្រសង្គម ភាគច្រើនយល់ថា គ្រូឧទ្ទេសរបស់វិទ្យាស្ថានជាតិអប់រំ មានការយល់ដឹង និងប្រើប្រាស់គោលវិធីសិស្សមជ្ឈមណ្ឌលនៅគ្រប់មេរៀន។

លំនាំនៃការបង្រៀនគ្រូចាំបាច់ត្រូវរៀបចំកិច្ចតែងការបង្រៀន និងគោរពតាមប្រាំជំហាន ទោះបីគ្រូអនុវត្តវិធីសាស្ត្រគ្រូមជ្ឈមណ្ឌល ឬសិស្សមជ្ឈមណ្ឌល។ ហេតុនេះបានជាធ្វើឱ្យការចង់ដឹងពីគរុនិស្សិត ស្តីអំពីសកម្មភាពបង្រៀនរបស់គ្រូឧទ្ទេស ។ ទន្ទឹមនេះដែរការស្រាវជ្រាវបានរកឃើញថា ១៣% មិនយល់ស្របថា គ្រូឧទ្ទេសអនុវត្តតាមប្រាំជំហាននោះទេ។ ក៏ប៉ុន្តែក្នុងនោះមាន៨៧ %យល់ ស្របថា គ្រូឧទ្ទេសបានអនុវត្តតាមប្រាំជំហាននៃកិច្ចតែងការបានត្រឹមត្រូវ។

តាមរបកគំហើញនេះធ្វើឱ្យគរុនិស្សិតបានយល់ឃើញថា គ្រូបង្រៀនមានការទទួលខុសត្រូវ និងមានសមត្ថភាពពេញលេញភាគច្រើនក្នុងការអនុវត្តវិធីសាស្ត្របង្រៀន។

លទ្ធផលបានបង្ហាញថាគរុនិស្សិត ៩៣ % យល់ថាគ្រូឧទ្ទេសរបស់ពួកគេមានជំនាញសម្របសម្រួលសកម្មភាពបង្រៀនតាមបែបសិស្សមជ្ឈមណ្ឌល រីឯគរុនិស្សិតដែលមិនស្របនោះមានតែ៧% ប៉ុណ្ណោះ។

តាមរយៈការវិភាគទិន្នន័យរកឃើញថា គ្រូឧទ្ទេសភាគច្រើនមានជំនាញពិតប្រាកដក្នុងការដឹកនាំសកម្មភាពបង្រៀន និងផ្ដល់ពុទ្ធិដ៏រឹងមាំលើសមត្ថភាពជំនាញ នឹងធ្វើឱ្យគរុនិស្សិតមានឥរិយាបថល្អថ្លៃថ្នូរក្នុងសង្គមថែមទៀតផង ។

ចំពោះការប្រើប្រាស់សម្ភារឧបទេសក្នុងម៉ោងបង្រៀនរបស់គ្រូឧទ្ទេស គរុនិស្សិត ១៨% បានឆ្លើយមិនយល់ស្រប ។ ប៉ុន្តែគរុនិស្សិត ៨២% បានបង្ហាញពីទស្សនរបស់ពួកគាត់ថាៈ អ្នកគ្រូ លោកគ្រូមានសម្ភារឧបទេស ប្រើប្រាស់ក្នុងម៉ោងបង្រៀនដូចជាក្រដាស ផ្ទាំង រូបភាព ។ល។

នៅក្នុងថ្នាក់រៀនរបស់គរុនិស្សិតនៅវិទ្យាស្ថានជាតិអប់រំ មានលក្ខណៈមិនទាន់សមស្របឆ្លើយតបទៅនឹងចំនួនសិស្សមាន ៤៩ % ។រីឯគរុនិស្សិត៥១ % ទៀតមានទស្សនថាៈ ថ្នាក់រៀនអាចអនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌលបានទៅតាមបរិបទរបស់វិទ្យាស្ថានជាតិអប់រំ។

ក្នុងការបង្រៀនលើឯកទេសនីមួយៗគ្រូឧទ្ទេសចាំបាច់ត្រូវប្រើប្រាស់សម្ភារឧបទេសឆ្លើយតបទៅនឹងខ្លឹមសានៃការបង្រៀន៕ ហេតុនេះហើយបានជាការប្រមូលព័ត៌មាន ពីគរុនិស្សិតអាចទទួលបានថាៈ ៨២% យល់ស្របការបង្រៀនរបស់គ្រូដែលប្រើសម្ភារឧបទេសជាញឹកញាប់។ ក៏ប៉ុន្តែក្នុងចំណោមគរុនិស្សិតយើង ១៨% បានឆ្លើយថាគ្រូឧទ្ទេសរបស់ពួកគេមិនទាន់ប្រើប្រាស់សម្ភារឧបទេសគ្រប់ពេលវេលានៅឡើយទេ។

បរិយាកាសថ្នាក់រៀនមានលក្ខណៈមិនទាន់សមស្របនៅឡើយតាមទស្សនៈរបស់គរុនិស្សិតដែលឆ្លើយបែបនេះមាន៤៩%។ ចំណែកគរុនិស្សិត៥១%យល់ឃើញថាៈថ្នាក់រៀនមានលក្ខណៈសមស្របដែលអាចឱ្យគ្រូឧទ្ទេសអនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌលបាន និងបត់បែនទៅតាមបរិបទនៃប្រទេសយើងដែលកំពុងអភិវឌ្ឍន៍។

គ្រូឧទ្ទេសមានស្មារតីទទួលខុសត្រូវផ្ទាល់ទោះបីពួកគាត់ជួបការលំបាកយ៉ាងណាក៏ដោយគ្រូបង្រៀនយើងនៅតែខិតខំប្រឹងប្រែងរៀបចំសម្ភារឧបទេសបង្រៀនដូចជាៈ ប្រដាប់បំពងសំឡេង Laptop ជាជំនួយក្នុងការបង្រៀនរបស់ពួកគាត់ឱ្យទទួលបាននូវគុណភាព។

យោងទៅតាមការសង្កេតថ្នាក់ និងការអង្កេតផ្ទាល់ក្នុងថ្នាក់រៀនមានចំនួនសិស្សច្រើនអង្គុយមានលក្ខណៈចង្អៀតជួបការលំបាកក្នុងការបែងចែកក្រុមពិភាក្សា ហេតុនេះហើយបានជាមានគរុនិស្សិតចំនួន ៦៤%មានទស្សនៈថា ៖ ការអនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌលមិនទាន់បានបង្កលក្ខណៈងាយស្រួលដល់គ្រូឧទ្ទេស និងគរុនិស្សិតនៅឡើយ។ ម្យ៉ាងទៀតដោយយោងលើសភាពជាក់ស្តែងគរុនិស្សិត ៤៦% បានឯកភាពថា ៖ ចំនួនសិស្សសមស្របឆ្លើយតបទៅនឹងការ

អនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌល។

គ្រូឧទ្ទេសនៅវិទ្យាស្ថានជាតិអប់រំ បានរៀបចំសកម្មភាពបង្រៀនដោយចែកក្រុមពិភាក្សាជាក្រុមធំ ក្នុងមួយក្រុមលើសពី១០នាក់។ ការបែងចែកក្រុមពិភាក្សាបែបនេះគរុនិស្សិត៦៦% បានផ្តល់ព័ត៌មានថាគ្រូឧទ្ទេសបានធ្វើសកម្មភាពនេះច្រើន។ គរុនិស្សិត៣៤% យល់ឃើញថា៖ ការអនុវត្តមិនទាន់សមស្របចំពោះការបែងចែកក្រុមធំនេះទេ។

ការអនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌលដែលធ្វើការពិភាក្សាក្រុមមធ្យមពី៦-១០នាក់នោះគរុនិស្សិត៧៧% យល់ឃើញថាសមរម្យអាចធ្វើការពិភាក្សាផ្លាស់ប្តូរយោបល់គ្នាទៅវិញទៅមក។ ក៏ប៉ុន្តែទោះបីមានចំនួនច្រើនភាគរយបានគាំទ្រក៏ដោយ ក៏នៅមានគរុនិស្សិតមួយចំនួនស្មើនឹង ២៣% មិនបានឯកភាពលើការអនុវត្តបែបនេះនៅឡើយ។

ក្រៅពីការពិភាក្សាក្រុមធំ (៦-១០នាក់) (លើសពី១០នាក់) គ្រូឧទ្ទេសរបស់យើងបានឱ្យគរុនិស្សិតពិភាក្សាក្រុមតូច(ពី៣-៥នាក់)ដាក់បញ្ហាឱ្យសិស្ស ដោះស្រាយជាបុគ្គល និងការងារក្រុម ដោយគោរពតាមគោលការណ៍ ផ្តល់សិទ្ធិឱ្យសិស្សបញ្ចេញមតិយោបល់។ គរុនិស្សិត៨៦% បានអនុវត្តការងារក្រុម ។ រីឯ១៤%មិនទាន់អនុវត្តបានល្អនៅក្នុងលំនាំនៃការបង្រៀន។ ហេតុនេះហើយបានជាលទ្ធផល ទទួលមក អាចបកស្រាយបានថា ៖ គ្រូមួយចំនួនធំបានអនុវត្តត្រឹមត្រូវមានវិធីសាស្ត្រល្អ។ គរុនិស្សិតទទួលយក ពុទ្ធិ និងព័ត៌មានទាំងនោះដើម្បីចងចាំបានយូរ ពង្រីកចំណេះដឹង តាមការចាត់តាំងរបស់សាស្ត្រាចារ្យ ពួកគាត់បានជ្រើសរើស និងបត់បែនទៅតាមខ្លឹមសារមេរៀន។

លើសពីនេះទៅទៀតគ្រូឧទ្ទេសបានឱ្យគរុនិស្សិតធ្វើការសន្ទនាជាដៃគូរ(២នាក់) ផ្លាស់ប្តូរគំនិតគ្នាអភិវឌ្ឍបំណិនគិតចេះធ្វើការពិចារណា ៥៦% បានអនុវត្តក្នុងពេលបង្រៀន។ គរុនិស្សិតធ្វើការពិភាក្សាជាដៃគូក្នុងថ្នាក់រៀនចំនួន៤៤%ពួកគេយល់ឃើញថា៖ សកម្មភាពបែបនេះគ្រូឧទ្ទេសយើងមិនទាន់បានអនុវត្តល្អនៅឡើយទេ។

រីឯការសួរឆ្លើយសំណួរជាលក្ខណៈបុគ្គល គ្រូឧទ្ទេសភាគច្រើនបានអនុវត្តពេលរំលឹកមេរៀនចាស់ និងពង្រឹងចំណេះដឹងថ្មី ក្នុងជំហានទី៤ នៃកិច្ចតែងការបង្រៀន។ ការអនុវត្តបែបនេះមានគរុនិស្សិត៨៦% យល់ថាគ្រូរបស់ពួកគេបានអនុវត្តយ៉ាងត្រឹមត្រូវ។

គរុនិស្សិត១៤%យល់ថាការអនុវត្តបែបនេះបានលទ្ធផលតិចតួចបំផុតនៅក្នុងការផ្តល់ចំណេះដឹង ចំណេះធ្វើ ឥរិយាបថដល់សិស្ស។ តាមមតិយោបល់របស់គរុនិស្សិត ពួកគេយល់ថា៖ ការអនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌលនៅវិទ្យាស្ថានជាតិអប់រំ មានអត្ថប្រយោជន៍យ៉ាងខ្លាំងចំពោះពួកគេជាគរុនិស្សិត។

នៅស្ថាប័ន ឬវិទ្យាស្ថានបណ្តុះបណ្តាលគ្រូបង្រៀនមានវិធីសាស្ត្រជាច្រើនចាំបាច់លើក

យកមកបង្រៀនដល់និស្សិតក៏ប៉ុន្តែប្រធានបទរបស់យើងគឺផ្ដោតការបង្រៀនតាមគោលវិធីសិស្សមជ្ឈមណ្ឌល។ ដូចនេះតាមលទ្ធផលនៃការអង្កេតបានឱ្យដឹងថាៈការបង្រៀនតាមបែបសិស្សមជ្ឈមណ្ឌលបានជះឥទ្ធិពលយ៉ាងខ្លាំងដល់ការសិក្សាដូចជា ធ្វើឱ្យពួកគេយល់បានកាន់តែច្បាស់នូវខ្លឹមសារមេរៀន។ គរុនិស្សិត៩២% យល់ឃើញថាការបង្រៀនតាមបែបនេះបានបណ្ដុះឱ្យសិស្សនូវចំណង់ចំណូលចិត្តស៊ីជម្រៅលើខ្លឹមសារបានល្អជាងវិធីផ្សេងៗ។ មតិផ្ទុយ មានគរុនិស្សិត ៨% ប៉ុណ្ណោះ ដែលបានយល់ថា មិនបានឱ្យសិស្សយល់ពីខ្លឹមសារមេរៀន។

ម្យ៉ាងទៀតនោះគរុនិស្សិតបានបង្កើនចំណេះដឹងរបស់គេតាមរយៈការពិភាក្សាផ្លាស់ប្តូរយោបល់សិក្សាពីគ្នាដកបទពិសោធពីគ្នាមាន៩៥%។ ទស្សនៈរបស់គរុនិស្សិតមួយចំនួនតូចស្មើនឹង៥% យល់ឃើញថាការអនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌលតាមរយៈការពិភាក្សាក្រុមមិនបានបង្កើនចំណេះដឹង ចំណេះ ធ្វើ និងបំណិនដល់ពួកគេទេ។

ការបង្រៀន និងរៀនតាមបែបគោលវិធីសិស្សមជ្ឈមណ្ឌលធ្វើឱ្យគរុនិស្សិតបានរៀនសូត្រដកបទពិសោធ និងអាចធ្វើការប្រៀបធៀបចំណេះដឹងរបស់ខ្លួនទៅនឹងមិត្តរួមថ្នាក់បានត្រឹមត្រូវមានរហូតដល់៩៤%។ រីឯគរុនិស្សិតមិនបានទទួលចំណេះដឹងពីមិត្តរួមថ្នាក់ក្នុងពេលពិភាក្សាក្រុមនោះមានចំនួនតិចតួចបំផុតគឺ ៦%។

យើងអាចនិយាយបានថាក្នុងថ្នាក់រៀនមួយ ដែលមានសភាពរស់រវើកចេះដោះស្រាយបញ្ហា និងចេះបកស្រាយអំណះអំណាងលើ គំនិត យោបល់ របស់ក្រុមនីមួយៗបានធ្វើឱ្យមិត្តរួមថ្នាក់បង្កើនចំណេះដឹងទ្វេដង ហើយចងចាំខ្លឹមសារមេរៀនបានល្អជាពិសេស គឺបានបណ្ដុះចតុស្តម្ភនៃការអប់រំដល់គរុនិស្សិតផង ពួកគេបានយល់ស្របចំពោះការអនុវត្តនេះមានចំនួន៧៤%។ ចំណែកឯគរុនិស្សិតដែលមិនបានបង្កើនចំណេះដឹងតាមរយៈមិត្តភ័ក្តិក្នុងថ្នាក់មានចំនួន ២៦%។

ការផ្ដល់ឱកាសដល់សិស្ស និងការទទួលនូវស្នាដៃ តាមរយៈការលើកសរសើរ និងការលើកទឹកចិត្តឱ្យមានការចង់ចេះចង់ដឹង មានការប្រកួតប្រជែងដណ្ដើមស្នាដៃ គរុនិស្សិតចំនួន៩១% យល់ថាការជួយលើកទឹកចិត្តពួកគេឱ្យមានការប្រកួតប្រជែងពិតជាមានឥទ្ធិពលយ៉ាងខ្លាំងក្នុងការអនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌល។ ទោះបីការ ស្វែងរកព័ត៌មានបានយ៉ាងនេះក៏ដោយក៏នៅមានគរុនិស្សិត៩%យល់ថាការអនុវត្តនេះមិនទាន់ទទួលលទ្ធផលល្អទេ។ តាមទិន្នន័យខាងលើនេះ អាចដឹងបានថា ៖ គ្រូផ្នែកវិទ្យាសាស្ត្រសង្គមនៃវិទ្យាស្ថានជាតិអប់រំមានសមត្ថភាពជំនាញគរុកោសល្យ ព្រមទាំងក្រមសីលធម៌ផងដែរ។

គោលបំណងក្នុងការអនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌលក្នុងម៉ោងបង្រៀនចង់បណ្ដុះភាពម្ចាស់ការរបស់គរុនិស្សិតគ្រប់រូបឱ្យមានស្មារតីភ្ញាក់រលឹកចេះស្រាវជ្រាវ មានភាពជឿជាក់ បំពេញនូវចំណីអារម្មណ៍ឱ្យបានគ្រប់គ្រាន់ហើយយើងក៏ទទួលបានពីការអង្កេតជាមួយគរុនិស្សិតចំនួន

១០០នាក់ ដែល៦៤%បានទទួលស្គាល់ថា៖ពួកគេមានភាពម្ចាស់ការលើខ្លួនឯងពិតប្រាកដមែន។ ប៉ុន្តែក្រោយពីការបង្រៀនរបស់គ្រូឧទ្ទេសនៅមានគរុនិស្សិត៣៦% មិនទាន់ទទួលយកឥទ្ធិពលវិជ្ជមានពីគោលវិធីសិស្សមជ្ឈមណ្ឌលនៅឡើយ។

គោលវិធីសិស្សមជ្ឈមណ្ឌលធ្វើឱ្យសិស្សមានភាពក្លាហានឡើងបញ្ចេញមតិយោបល់ ហ៊ានឡើងជជែកវែកញែករកហេតុផល ព្រមទាំងបានចែករំលែកគំនិត បទពិសោធន៍ល្អៗ រិះគន់ស្ថាបនាគ្នាទៅវិញទៅមក មានបរិយាកាសស្និទ្ធស្នាល មិនរើសអើង សាមគ្គីភាពល្អ ។

គរុនិស្សិតដែលមានទស្សនៈដូចបានរៀបរាប់ខាងលើមាន៩៧% រីឯ៣%យល់ឃើញថា ៖ មិនបានផ្តល់ និងពង្រឹងភាពក្លាហានក្នុងការចែករំលែកគំនិតគ្នាក្នុងពេលសិក្សានោះទេ។

**៨.២ ទស្សនៈរបស់គ្រូឧទ្ទេសចំពោះការអនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌល**

**៨.២.១** របកគំហើញ៖ ទស្សនៈនៃការអនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌលរបស់គ្រូឧទ្ទេស

**ការអនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌល**




ការធ្វើវិភាគបានឱ្យដឹងថាក្នុងចំណោមគ្រូចំនួន១០នាក់មានគ្រូ ៣០ %បានអនុវត្តម្តងម្កាល ៦០%ញឹកញាប់ និង១០% ទៀតអនុវត្តគ្រប់ម៉ោង។

**ជំហានក្នុងការអនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌល**




ការធ្វើវិភាគបានឱ្យដឹងថាក្នុងចំណោមគ្រូចំនួន១០នាក់មាន ៨០%បានអនុវត្តពីជំហានទី១ ដល់ជំហានទី៥និង ២០%ទៀតបានអនុវត្តតែជំហានទី៣និងទី៥។

## សកម្មភាពគ្រូក្នុងពេលបង្រៀនតាមបែបសិស្សមជ្ឈមណ្ឌល




ការធ្វើវិភាគបានឱ្យដឹងថាក្នុងចំណោមគ្រូចំនួន១០នាក់មានគ្រូចំនួន១០%បានផ្តោតទាំងសកម្មភាពគ្រូនិងសិស្ស ៣០%បានសួរ និងចែកក្រុមពិភាក្សា ១០%បានចែកក្រុមពិភាក្សានិងដាក់ការងារផ្ទះ ១០%បានជួយតម្រង់ទិសសិស្ស ២០%បានបង្ហាញរូបភាពឱ្យសិស្សពិភាក្សា ២០%ផ្តោតទៅលើគោលវិធីសិស្សមជ្ឈមណ្ឌល។

## ការប្រើសម្ភារក្នុងការបង្រៀន




ការធ្វើវិភាគបានឱ្យដឹងថាក្នុងចំណោមគ្រូចំនួន១០នាក់មានគ្រូចំនួន៦០%ដែលបានប្រើសម្ភារឧបទេសម្តងម្កាល ១០%ប្រើញឹកញាប់ និង៣០%ទៀតប្រើគ្រប់មេរៀន។

## សម្ភារឧបទេសដែលប្រើ




តាមដ្យាក្រាមខាងលើបានបង្ហាញថាក្នុងចំណោមគ្រូចំនួន១០នាក់ដែលបានធ្វើសម្ភាសន៍បានឱ្យដឹងថា គ្រូ១០%បានបង្រៀនឱ្យសិស្សស្រមើស្រមៃ និងបង្ហាញរូបភាព ៥០% បានប្រើក្រដាសកាតុង ស្កុត កន្ត្រៃ និងហ្វឺត ១០% បានប្រើក្រដាសមេរៀន រូបភាពនិងផែនទីក្នុងការបង្រៀន២០%បានប្រើគំនូរដែលគូរដោយសិស្សនិងគ្រូចំណែកឯ១០%ទៀតប្រើសៀវភៅសិស្ស។

### វិធីវាយតម្លៃសិស្ស




ការធ្វើវិភាគបានឱ្យដឹងថាក្នុងចំណោមគ្រូចំនួន១០នាក់មាន១០%មិនបានបញ្ចេញយោបល់ ៦០%ប្រើសំណួរផ្ទាល់មាត់ សំណួរសរសេរ និងស្រាវជ្រាវ។ ១០%សំណួរសរសេរ និងស្រាវជ្រាវ ១០%សង្ខេបមេរៀនតាមក្រុម ១០%ទៀតដាក់សំណួរសរសេរ ដាក់ការងារស្រាវជ្រាវ និងមើលលើសកម្មភាពជាក់ស្តែងរបស់សិស្ស។

### ការពិបាកក្នុងការអនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌល




ការធ្វើវិភាគ បានឱ្យដឹងថា ក្នុងចំណោមគ្រូចំនួន១០នាក់ មាន ៤០% មិនបញ្ចេញមតិយោបល់ ១០%ឆ្លើយថាមានការពិបាក ដូចជាពិបាកបែងចែកក្រុមក្នុងថ្នាក់មិនមានសណ្តាប់ធ្នាប់ ៤០%ដែលមានការពិបាកដូចជាខ្វះសម្ភារសិស្សច្រើនពេក និងមានពេលតិច ចំណែកឯ១០%ពិបាកដោយសារសិស្សច្រើនពេក ហើយម្យ៉ាងទៀតមានពេលតិច។

### មូលហេតុមិនប្រើគោលវិធីសិស្សមជ្ឈមណ្ឌល




ការធ្វើវិភាគបានឱ្យដឹងថា ក្នុងចំណោម គ្រូចំនួន១០នាក់ មាន៤០%មិនប្រើគោលវិធីសិស្សមជ្ឈមណ្ឌលដោយសារតែហេតុផលមួយចំនួន ដូចជាខ្វះសម្ភារសិស្សច្រើនពេក និងមានពេលតិចចំណែកឯ៦០%ទៀតបានប្រើគោលវិធីសិស្សមជ្ឈមណ្ឌល។

## មូលហេតុមិនប្រើសម្ភារឧបទេស




ការធ្វើវិភាគបានឱ្យដឹងថា ក្នុងចំណោមគ្រូឧទ្ទេសចំនួន១០នាក់ សុទ្ធតែបានប្រើប្រាស់សម្ភារឧបទេសទាំងអស់គ្នា។

## ការបញ្ចេញយោបល់លើការប្រើគោលវិធីសិស្សមជ្ឈមណ្ឌល




តាមការធ្វើស្ថិតិ លើគ្រូឧទ្ទេសចំនួន១០នាក់ យើងឃើញថាគ្រូមានមតិផ្សេងគ្នា៖ ១០%បានបញ្ចេញយោបល់ថាគ្រូមិនត្រូវធ្វើការបែងចែកជាក្រុម និងយកលទ្ធផលពីសិស្សប៉ុណ្ណោះទេ គ្រូគួរតែជំរុញសិស្សស្រាវជ្រាវផងដែរ ១០%ទៀតបានបញ្ចេញយោបល់ថាចំនួនសិស្សមិនគួរលើសពី៣០នាក់ថ្នាក់រៀនត្រូវតែសមស្របទៅនឹងការបង្រៀនបែបគោលវិធីសិស្សមជ្ឈមណ្ឌល ពួកគាត់បានឆ្លើយថា មានសម្ភារៈគ្រប់គ្រាន់ និងយ៉ាងតិចមានរយៈពេល២ម៉ោង ១០%ទៀតបានបញ្ចេញយោបល់ថាការអនុវត្តក្រុមរបស់សិស្សត្រូវតែកំណត់ឱ្យបានជាក់លាក់។ ចំណែកឯ៧០%ទៀតមិនបានបញ្ចេញយោបល់។

### ៤.២.២ ការវិភាគ ៖ ទស្សនៈនៃ ការអនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌលរបស់ គ្រូឧទ្ទេស

គ្រូឧទ្ទេសផ្នែកវិទ្យាសាស្ត្រសង្គមនៅពេលដែលក្រុមស្រាវជ្រាវបានចុះធ្វើសម្ភាសពាក់កណ្តាលរចនាសម្ព័ន្ធស្តីពីទស្សនៈផ្ទាល់ចំពោះការអនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌល ពួកគាត់បានឆ្លើយថា ធ្លាប់បានទទួលការបណ្តុះបណ្តាលគោលវិធីនេះ។ ក្នុងចំណោមពួកគាត់៨០% បានទទួលការបណ្តុះបណ្តាល១ដង និង២០%បានទទួលការបណ្តុះបណ្តាលចំនួន២ដង។ ដូចនេះមានន័យថាគ្រូឧទ្ទេសសុទ្ធតែបានទទួលការបណ្តុះបណ្តាលយ៉ាងតិច៥ថ្ងៃ ច្រើនបំផុត១០ថ្ងៃ ក៏ប៉ុន្តែគ្រូឧទ្ទេសដែលមិនបានទទួលការបណ្តុះបណ្តាលមាន៣៣%ប៉ុណ្ណោះ។

គ្រូឧទ្ទេស ដែលបង្រៀនលើមុខវិជ្ជា សីលធម៌ពលរដ្ឋ គរុកោសល្យ ចិត្តវិទ្យា អក្សរសាស្ត្រខ្មែរ សិល្បៈ និងភូមិវិទ្យា បានបង្រៀនថ្នាក់ឯកទេស និងថ្នាក់រួម។ ចំនួនគរុនិស្សិតតាមថ្នាក់នីមួយៗមានភាពខុសៗគ្នា ថ្នាក់ឯកទេសចំនួន១៥នាក់ដែលតិច ចំនួនគរុនិស្សិតច្រើនមានចំនួនលើសពី៤៧នាក់។

ចំពោះការអនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌលក្នុងម៉ោងសិក្សា អនុវត្តជាញឹកញាប់របស់គ្រូឧទ្ទេសមានរហូតដល់៦០% និងអនុវត្តបានយ៉ាងខ្ជាប់ខ្ជួនគ្រប់ម៉ោងដែលគាត់បង្រៀន១០% គ្រូឧទ្ទេស៣០% អនុវត្តម្តងម្កាល។ ដូចនេះតាមរយៈលទ្ធផលនៃការស្រាវជ្រាវបានអាចបង្ហាញឱ្យឃើញថាគ្រូយើងមានចំនួនតិចតួចបំផុតដែលមិនបានអនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌល។

ក្នុងដំណើកនាំសកម្មភាពបង្រៀន ចាប់ពីជំហានទី១ រហូតដល់ជំហានទី៥សាស្ត្រាចារ្យយើងមានស្មារតីលើវិជ្ជាជីវៈជាគ្រូបង្រៀនបាន៨០% ចំណែកសាស្ត្រាចារ្យឧទ្ទេស២០%មានការធ្វេសប្រហែសមិនបានអនុវត្តគ្រប់ជំហាន។ ពួកគាត់អនុវត្ត ចាប់ពីជំហានទី៣ដល់ជំហានទី៥តែម្តងនេះបញ្ជាក់ឱ្យឃើញថាគ្រូឧទ្ទេសរបស់យើងមួយចំនួនធំមានភាពឈ្លាសវៃ សមត្ថភាពគ្រប់គ្រាន់ប៉ិនប្រសប់នៅក្នុងការអនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌល។

ក្នុងពេលគ្រូធ្វើសកម្មភាពបង្រៀនរួមមាន សកម្មភាពសិស្ស និងសកម្មភាពគ្រូ ការដាក់ជាសំណួរ ការបែងចែកក្រុមពិភាក្សា ការដាក់កិច្ចការជាក្រុម និងការដាក់កិច្ចការផ្ទះ ដើម្បីស្រាវជ្រាវ គ្រូយើងបានជួយពន្យល់តម្រង់ទិសបានត្រឹមត្រូវ និងផ្តល់ព័ត៌មានត្រឡប់ដល់សិស្សវិញភ្លាមៗ។

ដើម្បីបង្រៀន រៀនប្រកបដោយប្រសិទ្ធភាព និងគុណភាព ការប្រើប្រាស់សម្ភារឧបទេសជាកត្តាសំខាន់ក្នុងការបណ្តុះបណ្តាលចំណេះដឹងជំនាញអនុវត្តដល់គរុនិស្សិត។ គ្រូឧទ្ទេសដែលប្រើប្រាស់សម្ភារឧបទេសម្តងម្កាលមានចំនួន៦០% គ្រូដែលប្រើប្រាស់ញឹកញាប់ក្នុងម៉ោងបង្រៀនមាន១០% រីឯ ៣០%ទៀតបានប្រើប្រាស់យ៉ាងទៀងទាត់គ្រប់មេរៀន។ ដូចនេះគ្រូឧទ្ទេសមួយចំនួនធំមិនបានប្រើសម្ភារឧបទេសបានយ៉ាងទៀងទាត់គ្រប់មេរៀនទេ ដែលនេះ គឺជាលទ្ធផលកំពុងព្រួយបារម្ភក្នុងការបណ្តុះបណ្តាលគរុនិស្សិតរបស់យើង។

ការយល់ដឹងពីសារប្រយោជន៍ នៃការប្រើប្រាស់សម្ភារឧបទេសនៅមានកម្រិតនៅឡើយ។ នៅពេលគាត់ប្រើសម្ភារឧបទេសមានដូចជា៖ រូបភាព ក្រដាសផ្ទាំងធំ ស្កុត កន្ត្រៃ ហ្វឺត សៀវភៅសិស្ស និងអត្ថបទចែកឱ្យសិស្សជាមុន។

ការប្រើប្រាស់សម្ភារៈឧបទេសមានលក្ខណៈប្លែកៗគ្នាទៅតាមខ្លឹមសារនៃមុខវិជ្ជានីមួយៗតាមឯកទេសផ្សេងៗ គ្នា។

របៀបវាយតម្លៃទៅលើលទ្ធផលសិក្សារបស់សិស្សតាមរូបភាពផ្សេងៗគ្នាទៅតាមបទពិសោធន៍ និងចំណង់ចំណូលចិត្តរបស់គ្រូម្នាក់ៗ ។ដូចជាការសួរសំណួរជាបុគ្គល សំណេរនិង

កិច្ចការ[illegible]មិនប្រើសម្ភារឧបទេស

ការអនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌលមានឧបសគ្គច្រើនដែល[illegible] ដូចជា ៖ ការបែងចែកក្រុម ថ្នាក់គ្មានវិន័យ សណ្តាប់ធ្នាប់ ខ្វះ[illegible]សិស្សច្រើន រយៈពេលតិច សិស្សខ្លះបង្កភាព[illegible]ការបង្រៀនរបស់គ្រូ ពីព្រោះគរុនិស្សិតខ្លះជាមន្ត្រីអប់រំដែលធ្លាប់ទទួលការបណ្តុះបណ្តាលរួចហើយ ។



ការសហការជាមួយពួកគាត់[illegible]ដែលបណ្តាលឱ្យគាត់មិនប្រើប្រាស់សម្ភារឧបទេស បណ្តាលមកពីសិស្សច្រើនគ្មានសម្ភារឧបទេសគ្រប់គ្រាន់។

៨.៣. [illegible] ក្នុងចំណោមគ្រូឧទ្ទេសចំនួន១០នាក់ សុទ្ធតែបានប្រើប្រាស់សម្ភារឧបទេស[illegible]

[illegible]ដែលប្រើប្រាស់ការអង្កេត និងសម្ភាសន៍ពាក់កណ្តាលរចនាសម្ព័ន្ធមិនអាចគ្រប់[illegible]ការស្រាវជ្រាវនេះក៏បានរៀបចំ[illegible]ផ្តោតទៅលើ ៖




ការអនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌល[illegible]មិនទាន់មានបរិយាកាស[illegible] និងលក្ខណៈវិនិច្ឆ័យលើការអនុវត្តពុំទាន់ឆ្លើយតបទៅនឹងតម្រូវការនៃការទទួលយកចំណេះដឹង ចំណេះធ្វើ ឥរិយាបថ និងបំណិនជីវិត។ ការស្រាវជ្រាវបានសង្កេតទៅលើបឯកទេស[illegible]ចំនួនគរុនិស្សិតនៅក្នុងថ្នាក់មានលើសពី ៥០ នាក់ក្នុងមួយបន្ទប់។ បន្ទប់រៀន [illegible] គ្មានផ្លូវចេញចូល[illegible]

[illegible]

គ្រូឧទ្ទេសជាអ្នក[illegible]គ្រប់គ្រាន់។

នៅក្នុងការអនុវត្ត[illegible]

[illegible]ការលើកទឹកចិត្តគរុនិស្សិត

ខ្វះកិច្ចការស្រាវជ្រាវបន្ថែមនៅផ្ទះ ដូចនេះសកម្មភាពបង្រៀន និងរៀនមិនសូវមានភាពរស់រវើក។ គរុនិស្សិតមានចំណាប់ចំណូលចិត្ត និងមានការសប្បាយរីករាយក្នុងការពិភាក្សាការងារជាក្រុម ដោយសារគ្រូឧទ្ទេសផ្តល់ការពន្យល់បកស្រាយពាក្យបច្ចេកទេសក្នុងឯកទេសជំនាញ។

សកម្មភាពសិស្សឆ្លើយជាបុគ្គលនិងជាដៃគូ ផ្តល់ឱកាសឱ្យសិស្សអានអត្ថបទរឿងមៅស្វិត និងមាយាស្ត្រី...ខ្លឹមសារអប់រំឱ្យបានច្បាស់នៃសាច់រឿងនីមួយៗ គ្រូធ្វើសំយោគលើមេរៀន ដោយពឹងផ្អែកលើចំណេះដឹងមានស្រាប់។

## ៩. សេចក្តីសន្និដ្ឋាន

លទ្ធផលដែលទទួលបានពីការសិក្សាស្រាវជ្រាវ ចំពោះទស្សនៈរបស់គ្រូឧទ្ទេសនៅវិទ្យាស្ថានជាតិអប់រំផ្នែកសង្គម យល់ឃើញថាការអនុវត្តគោលវិធីនេះបានបណ្តុះបំណិនគិត ពង្រឹងចំណេះដឹង សមត្ថភាពអនុវត្ត និងឥរិយាបថល្អដល់គរុនិស្សិតពិសេសគំនិតស្រាវជ្រាវ។

ការស្រាវជ្រាវនេះបានរកឃើញពីឥទ្ធិពលនៃការអនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌលរួមមានៈ ឥទ្ធិពលយ៉ាងខ្លាំងដល់ការសិក្សាពីមិត្តរួមថ្នាក់ មានឱកាសបញ្ចេញមតិយោបល់ ទទួលយកទស្សនរបស់មិត្តរួមថ្នាក់បានធ្វើឱ្យគរុនិស្សិតបង្កើនចំណេះដឹងបានល្អប្រសើរ។

គរុនិស្សិតទទួលបាននូវបទពិសោធថ្មីៗស្តីពីខ្លឹមសារមេរៀន និងចំណេះដឹង នៅក្នុងជីវិតការងារ។ លទ្ធផលឆ្លុះបញ្ចាំងឱ្យឃើញពីការប្រៀបធៀបទស្សនៈគរុនិស្សិត និងគ្រូខ្លួនឯងលើការអនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌល បង្ហាញឱ្យឃើញថា គ្រូឧទ្ទេស និងគរុនិស្សិតបានយល់ដឹង និងឱ្យតម្លៃខ្ពស់លើការអនុវត្ត ពួកគេបានទទួលចំណេះធ្វើ និងមានសមត្ថភាពច្នៃប្រឌិត និងបំណិនគិត។ គរុនិស្សិតទទួលបាននូវបទពិសោធការងារ និងស្រាវជ្រាវ តាមប្រព័ន្ធអ៊ីនធឺណិត ។

ទស្សនគរុនិស្សិតបានឆ្លុះបញ្ចាំងពីទស្សនៈយល់ឃើញរបស់ពួកគេថាៈគ្រូឧទ្ទេស ៨៥% បានអនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌលគ្រប់មេរៀន។ ក្នុងពេលបង្រៀនគ្រូឧទ្ទេសបានគោរពតាមជំហានទាំងប្រាំ ៨៧%នៃកិច្ចតែងការបង្រៀនគ្រូឧទ្ទេសមានសមត្ថភាពពេញលេញក្នុងការ សម្របសម្រួល។

ទោះបីគ្រូឧទ្ទេសមានការខ្វះខាតសម្ភារឧបទេសទំនើបមួយចំនួន ក៏ដោយប៉ុន្តែមានគរុនិស្សិតចំនួន ៨២% បានអះអាងថា គ្រូរបស់គាត់បានប្រើប្រាស់សមស្រប ។

## បញ្ហាប្រឈម

គ្រូឧទ្ទេសជួបការលំបាកច្រើនចំពោះគរុនិស្សិតដែលរំខាន ប្រើពាក្យសម្តីទឹកមុខកាយវិការបង្ក ភាពគ្មានសណ្តាប់ធ្នាប់ក្នុងថ្នាក់រៀន ពិបាកក្នុងការគ្រប់គ្រង។ ការប្រើប្រាស់សម្ភារទំនើបៗទាន់សម័យ និងឯកសារប្រើប្រាស់ផ្ទៃក្នុងតាមមុខវិជ្ជា មិនទាន់បានគ្រប់គ្រាន់តាមតម្រូវការរបស់គរុនិស្សិត និងគ្រូឧទ្ទេស ។

## ១០ .អនុសាសន៍

+ កំណត់និងផ្គត់ផ្គង់ អំពីបរិមាណសម្ភារឧបទេសទំនើបទាន់សម័យតិចបំផុតដែលអាចជួយដល់ការអនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌល ឱ្យមានប្រសិទ្ធភាពនៅវិទ្យាស្ថានជាតិអប់រំ ។
+ ពង្រឹងដំណើរការត្រួតពិនិត្យតាមដានលើការប្រើប្រាស់បន្ទប់សិក្សា ដើម្បីធានាបានអត្រាសិស្សបន្ទប់ ។
+ ពង្រឹងដំណើរការគ្រប់គ្រង និងត្រួតពិនិត្យតាមដានលើការផ្គត់ផ្គង់និងប្រើប្រាស់ ធនធាននិងសម្ភារឧបទេស។
+ លើកទឹកចិត្តដល់គ្រូឧទ្ទេសធ្វើយ៉ាងណាឱ្យគរុនិស្សិតចូលរួមកាន់តែសកម្មថែមទៀតក្នុងការអនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌល។

## ១១ .ចំណុចដែលត្រូវសិក្សាបន្ត

+ បន្ទាប់ពីការសិក្សាស្រាវជ្រាវនេះមក មិនមានតម្រូវការបន្ទាន់លើប្រធានបទនេះទៀតទេ អាស្រ័យហេតុនេះសូមសំណូមពរថា៖ ប្រធានបទ មួយចំនួនដូចជាការបញ្ច្រាបយេនឌ័រនៅសាលាមធ្យមសិក្សាបឋមភូមិ ឬ ការបោះបង់ការសិក្សារបស់សិស្សមធ្យមសិក្សាបឋមភូមិ គួរត្រូវធ្វើការសិក្សាបន្ថែម។

## ១២. ឯកសារយោង


១. បូ ជុំស៊ិន (១៩៩៦). *វិធីបង្រៀននៅសាលាបឋមសិក្សា និងមធ្យមសិក្សា៖*. ភ្នំពេញ៖ គណៈកម្មការ អភិវឌ្ឍអប់រំ បោះពុម្ពនិងកែសម្រួល

២. អ៊ឹម កុច (១៩៩៩). *ទ្រឹស្តីរបស់ចិត្តវិទូមនុស្សនិយម និងគោលវិធីសិស្សមជ្ឈមណ្ឌល.* ភ្នំពេញ៖ គណៈកម្មការអន្តរជាតិទទួលបន្ទុកការងារអប់រំសម្រាប់សតវត្សទី ២១ (១៩៩៦). ការសិក្សា៖ ទ្រព្យកំណប់នៅក្នុង ការសិក្សា. ភ្នំពេញ៖ អង្គការយូនីស្កូ

៣. នាយកដ្ឋានបណ្តុះបណ្តាល និងវិក្រិតការ (២០០១).ឯកសារបំប៉ននាយកសាលារៀន៖ បំណិនវិជ្ជាជីវៈ មធ្យមសិក្សាចំណេះ ទូទៅ

៤. National Institute of Education (2010). *Institutional Development Plan 2009-2010: Second Draft.* Phnom Penh: National Institute of Education.

៥. Rogers, Graham (2002). *Student-Centered Learning: A Practical Guide For Teachers.*

៦. Ginsburg, Mark (2006). *Challenges to Promoting Active-Learning, Student-Centered Pedagogies.* Washington, DC: USAID.

# វិទ្យាស្ថានជាតិអប់រំ

## ប្រធានបទ

## សមត្ថភាពដឹកនាំរបស់នាយកវិទ្យាល័យ

**ក្រុមសិក្សាស្រាវជ្រាវ**

*១. លោក គួយ សុគាន*

*២. លោក ថៅ លិន*

*៣. លោក សិត សេង*

*៤. លោក ប៉ូ ប៊ុន្ធន*

# មាតិកា

ខ្លឹមសារ ទំព័រ


ថ្លែងអំណរគុណ ..................... ៤
I-សេចក្តីផ្តើម ..................... ៤
II-ចំណោទបញ្ហានៃការសិក្សាស្រាវជ្រាវ..................... ៥
III-គោលបំណងនៃការសិក្សាស្រាវជ្រាវ..................... ៦
IV-សំណួរស្រាវជ្រាវ ..................... ៦
V-ប្រវត្តិនៃការសិក្សាស្រាវជ្រាវ..................... ៦
VI- រំលឹកទ្រឹស្តី..................... ៨
VII-វិធីសាស្ត្រប្រមូលទិន្នន័យ..................... ១២
១-វិធីសាស្ត្រវិភាគទិន្នន័យ..................... ១២
២-លទ្ធផលនៃការស្រាវជ្រាវរំពឹងទុក..................... ១៣
VIII-លទ្ធផលនៃការសិក្សាស្រាវជ្រាវ..................... ១៣
១-សញ្ញាប័ត្រចុងក្រោយ..................... ១៣
២-អំពីភេទ..................... ១៣
៣-អំពីអាយុ..................... ១៤
៤-១-ការរៀបចំផែនការយុទ្ធសាស្ត្រ..................... ១៤
៤-២-ការរៀបចំផែនការប្រតិបត្តិប្រចាំឆ្នាំ..................... ១៦
៤-៣-ការអភិវឌ្ឍគោលនយោបាយអប់រំ..................... ១៧
៤-៤-ផែនការគ្រប់គ្រងហិរញ្ញវត្ថុ..................... ១៨
៤-៥-ផែនការគ្រប់គ្រងធនធានសម្ភារៈ..................... ២០
៤-៦-ផែនការគ្រប់គ្រងពេលវេលា..................... ២១
៤-៧-ផែនការគ្រប់គ្រងគម្រោង..................... ២២
៤-៨-ការសម្របសម្រួល..................... ២៣
៤-៩-ការសម្រេចចិត្តលើការគ្រប់គ្រង..................... ២៣
៤-១០-អាកប្បកិរិយាដឹកនាំប្រតិបត្តិ..................... ២៤

៩-១១-ការគ្រប់គ្រងធនធានមនុស្ស.......................................... ២៦
៩-១២-ទំនាក់ទំនងរវាងសហការី............................................ ២៨
៩-១៣-ការងារក្រុម......................................................... ២៨
៩-១៤-ការគ្រប់គ្រងភាពប្រែប្រួល........................................... ២៩
៩-១៥-ការតាមដានត្រួតពិនិត្យ និងវាយតម្លៃ.............................. ២៩
៩-១៦-ការប្រមូលផ្តុំ និងការផ្តល់អំណាចដល់សហគមន៍........ ៣០
៩-១៧-ផែនការគ្រប់គ្រងហានិភ័យ........................................... ៣១
៩-១៨-ការប្រើប្រាស់ ICT.................................................... ៣២
៩-១៩-ការប្រើប្រាស់ភាសាអង់គ្លេស...................................... ៣២
IX-សន្និដ្ឋាន ........................................................................ ៣៣
X- ឯកសារយោង ................................................................ ៣៥

# អារម្ភកថា

ប្រធានបទស្រាវជ្រាវស្តីពីសមត្ថភាពដឹកនាំរបស់នាយកតាមវិទ្យាល័យ ដែលក្រុមយើងខ្ញុំបានធ្វើការសិក្សាស្រាវជ្រាវនេះ គឺជាប្រធានបទមួយដ៏មានសារសំខាន់ដែលក្រសួងអប់រំយុវជន និងកីឡា និងមជ្ឈដ្ឋានផ្សេងៗ ទៀតកំពុងចាប់អារម្មណ៍ និងយកចិត្តទុកដាក់ជាទីបំផុតព្រោះវាទាក់ទងជាមួយនឹងមូលដ្ឋាននៃការកសាងធនធានមនុស្សរបស់សិស្សតាមវិទ្យាល័យដើម្បីតម្រង់ទិសទៅរកវិជ្ជាជីវៈនៅឧត្តមសិក្សា។

ការសិក្សាពីសមត្ថភាពដឹកនាំរបស់នាយកវិទ្យាល័យ គឺជាការឆ្លុះបញ្ចាំងពីគុណភាពអប់រំទាំងសមត្ថភាពចំណេះដឹង សមត្ថភាពជំនាញ និងសីលធម៌ ជាពិសេសជីវភាពរស់នៅប្រចាំថ្ងៃរបស់សិស្ស និស្សិតនាពេលបច្ចុប្បន្ន។ ជាមួយគ្នានេះក៏ជាការឆ្លុះបញ្ចាំងពីសមត្ថភាពគ្រប់គ្រងធនធានមនុស្ស គ្រប់គ្រងពេលវេលា ហិរញ្ញវត្ថុ និងសម្ភារៈនៅក្នុងអង្គភាពរបស់ខ្លួនដែរ។ជាងនេះទៅទៀត វាក៏ជាការបង្ហាញអំពីទំនាក់ទំនងល្អរវាងអង្គភាពវិទ្យាល័យជាមួយសហគមន៍នានាក្នុងមូលដ្ឋាន ដើម្បីអភិវឌ្ឍអង្គភាពឱ្យមានការរីកចម្រើនស្របជាមួយគោលនយោបាយរបស់ក្រសួងអប់រំ យុវជន និងកីឡា ដែលបានលើកឡើងថាអ្នកដឹកនាំស្ថាប័ននីមួយៗត្រូវតែអភិវឌ្ឍស្ថាប័នធនធានមនុស្ស និងសមធម៌ដើម្បីឱ្យការអប់រំកម្ពុជាទទួលបានទាំងគុណភាពនិងបរិមាណ។

ការសិក្សាស្រាវជ្រាវនេះនឹងចង្អុលបង្ហាញពីបញ្ហាប្រឈមជាច្រើន ដែលជាកត្តារាំងស្ទះដល់ដំណើរការគ្រប់គ្រងអង្គភាព ការប្រើប្រាស់និយាមគរុកោសល្យ ការបែងចែកធនធាននៅក្នុងអង្គភាពសមស្របតាមនិយាមទំនើប ដើម្បីធានាបាននូវសក្តានុពលមួយឆ្លើយតបទៅនឹងការអភិវឌ្ឍក្នុងយុគសម័យទំនើប។ បញ្ហាមួយចំនួនដែលតែងតែកើតមានឡើងត្រូវបានក្រុមស្រាវជ្រាវយើងខ្ញុំរកឃើញហើយបានលើកជាសំណើទៅដល់ស្ថាប័នពាក់ព័ន្ធ ដើម្បីធ្វើការកែទម្រង់ឆ្ពោះទៅរកភាពជោគជ័យជាបន្តបន្ទាប់ក្នុងវិស័យអប់រំ។

ដូច្នេះ ក្រុមស្រាវជ្រាវយើងខ្ញុំសង្ឃឹមថា ប្រធានបទនេះពិតជាបានចូលរួមវិភាគទានមួយដ៏សំខាន់ក្នុងការដឹកនាំអង្គភាពឱ្យមានតម្លាភាព ប្រសិទ្ធភាព គុណភាពក៏ដូចជាការអភិវឌ្ឍធនធានមនុស្សនៅកម្ពុជាឱ្យទទួលបានជោគជ័យ។

# ថ្លែងអំណរគុណ

ជាបឋមក្រុមស្រាវជ្រាវយើងខ្ញុំសូមថ្លែងអំណរគុណដូចតទៅ៖

-សូមថ្លែងអំណរគុណដ៏ជ្រាលជ្រៅបំផុតចំពោះសាស្ត្រាចារ្យថ្នាក់ជាតិ និងអន្តរជាតិជាពិសេសចំពោះលោកស្រីបណ្ឌិត **Ann Glover** ដែលជាសាស្ត្រាចារ្យណែនាំ។លោកស្រីបានចំណាយពេលវេលាដ៏មានតម្លៃក្នុងការបង្ហាត់បង្ហាញជាទ្រឹស្តីផង និងការកែលម្អផងដើម្បីឱ្យការស្រាវជ្រាវទទួលបានលទ្ធផលជាផ្លែផ្កាដែលអាចទទួលយកបាន។

-ជាមួយគ្នានេះក៏សូមថ្លែងអំណរគុណដ៏ជ្រាលជ្រៅបំផុតចំពោះឯកឧត្តមបណ្ឌិត សៀង សុវណ្ណា នាយកវិទ្យាស្ថានជាតិអប់រំដែលឯកឧត្តមបណ្ឌិតតែងតែយកចិត្តទុកដាក់ជួយសម្របសម្រួលដោះស្រាយគ្រប់បញ្ហាដែលក្រុមស្រាវជ្រាវយើងខ្ញុំបានជួបប្រទះ មិនតែប៉ុណ្ណោះថែមទាំងបានលើកទឹកចិត្ត និងជួយជំរុញទាំងផ្នែកបច្ចេកទេស និងរដ្ឋបាលឱ្យការស្រាវជ្រាវនេះប្រព្រឹត្តទៅយ៉ាងរលូន។

-សូមថ្លែងអំណរគុណដល់ឯកឧត្តម អ៊ឹម សិទ្ធី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡាដែលឯកឧត្តមបានខិតខំជម្នះនូវគ្រប់ឧបសគ្គ ដើម្បីគុណភាពវិស័យអប់រំនៅកម្ពុជាជាពិសេសខិតខំកៀរគរជំនួយអន្តរជាតិនានាទាំងបច្ចេកទេសក្តីសម្ភារ និង ហិរញ្ញវត្ថុក្តីសម្រាប់អភិវឌ្ឍវិស័យអប់រំដូចជាគម្រោងលើកកម្ពស់គុណភាពអប់រំ(EEQP)។ ថវិកានៃគម្រោងនេះបានធានារ៉ាប់រងដល់ដំណើរការផ្សេងៗនៅក្នុងវិទ្យាស្ថានជាតិអប់រំ (ការកសាងសមត្ថភាពគ្រូបង្រៀនដូចជាការគ្រប់គ្រងអប់រំ ការស្រាវជ្រាវ និងសិក្ខាសាលាជាច្រើនទៀត) ជាពិសេសដំណើរការស្រាវជ្រាវនៃក្រុមរបស់យើងខ្ញុំនេះតែម្តងតាំងពីដើមរហូតដល់ចេញជាលទ្ធផល។

## I-សេចក្តីផ្តើម

ប្រទេសកម្ពុជា បានឆ្លងកាត់នូវសង្គ្រាមស៊ីវិលក្នុងស្រុកដ៏រ៉ាំរ៉ៃ រវាងគ្នាឯងអស់រយៈពេលជាង២ទសវត្សរ៍ ហើយបានបន្សល់ទុកនូវទុក្ខវេទនា សោកនាដកម្ម ការព្រាត់ប្រាស់គ្រួសារ និងអំពើហិង្សាគ្រប់បែបយ៉ាង ពោលប្រទេសកម្ពុជាបានបាត់បង់ស្ទើរទាំងអស់ នូវធនធានមនុស្សដែលធ្វើឱ្យការកសាងប្រទេសជួបការលំបាកជាខ្លាំងក្រោយថ្ងៃរំដោះ ៧ មករា ១៩៧៩។ ម៉្យាងវិញទៀតប្រទេសកម្ពុជាបានធ្វើសមាហរណកម្មក្នុងតំបន់ទាំងធនធានមនុស្ស និងសេដ្ឋកិច្ចដើម្បីលើកកម្ពស់វិស័យសេដ្ឋកិច្ចជាតិក្នុងគោលបំណងអភិវឌ្ឍប្រទេសនេះ ឱ្យមានការរីកចម្រើន និងប្រកួតប្រជែងជាមួយបណ្តាប្រទេសក្នុងតំបន់ក៏ដូចជានៅលើសាកលលោកផងដែរ។

ប្រទេសកម្ពុជាបានខិតខំស្តាទាំងធនធានមនុស្ស និងសេដ្ឋកិច្ចដោយឆ្លងកាត់ការលំបាក

គ្រប់បែបយ៉ាងក្នុងទិសដៅអភិវឌ្ឍសេដ្ឋកិច្ចដោយផ្អែកលើធនធានមនុស្ស ពោលគឺសេដ្ឋកិច្ចមានការរីកចម្រើន និងមាននិរន្តរភាពឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែងរបស់ប្រជាជនកម្ពុជា និងស្ថានភាពរបស់ប្រទេសនាពេលបច្ចុប្បន្ន។

យុទ្ធសាស្ត្រត្រីកោណ(មុំទី៣) យុទ្ធសាស្ត្រចតុកោណ(មុំទី៤)និងគោលដៅអភិវឌ្ឍសហស្សវត្សរ៍នៅកម្ពុជាសុទ្ធតែបានលើកឡើងពីការយកចិត្តទុកដាក់បំផុតក្នុងការអភិវឌ្ឍ ធនធានមនុស្សដែលជាឆ្អឹងខ្នងមួយនៃការអភិវឌ្ឍល្បឿនសេដ្ឋកិច្ចជាតិរបស់ប្រទេសក្នុងគោលបំណងកាត់បន្ថយភាពក្រីក្រ។ ការអភិវឌ្ឍធនធានមនុស្ស គឺជាកត្តាមួយដែលមានលក្ខណៈស្មុគស្មាញស៊ាំញ៉ាំជាទីបំផុតព្រោះវាមានទំនាក់ទំនងរវាងកត្តាគ្រូបង្រៀន សិស្សកម្មវិធីសិក្សា ការគ្រប់គ្រង និងហេដ្ឋារចនាសម្ព័ន្ធនានា។ កត្តា ទាំងអស់នេះជាសមាសធាតុដ៏សំខាន់មួយក្នុងការកសាងធនធានមនុស្សប្រកបដោយគុណភាព និងប្រសិទ្ធភាពសម្រាប់បម្រើការងារក្នុងសង្គម ជាពិសេសកត្តាសមត្ថភាពរបស់អ្នកគ្រប់គ្រងនៅតាមអង្គភាព និងគ្រឹះស្ថានសិក្សានានាក្នុងទូទាំងប្រទេស។

## II-ចំណោទបញ្ហានៃការសិក្សាស្រាវជ្រាវ

សមត្ថភាពគ្រប់គ្រងរបស់នាយកនៅតាមវិទ្យាល័យនានាទូទាំងប្រទេសកម្ពុជា ពិតជានៅមានកង្វះខាតលើការគ្រប់គ្រងបុគ្គលិក ហិរញ្ញវត្ថុ គ្រឿងបរិក្ខារ ជាពិសេសលើ ការបណ្តុះបណ្តាលសិស្សនៅមធ្យមសិក្សាទុតិយភូមិ ព្រោះអត្រាបោះបង់ការសិក្សានៅមានកម្រិតខ្ពស់រហូតដល់១៤.៩%អត្រាពិតនៃការសិក្សាមានកម្រិតទាបជាងចំណុចដៅទុក ១.១%អត្រាប្រឡងជាប់សញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិមានតែ ៧៧.៧៩% ទូទាំងប្រទេស (សន្និបាតបូកសរុបលទ្ធផលការងារក្រសួងអប់រំ យុវជន និងកីឡា ឆ្នាំសិក្សា ២០១០-២០១១ )។ ម៉្យាងវិញទៀតចំនួនសិស្សនៅមធ្យមសិក្សាទុតិយភូមិចេះតែកើនជារៀងរាល់ឆ្នាំ ក្នុងនោះគេសង្កេតឃើញចំនួនវិទ្យាល័យទូទាំងប្រទេសមានការកើនឡើងឥតឈប់ឈរ។ បើយើងធ្វើការប្រៀបធៀបរវាងឆ្នាំសិក្សា ២០០៨-២០០៩ និង ២០០៩-២០១០ សបញ្ជាក់ឱ្យឃើញថាកំណើនសាលាពី៣១៥ ទៅ ៣៨៣ វិទ្យាល័យដែលកើនចំនួន ៦៨ វិទ្យាល័យក្នុងរយៈពេលមួយឆ្នាំសិក្សា។ ចំណែកឆ្នាំសិក្សា ២០១០-២០១១ វិញចំនួនវិទ្យាល័យទូទាំងប្រទេសកើនដល់ ៤០៧ សាលា ហើយស្ថិតិ និងសូចនាករអប់រំនេះ ជាក្តីកង្វល់មួយចំពោះសមត្ថភាពនៃការគ្រប់គ្រងរបស់នាយកនាយិកាសាលា (សន្និបាតបូកសរុបលទ្ធផលការងារក្រសួងអប់រំ យុវជន និងកីឡា២០១០)។ ជាមួយគ្នានេះបញ្ហាដែលនាយកនាយិកាសាលាជាច្រើនបានប្រឈម គឺកង្វះខាតការបណ្តុះបណ្តាលផ្នែកការគ្រប់គ្រងការវាយតម្លៃ និងការអភិវឌ្ឍវិជ្ជាជីវៈជាអ្នកដឹកនាំ និងរបៀបធ្វើការងារជាក្រុម។ តែមាននាយកនាយិកាសាលាខ្លះ ក៏បានទទួលការបណ្តុះបណ្តាលលើផ្នែកនេះផងដែរ ពីកម្មវិធីគាំទ្រវិស័យ

អប់រំនៅកម្ពុជា និងបានចូលរួមសិក្ខាសាលាស្តីពីការគ្រប់គ្រងដែលបានរៀបចំឡើងដោយអង្គការអ្នកស្ម័គ្រចិត្តបម្រើការនៅបរទេស (VSO) (Peter, ២០០៨,៦៥)។

## III-គោលបំណងនៃការស្រាវជ្រាវ

ការស្រាវជ្រាវនេះមានគោលបំណងដើម្បី៖

- ពិនិត្យមើលសមត្ថភាពដឹកនាំរបស់នាយក នាយិកាវិទ្យាល័យនៅកម្ពុជា
- វិភាគបញ្ហាប្រឈមក្នុងការដឹកនាំរបស់នាយក នាយិកាវិទ្យាល័យនៅកម្ពុជា

## IV-សំណួរស្រាវជ្រាវ

ការស្រាវជ្រាវនេះនឹងឆ្លើយសំណួរខាងក្រោម៖

- តើនាយក នាយិកាវិទ្យាល័យមានសមត្ថភាពដឹកនាំយ៉ាងដូចម្តេច?
- តើនាយក នាយិកាវិទ្យាល័យមានបញ្ហាប្រឈមក្នុងការដឹកនាំអ្វីខ្លះ?

## V-ប្រវត្តិនៃការសិក្សាស្រាវជ្រាវ

ក្រោយការគ្រប់គ្រងរបស់អាណានិគមនិយមបារាំង រចនាសម្ព័ន្ធគ្រប់ផ្នែកនៅប្រទេសកម្ពុជាមានការប្រែប្រួលឥតឈប់ឈរ ជាពិសេសផ្នែកខាងសាលារៀនរបស់រដ្ឋ។ ប្រព័ន្ធសិក្សាអប់រំ កម្មវិធីសិក្សា វិធីសាស្ត្របង្រៀន គរុកោសល្យ និងការគ្រប់គ្រងរបស់នាយក នាយិកាសាលានៅកម្ពុជាបានកើតមានឡើងក្នុងរបបអាណានិគមនិយមបារាំង ដែលត្រួតត្រានៅប្រទេសកម្ពុជាចាប់ពីឆ្នាំ ១៨៦៣-១៩៥៣ ប៉ុន្តែគេសង្កេតឃើញបែបបទនៃការគ្រប់គ្រងរបស់នាយក នាយិកាបានកើតឡើងក្នុងពេលនោះដែរ ព្រោះអនុវិទ្យាល័យដែលបានកើតឡើងដំបូងមានឈ្មោះថា " អនុវិទ្យាល័យអាណាព្យាបាលបារាំងមានទីតាំងនៅទីក្រុងភ្នំពេញក្នុងឆ្នាំ ១៩០១ (មន្ទីរអប់រំរាជធានីភ្នំពេញបច្ចុប្បន្ន) ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់លោក Francois Fontaine និងអនុវិទ្យាល័យព្រះស៊ីសុវត្ថិ ឆ្នាំ ១៩១១ ដែលដឹកនាំដោយលោក Henri Russier។ នៅថ្ងៃទី ៨ ខែ កញ្ញា ឆ្នាំ ១៩៣៥ អនុវិទ្យាល័យព្រះស៊ីសុវត្ថិ បានក្លាយទៅជាវិទ្យាល័យព្រះស៊ីសុវត្ថិដំបូងគេនៅប្រទេសកម្ពុជាដឹកនាំដោយលោក Charles Paquier (យ៉ង់ ធី,១៩៩៨,១៩)។ ប៉ុន្តែអ្វីគួរកត់សម្គាល់គឺសមត្ថភាពនៃការគ្រប់គ្រងក្នុងពេលនោះមានលក្ខណៈបែបបស្ចិមប្រទេស គឺប្រទេសបារាំង។ នាយក នាយិកាសាលា ចាប់ពីកម្រិតបឋមសិក្សា អនុវិទ្យាល័យ និងវិទ្យាល័យសុទ្ធតែជាជនជាតិបារាំងដែលទទួលបានការបណ្តុះបណ្តាលពីប្រទេសបារាំង។ ជួនកាលនាយក នាយិកាទាំងនោះត្រូវបានគេប្តូរទៅគ្រប់គ្រងសាលានៅឯប្រទេសវៀតណាមវិញហើយសិស្សនៅពេលនោះត្រូវបានទទួលស្គាល់គុណភាពអប់រំដូចគ្នាទាំងអស់នៅក្នុងរដ្ឋឥណ្ឌូចិន។ នាយកនាយិកាវិទ្យាល័យនាពេលនោះត្រូវស្ថិតនៅក្រោមការគ្រប់គ្រងរបស់លោករេស៊ីដង់ជាន់ខ្ពស់ម្នាក់។ចំណែក

ឯការសិក្សារបស់សិស្សវិញក៏ត្រូវស្ថិតនៅក្រោមបញ្ជាផ្ទាល់របស់អគ្គនាយកសិក្សាសាធារណៈ នៅឯទីក្រុងហាណូយដែរ។ លើសពីនេះទៅទៀត សាលានីមួយៗ តែងតែមានបុគ្គលិកបារាំងម្នាក់ដែលមានតួនាទីជាអធិការចុះតាមដាន នៅ តាមសាលារៀនជាប់ជានិច្ចទាំងការងារនាយកនាយិកា និងកិច្ចការសិក្សារបស់សិស្ស។ ចាប់ពីឆ្នាំ១៩៥៨ ក្រសួងអប់រំជាតិបានរៀបចំកំណែទម្រង់ផ្នែករដ្ឋបាលជាបន្តបន្ទាប់ ដូចជាបណ្តុះបណ្តាល អធិការបឋមសិក្សា អធិការមធ្យមសិក្សា ដែលការបណ្តុះបណ្តាលនេះ ស្ថិតនៅតាមសាលាគរុកោសល្យ ដើម្បីឆ្លើយតបទៅនឹងកំណើនអនុវិទ្យាល័យ និងវិទ្យាល័យ ដែលបានកើតឡើង ព្រោងព្រាតពេញផ្ទៃប្រទេស។ ជាពិសេសធានាដល់ការគ្រប់គ្រងរបស់នាយក និងគុណភាពរបស់សិស្ស ព្រោះថាក្រោយពេលប្រឡងជាប់សិស្សទៅបម្រើការងារបានដោយជោគជ័យគួរជាទីគាប់ចិត្ត ហើយអ្វីដែលគួរឱ្យចាប់អារម្មណ៍គឺទម្រង់ការគ្រប់គ្រងបច្ចេកទេសក្នុងការត្រួតពិនិត្យគុណភាព វា ពឹងផ្អែកទាំងស្រុងលើបច្ចេកទេសរបស់ជនជាតិខ្មែរ។ ដំណើរការនេះបានបន្តជារៀងរហូតលុះដល់ប្រទេសកម្ពុជាបានធ្លាក់ចូលក្នុងសង្គ្រាមស៊ីវិល (១៩៧០-១៩៧៩)ដោយបានបន្សល់នូវទុក្ខវេទនា ភាពក្រីក្រ និងសោកនាដកម្មគ្រប់បែបយ៉ាង។ ហេដ្ឋារចនាសម្ព័ន្ធត្រូវបានខ្ទេចខ្ទីស្ទើរគ្មានសល់ «ជាពិសេសធនធានមនុស្សក្នុងវិស័យអប់រំបានបាត់បង់អស់ គ្រូបង្រៀន៧៥% និស្សិតសាកលវិទ្យាល័យ ៩៦% និងសិស្សបឋមសិក្សា និងមធ្យមសិក្សា៦៧%» (Luis Benveniste,2008VIII)។ ចាប់ពីថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៧៩ ការរៀបចំតែងតាំងគណៈគ្រប់គ្រងមាន ៥លំដាប់ថ្នាក់ គឺថ្នាក់កណ្តាល (ក្រសួង) ថ្នាក់ខេត្ត រាជធានី (មន្ទីរអប់រំ) ថ្នាក់ស្រុកខណ្ឌក្រុង(ការិយាល័យអប់រំស្រុក) ថ្នាក់ឃុំគណៈកម្មការអប់រំឃុំ និងថ្នាក់សាលារៀន (យង់ ធី ១៩៩៨)។ ការតែងតាំងនាយកនាយិកាសាលាអាចរៀបចំតាមមធ្យោបាយជា ច្រើនធ្វើយ៉ាងណាឱ្យតែសាលារៀននីមួយៗមានដំណើរការបណ្តុះបណ្តាលតែប៉ុណ្ណោះដោយមិនបានគិតដល់ស្តង់ដារសមត្ថភាព ជំនាញ និងគុណភាពនៃការគ្រប់គ្រងនោះទេ ពោលគឺតាមរូបភាពអ្នកចេះច្រើនបង្រៀនអ្នកចេះតិច អ្នកចេះតិចបង្រៀនអ្នកមិនចេះ ដើម្បីបំពេញតម្រូវការធនធានមនុស្ស ដែលបានបាត់បង់ជាបន្ទាន់សម្រាប់ប្រទេសជាតិនាពេលនោះ។

បច្ចុប្បន្ននេះបច្ចេកទេសវិទ្យាសាស្ត្រ និងកំណើនសេដ្ឋកិច្ចរីកចម្រើនឥតឈប់ឈរ ដើម្បីឆ្លើយតបនឹងតម្រូវការនេះគេចាំបាច់ពង្រឹងសមត្ថភាព គុណភាពរបស់គណៈគ្រប់គ្រងជាពិសេសសមត្ថភាពនាយកសាលាតាមវិទ្យាល័យឱ្យកាន់តែប្រសើរឡើង ក្នុងគោលបំណងធានាដល់ការដឹកនាំអង្គភាពឱ្យមានគុណភាព ប្រសិទ្ធភាពសំដៅលើកកម្ពស់គុណភាពនៃការបង្រៀន និងរៀនដើម្បីធានាបានដល់អភិបាលកិច្ចល្អ ការគ្រប់គ្រងល្អ ការបង្រៀនល្អ និងរៀន

ល្អសំដៅឱ្យធនធានមនុស្សក្នុងសង្គមមានការរីកចម្រើន ហើយមានសមត្ថភាពចូលរួមអភិវឌ្ឍប្រទេសដូចអារ្យប្រទេសនានាលើសាកលលោកផងដែរ។

ក្នុងពេលថ្មីៗនេះក្រសួងអប់រំ យុវជន និងកីឡាបានបោះពុម្ពឯកសារ (២០០៩)មួយដែលមានចំណងជើងថា «ការគ្រប់គ្រងរដ្ឋបាលសម្រាប់បំប៉ននាយកសាលាបឋម និងមធ្យម»។ អត្ថន័យនៃឯកសារនេះបានផ្តោតយ៉ាងខ្លាំងទៅលើការគ្រប់គ្រង ការដឹកនាំ និងភារកិច្ចរបស់នាយក នាយិកា ការរៀបចំក្រុមប្រឹក្សានានានៅក្នុងអង្គភាពជាពិសេសផ្តោតលើរបៀបសរសេរលិខិតរដ្ឋបាលព្រមទាំងចេះធ្វើផែនការសម្រាប់ការអភិវឌ្ឍអង្គភាពនីមួយៗ ទៀតផង។ សកម្មភាពនៃការបណ្តុះបណ្តាលនេះពិតមែនតែបានធ្វើសកម្មភាពតាមខេត្តក្រុងខ្លះក៏ដោយ តែក៏មិនទាន់បានបំពេញតាមតម្រូវការជាក់ស្តែងទាំងស្រុងនោះទេ។ តាមរយៈគម្រោង(EEQP)ក្រុមយើងខ្ញុំក៏បានចុះធ្វើការសិក្សាស្រាវជ្រាវផ្ទាល់លើសមត្ថភាពគ្រប់គ្រង និងការដឹកនាំរបស់នាយកនាយិកាវិទ្យាល័យតាមខេត្ត ក្រុង ដែលបានជ្រើសរើសដើម្បីចង់ដឹងពីតម្រូវការបន្ថែមលើអ្វីដែលបានសិក្សារួចហើយ។

## VI-រំលឹកទ្រឹស្តី

«២៥ឆ្នាំកន្លងមកនេះ បណ្តាប្រទេសជាច្រើនលើសាកលលោកបានបង្ហាញឱ្យឃើញថា ការសិក្សាស្រាវជ្រាវជាច្រើនត្រូវបានធ្វើដើម្បីរកឱ្យឃើញនូវលក្ខណៈសម្បត្តិរបស់នាយកសាលាដែលមានប្រសិទ្ធភាពខ្ពស់ និងលក្ខណៈសម្បត្តិមួយ ដែលត្រូវបានបង្ហាញយ៉ាងច្បាស់គឺវត្តមានបង្ហាញមុខរបស់នាយកសាលា។ សាលារៀននីមួយៗដែលទទួលបានលទ្ធផលសិក្សារបស់សិស្សខ្ពស់គឺជាសាលាដែលនាយកនាយិកាបានបង្ហាញមុខជាប់ជានិច្ច។ អ្នកដឹកនាំដែលមានវត្តមាន និងការបង្ហាញមុខ គឺជានាយកសាលា ដែលមានអន្តរសកម្មភាពជាមួយបុគ្គលិក សិស្សក្នុងថ្នាក់រៀននិងទីធ្លាសាលាតាមរយៈការចូលរួមសិក្ខាសាលា និងការសន្ទនាជាមួយគ្រូ និងមាតាបិតាសិស្ស។ វត្តមានបែបនេះរបស់នាយកសាលាធ្វើឱ្យអ្នកទាំងអស់គ្នាមានអារម្មណ៍ថាគាត់ជាអ្នកតាមដាននូវការសម្រេចចក្ខុវិស័យរបស់សាលារៀន»(គ្រប់គ្រងរដ្ឋបាល២០០៩,១៧៧)។

ភាពជាអ្នកដឹកនាំ គឺជាប្រធានបទមួយសំខាន់នៅក្នុងសតវត្សរ៍ចុងក្រោយនេះ។ អ្នកស្រាវជ្រាវជាច្រើនបានឱ្យនិយមន័យផ្សេងៗគ្នា។ អ្នកខ្លះយល់ថា អ្នកដឹកនាំមិនមែនកើតឡើងតាមធម្មជាតិនោះទេតែមនុស្សជាអ្នកបង្កើត។

អ្នកដឹកនាំគឺជាអ្នកដែលមានឥទ្ធិពលទៅលើសកម្មភាពក្រុមដើម្បីសម្រេចគោលដៅ។

អ្នកដឹកនាំ គឺជាការបញ្ចុះបញ្ចូលអ្នកដទៃឱ្យចូលរួម និងទទួលយកគោលដៅរបស់ក្រុមក៏ដូចជាគោលដៅរបស់ខ្លួនដែរ។

អ្នកដឹកនាំកសាងទំនាក់ទំនងស្អិតល្មួត និងកសាងខ្សែបណ្ដាយរបស់ក្រុម។ភាពខុសគ្នារវាងអ្នកដឹកនាំ និងអ្នកគ្រប់គ្រង៖ អ្នកគ្រប់គ្រង គឺជាអ្នកធ្វើឱ្យត្រូវការងារ ឯអ្នកដឹកនាំគឺជាអ្នកធ្វើការងារឱ្យត្រូវ។ អ្នកទី១ គឺជាអ្នកអនុវត្តនយោបាយ ឯអ្នកទី២ គឺជាអ្នកបង្កើតនយោបាយ។ អ្នកទី១ គឺជាអ្នកគិតក្នុងទម្រង់ជាដើមឈើ ឯអ្នកទី២ គឺជាអ្នកមានទស្សនៈទូលំទូលាយនៃជីវិត ហើយមានទំនាក់ទំនងជាមួយព្រៃឈើនៅតាមស្ថាប័ននីមួយៗ គេត្រូវការអ្នកគ្រប់គ្រងល្អដើម្បីសម្រួលការងារប្រចាំថ្ងៃដែលមានលក្ខណៈជាកិច្ចការវិលជុំ។ ចំណែកអ្នក ដឹកនាំដែលមានប្រសិទ្ធភាពមិនធ្វើការសម្រេចចិត្តច្រើន ហើយពួកគេផ្ដោតតែទៅលើចំណុចសំខាន់ដែលជាផលប៉ះពាល់តាមរយៈគណៈកម្មាធិការជាក្រុមដោយមានការទទួលខុសត្រូវខ្ពស់ (Fred. C,1996)។

ភាពជាអ្នកដឹកនាំ គឺជាសមត្ថភាពដែលអាចនាំ ឬជំរុញអ្នកឯទៀតក្នុងក្រុម ក្នុងអង្គភាពឱ្យពួតដៃគ្នាធ្វើការដើម្បីសម្រេចគោលដៅ។ អ្នកដឹកនាំជាបុគ្គលម្នាក់ ដែលត្រូវបានទទួលស្គាល់ពីសមាជិកក្នុងក្រុម ក្នុងអង្គភាពដើម្បីអនុវត្តការងារឱ្យសម្រេចតាមគោលបំណង ដែលបានគ្រោងទុក។ អ្នកដឹកនាំជាបង្គោលក្នុងការសម្រេចចិត្តដែលធ្វើឱ្យមានទំនាក់ទំនងគ្នាពីក្រុមមួយទៅក្រុមមួយ ហើយក៏ជាអ្នកជួយជំរុញលើកទឹកចិត្តផ្ដល់ជាសម្ភារៈក្នុងការធ្វើការងារនោះផង។ អ្នកដឹកនាំចែកជាពីរគឺ អ្នកដឹកនាំធម្មតា (ឪពុកម្ដាយក្នុងគ្រួសារ) និងអ្នកដឹកនាំផ្លូវការ (ដូចជានាយកសាលាជាដើម) (ការគ្រប់គ្រងរដ្ឋបាល ២០០៩)។

តាមរបាយការណ៍ស្រាវជ្រាវរបស់លោក Bennell Akyeampong ស្ដីពីការលើកទឹកចិត្តគ្រូបាននិយាយថាការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាពគឺជាការសំខាន់ណាស់ នឹងជួយលើកទឹកចិត្តដល់គ្រូបង្រៀនជាពិសេសនាយកសាលារៀន។ បើរចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងដែលបានបង្កើតឡើងដើម្បីគ្រប់គ្រង និងគាំទ្រគ្រូបង្រៀនមិនដំណើរការល្អវានាំឱ្យគ្រូបង្រៀនអាចបាត់បង់មនសិការក្នុងការទទួលខុសត្រូវលើវិជ្ជាជីវៈ និងការប្ដេជ្ញាចិត្តរបស់ខ្លួននៅកម្រិត សាលារៀន។ ការគ្រប់គ្រងគ្រូបង្រៀនគឺជាការចាំបាច់បំផុតពីព្រោះនៅកម្រិតនេះការងារ និងសមត្ថភាពបំពេញការងាររបស់គ្រូបង្រៀនត្រូវទទួលឥទ្ធិពលយ៉ាងខ្លាំងពីគុណភាពនៃការត្រួតពិនិត្យពីថ្នាក់ដឹកនាំខាងក្នុង និងខាងក្រៅសាលា (Peter,២០០៨)។

ការឱ្យនិយមន័យថា អ្នកដឹកនាំជាមនុស្សពោរពេញដោយទស្សនៈដឹងពីរបៀបផ្គុំរូបភាពដ៏ធំជាមួយគ្នាចេះលើកទឹកចិត្តខ្លួនឯង និងអ្នកដទៃឱ្យបំពេញការងារប្រែក្លាយជំនាញដឹកនាំទៅជាការអនុវត្ត ដោយប្រែក្លាយចំណុចអវិជ្ជមានទៅជាវិជ្ជមានយល់ពីតម្រូវការផ្សេងៗគ្នារបស់បុគ្គល និងការសម្រេចចិត្ត ( Randall M, 1994)។

ជារូមការដឹកនាំមានលក្ខណៈជាសិល្បៈ ហើយលទ្ធផលរបស់វាបង្ហាញឱ្យឃើញពីទំនាក់ទំនងរវាងអ្នកដឹកនាំ និងអ្នកដែលត្រូវគេដឹកនាំហើយគុណភាពរបស់អ្នកដឹកនាំត្រូវពឹងផ្អែកលើគុណភាពអ្នកដែលត្រូវគេដឹកនាំ។

ការពន្យល់លើពាក្យគ្រប់គ្រង គឺជា ការវិភាគបែបវិទ្យាសាស្ត្រលើដំណើរការបង្ហាញការងារ និងលទ្ធផលដើម្បីបង្កើនគុណភាព។ ការគ្រប់គ្រងល្អរបស់អង្គភាពគឺអាស្រ័យលើអ្នកគ្រប់គ្រងមានចំណេះដឹង ជំនាញ ចេះរៀបចំផែនការ ការត្រួតពិនិត្យ ការវាយតម្លៃតាមដានលើការងារប្រចាំថ្ងៃ ខែនិងប្រចាំឆ្នាំ ចេះរៀបចំកម្មវិធីសិក្សាវគ្គខ្លីវគ្គវែងដឹកនាំកសាងស្ថាប័នឱ្យមានការប្រែប្រួលជាបន្តបន្ទាប់មានឥរិយាបថ និងសីលធម៌ថ្លៃថ្នូរមានការគាំទ្រពីសហគមន៍នានា (W. Taylor,1994)។

ការគ្រប់គ្រងអង្គភាព ឬស្ថាប័នជាដំណើរការប្រើប្រាស់ ដើម្បីដឹកនាំការងាររបស់ខ្លួន និងធ្វើឱ្យប្រាកដថាបុគ្គលិក និងធនធានផ្សេងៗ របស់ខ្លួនប្រើប្រាស់បានត្រឹមត្រូវមានប្រសិទ្ធភាពនិងប្រកបដោយសន្សំសំចៃឆ្ពោះទៅរកការសម្រេចគោលដៅរបស់អង្គភាព។ អង្គភាពទីនេះសំដៅដល់អនុវិទ្យាល័យ វិទ្យាល័យ ដែលមាននាយកសាលាជាអ្នកដឹកនាំចាត់ចែងបុគ្គលិកឱ្យសមស្របនឹងទំហំការងាររបស់សាលាជាពិសេសរៀបចំបុគ្គលិក គ្រូបង្រៀនឱ្យត្រូវនឹងសមត្ថភាពឆន្ទៈជំនាញឯកទេស ដើម្បីទទួលបានលទ្ធផលជោគជ័យក្នុងអង្គភាព (ការគ្រប់គ្រងរដ្ឋបាល ២០០៩)។

ដូច្នេះ នាយក នាយិកាត្រូវមានមូលដ្ឋានរឹងមាំដោយមានការតាំងចិត្តបម្រើការងារបំពេញបេសកកម្មមានសញ្ញាប័ត្រខ្ពស់ អាកប្បកិរិយាល្អ មានផ្នត់គំនិត សហការក្នុងការ សម្រេចចិត្តមានទឹកចិត្តស្វាហាប់ប្រកបដោយថាមពល និងបទពិសោធន៍ក្នុងការដឹកនាំសាលារៀន (Wesleyan School, 2009)។ តួនាទី និងការទទួលខុសត្រូវ៖ តួនាទីនាយកមាន ៦ ផ្នែកគឺ៖ 1.ថ្លឹងថ្លែងពីតួនាទីគ្រប់គ្រង និងតួនាទីដឹកនាំ 2.មានសេចក្តីសង្ឃឹមខ្ពស់ និងតាមស្តង់ដារ 3.ទាមទារឱ្យការបង្ហាត់បង្រៀនទទួលបានលទ្ធផលខ្ពស់ 4.បង្កើតបរិយាកាសរៀនសូត្រ តាមបែបមនុស្សជំទង់ 5. ប្រើប្រភពចម្រុះធ្វើជាឧបករណ៍ដើម្បីវិភាគពីតម្រូវការចាំបាច់ និង 6.ទំនាក់ទំនងជាមួយសហគមន៍តាមរយៈសកម្មភាព( Leaders and Learners,2008)។

តាមតួនាទី និងការទទួលខុសត្រូវរបស់នាយក ៖ 1.ជាអ្នកដឹកនាំ 2. ជាអ្នកទំនាក់ទំនង 3.ជាអ្នករៀបចំកម្មវិធីសិក្សា និងសកម្មភាពសិស្ស 4. ជាអ្នករៀបចំបុគ្គលិក 5.ជាអ្នកគ្រប់គ្រង

6. ជាអ្នកទំនាក់ទំនងជាមួយសហគមន៍ និង 7.ជាអ្នកដឹកនាំកិច្ចការផ្សេងៗ ទៀត (Job Description,2008)។

តាមស្តង់ដារនាយក នាយិកាត្រូវមានសមត្ថភាព៥ យ៉ាងគឺៈ 1.ការបង្កើតគោលដៅ និងសេចក្តីសង្ឃឹម 2.យុទ្ធសាស្ត្របង្កើតធនធាន 3.ការរៀបចំផែនការសហការធ្វើការវាយតម្លៃការបង្រៀន និងកម្មវិធីសិក្សា 4.លើកតម្កើងការចូលរួមក្នុងការបង្រៀននិងរៀន និងការអភិវឌ្ឍ 5.ជំរុញការងារតាមលំដាប់ថ្នាក់ និងបង្កើតបរិយាកាសគាំទ្រ ( Leadership Dimensions,2007)។

គុណភាពនៃការអនុវត្តស្ថិតលើឱកាសនិងការប្រកួតប្រជែងរបស់អ្នកដឹកនាំសាលារៀន (នាយកសាលា)ក្នុងន័យនេះ គេសំដៅសមត្ថភាពរបស់អ្នកដឹកនាំសាលាទាំងអស់ចេះរៀបចំផែនការ ដើម្បីប្រកួតប្រជែងប្រចាំឆ្នាំជាពិសេសត្រូវមានផែនការកម្មវិធីប្រឡងប្រណាំងលើគុណភាព ដែលជាកត្តាមួយជំរុញឱ្យមាតា បិតាសិស្សមានជំនឿទុកចិត្តបញ្ជូនកូនទៅសាលារៀន ដើម្បីឱ្យកូនរបស់គាត់ទទួលបានការងារល្អ តែជាការពិតអ្នកគ្រប់គ្រងពុំមានប្រាក់បៀវត្សខ្ពស់ ការបណ្តុះបណ្តាលមិនគ្រប់គ្រាន់ ការធ្វើផែនការនៅមានកម្រិត និងយន្តការនៃការទទួលខុសត្រូវខ្សោយកម្រិតវិជ្ជាជីវៈទាប(Cisse and Okato,2009)នោះទេ។

ការគ្រប់គ្រង និងការដឹកនាំ គឺជាការងារស្មុគស្មាញ ដែលជាវិជ្ជាជីវៈរបស់នាយកសាលារៀន គុណភាពប្រសិទ្ធភាពគឺស្ថិតនៅលើការបណ្តុះបណ្តាលនិងបទពិសោធន៍របស់លោកនាយក។ នាយកនៅតាមវិទ្យាល័យតែងតែត្អូញត្អែរពីគុណភាពនៃការអប់រំ ជាពិសេសបារម្ភពីចំនួនសិស្សអវត្តមានច្រើន ដែលមិនមករៀនទៀងទាត់ និងសិស្សមួយចំនួនទៀតជក់បារីប្រើប្រាស់គ្រឿងញៀន។ ព័ត៌មានទាំងអស់នេះបានបញ្ជូនទៅមាតាបិតាសិស្សជារៀងរាល់ខែ ប៉ុន្តែព័ត៌មានត្រឡប់មកវិញពុំមានការគាំទ្រពីមាតាបិតាសិស្សនោះទេ។ សិស្សមិនគោរពបទបញ្ជារបស់សាលាគេចាត់ទុកថាជាបងធំដែលតែងបង្កការរំខានក្នុងថ្នាក់រៀន ហើយគ្រូភាគច្រើនចាត់ទុកថាជាបញ្ហាមួយក្នុងថ្នាក់ និងសាលាវិទ្យាល័យ ដែលជាដើមហេតុធ្វើឱ្យសិស្សមើលងាយគ្រូ ( Clawson, 2002)។

កង្វះខាតនៃការគ្រប់គ្រងរបស់នាយកសាលារៀន គឺជា ការធ្លាក់ចុះនៃគុណភាពអប់រំរបស់សិស្ស។ នាយកសាលារៀនភាគច្រើនតែងកេងបន្លំថវិកាតាមកម្មវិធីផ្សេងៗហើយទុកសម្រាប់ចាយផ្ទាល់ខ្លួនដោយជំនួសធនធានទាំងនោះជាសម្ភារៈតាមរយៈឱ្យសិស្សយកពីផ្ទះមកវិញ។ ជាងនេះទៅទៀត អំពើពុករលួយ បក្សពួកនិយម និងភាពកម្សោយនៃអ្នកដឹកនាំដែលជាការ

អស់សង្ឃឹមរបស់គ្រូបង្រៀនតាមថ្នាក់ ហើយបណ្តាលឱ្យគុណភាពរៀនរបស់សិស្សមានការធ្លាក់ចុះយ៉ាងខ្លាំង (Bayon and Gouel,2005)។

## VII- វិធីសាស្ត្រប្រមូលទិន្នន័យ

ការស្រាវជ្រាវនេះគឺប្រើប្រាស់តាមបែបគុណភាព និងបរិមាណ ដើម្បីប្រមូលទិន្នន័យ ពីនាយកនាយិកាវិទ្យាល័យតាមរយៈកម្រងសំណួរ និងការសម្ភាសន៍ពាក់កណ្តាលរចនាសម្ព័ន្ធ

- ការប្រមូលទិន្នន័យបែបគុណភាព ព្រោះយើងបានប្រើសម្ភាសន៍ពាក់កណ្តាលរចនាសម្ព័ន្ធចំនួន៨សំណួរជាមួយនាយកនាយិកា នាយករងតាមវិទ្យាល័យក្នុងខេត្ត និងក្រុងដូចជារាជធានីភ្នំពេញ ព្រៃវែង បាត់ដំបង និងខេត្តតាកែវ។

-ការប្រមូលទិន្នន័យបែបបរិមាណ ព្រោះយើងបានប្រើកម្រងសំណួរចែកជា៣ផ្នែកធំក្នុងនោះមាន១៩សំណួរ ដើម្បីឱ្យនាយកវិទ្យាល័យបំពេញកម្រងសំណួរទាំងនោះក្នុងការប្រមូលទិន្នន័យ។

ការសិក្សានេះនឹងប្រើកម្រងសំណួរដើម្បីប្រមូលទិន្នន័យពីនាយកសាលាវិទ្យាល័យចំនួន២៥នាក់ (៦.១៤% ក្នុងចំណោម ៤០៧វិទ្យាល័យ) ហើយ២៥នាក់នេះក៏ត្រូវធ្វើសម្ភាសន៍ពាក់កណ្តាលរចនាសម្ព័ន្ធ ហើយនាយករងវិទ្យាល័យចំនួន១០នាក់ក្នុងខេត្តនីមួយៗ និងនាយករង១៥នាក់ទៀតក្នុងរាជធានីភ្នំពេញក៏ត្រូវបំពេញកម្រងសំណួរ និងសម្ភាសន៍ពាក់កណ្តាលរចនាសម្ព័ន្ធដែរ។ វិធីសាស្ត្រជ្រើសរើសសំណាកដោយចៃដន្យចេញពីវិទ្យាល័យក្នុងរាជធានីភ្នំពេញ ខេត្តតាកែវ ខេត្តព្រៃវែង និងខេត្តបាត់ដំបង។ កម្រងសំណួរ និងសម្ភាសន៍នេះផ្តោតលើការគ្រប់គ្រងធនធានមនុស្ស ការគ្រប់គ្រងហិរញ្ញវត្ថុ ការគ្រប់គ្រងសម្ភារបរិក្ខារ ការគ្រប់គ្រងពេលវេលា និងទំនាក់ទំនងជាមួយសហគមន៍។

### ១-វិធីសាស្ត្រវិភាគទិន្នន័យ

- ទិន្នន័យកម្រងសំណួរនឹងត្រូវបានវិភាគជាមធ្យមភាគ ប្រេកង់ ភាគរយ និងកម្រិតទាបបំផុតខ្ពស់បំផុត។ ចំណែកឯទិន្នន័យនៃសម្ភាសន៍ពាក់កណ្តាលរចនាសម្ព័ន្ធត្រូវបានវិភាគជាលក្ខណៈរៀបរាប់ដោយផ្តោតលើនិន្នាការ ឬលក្ខណៈរួមនៃចម្លើយ។

- ព័ត៌មានដែលប្រមូលបានត្រូវធ្វើចំណាត់ថ្នាក់តាម Microsoft Excel, វិភាគតាមកម្មវិធី (SPSS) និង ( Alpha)៨.៧។

- ព័ត៌មានបែបសម្ភាសន៍ពាក់កណ្តាលរចនាសម្ព័ន្ធ ដែលទទួលបានមកនេះត្រូវធ្វើការវិភាគដោយប្រៀបធៀបជាមួយចំណាត់ថ្នាក់ស្តីពីតួនាទី និងមុខងាររបស់នាយកវិទ្យាល័យដែលបានកំណត់នៅក្នុងការរំលឹកទ្រឹស្តី និងទ្រឹស្តី CIPP (Context Input Process and Product)។

### ២-លទ្ធផលនៃការស្រាវជ្រាវដែលបានរំពឹងទុក

ការស្រាវជ្រាវនេះនឹងផ្តល់នូវការយល់ដឹងអំពីធាតុផ្សំនៃសមត្ថភាពនាយកវិទ្យាល័យនៅកម្ពុជា និងបញ្ហាប្រឈមក្នុងការដឹកនាំរបស់ពួកគេ។ ការសិក្សានេះនឹងបង្ហាញពីចំណុចខ្លាំងនៃសមត្ថភាពដឹកនាំ និងការលំបាកក្នុងការដឹកនាំដើម្បីឆ្លុះបញ្ចាំងពីចំណេះដឹង និងជំនាញដឹកនាំដែលនាយកវិទ្យាល័យចង់អភិវឌ្ឍ។

## VIII-លទ្ធផលនៃការសិក្សាស្រាវជ្រាវ

### ១-សញ្ញាប័ត្រចុងក្រោយបង្អស់

កម្រិតសញ្ញាប័ត្ររបស់នាយក នាយករងនៅតាមវិទ្យាល័យក្នុងចំណោម ៧០នាក់ មានដូចខាងក្រោម៖

សញ្ញាប័ត្រក្រោយឧត្តមសិក្សា (បរិញ្ញាបត្រជាន់ខ្ពស់) ចំនួន២៦នាក់ ក្នុងនោះអ្នកមានសញ្ញាប័ត្រ (បរិញ្ញាបត្រ+១)ចំនួន១០នាក់ និងអ្នកមានបរិញ្ញាបត្រអប់រំ១៦នាក់( បណ្តុះបណ្តាល គ្របខ័ណ្ឌគ្រូនៅសាកលវិទ្យាល័យភ្នំពេញ)។ ក្រៅពីនេះនាយក នាយិកា នាយករងសុទ្ធតែជាអ្នកមានកម្រិតសញ្ញាប័ត្រជាបរិញ្ញាបត្រអប់រំ បរិញ្ញាបត្រ+១ និងគ្រូកម្រិតមូលដ្ឋានក្នុងនោះក៏មានគ្រូបឋមសិក្សាផងដែរ។ ដោយឡែកអ្នកមានសញ្ញាប័ត្រទុតិយភូមិបានបន្តយកត្រឹមតែ បរិញ្ញាបត្រប៉ុណ្ណោះ។

តាមរយៈសញ្ញាប័ត្រទាំងអស់នោះបានសបញ្ជាក់ថា គណៈ គ្រប់គ្រងតាមវិទ្យាល័យពុំមានសមត្ថភាពដូចគ្នាឡើយអ្នកខ្លះទាប និងអ្នកខ្លះខ្ពស់អាស្រ័យលើការព្យាយាមរៀនសូត្រ និងឱកាសដែលតម្រូវឱ្យគណៈគ្រប់គ្រងខ្លះមានលទ្ធភាពបន្តការសិក្សា។ ចំណែកឯការបណ្តុះបណ្តាលក៏មានរយៈពេលពុំដូចគ្នាដែរអ្នកខ្លះរៀនរយៈពេល៣ ឆ្នាំ និងខ្លះទៀតពី៥ ទៅ៦ឆ្នាំ ដែលបញ្ជាក់ថាសមត្ថភាពរបស់អ្នកគ្រប់គ្រងអង្គភាពពុំអាចដូចគ្នាទេអាស្រ័យលើរបប នយោបាយ មនោគមវិជ្ជា ការបណ្តុះបណ្តាលវគ្គវែង វគ្គខ្លី ដែលក្រសួងអប់រំ យុវជន និងកីឡា ព្រមទាំង អង្គការជាតិ និងអន្តរជាតិមួយចំនួនបានធ្វើការបណ្តុះបណ្តាល។ ប៉ុន្តែលោកនាយក នាយករង ដែលមានកម្រិតសញ្ញាប័ត្រទាប (គ្រូអនុវិទ្យាល័យ និងគ្រូបឋម) និងជូនកាលទៀតបណ្តាលមក ពីកត្តាកង្វះធនធានមនុស្ស បច្ចេកទេសក្នុងការគ្រប់គ្រង ។

### ២-អំពីភេទ

អ្នកចូលរួមក្នុងការស្រាវជ្រាវនេះមានចំនួន៧០នាក់ក្នុងនោះស្ត្រីចំនួន០៧នាក់ស្មើ១០% បុរស៦៣នាក់ស្មើ៩០%។ លទ្ធផលនេះបង្ហាញឱ្យឃើញថា គណៈគ្រប់គ្រងវិទ្យាល័យពុំទាន់មានលក្ខណៈយេនឌ័រឆ្លើយតបទៅនឹងគោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងអាណត្តិ ទី ៥

(២០១៣) នៅឡើយដែលក្នុងគោលនយោបាយរាជរដ្ឋាភិបាលបញ្ជាក់ថានឹងខិតខំលើកកម្ពស់តម្លៃយេនឌ័រចាប់តាំងពីកម្រិតមូលដ្ឋានរហូតដល់អ្នកនយោបាយដូចជារដ្ឋមន្ត្រី អភិបាលខេត្ត ក្រុងនាយក នាយករងព្រោះការងារមួយចំនួនតម្រូវឱ្យនាយិកា នាយិការងជាអ្នកដោះស្រាយ និងទទួលបន្ទុក ប៉ុន្តែស្ត្រីគួរពង្រឹងសមត្ថភាពឱ្យបានពេញលេញដើម្បីសក្តិសមជាអ្នកដឹកនាំ។

## ៣-អំពីអាយុ

តាមតួលេខបានបង្ហាញឱ្យឃើញថាអ្នកចូលរួមដែលមានអាយុតិចជាង៤០ឆ្នាំមានចំនួន១០នាក់ស្មើ១៤.៣០%។ ចំណែកឯអ្នកដែលមានអាយុច្រើនជាង៤០ឆ្នាំមាន៦០នាក់ស្មើ៨៥.៧% មានន័យថា អ្នកមានអាយុច្រើនជាង៤០ជាអ្នកមានបទពិសោធន៍ក្នុងការងារទាំងបច្ចេកទេសបង្រៀនក៏ដូចជាការគ្រប់គ្រងដែរ ដែលនាំឱ្យការគ្រប់គ្រងវិទ្យាល័យនោះមានអភិបាលកិច្ចល្អ។ ការកំណត់ពីអាយុនេះក៏បានឆ្លុះបញ្ចាំងពីសមត្ថភាពមនុស្ស ដែលមានអាយុតិចជាង៤០ឆ្នាំ ដែលមានកម្រិតសញ្ញាប័ត្រខ្ពស់ក្នុងការដឹកនាំ ទំនាក់ទំនង សម្របសម្រួលល្អ និងមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ទើបក្លាយជាគណៈគ្រប់គ្រងបាន។

## ៤-១ ការរៀបចំផែនការយុទ្ធសាស្ត្រ ៖



ដ្យាក្រាមនេះ បង្ហាញពីសមត្ថភាពរបស់គណៈគ្រប់គ្រងតាមវិទ្យាល័យស្តីពីការរៀបចំផែនការយុទ្ធសាស្ត្ររបស់អង្គភាពពុំមានសមត្ថភាពដូចគ្នា គឺអាស្រ័យលើចំណេះដឹងបទពិសោធន៍និងការយកចិត្តទុកដាក់របស់គាត់។ ដ្យាក្រាមនេះបង្ហាញឱ្យឃើញថា អ្នកដែលគ្មានសមត្ថភាពមាន០២នាក់ មានសមត្ថភាពតិច០៥នាក់ មានសមត្ថភាពមធ្យម៣៣នាក់មានសមត្ថភាពច្រើន២៦នាក់ មានសមត្ថភាពល្អប្រសើរ៣នាក់ គ្មានចម្លើយ០១នាក់។ កម្រិតសមត្ថភាពទាប៧.១% និងខ្ពស់បំផុត៤.៣% ឆ្លុះបញ្ចាំងឱ្យឃើញថាការរៀបចំផែនការយុទ្ធសាស្ត្រនៅក្នុងអង្គភាពមិនទាន់បានល្អនៅឡើយដូចជាផែនការអភិវឌ្ឍស្ថាប័ន ដែលសំដៅលើការកែទម្រង់បរិស្ថានការងារ គោលនយោបាយគ្រប់គ្រងរចនាសម្ព័ន្ធ ការគ្រប់គ្រងលំហូរការងារ ការកំណត់សូចនាករគោលដៅការងារ និងផែនការអភិវឌ្ឍការងារធនធានមនុស្ស។ ចំណែកឯលទ្ធផលដែលបានពីសម្ភាសន៍ពាក់កណ្តាលរចនាសម្ព័ន្ធមានដូចជា៖

ការរៀបចំផែនការយុទ្ធសាស្ត្ររបស់វិទ្យាល័យ

ក- ពង្រឹងការងាររដ្ឋបាល

- ប្រជុំគណៈកម្មការធ្វើផែនការសកម្មភាពប្រចាំឆ្នាំ
- រៀបចំក្រុមប្រឹក្សា និងគណៈកម្មការ និងសកម្មភាពនានា
- រៀបចំទុកដាក់ឯកសារឱ្យមានសណ្តាប់ធ្នាប់
- ផ្សព្វផ្សាយឯកសារសារាចរ ច្បាប់ សេចក្តីណែនាំដល់គ្រូ សិស្ស ដើម្បីអនុវត្តឱ្យចំទិសដៅ។
- មានវិធានការលើកទឹកចិត្ត និងកែលម្អចំពោះបុគ្គលិក សិស្ស
- កែលម្អបរិស្ថានសាលា

ខ-លើកកម្ពស់គុណភាពសិក្សា

- ពង្រឹងការងារបច្ចេកទេស
- ពង្រឹងវិន័យគ្រូ សិស្ស

គ-ពង្រឹងការងារទំនាក់ទំនង

- ទំនាក់ទំនងជាមួយការិយាល័យ មន្ទីរ ក្រសួងដើម្បីទទួលការណែនាំនិងអនុវត្តន៍
- ទំនាក់ទំនងគ្រប់មជ្ឈដ្ឋាន អាជ្ញាធរ ដែនដី សប្បុរសជន មាតា បិតាសិស្សដើម្បីអភិវឌ្ឍសាលា ។

ការអនុវត្តកម្មវិធីសិក្សាមានការលំបាក ព្រោះកំណែទម្រង់ញឹកញាប់។ ផែនការយុទ្ធសាស្ត្ររបស់វិទ្យាល័យ គឺធ្វើឯកភាពគ្នាទូទាំងកម្រងដោយមានការចូលរួមពីសំណាក់នាយកវិទ្យាល័យ អនុវិទ្យាល័យត្រូវរៀបចំគណៈកម្មការឱ្យមានការចូលរួមជាមួយ នាយក នាយករង

និងសហគមន៍។ ប្រជុំរួមដើម្បីរៀបចំផែនការយុទ្ធសាស្ត្រ អ្នកចូលរួមមានគណៈកម្មការទ្រទ្រង់សាលាប្រធានក្រុមបច្ចេកទេស។ ការលំបាករៀបចំផែនការយុទ្ធសាស្ត្រនៅមានកម្រិតសាលារៀនត្រូវធ្វើផែនការដើម្បីឱ្យសាលាមានដំណើរការល្អ និងពង្រឹងសមត្ថភាពគ្រូរៀបចំវិន័យសិស្សគ្រូគ្រប់គ្រងសម្ភារបរិក្ខារដែលមានក្នុងសាលានិងប្រមូលទិន្នន័យដោយការចូលរួមពីគ្រូ សិស្ស និងសាលារៀន ហើយត្រូវធ្វើផែនការធ្វើឱ្យសាលាដើម្បីឱ្យមានដំណើរការពង្រឹងសមត្ថភាពគ្រូរៀបចំវិន័យសិស្ស គ្រូគ្រប់គ្រងសម្ភារបរិក្ខារដែលមានក្នុងសាលាប្រមូលទិន្នន័យមានការចូលរួមពីគ្រូ សិស្ស និងខ្វះការសិក្សា។ការប្រជុំដើម្បីរៀបផែនការយុទ្ធសាស្ត្រ អ្នកចូលរួមគណៈកម្មការទ្រទ្រង់សាលា ប្រធានក្រុមបច្ចេកទេស ។

តាមទិន្នន័យនេះបញ្ជាក់យ៉ាងច្បាស់ថា ការរៀបចំផែនការយុទ្ធសាស្ត្ររបស់នាយកនាយករងពុំមានលក្ខណៈដូចគ្នាទេ ដែលតម្រូវឱ្យក្រសួងអប់រំ យុវជន និងកីឡារៀបចំបើក វគ្គបណ្តុះបណ្តាលការរៀបចំផែនការយុទ្ធសាស្ត្រជាវគ្គវែង វគ្គខ្លីដើម្បីឱ្យវិទ្យាល័យនីមួយៗ ដំណើរការបានល្អប្រសើរស្របតាមបេសកកម្ម ទស្សនវិស័យ និងចេះច្នៃប្រឌិតរបស់អង្គភាព។

### ៤-២-ការរៀបចំផែនការប្រតិបត្តិប្រចាំឆ្នាំ

តាមដ្យាក្រាមខាងលើបង្ហាញឱ្យឃើញថា ការរៀបចំផែនការប្រតិបត្តិប្រចាំឆ្នាំរបស់នាយកនាយករង គឺមានសមត្ថភាពមិនដូចគ្នាទេ៖ សមត្ថភាពតិចមាន៧.១% សមត្ថភាពមធ្យមមាន៣៧.១% សមត្ថភាពច្រើនមាន៤៤.១% សមត្ថភាពល្អប្រសើរមាន៧.១% គ្មានចម្លើយមាន៤.៣%មានន័យថាសមត្ថភាពក្នុងការរៀបចំផែនការប្រតិបត្តិប្រចាំឆ្នាំរបស់នាយក នាយករងវិទ្យាល័យមានកម្រិតទាប៧.១%និងកម្រិតខ្ពស់បំផុត៧.១%។ សមត្ថភាពនេះឆ្លុះបញ្ចាំងពីការរៀបចំផែនការប្រតិបត្តិប្រចាំឆ្នាំសម្រាប់អភិវឌ្ឍស្ថាប័ន។ តាមគោលនយោបាយក្រសួងអប់រំ យុវជន និងកីឡា គឺផ្តោតលើផែនការអភិវឌ្ឍស្ថាប័ននីមួយៗដែលត្រូវលើកជាគម្រោងទាំងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ ការទំនាក់ទំនងជាមួយសហគមន៍ និងសមាគម សប្បុរសជននិងការបណ្តុះបណ្តាលធនធានមនុស្សនៅក្នុងអង្គភាព។

តាមលទ្ធផលនៃសម្ភាសន៍បង្ហាញឱ្យឃើញថា៖

ការរៀបចំផែនការប្រតិបត្តិប្រចាំឆ្នាំរបស់នាយកវិទ្យាល័យ

- ប្រជុំធ្វើការបែងចែកពេលវេលា និងកំណត់មុខសញ្ញាអនុវត្ត
- នាយក នាយករង ប្រធានក្រុមបច្ចេកទេស

ការលំបាកៈកំណត់មុខសញ្ញាការងារខ្លះពុំអាចអនុវត្តបាន គេត្រូវរៀបចំផែនការប្រចាំ សប្តាហ៍ ប្រចាំខែ ប្រចាំឆ្នាំ ព្រមទាំងដាក់ផែនការឱ្យគ្រូអនុវត្ត និងចុះអធិការកិច្ចផ្ទៃក្នុង ដោយ អនុវត្តតាម ការណែនាំពីមន្ទីរអប់រំរាជធានី ខេត្ត។ ការពង្រឹងសមត្ថភាពសិស្សតាមការប្រជុំក្រុម បច្ចេកទេស ការខ្វះគ្រូតាមឯកទេសការរៀបចំផែនការប្រចាំឆ្នាំធ្វើឱ្យឯកភាពគ្នាក្នុងកម្រងវិទ្យាល័យខ្លះបាន ផ្អែកលើសន្និបាតអប់រំប្រចាំឆ្នាំការណែនាំរបស់ក្រសួងអប់រំ យុវជន និងកីឡា និងរបស់មន្ទីរអប់រំ ខេត្ត ដោយមានការចូលរួម ពីនាយក នាយករង ប្រធានក្រុមបច្ចេកទេស និងសហគមន៍មានការ លំបាកដោយប្រើពេលវេលាយូរ គឺរហូតពេញមួយថ្ងៃដើម្បីដំណើរការបាននាយករៀបចំផែនការ ប្រចាំឆ្នាំ រៀបចំគណៈកម្មការផ្សេងៗ រៀបចំប្រធានក្រុមបច្ចេកទេសតាមមុខវិជ្ជារៀបចំគ្រូទទួល បន្ទុកថ្នាក់បំណែងចែកភារកិច្ចតាមកាលវិភាគ។ ការរៀបចំផែនការប្រតិបត្តិ ប្រចាំឆ្នាំផ្អែកលើ ផែនការយុទ្ធសាស្ត្រប្រជុំផ្សព្វផ្សាយដល់ លោកគ្រូ អ្នកគ្រូ ដើម្បីអនុវត្ត ហើយការអនុវត្តនេះមិន បាន 100% គេត្រូវរៀបចំផែនការប្រចាំសប្តាហ៍ ខែ ឆ្នាំ និងចុះអធិការកិច្ចជាប្រចាំ។

ការរៀបចំផែនការប្រតិបត្តិប្រចាំឆ្នាំរួមមាន ៖

- ប្រជុំធ្វើការបែងចែកពេលវេលា និងកំណត់មុខសញ្ញាអនុវត្ត
- នាយក នាយករង ប្រធានក្រុមបច្ចេកទេស

ដូច្នេះទិន្នន័យនេះបានបញ្ជាក់យ៉ាងច្បាស់ថា នាយក នាយករងតាមវិទ្យាល័យពុំមាន សមត្ថភាពដូចគ្នាឡើយគឺកម្រិតខ្ពស់បំផុត៧.១% និងកម្រិតទាបបំផុត៤.៣% ដែលតម្រូវឱ្យ ក្រសួងអប់រំ យុវជន និងកីឡារៀបចំវគ្គបណ្តុះបណ្តាល។ ការដឹកនាំអង្គភាព ការប្រើប្រាស់ ធនធានមនុស្ស និងការចាយវាយថវិកាប្រចាំឆ្នាំឲ្យមានតម្លាភាព។ ក្នុងនោះដែរត្រូវលើកកម្ពស់ សមត្ថភាពមធ្យមឱ្យទៅកម្រិតខ្ពស់ ហើយកម្រិត ទាបទៅជាកម្រិតមធ្យមវិញ។

## ៤-៣-ការអភិវឌ្ឍគោលនយោបាយអប់រំ

តាមតួលេខក្នុងតារាងបានបង្ហាញឲ្យឃើញថា ក្នុងចំណោមអ្នកចូលរួមចំនួន ៧០នាក់ អ្នកមានសមត្ថភាពតិច១០% អ្នកមានសមត្ថភាពមធ្យម៣៥.៧% អ្នកមានសមត្ថភាពច្រើន ៤៥.៧% អ្នកមានសមត្ថភាពល្អប្រសើរ៥.៧% និងអ្នកគ្មានចម្លើយ២.៩%។ តួលេខនេះបាន បង្ហាញពីគម្លាតរវាងសមត្ថភាពរបស់គណៈគ្រប់គ្រងវិទ្យាល័យ គឺកម្រិតទាប១០% និងកម្រិត ខ្ពស់បំផុត៥.៧%។ កាលណាពួកគេមិនទាន់យល់ច្បាស់ពីគោលនយោបាយអប់រំរបស់ក្រសួង អប់រំ យុវជន និងកីឡា ដែលជាហេតុនាំឱ្យការរៀបចំផែនការអភិវឌ្ឍអង្គភាពពុំបានចំគោល ដៅ។ គោលនយោបាយអប់រំរបស់ក្រសួងអប់រំ គឺធានាដល់គុណភាពនៃការបណ្តុះបណ្តាល

សិស្ស និងពង្រឹងសមត្ថភាពបុគ្គលិកសាស្ត្រាចារ្យ គ្រូបង្រៀន និងអភិវឌ្ឍអង្គភាពឱ្យរីកចម្រើនស្របតាមសម័យសកលភាវូបនីយកម្មដើម្បីសម្រេចគោលដៅអប់រំសម្រាប់ទាំងអស់គ្នាទាំងអស់គ្នាសម្រាប់ការអប់រំ ការធានាដល់ការអប់រំសាកលកម្មចំណេះទូទៅ៩ឆ្នាំដោយមិនគិតថ្លៃនិងអភិវឌ្ឍអក្ខរកម្មវិជ្ជាជីវៈ និងលើកកម្ពស់គុណភាពអប់រំតាមរយៈកំណែទម្រង់ប្រព័ន្ធអប់រំ។

ដូច្នេះទិន្នន័យនេះបានបញ្ជាក់យ៉ាងច្បាស់ថា នាយក នាយករងតាមវិទ្យាល័យពុំមានសមត្ថភាពដូចគ្នាឡើយ ដែលតម្រូវឱ្យក្រសួងអប់រំ យុវជននិងកីឡាផ្សព្វផ្សាយគោលយោបាយអប់រំឱ្យបានយ៉ាងទូលំទូលាយ និងរៀបចំបើកវគ្គបណ្តុះបណ្តាលលើការអនុវត្តគោលនយោបាយអប់រំរបស់ក្រសួងអប់រំ យុវជននិងកីឡា។

### ៤-៤-ផែនការគ្រប់គ្រងហិរញ្ញវត្ថុ




តារាងខាងលើបង្ហាញឱ្យឃើញថាក្នុងចំណោមអ្នកចូលរួម ៧០នាក់ គឺអ្នកដែលគ្មានសមត្ថភាព ១.៤% អ្នកមានសមត្ថភាពតិច១១.៤% និងអ្នកមានសមត្ថភាពមធ្យម ៣០.០% ហើយអ្នកមាន សមត្ថភាពច្រើន៤០.០%។ ចំណែកឯអ្នកមានសមត្ថភាពល្អប្រសើរ ៨.៦% រីឯអ្នកគ្មានចម្លើយ ៨.៦%។ កម្រិតគម្លាត ១.៤%ទៅ៨.៦%បញ្ជាក់ថាការបែងចែកនិងប្រើប្រាស់

ថវិកាក្នុងអង្គភាពមិនទាន់បានសុក្រិត។ ភាគច្រើននៃនាយកនាយករងសុទ្ធតែមានឯកទេសផ្សេងៗគ្នា ពោលពុំមានឯកទេសជាអ្នកហិរញ្ញវត្ថុឬ ជាអ្នកគណនេយ្យនោះទេ។ តាមធម្មតាការគ្រប់គ្រង ហិរញ្ញវត្ថុជាដំណើរការ ដែលមិនតម្រូវឱ្យតែអ្នកទទួលបន្ទុកជំនាញហិរញ្ញវត្ថុម្នាក់ជាអ្នកអនុវត្ត និងគ្រប់គ្រងនោះទេ។ ផ្ទុយទៅវិញការងារនេះ ទាមទារឱ្យមន្ត្រីគ្រប់រូបគ្រប់លំដាប់ថ្នាក់មានចំណេះដឹងនិងការយល់ច្បាស់លាស់គ្រប់គ្នា ប៉ុន្តែគណៈគ្រប់គ្រងគ្រប់រូបចាំបាច់មានចំណេះដឹង និងយល់ច្បាស់ពីគោលការណ៍ហិរញ្ញវត្ថុ និងនីតិវិធីនៃការអនុវត្ត ព្រោះថាចំណេះដឹងនេះអាចជួយគេឱ្យយល់ច្បាស់ពីលក្ខខណ្ឌនៃការកសាងផែនការ ការកំណត់សមត្ថភាព និងការកំណត់ទិសដៅចំណាយមិនត្រឹមតែប៉ុណ្ណោះវាអាចជួយបង្កើនតម្លាភាពនិងគណនេយ្យភាពចំណាយ។ជា ទូទៅការចំណាយ និង ការរកចំណូលរបស់គណៈគ្រប់គ្រងត្រូវតែមានប័ណ្ណចំណូលជាសាច់ប្រាក់។ ការគ្រប់គ្រងចំនួនសាច់ប្រាក់ក្នុងបេឡាត្រូវកត់ត្រាចូលក្នុងបញ្ជីតាមដានថវិកា និងធ្វើរបាយការណ៍។ ការចាយវាយផ្សេងៗ ដែលមានប័ណ្ណចំណាយសាច់ប្រាក់គ្រប់គ្រងការចំណាយឱ្យបានត្រឹមត្រូវមាននីតិវិធីក្នុងការបញ្ជូនប័ណ្ណចំណាយ។

លទ្ធផលនៃការសម្ភាសន៍បានបង្ហាញឱ្យឃើញថា៖

ការគ្រប់គ្រងហិរញ្ញវត្ថុរបស់វិទ្យាល័យគឺធ្វើតាមការណែនាំរបស់មន្ទីរ ក្រសួង ការិយាល័យ។ ការគ្រប់គ្រងហិរញ្ញវត្ថុវិទ្យាល័យមានបង្កើតគណៈកម្មការគ្រប់គ្រងប្រើប្រាស់ថវិកាPB មួយ និងគណៈកម្មការត្រួតពិនិត្យPB មួយ គឺមុននឹងធ្វើអ្វីមួយត្រូវប្រជុំពិភាក្សាគ្នាយ៉ាងល្អិតល្អន់រវាងគណៈកម្មការទាំងពីរ។ ឧទាហរណ៍ មុននឹងទិញសម្ភារអ្វីមួយត្រូវពិភាក្សាក្នុងការទិញ ពេលទិញមកត្រូវឱ្យគណៈកម្មការត្រួតពិនិត្យលើតម្លៃនិងគុណភាពទំនិញទើបបញ្ចូលឃ្លាំង ការគ្រប់គ្រងហិរញ្ញវត្ថុ គឺបានបែងចែកអ្នកទទួលខុសត្រូវមានបេឡាគណនេយ្យ។ រាល់ការចំណាយត្រូវមានផែនការច្បាស់លាស់ និងគម្រោងចាយវាយតាមរយៈគ្រូទទួលបន្ទុកថ្នាក់ និងប្រធានក្រុមបច្ចេកទេស។រៀបចំគណៈកម្មការសហាជីពដើម្បីគ្រប់គ្រងចំណូលតាមទីផ្សារមានគណនេយ្យ និងបេឡាសម្រាប់គ្រប់គ្រងថវិកាបែងចែកគណៈកម្មការកណ្តាលប្រើប្រាស់ថវិកា។ រីឯការលំបាកវិញគឺប្រាក់ PB មកមិនទាន់ពេលវេលា ថវិកា ទឹក ភ្លើង ប្រើមិនគ្រប់គ្រាន់ ។វិទ្យាល័យខ្លះបានរៀបចំគណៈកម្មការសហាជីពដើម្បីគ្រប់គ្រងចំណូលតាមទីផ្សារ មានគណនេយ្យ និងបេឡាសម្រាប់គ្រប់គ្រងថវិកា បែងចែកគណៈកម្មការប្រើប្រាស់ថវិកាក្នុងសាលា រាល់ការចំណាយត្រូវមានផែនការច្បាស់លាស់តាមរយៈគ្រូទទួលបន្ទុកថ្នាក់ ប្រធានក្រុមបច្ចេកទេស ការគ្រប់គ្រងហិរញ្ញវត្ថុ ៖

- រៀបចំគណៈកម្មការគ្រប់គ្រង និងប្រើប្រាស់ថវិកា ( តាមការណែនាំរបស់ក្រសួង )គ្រប់គ្រងពេលវេលាក្នុងការដឹកនាំតាមនីតិវិធី និងការងារបែបងាយស្រួលក្នុងការបែងចែកកាលវិភាគផ្អែកលើគោលការណ៍ឯកទេសផលប្រយោជន៍សិស្ស និងគ្រូ ។

ដូច្នេះ ទិន្នន័យនេះបានបញ្ជាក់យ៉ាងច្បាស់ថា នាយក នាយករងតាមវិទ្យាល័យសំណូមពរឱ្យក្រសួងអប់រំ យុវជន និងកីឡារៀបចំវគ្គបណ្តុះបណ្តាលការគ្រប់គ្រងហិរញ្ញវត្ថុ និងការរៀបចំផែន ការប្រើប្រាស់ប្រកបដោយប្រសិទ្ធភាពខ្ពស់បំផុត ព្រោះការគ្រប់គ្រងហិរញ្ញវត្ថុមិនមានតម្លាភាពល្អវាជាប្រភពនៃបញ្ហាក្នុងអង្គភាពនីមួយៗ ។

៤-៥ ផែនការគ្រប់គ្រងធនធានសម្ភារៈ




ដ្យាក្រាមខាងលើបានបង្ហាញឱ្យឃើញថា អ្នកចូលរួមចំនួន ៧០នាក់ដែលឆ្លើយលើសំណួរទាក់ទងសមត្ថភាពស្តីពីផែនការគ្រប់គ្រងធនធានសម្ភារៈហើយបង្ហាញឱ្យឃើញ ថា អ្នកមានសមត្ថភាពតិច២.៩%ហើយអ្នកមានសមត្ថភាពមធ្យម៣៧.១%។ ចំណែកអ្នកមានសមត្ថភាពច្រើន៤៥.៧% មានសមត្ថភាពល្អប្រសើរ១២.៩% និងអ្នកគ្មានចម្លើយ១.៤%។កម្រិតទាប២.៩% និងកម្រិតខ្ពស់១២.៩% សបញ្ជាក់ថាអ្នកមានក្នុងការរៀបចំផែនការគ្រប់គ្រង និងការបែងចែក

ប្រើប្រាស់ធនធានសម្ភារៈនៅមានកម្រិតនៅឡើយ។ ការគ្រប់គ្រងសម្ភារៈត្រូវកំណត់មុខសញ្ញាបែងចែកភារកិច្ចដល់ប្រធានក្រុមបច្ចេកទេសក្នុងការប្រើប្រាស់ក៏ដូចជា ការថែទាំ និងការគ្រប់គ្រងឱ្យបានល្អ។

លទ្ធផលនៃការសម្ភាសន៍មានដូចខាងក្រោម៖

ការគ្រប់គ្រងធនធានសម្ភារៈរបស់វិទ្យាល័យ ត្រូវតែមានការចាត់តាំងយាមកាមពេលយប់រាល់ការប្រើប្រាស់ត្រូវមានបញ្ជីស្លាមត្រឹមត្រូវរៀបចំឱ្យមានឃ្លាំង អ្នកចាំឃ្លាំង និងមាននាយករងម្នាក់គ្រប់គ្រងនិងថែរក្សាសម្បត្តិរដ្ឋ។ សម្ភារៈក្នុងវិទ្យាល័យមានអ្នកទទួលខុសត្រូវតាម ផ្នែកនីមួយៗ បន្ទប់ពិសោធន៍ បណ្ណាល័យ ការិយាល័យ សាលា គេហកិច្ច រោងជាង និងថ្នាក់ រៀន កុំព្យូទ័រ សម្ភារៈក្នុងវិទ្យាល័យមានអ្នកទទួលខុសត្រូវតាមផ្នែកនីមួយៗ បណ្ណាល័យ ឬ សាលា គេហកិច្ច រោងជាង និងថ្នាក់រៀនធម្មតា ។

ការគ្រប់គ្រងធនធានសម្ភារៈដូចជា បែងចែកមុខសញ្ញាទទួលខុសត្រូវតាំងពីសាលាដល់ថ្នាក់រៀនឱ្យម៉ត់ចត់គឺមាន ៨០%។

ដូច្នេះទិន្នន័យនេះបានបញ្ជាក់យ៉ាងច្បាស់ថា នាយក នាយករងតាមវិទ្យាល័យពុំមានសមត្ថភាពដូចគ្នាឡើយដែលតម្រូវឱ្យក្រសួងអប់រំយុវជន និងកីឡារៀបចំវគ្គបណ្តុះបណ្តាលលើការគ្រប់គ្រង និងរបៀបប្រើប្រាស់សម្ភារៈ និងប្រសិទ្ធភាពនៃសម្ភារៈឱ្យចំគោលដៅ។

## ៤-៦-ផែនការគ្រប់គ្រងពេលវេលា

តាមតួលេខក្នុងតារាងបានបង្ហាញថា មានអ្នកចូលរួមចំនួន៧០នាក់ក្នុងនោះសមត្ថភាពស្តីពីផែនការគ្រប់គ្រងពេលវេលាហើយសមត្ថភាពនីមួយៗនឹងបង្ហាញដូចតទៅ អ្នកមានសមត្ថភាពតិចមាន១.៤%អ្នកមានសមត្ថភាពមធ្យមមាន១១.៤% សមត្ថភាពច្រើនមាន៤៨.៦%មានសមត្ថភាពល្អប្រសើរមាន៣៧.១% អ្នកគ្មានចម្លើយមាន១.៤%។ កម្រិតសមត្ថភាពខុសគ្នាគឺកម្រិតទាប១.៤% និងកម្រិតខ្ពស់៣៧.១% មានន័យថា គណៈគ្រប់គ្រងតាមវិទ្យាល័យបានយល់ដឹងពីគ្រប់សកម្មភាពនៅក្នុងអង្គភាពរបស់ខ្លួនដូចជាសកម្មភាពប្រចាំថ្ងៃ ប្រចាំសប្តាហ៍ ប្រចាំខែ ប្រចាំឆ្នាំរបស់បុគ្គលិកទូទៅ និងសកម្មភាពប្រចាំថ្ងៃរបស់អ្នកដឹកនាំ។ បើយោងតាមសេចក្តីសម្រេចលេខ ០៧៣ស.រ.ច.ចុះថ្ងៃទី១៤ ខែឧសភា ឆ្នាំ១៩៨២របស់ក្រុមប្រឹក្សារដ្ឋមន្ត្រីស្តីពីការកំណត់ម៉ោងបំពេញការងារនៅវិទ្យាល័យ ១៦ម៉ោងក្នុងមួយសប្តាហ៍ជាម៉ោងកាតព្វកិច្ចសម្រាប់អ្នកបង្រៀនតែចំពោះមន្ត្រី និងគណៈគ្រប់គ្រងវិញ គឺអាចបង្រៀនបានត្រឹម៨ម៉ោងប៉ុណ្ណោះ។ នាយក នាយករងតាមវិទ្យាល័យត្រូវតែចេះបែងចែកម៉ោងចំពោះលោកគ្រូអ្នកគ្រូឱ្យមានចំនួនម៉ោងគ្រប់។ លោកគ្រូ អ្នកគ្រូខ្លះអាចបង្រៀនពីរមុខវិជ្ជាក៏អាចមានដែរ។ ចំពោះគ្រូ

បន្ទុកថ្នាក់វិញ បង្រៀនត្រឹមតែ១៥ ម៉ោងព្រោះ ៣ ម៉ោងទៀតជាម៉ោងគ្រូបន្ទុកថ្នាក់(ការសម្អាតថ្នាក់ការតុបតែង លម្អថ្នាក់រៀន ការគ្រប់គ្រងវត្តមាន អវត្តមានសិស្ស គ្រប់គ្រងការអប់រំសីលធម៌ គ្រប់គ្រងឯកសារផ្សេងដូចជាឯកសារបង្រៀន និងឯកសារការចូលរួមសង្គម)។

លទ្ធផលនៃការសម្ភាសន៍

ការគ្រប់គ្រងពេលវេលាក្នុងការដឹកនាំតាមវិទ្យាល័យ (ការបែងចែកកាលវិភាគលើការបង្រៀន)ការបែងចែកភារកិច្ចតាមជំនាញឯកទេស និងការទទួលខុសត្រូវរបស់បុគ្គលិកម្នាក់ៗ ការបែងចែកកាលវិភាគតាមការណែនាំរបស់ក្រសួង និងមន្ទីរ ដែលមាននាយករងទទួលបន្ទុកបច្ចេកទេសជាអ្នកទទួលខុសត្រូវ។ ការគ្រប់គ្រងពេលវេលាដោយធ្វើបំណែងចែកភារកិច្ចបុគ្គលិកក្នុងវិទ្យាល័យហើយពង្រឹងតាមផ្នែកនីមួយៗ នៅក្នុងវិទ្យាល័យគ្រប់គ្រងពេលវេលា ដោយធ្វើបំណែងចែកសម្ភារៈ គ្រប់គ្រងបុគ្គលិកហើយពង្រឹងការតាមដានតាមផ្នែកនីមួយៗនាយករងមួយរូបទៀតទទួលបន្ទុកបច្ចេកទេសរៀបចំកាលវិភាគតាមការណែនាំរបស់ក្រសួងដោយគិតពីផលប្រយោជន៍សិស្សផងគ្រូផង ។

### ៤-៧-ផែនការគ្រប់គ្រងគម្រោង

តាមតួលេខក្នុងតារាងបានបង្ហាញថា មានអ្នកចូលរួមចំនួន៧០នាក់ក្នុងនោះសមត្ថភាពស្តីពីផែនការគ្រប់គ្រងគម្រោងហើយសមត្ថភាពនីមួយៗនឹងបង្ហាញដូចជា អ្នកមានសមត្ថភាពតិចស្មើ៧.១% អ្នកមានសមត្ថភាពមធ្យមស្មើ៤០.០% អ្នកមានសមត្ថភាពច្រើនស្មើ៣៨.៣% ហើយអ្នកមានសមត្ថភាពល្អប្រសើរស្មើ១១.៤%។ចំណែកឯអ្នកគ្មានចម្លើយស្មើ២.៩%។ បើយើងប្រៀបធៀបរវាងសមត្ថភាពរបស់គណៈគ្រប់គ្រង ដែលមានកម្រិតទាបស្មើ៧.១% និងកម្រិតខ្ពស់ស្មើ១១.៤%។ សមត្ថភាពនេះបានឆ្លុះបញ្ចាំងពីការដឹកនាំ និងការរៀបចំការលើកគម្រោង និងដំណើរការរបស់វា។ កាលណាគេរៀបចំគម្រោងត្រូវតែទាក់ទងជាមួយថវិកា។ ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈមាត្រា៣៩ ការគ្រប់គ្រងគម្រោងថវិកាប្រចាំឆ្នាំអ្នករៀបចំត្រូវមានសមត្ថភាពដូចជា៖

- ការអភិវឌ្ឍគម្រោង
- វិធីសាស្ត្រនៃការអភិវឌ្ឍគម្រោង
- ព័ត៌មានតម្រូវការក្នុងការអភិវឌ្ឍគម្រោង

ដូច្នេះទិន្នន័យនេះបានបញ្ជាក់យ៉ាងច្បាស់ថា នាយក នាយករងតាមវិទ្យាល័យនៅមានកម្រិតទាបខាងផែនការធ្វើគម្រោងដែលតម្រូវឱ្យក្រសួងអប់រំ យុវជន និងកីឡារៀបចំវគ្គបណ្តុះបណ្តាលពីការរៀបចំគម្រោង ឬផែនការនេះឡើង។

៤-៨-ការសម្របសម្រួល

តាមតួលេខក្នុងតារាងបានបង្ហាញថា មានអ្នកចូលរួមចំនួន៧០នាក់បានឆ្លើយតបទៅនឹងកម្រងសំណួរ ដែលទាក់ទងទៅនឹងសមត្ថភាពការសម្របសម្រួលហើយសមត្ថភាពនីមួយៗនឹងបង្ហាញដូចតទៅអ្នកមានសមត្ថភាពតិចស្មើ១.៤% អ្នកមានសមត្ថភាពមធ្យមស្មើ៣០.០% អ្នកមានសមត្ថភាពច្រើនស្មើ៤៤.៣%មានសមត្ថភាពល្អប្រសើរស្មើ២៤.៣% ។ បើធៀបកម្រិតទាប១.៤%រឹងកម្រិតខ្ពស់២៤.៣% សមត្ថភាពនេះបានឆ្លុះបញ្ចាំងពីការដោះស្រាយបញ្ហាការសម្របសម្រួលក្នុងការដឹកនាំបុគ្គលិក ការបណ្តុះបណ្តាលសិស្ស សមាគមមាតា បិតាសិស្ស ក្រុមប្រឹក្សាអប់រំ ក្រុមប្រឹក្សាវិន័យក្រុមប្រឹក្សាយុវជន ក្រុមប្រឹក្សាសាងសងសាលា ក្រុមប្រឹក្សាបច្ចេកទេស ក្រុមប្រឹក្សាគរុកោសល្យអង្គភាពដៃគូអភិវឌ្ឍ និងសប្បុរសជននានា ដែលភាគច្រើននៃក្រុមប្រឹក្សាមាននាយក និងនាយករងជាប្រធាន អនុប្រធានរបស់ក្រុម ប្រឹក្សាក្នុងការដឹកនាំអង្គប្រជុំ។ អ្នកសម្របសម្រួលត្រូវស្គាល់ឱ្យបានច្បាស់សមាសភាពចូលរួមទស្សនវិស័យបេសកកម្ម វត្ថុបំណងការងារ និងផលប៉ះពាល់ខាងក្នុង និងខាងក្រៅ។ តាមកម្រិតសមត្ថភាពក្នុងការសម្របសម្រួល ២៤.៣%គឺមិនទាន់ឆ្លើយតបក្នុងការអភិវឌ្ឍអង្គភាពនៅឡើយដែលតម្រូវឱ្យក្រសួងអប់រំ យុវជន និងកីឡារៀបចំវគ្គបណ្តុះបណ្តាលការសម្របសម្រួល ការលើកទឹកចិត្ត និងការវាយតម្លៃដល់នាយក នាយករងតាមវិទ្យាល័យ។

៤-៩-ការសម្រេចចិត្តលើការគ្រប់គ្រង

តាមតួលេខក្នុងតារាងបានបង្ហាញថា មានអ្នកចូលរួមចំនួន៧០នាក់បានឆ្លើយតបទៅនឹងកម្រងសំណួរក្នុងការសម្រេចចិត្តលើការគ្រប់គ្រង ហើយសមត្ថភាពនីមួយៗនឹងបង្ហាញដូចតទៅអ្នកមានសមត្ថភាពតិចស្មើ៤.៣%អ្នកមានសមត្ថភាពមធ្យមស្មើ២៨.៦%អ្នកមានសមត្ថភាពច្រើនស្មើ៥៤.៣%អ្នកមានសមត្ថភាពល្អប្រសើរស្មើ១២.៩%។អ្នកមានសមត្ថភាពកម្រិតខ្ពស់បំផុត១២.៩% ដែលឆ្លុះបញ្ចាំងពីការសម្រេចចិត្តលើការគ្រប់គ្រងនៅមានកម្រិតព្រោះនាយកសាលារៀនជាប្រតិភូរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡាដែលទទួលបន្ទុកអភិបាល សាលារៀនមួយក្នុងនាមតំណាងឱ្យរដ្ឋមន្ត្រី។ នាយកសាលាជាប្រមុខអង្គភាពជាតំណាងឱ្យ អំណាច

រដ្ឋបាលដែលទទួលខុសត្រូវខ្ពស់បំផុត ក្នុងការសម្រេចចិត្តចាត់ចែងការងារដឹកនាំគ្រប់គ្រងសកម្មភាពរបស់សាលារៀនទាំងផ្នែករដ្ឋបាលបច្ចេកទេសនិងទំនាក់ទំនង។

លទ្ធផលនៃការធ្វើសម្ភាសន៍ស្តីអំពីជាការធ្វើការសម្រេចចិត្តក្នុងការគ្រប់គ្រងវិទ្យាល័យមានដូចជា៖

- គ្រប់គ្រងវិន័យសណ្តាប់ធ្នាប់គ្រូ សិស្ស

- អប់រំកែលំអគ្រូ សិស្សដែលមានការខ្វះខាតឱ្យបានទាន់ពេល ។ ចំណែកឯការពិបាកអវត្តមានច្រើនដោយបញ្ហាជីវភាពគ្រួសារ ។

នាយកវិទ្យាល័យនីមួយៗត្រូវមានការសម្រេចចិត្តខ្ពស់ទោះបីជាខុស ឬត្រូវ ត្រូវហ៊ានសម្រេចរួចកែលម្អក្រោយ ត្រូវមានគំនិតច្នៃប្រឌិតនិងការទទួលខុសត្រូវខ្ពស់ដោយពឹងផ្អែកនិងសហការជាមួយបុគ្គលិក។ ការលំបាករបស់បុគ្គលិកក្នុងការគ្រប់គ្រងវិទ្យាល័យគឺបើចង់ធ្វើអ្វីមួយត្រូវពិភាក្សាជាមួយនាយក នាយករង ដោយផ្អែកលើការណែនាំរបស់ថ្នាក់លើ។ អង្គភាពដំណើរ ការបានល្អត្រូវមានលក្ខណៈមួយសមស្របក្នុងការរៀបចំសមាសភាពអ្នកដឹកនាំតាំងពីនាយកប្រធានក្រុមបច្ចេកទេស និង គ្រូទទួលបន្ទុក។ការសម្រេចចិត្តក្នុងការគ្រប់គ្រងបានបែងចែកអ្នកចូលរួមមាននាយករងទទួលបន្ទុកបច្ចេកទេស ទទួលបន្ទុករដ្ឋបាលទទួលបន្ទុកយុវជនប្រធាន បុគ្គលអ្នកគ្រូទទួលបន្ទុកថ្នាក់និងប្រធានក្រុមបច្ចេកទេសតាមមុខវិជ្ជា។ការសម្រេចចិត្តក្នុងការគ្រប់គ្រងត្រូវ :

- ប្រជុំពិភាក្សាស្តាប់មតិ នាយករង ប្រធានក្រុមបច្ចេកទេសតែគោរពគោលការណ៍ការងារ និងណែនាំស្របនិងគោលនយោបាយអប់រំការសម្រេចចិត្តក្នុងការគ្រប់គ្រងសាលា គឺទាមទារស្វែងយល់ពីស្ថានភាពបរិយាកាស ។

- ពេលវេលាសមស្របពិសេសពីបច្ចេកទេស និងវិធីដែលឆ្លើយតបទៅនឹងស្ថានភាពនោះ ។

## ៤-១០-អាកប្បកិរិយាដឹកនាំប្រតិបត្តិ

តាមតួលេខក្នុងតារាងបានបង្ហាញថាមានអ្នកចូលរួមចំនួន ៧០នាក់ក្នុងនោះសមត្ថភាពស្តីពីអាកប្បកិរិយាដឹកនាំប្រតិបត្តិដូចតទៅ៖អ្នកមានសមត្ថភាពតិចមានស្មើ៤.៣%មានសមត្ថភាពមធ្យម២០.០% មានសមត្ថភាពច្រើន៦២.៩% មានសមត្ថភាពល្អប្រសើរ១១.៤%។តួលេខនេះបង្ហាញឲ្យឃើញថា កម្រិតខ្ពស់បំផុត១១.៤% និងកម្រិតទាបបំផុត៤.៣%ដែលឆ្លុះបញ្ចាំងពីអាកប្បកិរិយារបស់នាយក នាយករង។ នាយក នាយរង ត្រូវមានសីលធម៌ ពាក្យសម្តីម៉ឺងម៉ាត់កាយវិការសមរម្យ ឥរិយាបថសក្តិសមទៅតាមតំណែងនីមួយៗនិងមានលក្ខណៈសម្បត្តិជាអ្នក

ដឹកនាំ គឺយល់ច្បាស់ពីកិច្ចការដែលត្រូវបំពេញក្នុងការងារតាមមុខងារមុខតំណែងចេះកំណត់ការងារឱ្យបុគ្គលិកម្នាក់ៗដើរស្របបេសកកម្មគោលដៅនិងវត្ថុបំណងរបស់អង្គភាពស្ថាប័ន និងធានាសុក្រឹតភាពមិនលំអៀងក្នុងការវាយតម្លៃមន្ត្រី ក្រោមការគ្រប់គ្រងរបស់ខ្លួនព្រមទាំងបំពេញការងារស្នូលស្របតាមកម្មវិធី។ ជាមួយនេះគណៈគ្រប់គ្រង និងមន្ត្រីរាជការត្រូវមានទឹកចិត្តស្រឡាញ់ ការងារ គំនិតផ្តួចផ្តើមច្នៃប្រឌិត បំពេញ កាតព្វកិច្ចជាក្រុមយល់ដឹងពីសភាពការណ៍ ភក្តីភាព ចំពោះស្ថាប័នប្រឹងប្រែងឱ្យអស់លទ្ធភាព ក្នុងការបំពេញការងារ ហ៊ានលះបង់កម្លាំងកាយកម្លាំងចិត្ត និងពេលវេលាបំពេញការងារ គោរពវិន័យ និងពេលវេលាបំពេញការងារ និងទទួលខុសត្រូវសកម្មភាព ដែលខ្លួនបានអនុវត្ត។ នាយក នាយករងត្រូវចេះលើកទឹកចិត្តដល់បុគ្គលិកគ្រូបង្រៀនតាមរយៈសម្ភារប័ណ្ណសរសើរ ផ្តល់ចំណាត់ថ្នាក់តួនាទីផ្តល់ការងារសមស្របតាមសមត្ថភាព ការពិគ្រោះយោបល់ទំនាក់ទំនងល្អឧស្សាហ៍រំលឹក។ ត្រូវប្រើសម្តីសមរម្យសម្របសម្រួលគោរពគោលការណ៍ច្បាស់លាស់ ។ បើ តាមអនុក្រឹត្យស្តីពីក្រមសីលធម៌វិជ្ជាជីវៈគ្រូបង្រៀនមាត្រាទី១១ បានចែងថាគ្រូបង្រៀនត្រូវនិយាយដោយប្រុងប្រយ័ត្ន និងគិតទៅដល់ប្រតិឃាតនៃពាក្យសម្តីរបស់ខ្លួនចំពោះអ្នកសិក្សា និងសាធារណជនក្នុងការផ្តល់ព័ត៌មានអំពីការអប់រំទាំងសាធារណៈទាំងឯកជនតាមគ្រប់មធ្យោបាយផ្សព្វផ្សាយ។ គ្រូបង្រៀនមិនត្រូវ ធ្វើប្រជាភិថុតចំពោះអ្នកសិក្សាឡើយ ។ គ្រូបង្រៀនត្រូវដឹកនាំសកម្មភាពសិក្សាក្នុងថ្នាក់ និង ក្រៅថ្នាក់ និងលើកទឹកចិត្តដល់អ្នកសិក្សាជាប់ជាប្រចាំ។

ដូច្នេះទិន្នន័យនេះបានបញ្ជាក់យ៉ាងច្បាស់ថា នាយក នាយករងតាមវិទ្យាល័យសំណូមពរឱ្យក្រសួងអប់រំយុវជន និង កីឡារៀបចំវគ្គបណ្តុះបណ្តាលជាទ្រឹស្តីទាក់ទងជាមួយចិត្តសាស្ត្រគ្រប់គ្រងការលើកទឹកចិត្តស្តីពីរបៀបដឹកនាំការងារប្រតិបត្តិ។

## ៤-១១-ការគ្រប់គ្រងធនធានមនុស្ស




តាមតួលេខក្នុងតារាងបានបង្ហាញថាមានអ្នកចូលរួមចំនួន ៧០នាក់ក្នុងនោះសមត្ថភាពស្តីពីផែនការគ្រប់គ្រងធនធានមនុស្សមានដូចតទៅ៖ មានសមត្ថភាពតិច៤.៣% មានសមត្ថភាពមធ្យម២៨.៦% មានសមត្ថភាពច្រើន៥២.៩% មានសមត្ថភាពល្អប្រសើរ១២.៩%។ កម្រិតសមត្ថភាពខុសគ្នារវាងកម្រិតទាប៤.៣% និងកម្រិតខ្ពស់បំផុត១២.៩%។គម្លាតសមត្ថភាពនេះបានឆ្លុះបញ្ចាំងពីសកម្មភាពរបស់គណៈគ្រប់គ្រងតាម វិទ្យាល័យក្នុងការចាត់ចែងប្រើប្រាស់ធនធានមនុស្សទៅតាមសមត្ថភាពជំនាញកម្រិត និងក្របខ័ណ្ឌដែលមានស្រាប់ក្នុងអង្គភាពនៅមានកម្រិត។ កត្តាដែលការចាត់ចែងធនធានមនុស្សមិនបានល្អដោយសារការខ្វះខាតធនធានមនុស្សនិងសមត្ថភាពនៅមានកម្រិត។ ករណីបុគ្គលិកមានសមត្ថភាពមិនគ្រប់គ្រាន់ នាយកនាយករង ត្រូវពន្យល់ការងារដែលអាចធ្វើបាន ហើយធ្វើតាមជំហានៗ មិនត្រូវប្រគល់ការងារឱ្យច្រើនពេកក្នុងពេលតែមួយមិនត្រូវប្រគល់ការងារឱ្យអនុវត្តមុនពេលមានការវាយតម្លៃជាជំហានៗ ហើយការផ្តល់យោបល់ដល់បុគ្គលិកនោះគួរតែរៀនបន្តទៀតឬបញ្ជូនទៅសិក្សាបន្ត។ តាមធម្មតា

ការគ្រប់គ្រងធនធានមនុស្សគឺជាផែនការ យុទ្ធសាស្ត្រមួយដើម្បីកំណត់ពីភាពជោគជ័យនិងភាពបរាជ័យក្នុងការងារប្រតិបត្តិ។ ការសម្រេចចិត្តខ្ពស់របស់អ្នកគ្រប់គ្រងក្នុងការដាក់សមត្ថភាពជំនាញមនុស្សទៅតាមគោលដៅការងារ និងទំហំសមមូលរវាងការងារនិងធនធានមនុស្ស។ ការប្រើប្រាស់ធនធានមនុស្សប្រកបដោយគុណភាព គឺបានឆ្លុះបញ្ចាំងទៅលើការប្រើប្រាស់ពេលវេលាការអនុវត្តការងារការផ្តល់រង្វាន់ការចំណាយចំគោលដៅការប្រើប្រាស់ជំនាញបច្ចេកទេសការកំណត់បែបបទរដ្ឋបាលលិខិត បទដ្ឋានការតាមដានវាយតម្លៃត្រួតពិនិត្យ ការផ្សព្វផ្សាយប្រកបដោយភាពសុចរិតរបស់គណៈគ្រប់គ្រងអង្គភាពដែលអាចនិយាយបានថា ការគ្រប់គ្រងធនធានមនុស្ស គឺជាការគ្រប់គ្រង ប្រព័ន្ធការងារទាំងមូលរបស់អង្គភាព ដើម្បីឆ្លើយតបទៅនឹងទស្សនវិស័យបេសកកម្មរបស់ អង្គភាពក្នុងការបំពេញការងាររបស់សាស្ត្រាចារ្យគ្រូបង្រៀនបុគ្គលិកដោយភាពរលូនដោយទទួលបានភាពជោគជ័យ។ លទ្ធផលនៃការសម្ភាសន៍មានជាមួយនាយក នាយករងស្តីពីការគ្រប់គ្រងសាស្ត្រាចារ្យ បុគ្គលិកវិទ្យាល័យបានរកឃើញ ថា វិទ្យាល័យភាគច្រើនដំណើរការល្អ គ្រូភាគច្រើនមានសមត្ថភាពតែមុខវិជ្ជាខ្លះដែលខ្វះគ្រូត្រូវយកគ្រូមុខវិជ្ជាផ្សេងតែត្រូវបណ្តុះបណ្តាលតាមក្រុមបច្ចេកទេស និងត្រួតពិនិត្យតាមដានជាប្រចាំពីក្រុមបច្ចេកទេសហើយធ្វើការវាយតម្លៃ។ការគ្រប់គ្រងបុគ្គលិកសាស្ត្រាចារ្យដោយតាមដានការអនុវត្តផែនការប្រជុំ និង វាយតម្លៃលំអ ការលើកទឹកចិត្ត និងជូនរង្វាន់តាមលទ្ធភាព។ រាល់ម៉ោងធ្វើការច្បាប់បុគ្គលិកទី ចាត់ការត្រូវចុះហត្ថលេខាលើសៀវភៅវត្តមានបុគ្គលិកព្រឹកមួយដងនិងរសៀលមួយដងរីឯបុគ្គលិកបង្រៀនបើត្រូវបង្រៀនព្រឹកចុះហត្ថលេខាពេលព្រឹកបើបង្រៀនរសៀលត្រូវចុះហត្ថលេខារសៀល រីឯនាយករងមានសៀវភៅស្រង់វត្តមានផ្ទាល់មួយទៀតសម្រាប់ស្រង់វត្តមាន គ្រូណាសុំច្បាប់ គ្រូណាមិនសុំច្បាប់ គ្រូណាមកយឺតគ្រូណាចេញមុនម៉ោងចំពោះបុគ្គលិក ណាដែលគោរពវិន័យបានល្អស្នើដំឡើងកាំប្រាក់រាល់ពេលត្រូវវេនដំឡើង និងចារដាក់និទ្ទេស ល្អចំពោះព័ត៌មានសម្រាប់ចេញទៅធ្វើគណៈមេប្រយោគប្រឡង ព្រមទាំងស្នើសុំមេដាយការងារប្រចាំឆ្នាំ។ យន្តការត្រួតពិនិត្យអធិការកិច្ចជាប្រចាំ និងមានការលើកទឹកចិត្តចំពោះអ្នកដែលមានស្នាដៃល្អ និងកែលំអអ្នកដែលមានការខ្វះខាត។ ការគ្រប់គ្រងសាស្ត្រាចារ្យបុគ្គលិកយើង បានរៀបចំបទបញ្ជាផ្ទៃក្នុងរបស់អង្គភាពប្រជុំផ្សព្វផ្សាយការណែនាំរបស់ក្រសួងមន្ទីរ និងដាក់ផែនការអនុវត្តត្រួតពិនិត្យ។ វិទ្យាល័យដំណើរការល្អសមត្ថភាពគ្រូភាគច្រើនមានតែមុខវិជ្ជាខ្លះ ត្រូវយកគ្រូមុខវិជ្ជាផ្សេងៗមកជំនួសរួចធ្វើការបណ្តុះបណ្តាលនិងត្រួតពិនិត្យតាមដានជាប្រចាំរបស់ក្រុមបច្ចេកទេសដើម្បីធ្វើការវាយតម្លៃ។

ដូច្នេះទិន្នន័យខាងលើបានបញ្ជាក់យ៉ាងច្បាស់ថាសមត្ថភាព នាយកនាយករងតាមវិទ្យាល័យ នៅមានកម្រិតដែលតម្រូវឱ្យក្រសួងអប់រំ យុវជន និងកីឡារៀបចំវគ្គបណ្ដុះបណ្ដាល ស្ដីពីការបែងចែកប្រើប្រាស់ និងការគ្រប់គ្រងធនធានមនុស្ស។

## ៤-១២-ទំនាក់ទំនងរវាងសហការី

តាមតួលេខក្នុងតារាងបានបង្ហាញថាមានអ្នកចូលរួមឆ្លើយសំណួរទំនាក់ទំនងរវាងសហការី មានចំនួន៧០នាក់ក្នុងចំណោមអ្នកផ្ដល់ចម្លើយទាំងនោះអ្នកដែល៖ មានសមត្ថភាពតិច១.៤% មានសមត្ថភាពមធ្យម១១.៤% មានសមត្ថភាពច្រើន៥០.០% មានសមត្ថភាពល្អប្រសើរ៣៥.៧%។ ទិន្នន័យនេះបង្ហាញឲ្យឃើញថាគម្លាតសមត្ថភាពខ្ពស់បំផុត៣៥.៧% និងកម្រិតទាប១.៤%មានន័យថាសមត្ថភាពទំនាក់ទំនង សហការីរបស់នាយក នាយរងមានលក្ខណៈល្អ។ តាមធម្មតា នាយកមានភារកិច្ចជាទីប្រឹក្សា គរុកោសល្យជាមួយគ្រូបង្រៀន និងបុគ្គលិក ជា មន្ត្រីរដ្ឋបាលជាអាជ្ញាធរអប់រំជាអធិការអប់រំអចិន្ត្រៃយ៍ និង ជា ភ្នាក់ងារអភិវឌ្ឍសហគមន៍ជាពិសេសការងារទំនាក់ទំនង ( ការងារទំនាក់ទំនងជាមួយ នាយករងគ្រូបង្រៀន បុគ្គលិក និងសិស្សានុសិស្ស ដើម្បីប្រសិទ្ធភាពផ្ទៃក្នុង )។

ដូច្នេះទិន្នន័យនេះបានបញ្ជាក់យ៉ាងច្បាស់ថា នាយក នាយករងតាមវិទ្យាល័យពុំមានសមត្ថភាពដូចគ្នាឡើយ ដែលតម្រូវឱ្យក្រសួងអប់រំ យុវជន និងកីឡារៀបចំណែកនាំពីការបែងចែកការងារក្នុងអង្គភាព។

## ៤-១៣-ការងារក្រុម

តាមតួលេខក្នុងតារាងបានបង្ហាញថា មានអ្នកចូលរួមចំនួន៧០នាក់ក្នុងនោះសមត្ថភាពស្ដីពីការងារក្រុមមានដូចតទៅ៖ មានសមត្ថភាពតិច១.៤% មានសមត្ថភាពមធ្យម៣២.៩% មានសមត្ថភាពច្រើន៥២.៩%មានសមត្ថភាពល្អប្រសើរ១២.៩%។កម្រិតសមត្ថភាពខ្ពស់បំផុត ១២.៩%និងកម្រិតសមត្ថភាពទាបបំផុត១.៤%។ សមត្ថភាពនៃការងារក្រុមបានឆ្លុះបញ្ចាំងពីសាមគ្គីផ្ទៃក្នុងការគ្រប់គ្រងប្រព័ន្ធការងារដោយរលូន និង ការបែងចែកបុគ្គលិកតាមជំនាញមុខវិជ្ជាវិជ្ជាជីវៈក្រុមបច្ចេកទេស។ តាមធម្មតាការបែងចែកក្រុមអាស្រ័យចំនួនបុគ្គលិក និងវិជ្ជាជីវៈបច្ចេកទេសការងារ។

ដូច្នេះទិន្នន័យនេះបានបញ្ជាក់យ៉ាងច្បាស់ថា នាយក នាយករងតាមវិទ្យាល័យពុំមានសមត្ថភាពដូចគ្នាឡើយ ដែលតម្រូវឱ្យក្រសួងអប់រំ យុវជន និងកីឡា លើកទឹកចិត្តឱ្យគណៈគ្រប់គ្រងចេះធ្វើការងារជាក្រុម។

## ៤-១៤-ការគ្រប់គ្រងភាពប្រែប្រួល

តាមតួលេខក្នុងតារាងបានបង្ហាញថា មានអ្នកចូលរួមចំនួន៧០នាក់ក្នុងនោះសមត្ថភាពស្តីពីការគ្រប់គ្រងភាពប្រែប្រួលមានដូចតទៅ៖ មានសមត្ថភាពតិច១១.៤% មានសមត្ថភាពមធ្យម៣៨.៦% មានសមត្ថភាពច្រើន៤១.៤% មានសមត្ថភាពល្អ ប្រសើរ៧.១% គ្មានចម្លើយ ១.៤%។ ការបម្រែបម្រួលក្នុងន័យកំណែទម្រង់គោលនយោបាយកម្មវិធីសិក្សា ចំនួនម៉ោងបង្រៀន វិធីសាស្ត្របង្រៀន កំណែទម្រង់ក្នុងការប្រឡងថ្នាក់ជាតិ។

ដូច្នេះទិន្នន័យនេះបានបញ្ជាក់យ៉ាងច្បាស់ថា នាយក នាយករងតាមវិទ្យាល័យពុំមានសមត្ថភាពដូចគ្នាឡើយ ព្រោះខ្លះក៏ទទួលបានការផ្សព្វផ្សាយ និងបណ្តុះបណ្តាល និងខ្លះទៀតមិនបានទទួលការបណ្តុះបណ្តាល និងការណែនាំពីថ្នាក់ក្រសួងទាល់តែសោះ។

## ៤-១៥ -ការតាមដានត្រួតពិនិត្យ និងវាយតម្លៃ

តាមតួលេខក្នុងតារាងបានបង្ហាញថា មានអ្នកចូលរួមចំនួន៧០នាក់ក្នុងនោះសមត្ថភាពស្តីពីតាមដានត្រួតពិនិត្យ និងវាយតម្លៃមានដូចតទៅ៖ មានសមត្ថភាពតិច១.៤% មានសមត្ថភាពមធ្យម២៥.៧% មានសមត្ថភាពច្រើន៦០.០% មានសមត្ថភាពល្អប្រសើរ១២.៩%។កម្រិតខ្ពស់នៃអ្នកមានសមត្ថភាពខ្ពស់បំផុតគឺ១២.៩% និង មានសមត្ថភាពទាបកម្រិត១.៤%ដែលបញ្ជាក់ថានាយក នាយករងតាមវិទ្យាល័យមានចំណេះដឹងអាចតាមដានត្រួតពិនិត្យនិងវាយតម្លៃការងារជាប្រចាំនៅក្នុងអង្គភាពរបស់ខ្លួនបាន ប៉ុន្តែកម្រិតសមត្ថភាពនេះមិនទាន់គ្រប់គ្រាន់តាមតម្រូវការនៅឡើយ។ តាមធម្មតាការតាមដានត្រួតពិនិត្យវាយតម្លៃត្រូវផ្អែកតាមវិធីសាស្ត្រមួយច្បាស់លាស់ដោយពិនិត្យទាំងគុណភាពបរិមាណ បរិយាកាសអនុវត្តពេលវេលា និងលទ្ធផល។ ការពិនិត្យវាយតម្លៃត្រូវធ្វើតាមដំណាក់ និងវាយតម្លៃបញ្ចប់។ តាមច្បាប់ស្តីពីការអប់រំ (២០០៧) វិស័យអប់រំត្រូវមានប្រព័ន្ធត្រួតពិនិត្យ តាមដាននិងវាយតម្លៃវិស័យអប់រំដែលត្រូវបញ្ចូលការត្រួតពិនិត្យតាមដានអធិការ និងសវនកម្ម ផ្ទៃក្នុងលើការបំពេញការងារ។ ក្រសួងអប់រំទទួលបន្ទុកវិស័យអប់រំមានភារកិច្ចទទួលខុសត្រូវ រៀបចំយន្តការនៃការត្រួតពិនិត្យតាមដាន និងវាយតម្លៃ។ បើបុគ្គលិកមិនយកចិត្តទុកដាក់ ចំពោះការងារនាយកនាយករងត្រូវព្យាយាមវាយតម្លៃ

ព្យាយាមលុបបំបាត់ការយកលេសផ្សេងៗ ត្រូវផ្ដល់យោបល់ពីសារប្រយោជន៍នៃការងារ និងទុកឱកាសគ្រប់គ្រាន់សម្រាប់ការងារតាមរយៈការពិនិត្យតាមដាននិងលើកទឹកចិត្តជាប្រចាំ ។

ដូច្នេះទិន្នន័យនេះបានបញ្ជាក់យ៉ាងច្បាស់ថា នាយក នាយករងតាមវិទ្យាល័យពុំមានសមត្ថភាពដូចគ្នាឡើយ ដែលតម្រូវឱ្យក្រសួងអប់រំយុវជន និងកីឡារៀបចំវគ្គបណ្ដុះបណ្ដាលស្ដីពីការវាយតម្លៃ។

## ៤.១៦.ការប្រមូលផ្ដុំ និងផ្ដល់អំណាចដល់សហគមន៍

តាមតួលេខក្នុងតារាងបានបង្ហាញថាមានអ្នកចូលរួមចំនួន៧០នាក់ ក្នុងនោះសមត្ថភាពស្ដីពីការប្រមូលផ្ដុំ និងផ្ដល់អំណាចដល់សហគមន៍មានដូចតទៅ៖ សមត្ថភាពតិចមាន៤.៣% សមត្ថភាពមធ្យមមាន៣០.០% សមត្ថភាពច្រើនមាន៥១.៤% សមត្ថភាពល្អប្រសើរមាន១២.៩% អ្នកគ្មានចម្លើយមាន១.៤%។ កម្រិតសមត្ថភាពខ្ពស់បំផុតមាន១២.៩% និងកម្រិតទាបបំផុតមាន៤.៣%។ ក្នុងន័យនេះ នាយក នាយករងមានសមត្ថភាពខ្ពស់ក្នុងការកៀរគសមាគម សហគមន៍ និងអ្នកផ្ដល់អំណោយដល់ពួកគេ ហើយក៏អាចនិយាយបានថាសហគមន៍សមាគមមានទំនាក់ទំនងល្អជាមួយសាលារៀនព្រមទាំងចូលរួមអភិវឌ្ឍទៀតផង។ សមាគមទាំងអស់នោះមាន៖ សមាគមមាតាបិតាសិស្ស សមាគមអភិវឌ្ឍស្ថាប័ន សមាគម សិស្ស ប៉ុន្តែយើងសង្កេតឃើញថា វិទ្យាល័យនីមួយៗក្នុងការអភិវឌ្ឍការកសាងហេដ្ឋារចនាសម្ព័ន្ធផ្សេងៗក៏ដូចជាការរក្សាបរិស្ថានជាដើម គឺត្រូវពឹងផ្អែកលើធនធានសម្ភារហិរញ្ញវត្ថុពី ក្រសួងអប់រំស្ទើរទាំងស្រុងដែលបញ្ជាក់ថា នាយក នាយរង វិទ្យាល័យពុំទាន់មានសមត្ថភាព គ្រប់គ្រាន់ក្នុងការទាក់ទាញសហគមន៍ និងសមាគមនានាសម្រាប់អភិវឌ្ឍន៍ស្ថាប័នរបស់ខ្លួនដោយផ្ទាល់។ លទ្ធផលដែលបានពីការសម្ភាសន៍រួមមាន ៖

ទំនាក់ទំនងជាមួយអាណាព្យាបាលសិស្ស និងសហគមន៍

ទំនាក់ទំនងអាណាព្យាបាលសិស្ស និងសហគមន៍ សប្បុរសជននិង អាជ្ញាធរដែនដីជាប្រចាំ ដើម្បីចូលរួមអភិវឌ្ឍសាលារៀន ។

- ជួបគាត់នៅកន្លែងណាអាចប្រាប់ពីការសិក្សារបស់កូនគាត់ប្រាប់ពីចំណុចល្អរបស់កូនគាត់ ( ទីកន្លែងជួបតាមវត្ត រោងបុណ្យក្នុងភូមិ ឬទៅដល់ផ្ទះគាត់ ) ។

- យល់ថាសហគមន៍ជាអ្នកចូលរួមក្នុងការអភិវឌ្ឍសាលារៀន ។ ដូចនេះចាំបាច់ត្រូវតែមានទំនាក់ទំនងល្អជាមួយសហគមន៍ ។

- ធ្វើឱ្យសហគមន៍មានជំនឿជាក់លើការងារគ្រប់គ្រងរបស់នាយកសាលា ដើម្បីកូនចៅរបស់គាត់ ។

- ទំនាក់ទំនងល្អជាមួយអាណាព្យាបាលសិស្ស ជាប្រចាំតាមគ្រូទទួលបន្ទុកថ្នាក់តាម

សៀវភៅតាមដានប្រចាំខែ និងទំនាក់ទំនងតាមលេខទូរស័ព្ទ ឬធ្វើលិខិតជម្រាបដល់អាណាព្យាបាលសិស្សនាយក នាយករងសាលាមួយចំនួនតែងតែធ្វើដូចតទៅ ៖

- អញ្ជើញសហគមន៍ដូចជា ចៅអធិការវត្ត មេឃុំ មេភូមិ គណៈកម្មការអាចារ្យនិងតំណាងមាតាបិតាសិស្សមកប្រជុំដើម្បីពិភាក្សាគ្នាក្នុងគោលបំណងសម្រេចធ្វើការងារអ្វីមួយ

- ចំពោះការប្រើប្រាស់ថវិកាPB ទាំងពេលបានថវិកាពី BMC ទាំងពេលចំណាយ និងពេលធ្វើគម្រោងចំណាយត្រូវតែមានវត្តមានសហគមន៍ជានិច្ច

- ពេលបើកថវិកាអាហារូបករណ៍ដល់សិស្សក្រីក្រក៏មានមេឃុំ និងសហគមន៍ចូលរួម

- ចំពោះសិស្ស ដែលអវត្តមានចាប់ពី 10ដងឡើងទៅតែងជូនដំណឹងដល់ឪពុកម្តាយអាណាព្យាបាលសិស្សឱ្យដឹងដោយអញ្ជើញគាត់មកសាលា ដើម្បីជូនព័ត៌មានបន្ថែម និងរកវិធានការណ៍ទប់ស្កាត់អវត្តមានបន្តទៀត ។

- បង្កើតសៀវភៅទំនាក់ទំនងមាតាបិតាសិស្សដោយបញ្ជូនទៅអាណាព្យាបាលសិស្សរាល់ខែឱ្យដឹងពីព័ត៌មាននៃការរៀនសូត្ររបស់កូនគាត់ ។

- ចំពោះការចូលរួមរបស់មាតាបិតាសិស្សគឺគាត់បានមកតាមការអញ្ជើញខ្លះ និងអត់ខ្លះ ដោយគាត់ឆ្លើយថា គាត់ជាប់រវល់ ខ្លះអញ្ជើញរហូត 3 ដងទើបមក ។

យើងមានសៀវភៅទំនាក់ទំនងសិស្សជាមួយអាណាព្យាបាល និងរួមចំណែកជាមួយសហគមន៍ ដើម្បីសហការអប់រំសម្រាប់ទាំងអស់គ្នា ។

មានសៀវភៅទំនាក់ទំនងអាណាព្យាបាលសិស្សធ្វើលិខិតជូនដំណឹងដល់ឪពុកម្តាយសិស្សដើម្បីឱ្យគាត់ជួយជំរុញបន្ថែមទំនាក់ទំនងជាប្រចាំជាមួយសហគមន៍

- សៀវភៅទំនាក់ទំនង : កំណត់ពេលប្រជុំ ( សុំជួបប្រជុំ ) 1 ឆ្នាំ 3 ដង

- ការប្រាស្រ័យទាក់ទងផ្ទាល់

- តាមលិខិតរដ្ឋបាល

## ៤-១៧ -ផែនការគ្រប់គ្រងហានិភ័យ

តាមតួលេខក្នុងតារាងបានបង្ហាញថា មានអ្នកចូលរួមចំនួន៧០នាក់ក្នុងនោះសមត្ថភាពស្តីពីផែនការគ្រប់គ្រងហានិភ័យមានដូចតទៅ៖ គ្មានសមត្ថភាព២.៩% មានសមត្ថភាពតិច៧.១% មានសមត្ថភាពមធ្យម៤៥.៧% មានសមត្ថភាពច្រើន៣២.៩% មានសមត្ថភាពល្អប្រសើរ០៤នាក់ស្មើ៥.៧%គ្មានចម្លើយ៥.៧%។ កម្រិតសមត្ថភាពរវាងអ្នកមានសមត្ថភាពខ្ពស់បំផុត៥.៧% និងកម្រិតទាបបំផុត២.៩%។ សមត្ថភាពក្នុងការគ្រប់គ្រងហានិភ័យគឺដោយសារកង្វះខាតសម្ភារបច្ចេកទេសវិទ្យាសាស្ត្រ សមត្ថភាពក្នុងការប្រើប្រាស់ និងសហការជាមួយអាជ្ញាធរដែនដី។ ហានិភ័យទាក់ទងជាមួយ សង្គមដូចជាក្រុមក្មេងទំនើងការប្រើប្រាស់គ្រឿងញៀន និងហានិភ័យទាក់ទងជាមួយធម្មជាតិ ដូចជាទឹកជំនន់ និងខ្យល់ព្យុះ ។

## ៤-១៨ -សមត្ថភាពការប្រើប្រាស់ICT

តាមតួលេខក្នុងតារាងបានបង្ហាញថាមានអ្នកចូលរួមចំនួន ៧០នាក់ក្នុងនោះសមត្ថភាពស្តីពីការប្រើប្រាស់ICT មានដូចតទៅៈ គ្មានសមត្ថភាពមាន២០% មានសមត្ថភាពតិច២៨.៦% មានសមត្ថភាពមធ្យម៤១.៤% មានសមត្ថភាពច្រើន៨.៦% មានសមត្ថភាពល្អ(0%)អ្នកគ្មានចម្លើយ១.៤%។ អ្នកមានជំនាញខ្ពស់បំផុតគឺ0% និងជំនាញតិច២៨.៦%។បច្ចេកវិទ្យា(ICT)បានសាយភាយយ៉ាងជ្រាលជ្រៅលើប្រព័ន្ធសេដ្ឋកិច្ច សង្គម និងការគ្រប់គ្រង។

ជាមួយគ្នានេះបច្ចេកវិទ្យា(ICT)បានដើរតួយ៉ាងសំខាន់ក្នុងវិស័យអប់រំទាំងក្នុងប្រព័ន្ធនិងក្រៅប្រព័ន្ធ ជាពិសេសជួយអភិវឌ្ឍវិស័យអប់រំគ្រប់ផ្នែកគ្រប់លំដាប់ជាពិសេសក្នុងការគ្រប់គ្រងអប់រំដូចជា នាយកនាយរងតាមវិទ្យាល័យត្រូវតែមានសមត្ថភាពខាងបច្ចេកវិទ្យានេះព្រោះងាយទទួលបាន ព័ត៌មានទាំងក្នុងនិងក្រៅក៏ដូចជាការគ្រប់គ្រងបុគ្គលិកសិស្ស និងសម្ភារៈផ្សេងៗពោលគឺទាំង ព័ត៌មានក្តី ការគ្រប់គ្រងក្តី និងការអភិវឌ្ឍអង្គភាពក្តី។

ទិន្នន័យនេះបញ្ជាក់យ៉ាងច្បាស់ថាសមត្ថភាពនាយក នាយករងវិទ្យាល័យមានសមត្ថភាពក្នុងការប្រើប្រាស់ICT នៅមានកម្រិតដែលតម្រូវឱ្យក្រសួងអប់រំ យុវជន និងកីឡា រៀបចំវគ្គបណ្តុះបណ្តាល ICT ជាបន្តបន្ទាប់ទៅតាមតំបន់ដែលអាចធ្វើទៅបានដើម្បីឆ្លើយឈានឲ្យទាន់សម័យបច្ចេកវិទ្យាទំនើប។

## ៤-១៩- ការប្រើប្រាស់ភាសាអង់គ្លេស

តាមតួលេខក្នុងតារាងបានបង្ហាញថាមានអ្នកចូលរួមចំនួន៧០នាក់ ក្នុងនោះសមត្ថភាពស្តីពីការប្រើប្រាស់ភាសាអង់គ្លេសមានដូចតទៅៈ គ្មានសមត្ថភាព២៥% សមត្ថភាពតិច៤៧.១% សមត្ថភាពមធ្យម២១.៤% សមត្ថភាពច្រើន៥.៧% សមត្ថភាពល្អប្រសើរគឺ0%។ បើប្រៀបធៀបកម្រិតខ្ពស់ទាបគឺកម្រិតសមត្ថភាពខ្ពស់បំផុតគឺ0%និងកម្រិតទាបបំផុតគឺ៤៧.១%។ ទិន្នន័យនេះឆ្លុះបញ្ចាំងពីសមត្ថភាពក្នុងការប្រើប្រាស់ភាសាអង់គ្លេសនៅមានកម្រិតទាបណាស់ ដែលជាប្រការមួយនាំឱ្យលោកនាយក នាយករងពិបាកនឹងទទួលព័ត៌មានផ្សេងៗក្រៅពីព័ត៌មានដែលផ្សព្វផ្សាយជាភាសាខ្មែរចំពោះព័ត៌មានស្តីពីការអភិវឌ្ឍអង្គភាពជាមួយដៃគូអន្តរជាតិសប្បុរសជនជាបរទេសទ្រឹស្តីថ្មីដែលទាក់ទងជាមួយវិធីសាស្ត្រ អធិការកិច្ច គោលនយោបាយលើកកម្ពស់គុណភាពអប់រំនៃបណ្តាប្រទេសជឿនលឿនក្នុងពិភពលោកគឺពិបាកនឹងទទួល។

ដូច្នេះទិន្នន័យនេះបានបញ្ជាក់យ៉ាងច្បាស់ថា នាយក នាយករងតាមវិទ្យាល័យពុំមានសមត្ថភាពដូចគ្នាឡើយ ដែលតម្រូវឱ្យក្រសួងអប់រំយុវជន និងកីឡារៀបចំវគ្គបណ្តុះបណ្តាលភាសាបរទេសទាំងភាសាសរសេរ និងភាសានិយាយដើម្បីអភិវឌ្ឍអង្គភាព។

## IX-សន្និដ្ឋាន

តាមរយៈទិន្នន័យដែលបានបង្ហាញ យើងឃើញថាសមត្ថភាពរបស់នាយក នាយករង នាយិកា នាយិការងតាមវិទ្យាល័យដែលក្រុមយើងខ្ញុំបានសិក្សាស្រាវជ្រាវ គឺបានបង្ហាញនូវចំណុចខ្លាំង និងចំណុចខ្សោយជាច្រើនប៉ុន្តែបញ្ហាដែលយើងត្រូវដោះស្រាយជាបន្ទាន់នោះ គឺបញ្ហាប្រឈមជាច្រើនក្នុងការដឹកនាំអង្គភាពនាពេលកន្លងមកក៏ដូចជាពេលបច្ចុប្បន្ន ព្រោះកិច្ចការខ្លះតម្រូវ ឱ្យពួកគាត់អនុវត្តតាមទម្លាប់តៗគ្នាពីអ្នកដឹកនាំមុនៗដែលក្នុងនោះចំណុចខ្សោយរួមមានការរៀបចំគ្រប់គ្រងហិរញ្ញវត្ថុ អ្នកគ្មានសមត្ថភាព១.៤% អ្នកមានសមត្ថភាពទាប១១.៤%។ លទ្ធផលនេះបញ្ជាក់ថា ការចំណាយចំណូលថវិកាក្នុងអង្គភាពពុំទាន់មាននីតិវិធី និងបែបបទនៃការប្រើប្រាស់នៅឡើយ ព្រោះថាថវិកាជាប្រភពនៃបញ្ហានៅក្នុងអង្គភាព។ ការរៀបចំគោលនយោបាយអប់រំមានកម្រិតទាប១០% បញ្ជាក់ថាសមត្ថភាពយល់ដឹងពីការអភិវឌ្ឍអង្គភាពគុណភាពអប់រំ ការកសាងសមត្ថភាពបុគ្គលិក សមធម៌ភេទនៅមានកម្រិត ព្រោះពួកគាត់ភាគច្រើនមិនដែលបានឆ្លងកាត់វគ្គសិក្សានោះ។ ការរៀបចំផែនការយុទ្ធសាស្ត្រ អ្នកគ្មានសមត្ថភាព ២.៩% អ្នកមានសមត្ថភាពទាប៧.១% ការគ្រប់គ្រងផែនការមានសមត្ថភាពកម្រិតទាប៧.១% ការគ្រប់គ្រងគម្រោងមានសមត្ថភាពកម្រិតទាប៤.៣% ការគ្រប់គ្រងធនធានមនុស្សមានសមត្ថភាពទាបកម្រិតត្រឹម៤.៣% ឥរិយាបថក្នុងការដឹកនាំមានសមត្ថភាពទាបកម្រិត៤.៣% ការសម្រេចចិត្តក្នុងការប្រតិបត្តិការងារផ្សេងៗសមត្ថភាពទាបកម្រិតត្រឹម៤.៣% ទំនាក់ទំនងសហគមន៍ សមត្ថភាពទាបកម្រិត៤.៣% ការគ្រប់គ្រងហានិភ័យ អ្នកគ្មានសមត្ថភាព២.៩% និងសមត្ថភាពកម្រិតទាប៧.១% សមត្ថភាព ICT អ្នកគ្មានសមត្ថភាព២០% និងសមត្ថភាពទាប២៨.៦% ដែលតម្រូវឱ្យក្រសួងអប់រំ យុវជន និងកីឡា រៀបចំការកែទម្រង់លើកកម្ពស់សមត្ថភាពនាយក ៗនាយិកា នាយករង នាយិការងតាមរយៈវគ្គបណ្តុះបណ្តាលដើម្បីលើកកម្ពស់ប្រសិទ្ធភាពគុណភាពនៃការគ្រប់គ្រងតាមអង្គភាពនានាឱ្យល្អប្រសើរ។
ការបណ្តុះបណ្តាលទាំងអស់នោះមានដូចជា ៖

-ការរៀបចំផែនការយុទ្ធសាស្ត្រ ដោយផ្សារភ្ជាប់ជាមួយគោលនយោបាយអប់រំដើម្បីឱ្យ

នាយក នាយិកា នាយករង នាយិការង ទាំងនោះមានសមត្ថភាពគ្រប់គ្រាន់ក្លាយជាអ្នកដឹកនាំពិតប្រាកដ និងចេះរៀបចំរចនាសម្ព័ន្ធរបស់អង្គភាពស្របតាមគោលនយោបាយអប់រំក្នុងការអភិវឌ្ឍស្ថាប័ននិងការអភិវឌ្ឍសមត្ថភាពបុគ្គលិក។

-ការគ្រប់គ្រងហិរញ្ញវត្ថុ ដើម្បីឱ្យនាយក នាយិកា នាយករង នាយិការងមានវិធីសាស្ត្រចំណាយថវិកាប្រកបដោយគណនេយ្យភាព តម្លាភាពស្របតាមផែនការអភិវឌ្ឍជៀសវាងមានទំនាស់ផ្សេងៗក្នុងអង្គភាពជាពិសេសឱ្យមានតុល្យភាពរវាងការចំណាយថវិកា និងសកម្មភាពផ្សេងៗ។

-ការគ្រប់គ្រងធនធានដើម្បីឱ្យនាយក នាយិកា នាយករង នាយិការង ក្លាយជាអធិការអចិន្ត្រៃយ៍ ក្រុមប្រឹក្សាអ្នករដ្ឋបាល អ្នកបច្ចេកទេស អ្នកកៀរគមាតាបិតាសិស្ស សប្បុរសជនក្នុងការកសាងអង្គភាពជាពិសេសមានគំនិតច្នៃប្រឌិត ចេះបែងចែកប្រព័ន្ធការងារសមស្របជាមួយធនធានមនុស្ស ដែលមានតាមកម្រិតជំនាញ សញ្ញាប័ត្រ សមត្ថភាព និងចេះយល់ដឹងពីចំណុចខ្លាំង និងចំណុចខ្សោយរបស់បុគ្គលិកដើម្បីធានាដល់គុណភាព ប្រសិទ្ធភាពការងារក្នុងអង្គភាព។ ការអភិវឌ្ឍស្ថាប័នមួយរីកចម្រើនទៅបានអាស្រ័យលើការចូលរួម និងការបំពេញការងាររបស់បុគ្គលិកទៅតាមសមត្ថភាព និងជំនាញរៀងៗខ្លួន។

-**ICT** ជាបច្ចេកវិទ្យាមួយដែលមាននិន្នាការថ្មីក្នុងការគ្រប់គ្រងបុគ្គលិក សិស្ស និងប្រព័ន្ធព័ត៌មានផ្សេងៗស្របតាមស្ថានភាពនៃវិទ្យាសាស្ត្ររីកចម្រើននាពេលបច្ចុប្បន្ននេះ។

-ចិត្តវិទ្យាអប់រំដែលជាមូលដ្ឋានទ្រឹស្តីផ្នែកចិត្តសាស្ត្រ ដើម្បីស្គាល់ចិត្តគំនិតសមត្ថភាពបទពិសោធន៍ និងស្ថានភាពផ្សេងៗរបស់បុគ្គលិកវិធីសាស្ត្របង្រៀន គោលការណ៍ការគ្រប់គ្រងការទំនាក់ទំនង និងក្រមសីលធម៌ក្នុងសម័យទំនើបកម្មសម្រាប់អ្នកដឹកនាំ។

-ការបណ្ដុះបណ្ដាលត្រូវរៀបចំចាប់ពីប្រធានក្រុមបច្ចេកៈនាយក នាយិកា នាយករង នាយិការងដើម្បីបានបន្តនិរន្តរភាពការងារក្នុងអង្គភាព ហើយបង្កើតឱ្យមានស្តង់ដារសម្រាប់នាយក នាយិកា នាយករង នាយិការង វិទ្យាល័យមួយប្រើប្រាស់ទូទាំងប្រទេស។

-បង្កើតកម្រងនាយក នាយិកាវិទ្យាល័យ នៅតាមបណ្ដារាជធានី ខេត្តនានា ដើម្បីប្រជុំប្រចាំសប្ដាហ៍ ប្រចាំខែក្នុងគោលបំណងចែករំលែក ប្ដូរបទពិសោធន៍ទាំងការគ្រប់គ្រងការងារបច្ចេកទេស និងអភិវឌ្ឍន៍អង្គភាពជាពិសេសសម្រាប់អធិការកិច្ចផ្ទៃក្នុងដោយរួមសហការជាមួយអ្នកជំនាញផ្សេងៗរបស់ក្រសួងអប់រំ។

# References


1.Craig A. (2005) *Introduction to Educational Research* ( 6th ) Pearson Education. Inc : New York

2. Douglas A. (2000) *Basic Statistics for Business and Economics*, McGraw-Hill Higher Education North America.
3. Farah R. (2010) *Authentic Leadership for Democracy in schools.*
4. Fred C. (1996) *Concepts an Practices* ( 2nd ed), New York: Wadsworth Publishing Company.
5. James G. (2003) *Level Three Leadership* (2nd ed) Parson Education, Inc, New Jersey.
6. Joyce H. ( 2008) *Educational Leadership* ( 1st ed) New York: McGraw-Hill Companies. Inc.
7. Laura M. (2002) *Leadership of Deans in Private Universities in Thailand, Malaysia, and Singapore,* Au Graduate School of Education Journal.
8. Cisse M and Okato T. (2009) *The Organizational Strategies of School Management in Japan,* Conference Proceedings, Texas, USA.
9. Ministry of Education (2006-2010) *Education Strategic Plan.*
10.Oideachais (2005) *School Development Planning.*
11. OECD (2004) *Handbook for Internationally Comparative Education Statistics*, Paris.
12. Philip H. (2007) *Research on the practice of instructional and transformational leadership,* Keynote papers, Australia Conference.
13. Rober B. ( 2000) *Introduction to Research Methods*, ( 4th ed) SAGS Publications Ltd : London.
14. Paige R. (2003) *School Facilities Maintenance Task Force*, National Forum on Education Statistics, Washington, DC.
15. Stephen J. (1997) *The Role of International Organizations in The Financing of Higher Education in Cambodia,* Melbourne, Australia.
16. Viviane M.J. (2007) *The Impact of Leadership on Student Outcomes,* Australia Conference.
17. The World Bank (2008) *Teaching in Cambodia*
18. Thomas C. ( 1995) *French Colonial Educational Development in Cambodia*, A peer-reviewed scholarly electronic journal
19. UNECO (1992) *Book of reading in Educational Management, Phnom Penh.*

*20. Petter(2008)* បញ្ហានៃការបង្រៀន, ភ្នំពេញ ,២០០៩។

# វិទ្យាស្ថានជាតិអប់រំ

## ប្រធានបទ

## គោលវិធីសិស្សមជ្ឈមណ្ឌលមុខវិជ្ជា សិក្សាសង្គមនៅវិទ្យាល័យ

**ក្រុមសិក្សាស្រាវជ្រាវ**

១. លោក លុយ អោក

២. លោក ញ៉ែម ចន្ទា

៣. លោក អ៊ុក ញ៉ាល់

៤. លោក ចេង ហង

# មាតិកា

ខ្លឹមសារ ទំព័រ

**មូលបទ**

**សេចក្តីថ្លែងអំណរគុណ**

១. សេចក្តីផ្តើម ........ ១

២. សារតានៃបញ្ហាស្រាវជ្រាវ ........ ២

៣. គោលបំណងនៃការស្រាវជ្រាវ ........ ៤

៤. សំណួរស្រាវជ្រាវ ........ ៤

៥. ការរំលឹកទ្រឹស្តី និងការសិក្សាដែលពាក់ព័ន្ធ ........ ៤

៦. វិធីសាស្ត្រស្រាវជ្រាវ ........ ៥-៦

៦.១. វិធីសាស្ត្រប្រមូលទិន្នន័យ

៦.២. វិធីសាស្ត្រវិភាគទិន្នន័យ

៧. លទ្ធផលរំពឹងទុកនៃការស្រាវជ្រាវ ........ ៦

៨. លទ្ធផលនៃការស្រាវជ្រាវស្តីពីគោលវិធីសិស្សមជ្ឈមណ្ឌល ........ ៦-២២

*៨.១. ការសម្ភាសន៍ជាមួយគ្រូបង្រៀន* ........ ៦-១៨

៨.១.១. លក្ខណៈអ្នកឆ្លើយ

៨.១.២. ការបណ្តុះបណ្តាលពីគោលវិធីសិស្សមជ្ឈមណ្ឌល

៨.១.៣. ចំណេះដឹងស្តីពីគោលវិធីសិស្សមជ្ឈមណ្ឌល

៨.១.៤. ការអនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌល

៨.១.៥. ការជះឥទ្ធិពលដល់សិស្ស

៨.១.៦. បញ្ហាដែលកើតមានកន្លងមកក្នុងការអនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌល

៨.១.៧. ដំណោះស្រាយ

៨.១.៨. កត្តាប្រឈមក្នុងការអនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌល

៨.១.៩.ការយល់ឃើញរបស់គ្រូចំពោះគោលវិធីសិស្សមជ្ឈមណ្ឌល

៨.១.១០. សំណើដើម្បីអនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌលឲ្យបានប្រសើរជាងមុន

*៨.២.ការសម្ភាសន៍ជាមួយសិស្ស* ........ ១៨-២២

៨.២.១. លក្ខណៈអ្នកឆ្លើយ

៨.២.២. សកម្មភាពបង្រៀនរបស់គ្រូ(ចម្លើយរបស់សិស្ស)

៨.២.៣. ការជះឥទ្ធិពលដល់សិស្សក្នុងការអនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌល

៨.២.៤. សម្ភារប្រើប្រាស់របស់គ្រូបង្រៀនផ្នែកសង្គម
៨.២.៥. ការលំបាករបស់សិស្សក្នុងការអនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌល
៨.២.៦. កត្តាប្រឈមដែលធ្វើឲ្យសិស្សមិនអាចអនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌលបាន
៨.២.៧. សំណើរបស់សិស្សដើម្បីអនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌលឲ្យមានភាពប្រសើរជាងមុន
៨.២.៨. ការយល់ឃើញរបស់សិស្សចំពោះគោលវិធីសិស្សមជ្ឈមណ្ឌល

*៨.៣.ការសង្កេតថ្នាក់រៀននៅវិទ្យាល័យ* ........ ២២-២៨

៨.៣.១. លក្ខណៈថ្នាក់រៀន
៨.៣.២. ឯកសារនិងសម្ភារគ្រូ-សិស្ស
៨.៣.៣. សកម្មភាពពិភាក្សាក្រុម
៨.៣.៤. សកម្មភាពសម្របសម្រួល
៨.៣.៥. អនុវត្តជាក់ស្តែងនៃដំណើរការបង្រៀន

**៩. ការវិភាគ និងការបកស្រាយ** ........ ២៧-៣៣

*៩.១. របកគំហើញនិងការបកស្រាយទៅលើលទ្ធផល* ........ ២៨

៩.១.១. ទស្សនៈរបស់គ្រូនិងសិស្សចំពោះគោលវិធីសិស្សមជ្ឈមណ្ឌល
៩.១.២. ចំណេះដឹង
៩.១.៣. ការអនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌល
៩.១.៤. បញ្ហាប្រឈមនៃការអនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌល

**១០.កំហិតតាពនៃការស្រាវជ្រាវ និងចំណុចដែលត្រូវសិក្សាបន្ត** ........ ៣៤

**១១. សន្និដ្ឋាន** ........ ៣៤

**១២. អនុសាសន៍** ........ ៣៥

**ឯកសារយោង** ........ ៣៦

## តារាងទិន្នន័យ និងរូបភាព

### រូបភាព

រូបភាពទី ១ ការសម្ភាសន៍គ្រូវិទ្យាល័យដោយបំពេញកម្រងសំណួរពាក់កណ្តាលរចនាសម្ព័ន្ធនៅខេត្តតាកែវ

រូបភាពទី ២ ការសម្ភាសគ្រូវិទ្យាល័យបែបគុណភាពនៅខេត្តព្រះវិហារ

រូបភាពទី ៣ ការធ្វើសកម្មភាពរៀនតាមរយៈការពិភាក្សាក្រុមតូច

រូបភាពទី ៤ តំណាងក្រុមឡើងសរសេរក្តារខៀន និងរាយការណ៍

រូបភាពទី ៥ ការសម្ភាសន៍សិស្សដោយបំពេញកម្រងសំណួរ

រូបភាពទី ៦ ការសម្ភាសន៍សិស្សជាបុគ្គល

រូបភាពទី ៧ ការធ្វើសកម្មភាពរបស់គ្រូឲ្យសិស្សអាន

រូបភាពទី ៨ ការសកម្មភាពគ្រូឲ្យហៅ សិស្សកត់ត្រានូវចំណុចសំខាន់ៗ

### តារាងទិន្នន័យ

គំនូសតាងទី ១ ទិន្នន័យចំណេះដឹងគ្រូវិទ្យាល័យស្តីពីគោលវិធីសិស្សមជ្ឈមណ្ឌល

គំនូសតាងទី ២ ទិន្នន័យស្តីពីការអនុវត្តរបស់គ្រូវិទ្យាល័យនូវគោលវិធីសិស្សមជ្ឈមណ្ឌល

គំនូសតាងទី ៣ ទិន្នន័យពីសិស្សស្តីពីការអនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌលរបស់គ្រូ

គំនូសតាងទី ៤ ទិន្នន័យសង្កេតថ្នាក់ស្តីពីការអនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌលរបស់គ្រូ

## អារម្ភកថា

យើងខ្ញុំបានទទួលការបណ្តុះបណ្តាលពីវិធីសាស្ត្រស្រាវជ្រាវ នៅវិទ្យាស្ថានជាតិអប់រំ(វជអ) ដោយមានការឧបត្ថម្ភពីគម្រោងលើកកម្ពស់គុណភាពអប់រំ(EEQP)។ ក្នុងការអនុវត្តទ្រឹស្តីស្រាវជ្រាវ ក្រុមយើងខ្ញុំបានជ្រើសរើសយកប្រធានបទស្តីពីគោលវិធីសិស្សមជ្ឈមណ្ឌល នៅវិទ្យាល័យដើម្បីធ្វើការសិក្សាស្រាវជ្រាវ។

គោលវិធីសិស្សមជ្ឈមណ្ឌលជាវិធីមួយ ដែលធ្វើឲ្យសិស្សទទួលបានចំណេះដឹងពិតប្រាកដ មានភាពឯករាជ្យក្នុងការសិក្សា ចេះពិចារណាវិភាគ ចេះដោះស្រាយបញ្ហាដោយខ្លួនឯងបាន និងអាចអភិវឌ្ឍ ខ្លួនឯងគ្រួសារ និងសង្គមបាន។

គោលវិធីសិស្សមជ្ឈមណ្ឌលជាវិធីមួយជួយសិស្សឲ្យក្លាហាន រៀនបង្ហាញពីគំនិតរបស់ខ្លួនដោយមានហេតុផល និងរៀនទទួលយកគំនិតអ្នកដទៃ។ ជាងនេះទៀត វាក៏ជាវិធីមួយដ៏ល្អសម្រាប់ការកសាងទំនាក់ទំនងរវាងសិស្សនិងគ្រូ, សិស្សនិងសិស្ស និងកសាងលទ្ធិប្រជាធិបតេយ្យនៅក្នុងថ្នាក់ផងដែរ។

តាមលទ្ធផលនៃការស្រាវជ្រាវ គ្រូភាគច្រើនលើសលប់មានចំណេះដឹងពីគោលវិធីសិស្សមជ្ឈមណ្ឌល។ ប៉ុន្តែការអនុវត្តជាក់ស្តែងនៅមានកម្រិតទាបនៅឡើយ។ ទោះបីជាយ៉ាងណាក៏ដោយការស្រាវជ្រាវនេះ នៅមានចំណុចខ្វះខាត និងខ្វះព័ត៌មានជាច្រើនទៀត។ យើងខ្ញុំជាក្រុមស្រាវជ្រាវរង់ចាំទទួលការផ្តល់មតិយោបល់បន្ថែម និងការកែលម្អដោយរីករាយ។

ជាបញ្ចប់ ក្រុមស្រាវជ្រាវយើងខ្ញុំសំណូមពរឲ្យលោកគ្រូអ្នកគ្រូទាំងអស់ បង្កើនការអនុវត្តវិធីនេះជាប្រចាំ ដើម្បីកសាងធនធានមនុស្សឲ្យសម្បូរបែប និងកសាងមូលដ្ឋានគ្រឹះប្រជាធិបតេយ្យនៅប្រទេសជាតិរបស់យើង។

# មូលបទ

ចាប់ពីអំឡុងឆ្នាំ១៩៩០មក សាលាគរុកោសល្យនិងវិក្រិតការខេត្ត មជ្ឈមណ្ឌលគរុកោសល្យភូមិភាគ និងជាពិសេសនៅវិទ្យាស្ថានជាតិអប់រំបានបណ្តុះបណ្តាលគោលវិធីសិស្សមជ្ឈមណ្ឌលដើម្បីឱ្យលោក គ្រូ អ្នកគ្រូ យកទៅអនុវត្ត តាមវិទ្យាល័យនានាទូទាំងប្រទេស។ ក្រុមយើងខ្ញុំបានទទួលការបណ្តុះបណ្តាលវិធីសាស្ត្រស្រាវជ្រាវរបស់គម្រោងEEQP ដើម្បីពង្រឹងសមត្ថភាពសាស្ត្រាចារ្យនៅវិទ្យាស្ថានជាតិអប់រំ។យើងខ្ញុំបានជ្រើសរើសយកប្រធានបទស្រាវជ្រាវបញ្ចប់វគ្គស្តី វិធីសាស្ត្របង្រៀនបែបសិស្សមជ្ឈមណ្ឌលសម្រាប់មុខវិជ្ជាវិទ្យាសាស្ត្រសង្គមនៅវិទ្យាល័យ ។ ការស្រាវជ្រាវនេះមានគោលបំណងសិក្សាស្វែងយល់អំពីការបណ្តុះបណ្តាល ការអនុវត្ត និងទស្សនៈយល់ឃើញរបស់គ្រូ និងសិស្សចំពោះគោលវិធីសិស្សមជ្ឈមណ្ឌលសម្រាប់មុខវិជ្ជាវិទ្យាសាស្ត្រសង្គមនៅវិទ្យាល័យ។

ទីតាំងចំនួន៥កន្លែងត្រូវជ្រើសរើសដើម្បីប្រមូលទិន្នន័យគឺ រាជធានីភ្នំពេញ ខេត្តបាត់ដំបង ខេត្តតាកែវ និង ខេត្តព្រះវិហារ។ គ្រូវិទ្យាល័យចំនួន៩៥នាក់ត្រូវបានជ្រើសរើសមកធ្វើសំណាកសម្ភាសន៍ និង សិស្សថ្នាក់ទី១០-១១និងទី១២ចំនួន៧២នាក់ ព្រមទាំងធ្វើការសង្កេតថ្នាក់ចំនួន៣២។ ការសិក្សានោះ ផ្តោតទៅលើចំណេះដឹងរបស់គ្រូស្តីពីការអនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌលបញ្ហានានាកត្តាប្រឈម ដំណោះស្រាយ ការជះឥទ្ធិពល និងការយល់ឃើញរបស់គ្រូ និងសិស្ស។

លោកគ្រូ អ្នកគ្រូយល់ឃើញថា ការបង្រៀនបែបគោលវិធីសិស្សមជ្ឈមណ្ឌល ធ្វើឱ្យសិស្សរបស់ពួកគេទទួលការអប់រំដ៏ល្អប្រសើរ។

ចំណែកសិស្សវិញ ពួកគេយល់ឃើញថា ការបង្រៀនបែបគោលវិធីសិស្សមជ្ឈមណ្ឌលធ្វើឲ្យពួកគេទទួលបានការអប់រំដ៏ល្អផងដែរ។

៩៨%នៃគ្រូបង្រៀនមានចំណេះដឹងច្បាស់លាស់ស្តីពីគោលវិធីសិស្សមជ្ឈមណ្ឌល។ ប៉ុន្តែការអនុវត្តជាក់ស្តែងនៅមានកម្រិតទាបនៅឡើយ ដោយសារមានបញ្ហាប្រឈមជាច្រើន។ បញ្ហាប្រឈមទាំងនោះរួមមាន ចំនួនសិស្សច្រើននៅក្នុងថ្នាក់រៀន ខ្វះសម្ភារឧបទេស និងឯកសារពាក់ព័ន្ធសម្រាប់គ្រូ ខ្វះសៀវភៅគោលសម្រាប់សិស្សសិក្សា សិស្សអសកម្ម និងពិបាកគ្រប់គ្រង សមត្ថភាពគ្រូនៅមានកម្រិតលើការបង្រៀនដោយសារគ្រូមួយចំនួននៅអនុវិទ្យាល័យត្រូវទៅបង្រៀននៅវិទ្យាល័យ វិទ្យាល័យខ្លះខ្វះគ្រូមុខវិជ្ជាឯកទេស ការអនុវត្តកម្មវិធីសិក្សាជួបប្រទះបញ្ហាខ្លះៗ បរិស្ថានបន្ទប់រៀន និងតុកៅអីមិនទាន់បានសមស្រប និងបញ្ហាកង្វះជីវភាពគ្រូបង្រៀន។

ទិន្នន័យដែលប្រមូលបានទាំងនេះត្រូវបានបញ្ចូលទៅក្នុងរបាយការណ៍ ក្នុងនោះរួមមានការវិភាគទិន្នន័យជាលេខ រៀបរាប់មូលន័យទៅលើការយល់ឃើញ ការអនុវត្តបញ្ហាប្រឈមនានាដាក់ទៅក្នុងរបាយការណ៍នេះផងដែរ។

ក្រុមសិក្សាស្រាវជ្រាវរបស់យើងខ្ញុំ សង្ឃឹមថាស្ថាប័នពាក់ព័ន្ធ នឹងយកលទ្ធផលនៃការស្រាវជ្រាវនេះទៅប្រើប្រាស់ជាឯកសារយោង សម្រាប់ធ្វើឱ្យការអនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌលឱ្យកាន់តែប្រសើរឡើងនៅក្នុងប្រទេសកម្ពុជានាពេលអនាគត។

## សេចក្តីថ្លែងអំណរគុណ

ក្រុមស្រាវជ្រាវយើងខ្ញុំសូមថ្លែងអំណរគុណដល់លោកគ្រូអ្នកគ្រូ និងសិស្សវិទ្យាល័យនៅក្នុងរាជធានីភ្នំពេញ ខេត្តបាត់ដំបង ខេត្តតាកែវ និងខេត្តព្រះវិហារ ដែលបានផ្តល់ពេលវេលា និងអនុញ្ញាតឱ្យយើងខ្ញុំធ្វើបទសម្ភាសន៍។

សូមថ្លែងអំណាគុណចំពោះឯកឧត្តម អ៊ឹម កុច ជាអតីតនាយក និងឯកឧត្តម សៀង សុវណ្ណា នាយកវិទ្យាស្ថានជាតិអប់រំ ដែលបានគាំទ្រគម្រោង និងលើកទឹកចិត្តដល់ក្រុមស្រាវជ្រាវទាំងអស់។

សូមថ្លែងអំណរគុណជាពិសេស ចំពោះលោកស្រីបណ្ឌិត អាន គ្លូវើ និងលោកបណ្ឌិត ងិន ច័ន្ទរិទ្ធ ដែលបានខិតខំអស់ពីកម្លាំងកាយ និងលះបង់ពេលវេលាជួយបណ្តុះបណ្តាល និងណែនាំរហូតដល់លទ្ធផលការស្រាវជ្រាវនេះបានសម្រេចឡើង។

សូមថ្លែងអំណរគុណដល់ថ្នាក់ដឹកនាំក្រសួងអប់រំ យុវជន និងកីឡាដែលបានគាំទ្រនូវគម្រោងនេះ ដល់វិទ្យាស្ថានជាតិអប់រំ។

# ១. សេចក្ដីផ្ដើម

ការអភិវឌ្ឍកម្មវិធីសិក្សា កំពុងតែទទួលនូវការយកចិត្តទុកដាក់យ៉ាងខ្លាំងនៅក្នុងពេលបច្ចុប្បន្ននេះ ស្របពេលដែលពិភពលោកមានការប្រែប្រួលយ៉ាងឆាប់រហ័ស។ ប្រទេសជាច្រើននៅលើសកលលោកបានទទួលស្គាល់ថាការផ្ទេរចំណេះដឹងពីគ្រូទៅសិស្ស គឺមិនមានភាពងាយស្រួលដូចការផ្ទេរទឹកធុងចូលទៅក្នុងពាងឡើយ។ ទស្សនវិជ្ជាថ្មីបានកំណត់ថា លទ្ធផលនៃសិក្សាគឺជាគោលបំណងចម្បងក្នុងការអភិវឌ្ឍកម្មវិធីសិក្សា។ បញ្ញត្តិនៃកម្មវិធីសិក្សាបានធ្វើឱ្យមានការផ្លាស់ប្តូរទស្សនៈគោលគំនិតគរុកោសល្យ និងវិធីសាស្ត្រសម័យមុន ដោយប្រែក្លាយពីការបង្រៀនមកជាការរៀនហើយផ្អែកលើសកម្មភាពសិស្សជាគោល(សិស្សមជ្ឈមណ្ឌល) ។ ពោលគឺពីការផ្ទេរពុទ្ធិមកជាការស្ថាបនាពុទ្ធិដោយខ្លួនឯង ព្រមទាំងអភិវឌ្ឍន៍បំណិនសមត្ថភាពសិស្ស ឱ្យចេះស្រឡាញ់ការសិក្សាពេញមួយជីវិត ព្រមទាំងធានាគុណភាព អប់រំសម្រាប់ទាំងអស់គ្នា។

ការវិវឌ្ឍឆ្ពោះទៅលើគុណភាពអប់រំនេះនឹងធ្វើឱ្យជីវិតរស់នៅកាន់តែល្អប្រសើរដោយបង្កើនការផ្សារភ្ជាប់កម្មវិធីសិក្សាទៅនឹងជីវភាពប្រចាំថ្ងៃ។ ទំនោរនៃការអប់រំនៅប្រទេសកម្ពុជាមិនខុសពីការអប់រំនៅលើពិភពលោកទេ ព្រោះតម្រូវការអភិវឌ្ឍសង្គមជាតិ និងការរីកចម្រើនសេដ្ឋកិច្ចមិនអាចខ្វះធនធានមនុស្សបានឡើយ។ ក្រសួងអប់រំ យុវជន និងកីឡាបានកែលម្អកម្មវិធីសិក្សាជាបន្តបន្ទាប់ដើម្បីឱ្យឆ្លើយតបទៅនឹងតម្រូវការទីផ្សារពលកម្ម ផលប្រយោជន៍របស់អ្នកសិក្សា អ្នកវិទ្យាសាស្ត្រ និងវិនិយោគិនជាតិ និងអន្តរជាតិ។

រាជរដ្ឋាភិបាលបានកំណត់យុទ្ធសាស្ត្រចតុកោណ សម្រាប់អភិវឌ្ឍប្រទេសជាតិឱ្យកាន់តែរីកចម្រើន ស៊ីចង្វាក់គ្នាលើគ្រប់វិស័យដូចជា ការលើកស្ទួយវិស័យកសិកម្ម ការបន្តស្តារ និងកសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ការអភិវឌ្ឍផ្នែកបច្ចេកទេស ការងារកសាងសមត្ថភាព និងអភិវឌ្ឍធនធានមនុស្ស។ ឯការកសាងសមត្ថភាព និងការអភិវឌ្ឍធនធានមនុស្សជាតួនាទីរបស់ការងារអប់រំនៅក្នុងសង្គមជាតិយើង។ ឈរលើគោលគំនិតខាងលើនេះក្រសួងអប់រំ យុវជន និងកីឡា បានធ្វើការកែសម្រួលកម្មវិធីសិក្សាមធ្យមសិក្សាទុតិយភូមិ ដោយបញ្ចូលកម្មវិធីអប់រំវិជ្ជាជីវៈជម្រើស ដែលធ្វើឱ្យកម្មវិធីសិក្សាជាតិកាន់តែមានប្រសិទ្ធភាពខ្ពស់ (នាយកដ្ឋានស្រាវជ្រាវគរុកោសល្យ ២០០៨)។

បច្ចុប្បន្ន ប្រសិនជាបុគ្គលិកអប់រំចង់ឱ្យសិស្សក្លាយជាធនធានមនុស្សដែលមានប្រយោជន៍នៅក្នុងសង្គមសម័យវិទ្យាសាស្ត្រនាសតវត្សរ៍ទី២១ យើងត្រូវរៀបចំថ្នាក់រៀនយ៉ាងណាដើម្បីផ្តល់ឱកាសឱ្យសិស្សក្លាយជាអ្នកសកម្មចេះគិត និងត្រិះរិះពិចារណាឱ្យបានល្អិតល្អន់ មានសមត្ថភាពរឹងមាំ។

ដើម្បីសម្រេចគោលដៅនេះបាន បុគ្គលិកអប់រំ គ្រូបង្រៀនត្រូវមានការយកចិត្តទុកដាក់លើ

គោលការណ៍ចតុស្កម្ភនៃការអប់រំឱ្យបានល្អ ពោលគឺរៀនដើម្បីចេះ រៀនដើម្បីធ្វើ រៀនដើម្បីស្គាល់ខ្លួនឯងល្អ និងរៀនដើម្បីរស់នៅជាមួយគ្នា។ ដូចនេះថ្នាក់រៀនត្រូវរៀបចំសកម្មភាពបង្រៀន និងរៀនឱ្យសិស្សចូលរួមសកម្មភាពក្នុងការសិក្សាឱ្យបានគ្រប់ៗគ្នាពោលគឺ ចូលរួមជាប់ក្នុងសកម្មភាពថ្នាក់រៀនត្រូវចេះគិតដោយខ្លួនឯង ទទួលខុសត្រូវចំពោះសកម្មភាពរបស់ខ្លួនទាំងក្នុងថ្នាក់ និងក្រៅថ្នាក់។

## ២. សាវតានៃបញ្ហាស្រាវជ្រាវ

ក្នុងឆ្នាំ១៩៥៨សាស្ត្រាចារ្យ ពៅ សាគួង បានលើកឡើងពីចំណុចខ្សោយរបស់វិធីពណ៌នា និងផលល្អរបស់វិធីចោទឆ្លើយ វិធីចម្រុះ និងវិធីសកម្ម។ លោក ពៅ សាគួងបានលើកឡើងថាវិធីបង្រៀនដែលមានសារៈសំខាន់បំផុតទាល់ តែវិធីនោះមានគោលបំណងពីរយ៉ាង:

- មានប្រយោជន៍ដល់ក្មេង និងដល់ជីវភាពរបស់ក្មេង
- នាំក្មេងឲ្យចូលចិត្តរៀនដោយខ្លួនឯងទៅអនាគត ។

វិធីបង្រៀនបែបនេះ អាចបំពេញគោលបំណងទាំងពីរនោះបាន ទាល់តែវិធីនោះអាចបណ្តុះបញ្ញាទាំងឡាយរបស់ក្មេងបានសមរម្យ ព្រមទាំងបណ្តុះឆន្ទៈរបស់ក្មេងនោះផង។ ទោះបីជា យ៉ាងណាក៏ដោយ វិធីបង្រៀនតាមគំនិតលោក ពៅ សាគួង ដែលចុះផ្សាយក្នុងទស្សនាវដ្ដីគ្រូបង្រៀននេះមិនដឹងជាគ្រូយកទៅអនុវត្តបានកម្រិតណាទេ ព្រោះក្រោយមកគេមិនឃើញការចុះផ្សាយពីការអនុវត្តតាមវិធីនេះដោយរបៀបណាទេ តែលោក ពៅ សាគួង មានគំនិតផ្សារភ្ជាប់ទៅនឹងការអនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌលមុនគេបង្អស់នៅក្នុងសាលារៀនប្រទេសកម្ពុជា។ លុះក្រោយមកនៅក្នុងឆ្នាំ១៩៥៩ លោក ឈូក ម៉ឹងម៉ៅ និងលោក ហូ តុងហូ មិនបានយកចិត្តទុកដាក់ក្នុងការប្រើប្រាស់វិធីនោះទេ ហើយវិធីនោះក៏បានសាបរលាបទៅ ។

មកដល់ឆ្នាំ១៩៦០ ទស្សនាវដ្ដីគ្រូបង្រៀនលេខពិសេស បានលើកឡើងពីកម្មវិធីសិក្សាទូទៅដែលជៀសមិនផុតពីបរាជ័យចំពោះការអនុវត្តវិធីសាស្ត្របង្រៀន តាមបែបបំពេញចំណេះដឹងទៅក្នុងខួរក្បាលសិស្ស។ សិស្សធ្វើអ្វីៗទៅតាមបញ្ជាពីគ្រូមិនមែនចេញពីឆន្ទៈខ្លួនឯង។ ការអនុវត្តវិធីអនុមានញែកដំបូងគឺចេញពីទ្រឹស្ដី តែគ្មានការប្រតិបត្តិ។ វិធីសកម្មតាមអនុមានរួមក៏មិនទទួលបានជោគជ័យដែរព្រោះកុមារផ្ដើមចេញពីការធ្វើពិសោធន៍ ការប្រតិបត្តិ ការប្រៀបធៀប ការធ្វើសំយោគពាក់ព័ន្ធទៅនឹងជីវភាពរស់នៅជាក់ស្ដែងហេតុការណ៍ ព្រឹត្តិការណ៍ដើម្បីឈានទៅដល់របកគំហើញផ្នែកទ្រឹស្ដី ឬនិយមន័យតែ ទីបំផុតគ្រូនៅតែមិនមានសមត្ថភាពណែនាំសិស្សឱ្យសម្រេចបានតាមគោលដៅនេះ។ ការសិក្សាត្រូវប្រព្រឹត្តទៅក្នុងបរិយាកាសមួយនៃសេរីភាព មានទំនុកចិត្តសុវត្ថិភាព និងសប្បាយរីករាយ។ ការលើកឡើងបែបនេះ គឺក្នុងគោលបំណងឱ្យគ្រូអនុវត្តគោលវិធីបង្រៀនតាមបែបសិស្សមជ្ឈ

មណ្ឌល តែគេមិនបានផ្សារភ្ជាប់គំនិតនេះទៅនឹងគំនិតរបស់លោក ៧ សាគួង កាលពីឆ្នាំ១៩៥៨ទេ តែនេះជាគំនិតរបស់អ្នកនិពន្ធផ្សេងទៅវិញ។

ក្នុងឆ្នាំ១៩៩២លោក **Keart Predibert** ជាទីប្រឹក្សារបស់អង្គការ **Redd Barna** បានធ្វើសិក្ខាសាលាផ្សព្វផ្សាយវិធីសាស្ត្របង្រៀនមួយដែលមានឈ្មោះថា ការសិក្សាតាមបែបសហការ។ អ្នកចូលរួមសិក្ខាសាលា គឺជួរគ្រូឧទ្ទេសបឋមសិក្សាសម្រាប់ចុះទៅបំប៉ន ជួរគ្រូបឋមសិក្សាតាមស្រុកឱ្យចេះប្រើប្រាស់វិធីសាស្ត្របង្រៀន ៖

- ភាសាខ្មែរ ថ្នាក់ទី១ ទី២ និង ទី៣
- ភូមិវិទ្យា និងប្រវត្តិវិទ្យា ថ្នាក់ទី៤
- មុខវិទ្យាវិទ្យាសាស្ត្រ ថ្នាក់ទី ៤

វិធីសាស្ត្របង្រៀនមុខវិជ្ជាទាំងនេះ ត្រូវបានគ្រូបឋមសិក្សានៅក្នុងស្រុកចំនួន៤ក្នុងខេត្តកំពង់-ចាម យកទៅអនុវត្តគឺស្រុកព្រៃឈរ-បាធាយ-ត្បូងឃ្មុំ-និងជើងព្រៃ ដែលមានសាលារៀនសរុបចំនួន ៣០កន្លែង និងសិស្សចូលរួមចំនួន ២២ ០០០នាក់។

នៅដើមឆ្នាំ១៩៩៤ ពីថ្ងៃទី២១ ខែ កុម្ភៈ ដល់ថ្ងៃទី១៨ ខែ មីនា ឆ្នាំ ១៩៩៤ មានសិក្ខាសាលាមួយបានប្រារព្ធធ្វើនៅមហាវិទ្យាល័យគរុកោសល្យនាទីក្រុងភ្នំពេញ ក្រោមការណែនាំរបស់លោកបណ្ឌិត Ratta nayke ជាជនជាតិស្រីលង្កាមកពីអង្គការ Redd Barna អ្នកចូលរួមសិក្ខាសាលាមាននាយក នាយករងសាលា ប្រធាន និងអនុប្រធានការិយាល័យអប់រំស្រុកមកពីទូទាំងប្រទេស។ សិក្ខាសាលា នោះលើកឡើងពី ៖

- ការវិភាគពីស្ថានភាពមានបញ្ហា ដើម្បីអភិវឌ្ឍញ្ញាណរបស់កុមារនៅបឋមសិក្សា
- ល្បែងសិក្សា និងបច្ចេកទេសបង្រៀនដែលជំរុញឱ្យកុមារចេះវិភាគស្ថានភាពបញ្ហា
- ការអនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌលលើគ្រប់មុខវិជ្ជា ជាពិសេសមុខវិជ្ជាគណិតវិទ្យា។

នៅខែសីហា និងខែកញ្ញាឆ្នាំ១៩៩៤ មានសិក្ខាសាលាក្រោមការឧបត្ថម្ភរបស់អង្គការ World Learning Inc/World Education andSave the Children/USA នៅតាមកម្រងសាលាចំនួន៤ក្នុងខេត្តតាកែវគឺប្រាសាទនាងខ្មៅ ត្រពាំងធំ ភ្នំចចក និងចំបក់។សិក្ខាសាលានេះបំផុសពីគោលការណ៍នៃការបង្រៀនតាមបែបសិស្សមជ្ឈមណ្ឌល ដោយសង្កត់ធ្ងន់លើការបង្រៀនភាសាខ្មែរ និងគណិតវិទ្យា ។

នៅឆ្នាំ១៩៩៦កម្មវិធីសិក្សាកែទម្រង់នេះបានមកពីសំយោគរវាងកម្មវិធីសិក្សារបស់សង្គមជាតិយើងទាំងឡាយពីជំនាន់មុន មានកម្មវិធីសិក្សាឆ្នាំ១៩៥៨ កម្មវិធីសិក្សាឆ្នាំ១៩៦៧ (ជំនាន់សង្គមរាស្ត្រនិយម) កម្មវិធីសិក្សាឆ្នាំ១៩៨០ កម្មវិធីសិក្សាឆ្នាំ១៩៨៦ (ជំនាន់សាធារណរដ្ឋប្រជាមានិតកម្ពុជា) និង

កម្មវិធីរបស់ប្រទេសជឿនលឿននៅក្នុងតំបន់ និងក្នុងពិភពលោក។

ការបណ្តុះបណ្តាលធនធានមនុស្សនៅវិទ្យាល័យមានការកែប្រែកម្មវិធីសិក្សានិងមេរៀនរហូតដល់សព្វថ្ងៃ។ បច្ចុប្បន្នយើងចង់ដឹងថា វិធីបង្រៀននិងរៀនតាមកម្មវិធីសិក្សាមានឥទ្ធិពលបែបណាចំពោះការបង្រៀន និងរៀននៅវិទ្យាល័យ។ ដូច្នេះវាទាមទារឱ្យមានការសិក្សាអំពីការអនុវត្ត និងប្រសិទ្ធិភាពនៃវិធីសាស្ត្របង្រៀនតាមបែបគោលវិធីសិស្សមជ្ឈមណ្ឌលនៅវិទ្យាល័យនៅកម្ពុជា។

សារៈសំខាន់នៃការស្រាវជ្រាវគឺរកឱ្យឃើញពីបញ្ហាដែលពាក់ព័ន្ធវិធីបង្រៀន និងរៀនផ្នែកវិទ្យាសាស្ត្រសង្គម ស្វែងរកដំណោះស្រាយបទពិសោធន៍ចំពោះតម្រូវការនូវការបង្រៀន និងរៀនតាមរយៈវិធីសាស្ត្រទំនើបៗ និងធ្វើឱ្យការបង្រៀនកាន់តែមានគុណភាពខ្ពស់ថែមទៀត។

## ៣. គោលបំណងនៃការស្រាវជ្រាវ

ការស្រាវជ្រាវនេះមានគោលបំណងសិក្សាស្វែងយល់ពីការបណ្តុះបណ្តាល ការអនុវត្ត និងទស្សនៈយល់ឃើញរបស់គ្រូ និងសិស្ស ចំពោះវិធីសាស្ត្របង្រៀនបែបសិស្សមជ្ឈមណ្ឌលមុខវិជ្ជាវិទ្យាសាស្ត្រសង្គមនៅវិទ្យាល័យ។

## ៤. សំណួរស្រាវជ្រាវ

លទ្ធផលនៃការសិក្សានេះនឹងឆ្លើយនូវសំណួរស្រាវជ្រាវដូចខាងក្រោម ៖

- តើការអនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌលនៃមុខវិជ្ជាវិទ្យាសាស្ត្រសង្គមនៅវិទ្យាល័យមានលក្ខណៈយ៉ាងដូចម្តេច?
- តើសាស្ត្រាចារ្យយល់ឃើញយ៉ាងដូចម្តេចអំពីការអនុវត្តនូវគោលវិធីសិស្សមជ្ឈមណ្ឌល?
- តើសិស្សយល់ឃើញយ៉ាងដូចម្តេចអំពីការអនុវត្តនូវគោលវិធីសិស្សមជ្ឈមណ្ឌល?

## ៥. ការរំលឹកទ្រឹស្តី និងការសិក្សាដែលពាក់ព័ន្ធ

គោលវិធីសិស្សមជ្ឈមណ្ឌល គឺជាលំនាំនៃការសិក្សា និងការបង្រៀនដោយផ្តោតលើសកម្មភាពសិស្សជាមូលដ្ឋាន។ នៅក្នុងគោលវិធីនេះគ្រូទាមទារឱ្យសិស្សដើរតួនាទីជាអ្នកធ្វើសកម្មភាពស្វែងយល់ និងឈានដល់របកគំហើញបែបណាមួយដោយខ្លួនឯង ក្រោមការដឹកនាំរបស់គ្រូ សំដៅជួយសិស្សឱ្យសម្រេចបាននូវចំណេះដឹង បំណិន ការអភិវឌ្ឍកម្រិតយល់ដឹង និងបុគ្គលិកលក្ខណៈ។

ក្នុងចំណោមទស្សនៈវិទូ និងគរុវិទូដែលបានយកចិត្តទុកដាក់ដល់ការអភិវឌ្ឍចំណេះដឹងរបស់សិស្សតាមបែបក្បួនគរុកោសល្យបុរាណ និងគរុកោសល្យទំនើបមានដូចជា៖

ទស្សនៈអ្នកប្រាជ្ញដែលបានលើកយកការបង្រៀនតាមរយៈសំណួរដើម្បីឱ្យសិស្សចេះស្រាវជ្រាវរកនូវរបកគំឃើញ និងចំណេះដឹងដោយខ្លួនឯងមានដូចជា លោក **Socrate** (៤៦៩-៣៩៩មុនគ-ស)

បានពោលថា ម្តាយខ្ញុំជាឆ្មបសម្រាលកូន ចំណែកខ្ញុំជាឆ្មបសម្រាលគំនិត, លោក**Platon** (៤២៧-៣៤៨មុនគ-ស) ពោលថា«សិល្បៈគរុកោសល្យគឺជាសិល្បៈនៃការចោទសួរ»លោកConfucius (៥៥១-៤៧៩មុនគ-ស) បើចង់ចេះតែមិនមានឆន្ទៈនោះគឺមិនរីកបញ្ញាទេ បើចង់យល់ច្បាស់តែមិនខឹងចិត្តនោះក៏មិនដុះគំនិតដែរ, លោក *Gallimore* និង*Trarp*(១៩៩០), លោកCarl Rogers(១៩៨៣) ជាចិត្តវិទូអាមេរិកាំង, លោកTorrance (១៩៧២) ។

ទស្សនៈអ្នកប្រាជ្ញដែលបានលើកឡើងពីគោលការណ៍បង្រៀន និងរូបភាពបង្រៀនដោយសង្កត់ធ្ងន់ទៅលើវិធីសកម្ម (ចរិតសកម្ម ចរិតម្ចាស់ការ និងគំនិតច្នៃប្រឌិត) របស់សិស្សមានដូចជា លោក Komenski(១៥៩២-១៦៧០មុនគ-ស)ជាវិទូជាតិឆេក្ង លោកUchinsky(១៨២៤-១៨៧០)ជាគរុវិទូជាតិរុស្ស៊ី លោក Distrveck (១៧៩០-១៨៦៦)ជាគរុវិទូជាតិអាល្លឺម៉ង់ លោកJeanJacques Rouseau (១៧១២-១៧៧៨)ជាគរុវិទូជាតិបារាំង លោកY Hossba(១៧៧៦-១៨១៤)ជាគរុវិទូ និងចិត្តវិទូដ៏ល្បី ជាតិអាល្លឺម៉ង់ លោកJohn Lock (១៦៣០-១៧០៤)ជាគរុវិទូជាតិអង់គ្លេស លោកJohann Henrich Peatalozzi (១៧៤៦-១៨២៧)ជាគរុវិទូជាតិស្វិស លោក Herbert Spencer(១៨២០-១៨២៧)ជាគរុវិទូនិងទស្សនៈវិទូជាតិអាល្លឺម៉ង់ លោក G.ISukinas ជា គរុវិទូជាតិរុស្ស៊ី លោក R.A.Nizamovជាគរុវិទូជាតិរុស្ស៊ី លោកស្រី L.Aristova ជាចិត្តវិទូជាតិរុស្ស៊ី លោក B.P.Exipov ជាគរុវិទូជាតិរុស្ស៊ី, លោក Jean Piaget (១៨៩៦-១៩៨០)ជាគរុវិទូជាតិស្វីស, លោកJerome Bruner ជាអ្នកប្រាជ្ញផ្នែកវិទ្យាសាស្ត្រអប់រំជាតិអាមេរិកកាំង, លោក Guilford ចិត្តវិទូ អៀរឡង់(Ireland), និង លោក Torrance (១៩៧២)។

ទស្សនៈអ្នកប្រាជ្ញដែលបានលើកឡើងពីគោលការណ៍បង្រៀនដោយសង្កត់ធ្ងន់ទៅលើការអនុវត្តនិងតម្រូវការរបស់សិស្សមានដូចជា លោក John Dewey (១៨៥៩-១៩៥២) ជាគរុវិទូជាតិអាមេរិកកាំង លោក Gaston Bacherlard(១៨៨៤-១៩៦២), ជាទស្សនវិទូជាតិបារាំង, លោក G.I Sukinas ជាគរុវិទូជាតិរុស្ស៊ី,លោក R.A.Nizamov ជាគរុវិទូជាតិរុស្ស៊ីដ៏ល្បីឈ្មោះលោក Lev Semenovch Vygotsky (១៨៩៦-១៩៣៤) ជាចិត្តវិទូរុស្ស៊ីដ៏មានទេពកោសល្យ លោក Jerome Bruner ជាអ្នកប្រាជ្ញផ្នែកវិទ្យាសាស្ត្រអប់រំជាតិអាមេរិកកាំង, លោកCarl Rogersជាចិត្តវិទូអាមេរិកាំង, លោក Arthur Comb (១៩៧៤) លោក Abraham Maslow ជាចិត្តវិទូអាមេរិកកាំង។

## ៦. វិធីសាស្ត្រស្រាវជ្រាវ

### *៦.១. វិធីសាស្ត្រប្រមូលទិន្នន័យ*

ការសិក្សានេះនឹងប្រើកម្រងសំណួរដើម្បីប្រមូលទិន្នន័យពីគ្រូបង្រៀន និងសិស្សនៅវិទ្យាល័យចំនួន២០៤នាក់ ដោយធ្វើការសម្ភាសពាក់កណ្តាលរចនាសម្ព័ន្ធជាមួយគ្រូបង្រៀនសម្រាប់មុខវិជ្ជា

អក្សរសាស្ត្រ ប្រវត្តិវិទ្យា ភូមិវិទ្យា សីលធម៌ពលរដ្ឋ និងសិស្សថ្នាក់ទី១០ ថ្នាក់ទី១១ និងថ្នាក់ទី១២។ គ្រូបង្រៀន និងសិស្សនៅវិទ្យាល័យនឹងជ្រើសរើសដោយចៃដន្យចេញពីវិទ្យាល័យនៅរាជធានីភ្នំពេញ ខេត្តតាកែវ ខេត្តបាត់ដំបង និងខេត្តព្រះវិហារ។ រាជធានីខេត្តទាំងនេះត្រូវបានជ្រើសរើស ដើម្បីឆ្លុះបញ្ចាំងពីវិទ្យាល័យនៅរាជធានីភ្នំពេញ ខេត្តតំបន់ប្រជុំជន ខេត្តតំបន់ជនបទ និងខេត្តដាច់ស្រយាល។

គ្រូបង្រៀនផ្នែកវិទ្យាសាស្ត្រសង្គមចំនួន៩៦នាក់សិស្សចំនួន៧២នាក់ត្រូវបានជ្រើសរើសចេញពីរាជធានីភ្នំពេញ ខេត្ត ព្រះវិហារ ខេត្ត តាកែវ នឹង ខេត្ត បាត់ដំបង ដែលក្នុងមួយរាជធានី ឬ ខេត្ត មានគ្រូផ្នែកវិទ្យាសាស្ត្រសង្គមចំនួន ២៤នាក់ និង សិស្សចំនួន ១៨ នាក់ត្រូវបានរើស និងខេត្តនីមួយៗ ដើម្បីធ្វើសម្ភាសបំពេញកម្រងសំណួរ។ មុនធ្វើសម្ភាសន៍បំពេញកម្រងសំណួរ។ ក្រៅពីនេះ គ្រូបង្រៀនចំនួន៣២នាក់ ក្នុងចំណោមគ្រូ៩៦នាក់ក៏ត្រូវបានជ្រើសរើស ដើម្បីធ្វើការសង្កេតថ្នាក់ផងដែរ។

កម្រងសំណួរ និងសំណួរសម្ភាសន៍បានផ្តោតទៅលើការបណ្តុះបណ្តាល ការអនុវត្តបញ្ហាប្រឈមដំណោះស្រាយ និងការយល់ឃើញរបស់គ្រូចំពោះការអនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌល ចំណែក សិស្សផ្តោតលើបទពិសោធទទួលបានពីគ្រូបង្រៀនបែបគោលវិធីសិស្សមជ្ឈមណ្ឌល និងទស្សនៈយល់ឃើញចំពោះគោលវិធីសិស្សមជ្ឈមណ្ឌល។

*៦.២. វិធីសាស្ត្រវិភាគទិន្នន័យ*

ទិន្នន័យដែលបានមកពីការបំពេញកម្រងសំណួរ និងសម្ភាសន៍ត្រូវបានយកទៅវិភាគជាប្រេកង់ ភាគរយ មធ្យមភាគ កម្រិតទាបបំផុត កម្រិតខ្ពស់បំផុត ជាដ្យាក្រាម និងជាលក្ខណៈរៀបរាប់ដោយផ្តោតលើនិន្នាការ ឬលក្ខណៈរួមនៃចម្លើយ។

## ៧. លទ្ធផលរំពឹងទុកនៃការស្រាវជ្រាវ

ការស្រាវជ្រាវនេះនឹងផ្តល់នូវការយល់ដឹងអំពីការបណ្តុះបណ្តាល ការអនុវត្ត ការប្រឈម និងទស្សនៈយល់ឃើញរបស់គ្រូ និងសិស្សចំពោះគោលវិធីសិស្សមជ្ឈមណ្ឌល ដើម្បីទទួលបានការអប់រំមួយប្រកបដោយគុណភាព និងប្រសិទ្ធភាព នៅប្រទេសកម្ពុជានាពេលអនាគត។

## ៨. លទ្ធផលនៃការស្រាវជ្រាវស្តីពីគោលវិធីសិស្សមជ្ឈមណ្ឌល

### ៨.១. ការសម្ភាសជាមួយគ្រូបង្រៀន

*៨.១.១ លក្ខណៈអ្នកឆ្លើយ*

*សំណាក និងទីតាំង*

ជ្រើសរើសទីតាំងចំនួន៤កន្លែងសម្រាប់ប្រមូលទិន្នន័យគឺ រាជធានីភ្នំពេញ ខេត្តបាត់ដំបង ខេត្តតាកែវ និងខេត្តព្រះវិហារ។ សម្រាប់វិទ្យាល័យសំណាកជាគ្រូបង្រៀនត្រូវបានជ្រើសរើសដោយចៃដន្យ ក្នុងមួយទីតាំងមានចំនួន២៥នាក់ រីឯនៅខេត្តព្រះវិហារប្រមូលបានសំណាកតែ២០នាក់ប៉ុណ្ណោះ។ សរុបមានលោកគ្រូ អ្នកគ្រូចំនួន៩៥នាក់ដែលត្រូវបានជ្រើសរើសជាសំណាកសម្រាប់សម្ភាសន៍។



រូបទី១ សម្ភាសន៍គ្រូដោយបំពេញកម្រងសំណួរ



រូបទី២ សម្ភាសន៍គ្រូជាក្រុម

*ក្រុមអាយុ និងភេទ*

សំណាកត្រូវបានបែងចែកជា៨ក្រុមអាយុ ក្រុមទាបបំផុតមានអាយុចន្លោះពី២០-២៥ឆ្នាំ និងក្រុមអាយុច្រើនបំផុតចន្លោះពី៥៥-៦០ឆ្នាំ។ ក្រុមអាយុនៃសំណាកទាំង៨ក្រុមនោះគឺ ក្រុមអាយុចន្លោះពី២០-២៥ឆ្នាំមាន៦% ២៦-៣០ឆ្នាំមាន២៦% ៣១-៣៥ឆ្នាំមាន១០% ក្រុមអាយុពី៣៦-៤០ឆ្នាំមាន៣០% ៤១-៤៥ឆ្នាំមាន១៨% ៤៦-៥០ឆ្នាំមាន២% ៥១-៥៥ឆ្នាំមាន៣% និងក្រុមអាយុពី៥៦-៦០ឆ្នាំមាន៥%។ ដោយឡែកភេទប្រុសមាន៧០% និងភេទស្រី៣០%។

*រយៈពេលបំពេញការងារ*

រយៈពេលបំពេញការងាររបស់គ្រូ ត្រូវបានបែងចែកជា៧ក្រុមយ៉ាងតិចបំផុតគឺ ចន្លោះពី១-៥ឆ្នាំ និងច្រើនបំផុតពី៣១-៣៥ឆ្នាំ។ ក្រុមដែលបានបំពេញការងារពី១-៥ឆ្នាំមាន១៧% ៦-១០ឆ្នាំមាន២០% ១១-១៥ឆ្នាំមាន២៣% ១៦-២០ឆ្នាំមាន១៨% ២១-២៥ឆ្នាំមាន១៦% ២៦-៣០ឆ្នាំមាន៤% និង៣១-៣៥ឆ្នាំ មាន២%។

*មុខវិជ្ជា*

លោកគ្រូ អ្នកគ្រូមុខវិជ្ជាផ្នែកសង្គមចំនួនបួនសំខាន់ត្រូវបានជ្រើសមកសម្ភាសន៍គឺ មុខវិជ្ជាអក្សរ

សាស្ត្រមាន៣៩% ភូមិវិទ្យាមាន១៧% ប្រវត្តិវិទ្យាមាន២១% សីលធម៌ពលរដ្ឋមាន១៧% ក្រៅពីនោះមានមុខវិជ្ជាផ្នែកសង្គមផ្សេងៗទៀត ដូចជាមុខវិជ្ជាសេដ្ឋកិច្ច គេហកិច្ច និងភាសាអង់គ្លេសមាន៦%។

*កម្រិតវប្បធម៌*

លោកគ្រូ អ្នកគ្រូដែលបានចូលរួមផ្តល់សម្ភាសន៍មានកម្រិតវប្បធម៌ទាបបំផុតសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ និងខ្ពស់បំផុតកម្រិតបរិញ្ញាបត្រជាន់ខ្ពស់។ អ្នកដែលមានសញ្ញាបត្រទុតិយភូមិមាន៣០%, បរិញ្ញាបត្រ៥៦% និងបរិញ្ញាបត្រជាន់ខ្ពស់មាន១៥%។

*បទពិសោធន៍នៃការងារបង្រៀន*

លោកគ្រូ អ្នកគ្រូដែលធ្លាប់បានបង្រៀននៅបឋមសិក្សា អនុវិទ្យាល័យ និងវិទ្យាល័យមាន១%, នៅអនុវិទ្យាល័យ និងវិទ្យាល័យមាន៤៤% និងនៅវិទ្យាល័យមាន៥៥% ។

*៨.១.២. ការបណ្តុះបណ្តាលពីគោលវិធីសិស្សមជ្ឈមណ្ឌល*

លោកគ្រូ អ្នកគ្រូដែលបានទទួលការបណ្តុះបណ្តាលពីគោលវិធីសិស្សមជ្ឈមណ្ឌលមាន៩៩% និងអ្នកដែលមិនបានទទួលការបណ្តុះបណ្តាលមាន១%។ អ្នកដែលបណ្តុះបណ្តាលនៅសាលាគរុកោសល្យមាន២% មជ្ឈមណ្ឌលគរុកោសល្យភូមិភាគទាំង៦មាន៣៥% វិទ្យាស្ថានជាតិអប់រំមាន៣០% សាលាគរុកោសល្យ និងមជ្ឈមណ្ឌលគរុកោសល្យភូមិភាគមាន១៧% សាលាគរុកោសល្យ មជ្ឈមណ្ឌលគរុកោសល្យភូមិភាគ និងវិទ្យាស្ថានជាតិអប់រំមាន៤% សាលាគរុកោសល្យ និងវិទ្យាស្ថានជាតិអប់រំមាន៤% បរទេសមាន៥% ក្រៅពីនោះធ្លាប់បានបណ្តុះបណ្តាលនៅកន្លែងផ្សេងៗទៀតមាន៤%។

*៨.១.៣. ចំណេះដឹងស្តីពីគោលវិធីសិស្សមជ្ឈមណ្ឌល*

*សម្ភារ*

ទ្រឹស្តីនៃការប្រើប្រាស់សម្ភារក្នុងការបង្រៀន និងរៀនបែបសិស្សមជ្ឈមណ្ឌលមាន៣ចំណុច។ ទី១គ្រូ និងសិស្សមានសម្ភារដូចគ្នាសម្រាប់អាន សង្កេត ពិសោធន៍ និងអនុវត្តឱ្យចំទិសដៅ។ ទី២សិស្សចេះប្រើសម្ភារឧបទេស និងចេះអនុវត្ត។ ទី៣គ្រូធ្វើសកម្មភាពតិច ឯសិស្សវិញធ្វើសកម្មភាពច្រើន។ យោងតាមទ្រឹស្តីខាងលើនេះ៩៧,៥% នៃលោកគ្រូអ្នកគ្រូដែលបានផ្តល់សម្ភាសន៍ ចេះទ្រឹស្តីពីការប្រើប្រាស់សម្ភារឧបទេសក្នុងការបង្រៀន និងរៀនតាមបែបគោលវិធីសិស្សមជ្ឈមណ្ឌល។ ហើយមានតែ២,៥%នៃលោកគ្រូអ្នកគ្រូប៉ុណ្ណោះដែលមិនទាន់បានយល់ទ្រឹស្តីគោលវិធីសិស្សមជ្ឈមណ្ឌល។

*វត្ថុបំណង*

ទ្រឹស្តីនៃវត្ថុបំណងបង្រៀន និងរៀនបែបសិស្សមជ្ឈមណ្ឌលមាន៣ចំណុច។ ទី១កំណត់ឱ្យសិស្សយល់បានពី៨៥ទៅ១០០%។ ទី២ ពិតជាអាចសម្រេចតាមវត្ថុបំណង។ ទី៣ គ្រូត្រូវមានកិច្ចតែងការ

បង្រៀន។ យោងតាមទ្រឹស្តីខាងលើនេះ ៩៨%នៃលោកគ្រូ អ្នកគ្រូដែលបានសម្ភាសន៍ចេះពីទ្រឹស្តីនៃវត្ថុបំណងក្នុងការបង្រៀន និងរៀនតាមបែបគោលវិធីសិស្សមជ្ឈមណ្ឌល ហើយមានតែ២%នៃលោកគ្រូ អ្នកគ្រូប៉ុណ្ណោះ ដែលមិនទាន់យល់ទ្រឹស្តីនេះ ។

*សកម្មភាព*

ទ្រឹស្តីនៃសកម្មភាពបង្រៀន និងរៀនតាមបែបគោលវិធីសិស្សមជ្ឈមណ្ឌលមាន១៦ចំណុច។ ទី១គ្រូធ្វើសកម្មភាពបង្រៀន ដោយប្រើរូបភាពរំលឹកមេរៀនចាស់ ទី២សិស្សអាចភ្ជាប់ចំណេះដឹងចាស់ និងថ្មី។ ទី៣គ្រូណែនាំសិស្សឱ្យធ្វើការងារជាក្រុម និងធ្វើលំហាត់ជាក្រុម ឬជាបុគ្គល។ ទី៤គ្រូដាក់បញ្ហាឱ្យសិស្សដោះស្រាយតាមក្រុម ទី៥សិស្សពិភាក្សាដោះស្រាយបញ្ហាតាមក្រុម ទី៦សិស្សឡើងសរសេរចម្លើយតាមក្រុម ទី៧សិស្សពិភាក្សាជាក្រុមរកចម្លើយរួម ទី៨ទិដ្ឋភាពក្នុងថ្នាក់រៀនសិស្សមានសកម្មភាពរស់រវើក ទី៩គ្រូយកចិត្តទុកដាក់ទៅលើតួនាទីរបស់សិស្ស ទី១០គ្រូជួយជំរុញឱ្យសិស្សស្រាវជ្រាវដោយខ្លួនឯង ទី១១គ្រូបំផុសគំនិតឱ្យសិស្សចង់រៀនយកស្នាដៃ ទី១២គ្រូសង្កត់ធ្ងន់លើការងារជាក្រុមតូចឬធំ ទី១៣គ្រូផ្តល់បទពិសោធន៍ថ្មីតិចតួចឱ្យសិស្ស ទុកឱ្យសិស្សរកឃើញខ្លួនឯង ទី១៤គ្រូបញ្ជ្រាបសីលធម៌លើមុខវិជ្ជាសិក្សា ទី១៥គ្រូទម្លាប់ឱ្យសិស្សក្លាហានក្នុងការនិយាយ និងទី១៦សិស្សត្រៀមខ្លឹមសារសម្រាប់ឆ្លើយ។

យោងតាមទ្រឹស្តីខាងលើ ៩៨%នៃលោកគ្រូ អ្នកគ្រូដែលបានសម្ភាសន៍ចេះពីសកម្មភាពបង្រៀន និងរៀនបែបគោលវិធីសិស្សមជ្ឈមណ្ឌល ហើយមានតែ២%នៃលោកគ្រូ អ្នកគ្រូប៉ុណ្ណោះ ដែលមិនទាន់ចេះទ្រឹស្តីនេះ។

*ខ្លឹមសារ*

ទ្រឹស្តីនៃខ្លឹមសារបង្រៀន និងរៀនតាមបែបគោលវិធីសិស្សមជ្ឈមណ្ឌលមាន៧ចំណុច។ ទី១សិស្សកសាងមេរៀនបានដោយខ្លួនឯង ក្រោមការដឹកនាំ និងណែនាំរបស់គ្រូ ទី២សិស្សស្ទើរតែទាំងអស់យល់ខ្លឹមសារមេរៀន ទី៣សិស្សអាងលើសមត្ថភាពរួមកសាងមេរៀន ទី៤សិស្សទទួលព័ត៌មាន និងយល់ដឹងពីមិត្តភក្តិ ទី៥សិស្សចេះបង្កើតសម្មតិកម្ម និងដោះស្រាយបញ្ហា ទី៦សិស្សចូលរួមដោះស្រាយបញ្ហា និងទី៧សិស្សជាអ្នកចូលរួមកសាងឯកសារមេរៀន។

យោងតាមទ្រឹស្តីខាងលើ ៩៣%នៃលោកគ្រូអ្នកគ្រូ ដែលបានសម្ភាសន៍ចេះពីខ្លឹមសារបង្រៀន និងរៀនបែបគោលវិធីសិស្សមជ្ឈមណ្ឌល ហើយមានតែ៧%នៃលោកគ្រូ អ្នកគ្រូប៉ុណ្ណោះ ដែលមិនទាន់ចេះទ្រឹស្តីនេះ។

*ការអភិវឌ្ឍបុគ្គលិកលក្ខណៈរបស់សិស្ស*

ទ្រឹស្តីនៃការអភិវឌ្ឍបុគ្គលិកលក្ខណៈរបស់សិស្សតាមរយៈការបង្រៀន និងរៀនបែបគោលវិធីសិស្សមជ្ឈមណ្ឌលមាន៧ចំណុច ៖ ទី១សិស្សមានទម្លាប់រៀនដោយខ្លួនឯង ទី២សិស្សមានទំនុកចិត្តលើខ្លួនឯង ទី៣សិស្សមានទម្លាប់ឡើងបញ្ចេញមតិយោបល់ ទី៤សិស្សមិនទម្លាប់និយាយកាត់សំដីអ្នកដទៃ ទី៥សិស្សមានទម្លាប់គោរពលទ្ធិប្រជាធិបតេយ្យ ទី៦សិស្សគោរពសិទ្ធិគ្នានៅក្នុងក្រុម។ ទី៧សិស្សមានទម្លាប់ម្ចាស់ការស្រាវជ្រាវដោយខ្លួនឯង។ (បណ្ឌិត.ចាន់ រដ្ឋសុធា២០០៥)

យោងតាមទ្រឹស្តីខាងលើ៩៨%នៃលោកគ្រូ អ្នកគ្រូដែលបានសម្ភាសន៍យល់ពីទ្រឹស្តីនៃការអភិវឌ្ឍបុគ្គលិកលក្ខណៈរបស់សិស្ស តាមរយៈការបង្រៀន និងរៀនបែបគោលវិធីសិស្សមជ្ឈមណ្ឌល។

*លទ្ធផលសិក្សា*

ទ្រឹស្តីនៃលទ្ធផលសិក្សារបស់សិស្ស តាមការបង្រៀន និងរៀនបែបគោលវិធីសិស្សមជ្ឈមណ្ឌលមាន៩ចំណុច ៖ ទី១សិស្សយល់ដឹងដោយធ្វើសកម្មភាពខ្លួនឯង ទី២ សិស្សយល់ដោយធ្វើការពិភាក្សាគ្នា ទី៣សិស្សយល់ និងចងចាំបានយូរ ទី៤ សិស្សអាចពង្រឹងចំណេះធ្វើ និងបំណិន ទី៥សិស្សអាចឈានដល់កម្រិតស្វ័យអភិវឌ្ឍ ទី៦ សិស្សអាចអភិវឌ្ឍគ្រួសារ និងសង្គមបាន ទី៧ពឹងផ្អែកលើសកម្មភាពម្ចាស់ការរបស់សិស្ស ទី៨ការអប់រំសម្រេចតាមគោលបំណង ទី៩គ្រូអាចវាយតម្លៃសមត្ថភាពសិស្សម្នាក់ៗ។ (បណ្ឌិត.ចាន រដ្ឋសុធា២០០៥)

យោងតាមទ្រឹស្តីខាងលើ ៩៩%នៃលោកគ្រូ អ្នកគ្រូ ដែលបានសម្ភាសន៍យល់ពីទ្រឹស្តីនៃលទ្ធផលរបស់សិស្ស តាមរយៈការបង្រៀន និងរៀនបែបគោលវិធីសិស្សមជ្ឈមណ្ឌល។

*កិច្ចតែងការបង្រៀន*

លោកគ្រូ អ្នកគ្រូ៩៨%បានរៀនពីរបៀបធ្វើកិច្ចតែងការបង្រៀន និងមានតែ២%មិនបានរៀន។ នៅក្នុងកិច្ចតែងការបង្រៀនមានចំណុច៦សំខាន់ៗ៖ ទី១ចំណងជើងមេរៀន ទី២រយៈពេលនៃការបង្រៀនមេរៀន ទី៣វត្ថុបំណងមេរៀនក្នុងនោះមានចំណេះដឹង បំណិននិងឥរិយាបថ ទី៤ខ្លឹមសារសំខាន់ៗ ទី៥សម្ភារៈឧបទេស ទី៦ដំណើរការបង្រៀនមាន **ជំហានទី១**គ្រូសំណេះសំណាលជាមួយសិស្ស ត្រួតពិនិត្យអវត្តមាន អនាម័យ សណ្តាប់ធ្នាប់ **ជំហានទី២**រំលឹកមេរៀនចាស់ **ជំហានទី៣**ចូលមេរៀនថ្មី **ជំហានទី៤**ពង្រឹងពុទ្ធិ និង**ជំហានទី៥**បណ្តាំផ្ញើរបស់គ្រូឬកិច្ចការផ្ទះ។

យោងតាមទ្រឹស្តីខាងលើ៩៩,៨១%នៃលោកគ្រូអ្នកគ្រូដែលបានសម្ភាសន៍ ចេះពីរបៀបធ្វើកិច្ចតែងការបង្រៀន និងរៀនតាមបែបគោលវិធីសិស្សមជ្ឈមណ្ឌល។

សរុប៩៨%នៃលោកគ្រូ អ្នកគ្រូដែលបានសម្ភាសន៍មានចំណេះដឹងស្តីពីការបង្រៀន និងរៀនបែប

គោលវិធីសិស្សមជ្ឈមណ្ឌល។




**គំនូសតាងទី ១ ទិន្នន័យចំណេះដឹងគ្រូពីគោលវិធីសិស្សមជ្ឈមណ្ឌល**

*៨.១.៤. ការអនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌល*

លោកគ្រូ អ្នកគ្រូ១៩%បានអនុវត្តជាប្រចាំ ហើយ៨១%អនុវត្តបានខ្លះមិនបានខ្លះ។ តាមទិន្នន័យរបស់លោកគ្រូ អ្នកគ្រូផ្តល់សម្ភាសន៍ដោយផ្អែកលើចំនួនមេរៀន ជំហានទាំង៥ ជំនាញសម្របសម្រួល ការប្រើប្រាស់សម្ភារឧបទេសក្នុងពេលបង្រៀន កម្រិតសមស្របនៃថ្នាក់រៀន ចំនួនសិស្ស រយៈពេលបង្រៀននៃមេរៀននីមួយៗ និងសកម្មភាពក្រុមពិភាក្សាមួយចំនួនដូចជា ការពិភាក្សាក្រុមរបស់សិស្សមានសមាជិកលើសពី១០នាក់ មានសមាជិកពី៦-១០នាក់ មានសមាជិកពី៣-៥នាក់ ពិភាក្សាជាដៃគូ ចោទឆ្លើយជាបុគ្គល លោកគ្រូ អ្នកគ្រូនៅវិទ្យាល័យ អនុវត្តបានល្អបង្គួរ (៦៨%)នូវគោលវិធីសិស្សមជ្ឈមណ្ឌល ហើយសកម្មភាពពិភាក្សា ដែលលោកគ្រូ អ្នកគ្រូនិយមអនុវត្តជាងគេ គឺការចោទឆ្លើយជាបុគ្គល(៩៨%)។




**គំនូសតាងទី ២ ទិន្នន័យការអនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌលរបស់គ្រូ**

*៨.១.៥. ការជះឥទ្ធិពលដល់សិស្ស*

៩៥%នៃលោកគ្រូអ្នកគ្រូដែលបានសម្ភាសន៍បង្ហាញថា ការបង្រៀនបែបសិស្សមជ្ឈមណ្ឌល

ពិតជាជះឥទ្ធិពលល្អប្រសើរដល់ការសិក្សារបស់សិស្ស។ លទ្ធផលនេះបានមកពីការសិក្សាដោយផ្អែកលើចំណុចមួយចំនួន ដូចជាទី១ សិស្សយល់ច្បាស់អំពីខ្លឹមសារមេរៀន,ទី២ បង្កើនចំណេះដឹងសិស្សតាមរយៈការពិភាក្សាផ្លាស់ប្តូរយោបល់រវាងសិស្ស និងសិស្ស,ទី៣ សិស្សរៀនសូត្រពីមិត្តរួមថ្នាក់, ទី៤ សិស្សទទួលបានចំណេះដឹងដោយខ្លួនឯង,ទី៥ សិស្សមានការប្រេឡងប្រណាំងក្នុងការសិក្សា និងទី៦ សិស្សមានភាពឯករាជ្យក្នុងការសិក្សា។(បណ្ឌិត.ចាន់ រដ្ឋសុជា២០០៥)

*៨.១.៦. បញ្ហាដែលកើតមានកន្លងមកក្នុងការអនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌល*

*ចំនួនសិស្សច្រើន(៩៩%)*

ចំនួនសិស្សច្រើនជាបញ្ហាមួយ នៅក្នុងការអនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌល ដូចជាពិបាកក្នុងការរៀបចំក្រុម ចំណាយពេលវេលាក្នុងការរៀបចំក្រុម សិស្សច្រើនពិភាក្សាមិនបានគ្រប់គ្នា ក្រុមច្រើនប្រើរយៈពេលយូរដើម្បីបកស្រាយ ហើយមិនចប់តាមកាលកំណត់ ពិបាកគ្រប់គ្រងនិងពិបាកទំនាក់ទំនងរវាងគ្រូនិងសិស្ស សិស្សនិងសិស្ស។

*គ្រូខ្វះសម្ភារឧបទេស និងឯកសារដែលពាក់ព័ន្ធ(៩៨%)*

លោកគ្រូ អ្នកគ្រូខ្វះខាតយ៉ាងខ្លាំងនូវសម្ភារឧបទេស និងឯកសារសម្រាប់បង្រៀន។ ជាទូទៅសម្ភារដែលលោកគ្រូ អ្នកគ្រូប្រើប្រាស់នៅពេលបង្រៀន មានដូចជាសៀវភៅគោលរបស់គ្រូ សៀវភៅគោលរបស់សិស្ស ដីស ក្ដារខៀន ហ្វឺត ប្រដាប់លុប។ ប៉ុន្តែលោកគ្រូ អ្នកគ្រូខ្លះគ្មានទាំងសៀវភៅគោលសម្រាប់បង្រៀនផង ឧទាហរណ៍មុខវិជ្ជាសេដ្ឋកិច្ច។ សម្ភារ និងឯកសារដូចជាក្រដាសធំ ឬហ្វឺត ឯកសារសម្រាប់ស្រាវជ្រាវ និងសន្ទានុក្រមតាមមុខវិជ្ជានីមួយៗ គឺមានការខ្វះខាតយ៉ាងខ្លាំងសម្រាប់បង្រៀន និងការស្រាវជ្រាវរបស់ពួកគេ។ ជាពិសេស លោកគ្រូ អ្នកគ្រូបង្រៀននៅអនុវិទ្យាល័យ ហើយត្រូវបង្រៀននៅវិទ្យាល័យ មានការលំបាកយល់ឱ្យបានស៊ីជម្រៅទៅលើខ្លឹមសារមេរៀន និងពាក្យគន្លឹះមួយចំនួន។ ទាំងនេះហើយដែលធ្វើឱ្យការបង្រៀនរបស់ពួកគាត់ជួបបញ្ហា។

ក្រៅពីរូបភាពដែលមាននៅក្នុងសៀវភៅគោល ជាទូទៅ លោកគ្រូ អ្នកគ្រូបង្រៀនដោយប្រើពាក្យសំដីពន្យល់ជាអរូបិយ គ្មានរូបភាព និងឧបករណ៍ផ្សេងៗសម្រាប់បង្ហាញទេ។

គ្រូភាគច្រើនមិនបានផលិតសម្ភារដោយខ្លួនឯងសម្រាប់បង្រៀនទេ ដោយបញ្ហាជីវភាព ពួកគាត់បានប្រើប្រាស់ពេលទំនេរសម្រាប់ធ្វើការងារផ្សេងៗ ដើម្បីរកថវិកាបន្ថែមសម្រាប់គ្រួសារ។

ចំពោះលោកគ្រូ អ្នកគ្រូនៅភ្នំពេញពួកគាត់ធ្វើមេរៀនសង្ខេប កម្រងសំណួរចម្លើយសម្រាប់បង្រៀនសិស្ស។

សាលាគ្មានថវិកាសម្រាប់ចំណាយលើសម្ភារ និងបង្កើតសម្ភារនៅក្នុងការបង្រៀនទេ។

*កង្វះសៀវភៅសិក្សាគោលសម្រាប់សិស្ស(៩៨%)*

បញ្ហាមួយសំខាន់ ក្នុងចំណោមបញ្ហាទាំងឡាយនៃការអនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌលគឺខ្វះខាតសៀវភៅសិក្សាគោលសម្រាប់សិស្ស។ បញ្ហាទាំងនោះរួមមាន ៖

ទី១នៅពេលបង្រៀន គ្រូឱ្យសិស្សណាម្នាក់ឡើងអានមេរៀន ហើយឱ្យសិស្សដទៃទៀតអានតាមដោយស្ងាត់ស្ងៀម។ សិស្សដែលគ្មានសៀវភៅត្រូវស្តាប់គេអាន អ្នកស្តាប់មិនក្តាប់អត្ថន័យបានច្រើនដូចអ្នកដែលមានឯកសារអានទេ។ នៅពេលគ្រូឱ្យសិស្សពិភាក្សាជាក្រុម ពួកគេភាគច្រើនចាំតែឯកភាពប៉ុណ្ណោះ។

ទី២ក្នុងម៉ោងសិក្សា សិស្សដែលគ្មានសៀវភៅសិក្សាគោលមួយចំនួនបង្កជាបាតុភាពផ្សេងៗដែលធ្វើឱ្យរំខានដល់ការសិក្សានៅក្នុងថ្នាក់ទាំងមូល ដូចជាស្រែកឡូឡា ជជែកគ្នា លេងល្បែងតាមទូរស័ព្ទ ឬមិនចូលរួមពិភាក្សាជាក្រុម ឬធ្វើឱ្យគ្រូពិបាកគ្រប់គ្រង ឬគ្រប់គ្រងមិនបាន។

ទី៣ ពេលគ្រូដាក់កិច្ចការឱ្យសិស្សធ្វើនៅផ្ទះ ពួកគេមិនធ្វើដោយសារគ្មានសៀវភៅសិក្សាគោល។ សិស្សដែលគ្មានឯកសារមិនបានស្រាវជ្រាវទេជាហេតុធ្វើឱ្យការបង្រៀនរបស់គ្រូជួបប្រទះនូវការលំបាក។ ការលំបាកកាន់តែកើនឡើងថែមទៀតក្នុងថ្នាក់ នៅពេលសិស្សមានសៀវភៅសិក្សាគោលមិនមករៀន។

*សិស្សអសកម្ម និងពិបាកគ្រប់គ្រង(៧៦%)*

*ការពិភាក្សាក្រុម*

នៅពេលលោកគ្រូ អ្នកគ្រូពិភាក្សាក្រុម សិស្សបានជួបប្រទះនឹងបញ្ហាមួយចំនួន ៖ ទី១ សិស្សមិនបញ្ចេញមតិយោបល់សោះ និងមិនយកចិត្តទុកដាក់នៅក្នុងការពិភាក្សា ទី២ពេលពិភាក្សាសិស្សខ្លះពឹងផ្អែកលើគំនិតយោបល់អ្នកដទៃ(សិស្សឧស្សាហ៍ឬសិស្សពូកែ) ទី៣នៅក្នុងក្រុមពិភាក្សាមានតែសិស្សពូកែពីរទៅបីនាក់ដែលសកម្ម រីឯសិស្សខ្សោយចាំតែឯកភាព និងទី៤ពេលខ្លះគ្រូចែកជាក្រុមពិភាក្សាឱ្យសិស្ស។ ពួកគេមិនអនុវត្តន៍តាម ដោយយកពេលនិយាយរឿងផ្សេងៗស្រែកឡូឡារំខានដល់ការរៀនសូត្ររបស់សិស្សដទៃសិស្សខ្លះទៀតនិយាយទូរស័ព្ទ ឬ លេងGAME ក្នុងទូរស័ព្ទដៃ ឬមើល VCD តាមទូរស័ព្ទដៃ ឬធ្វើកិច្ចការមុខវិជ្ជាផ្សេង។

ដោយសារមានក្រុមពិភាក្សាច្រើន ការគ្រប់គ្រងសកម្មភាពនៅខ្វះចន្លោះ។ ពេលខ្លះការឡើងរាយការណ៍តាមក្រុមមិនបានគ្រប់គ្នា។ ហើយសិស្សពេលខ្លះធុញទ្រាន់នឹងសកម្មភាពដដែលៗ។

*សំណួរពិភាក្សា*

លោកគ្រូ អ្នកគ្រូខ្លះដាក់សំណួរច្រើន ហើយបែងចែកសំណួរនីមួយៗឱ្យសិស្សទទួលខុសត្រូវ

តាមក្រុម។ ក្នុងករណីនេះសិស្សមិនយកចិត្តទុកដាក់លើសំណួររបស់ក្រុមផ្សេងទេ ដូច្នេះពួកគេយល់បានតែចំណុចដែលបានពិភាក្សាប៉ុណ្ណោះ។

*បក្ខពួក និងការអៀនខ្មាស់*

សិស្សខ្លះប្រកាន់បក្ខពួកធ្វើការពិភាក្សាតែជាមួយក្រុមដដែលៗ នៅពេលដែលគ្រូប្តូរក្រុមឱ្យពិភាក្សា ពួកគេមិនចូលរួមដោយអៀនខ្មាស់ មិនផ្តល់មតិយោបល់ ឬមិនចូលរួមផ្តល់ចម្លើយដល់ក្រុមពិភាក្សា ឬរើសអើងគ្នា។

**សមត្ថភាព និងកង្វះគ្រូមុខវិជ្ជាឯកទេស(៨៩%)**

គ្រូបង្រៀនកម្រិតឧត្តម(បរិញ្ញា+១)តាមនិយាមគរុកោសល្យគឺខ្វះខាតនៅតាមវិទ្យាល័យមួយចំនួនក្នុងប្រទេសកម្ពុជា។ ដូច្នេះដើម្បីឱ្យការបង្រៀននៅតាមវិទ្យាល័យមានដំណើរការ លោកគ្រូ អ្នកគ្រូបង្រៀនកម្រិតអនុវិទ្យាល័យត្រូវបានជ្រើសរើសឱ្យបង្រៀន នៅវិទ្យាល័យដោយប្រើប្រាស់របបម៉ោងបន្ថែមរបស់រដ្ឋ។ លោកគ្រូ អ្នកគ្រូទាំងនេះ មិនបានទទួលការបណ្តុះបណ្តាលមុខវិជ្ជាឯកទេសណាមួយបន្ថែមដើម្បីបង្រៀននៅវិទ្យាល័យទេ គឺការស្រាវជ្រាវតែតាមសៀវភៅក្រសួងមកបង្រៀនប៉ុណ្ណោះ។ លោកគ្រូ អ្នកគ្រូខ្លះយល់ដឹងពីខ្លឹមសារមេរៀន និងពាក្យគន្លឹះមួយចំនួននៅមានកម្រិត។ ពួកគាត់មិនអាចយល់ខ្លឹមសារ ពេលខ្លះត្រូវបង្ខំចិត្តបង្រៀនរំលងមេរៀន ឬ មិនបង្រៀនផ្នែកណាមួយក៏មានដែរ។

វិធីមួយទៀតដើម្បីបង្គ្រប់គ្រូបង្រៀន គឺត្រូវជ្រើសរើសគ្រូឱ្យបង្រៀនច្រើនមុខវិជ្ជា។ គ្រូម្នាក់អាចបង្រៀន៤មុខវិជ្ជាក៏មាន។ ពួកគាត់មានចំណេះដឹងតែមុខវិជ្ជាឯកទេស ប៉ុន្តែមុខវិជ្ជាផ្សេងៗទៀតពួកគាត់ត្រូវស្រាវជ្រាវបន្ថែមច្រើន។ ចំណុចនេះធ្វើឱ្យពួកគាត់មិនអាចរៀបចំការបង្រៀនបានល្អ ឬគ្មានកិច្ចតែងការបង្រៀន ការយល់ដឹងលើខ្លឹមសារមេរៀន និងពាក្យគន្លឹះនៅមានកម្រិតដែលធ្វើឱ្យការបង្រៀនរបស់គាត់អាចមានភាពច្របូកច្របល់ សិស្សពិបាកយល់ខ្លឹមសារមេរៀន និងមិនយកចិត្តទុកដាក់ក្នុងការសិក្សា។

***កម្មវិធីសិក្សា និងថ្នាក់រៀន(៩២%)***

បរិស្ថានថ្នាក់រៀន កម្មវិធី និងមេរៀនច្រើន ជាបញ្ហាមួយទៀតក្នុងចំណោមបញ្ហាទាំងឡាយដែលបណ្តាលឱ្យលោកគ្រូ អ្នកគ្រូពិបាកអនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌល។ កម្មវិធីសិក្សាមានច្រើនពេក ប៉ុន្តែម៉ោងសិក្សាមានតិច ពិបាកបែងចែកម៉ោងឱ្យសមស្របទៅតាមរបាយម៉ោងប្រចាំឆ្នាំ ឧទាហរណ៍មុខវិជ្ជាគេហកិច្ចថ្នាក់ទី១២ត្រូវបង្រៀន២ម៉ោងក្នុងមួយសប្តាហ៍ តែជាក់ស្តែងបង្រៀនបានតែ១ម៉ោងក្នុងមួយសប្តាហ៍។ ដូច្នេះតម្រូវឱ្យគ្រូសង្ខេបខ្លឹមសារមេរៀន ដែលធ្វើឱ្យប៉ះពាល់ដល់ការបង្រៀន

មេរៀននីមួយៗមិនបានក្បោះក្បាយឬបង្រៀនយឺត មិនចប់កម្មវិធីសិក្សា។ មុខវិជ្ជាខ្លះមានតែកម្មវិធីសិក្សា ប៉ុន្តែគ្មានសៀវភៅគោលសម្រាប់បង្រៀន ឧទាហរណ៍មុខវិជ្ជាសេដ្ឋកិច្ច។

ក្រៅពីនេះ នៅមានបញ្ហាថ្នាក់រៀនទ្រុឌទ្រោម និងតុកៅអី(វែងៗ)មិនសមស្របសម្រាប់ការបង្រៀន និងរៀនតាមបែបគោលវិធីសិស្សមជ្ឈមណ្ឌល។

*៤.១.៧. ដំណោះស្រាយ*

*ថ្នាក់មានសិស្សច្រើនពេក*

តាមបទពិសោធន៍របស់លោកគ្រូ អ្នកគ្រូបានដោះស្រាយជាក់ស្តែងចំពោះថ្នាក់រៀនដែលមានសិស្សច្រើនដូចតទៅ ទី១គ្រូឱ្យសិស្សពិភាក្សាតាមក្រុមហើយជំរុញឱ្យសិស្សខិតខំប្រឹងប្រែងសិក្សាទាំងអស់គ្នា បន្ទាប់មកគ្រូចុចឈ្មោះសិស្សឱ្យឡើងឆ្លើយ ឬសរសេរនៅលើក្តារខៀន ហើយឱ្យពិន្ទុមជាក្រុម ទី២គ្រូដាក់សិស្សខ្សោយជាមួយក្រុមសិស្សពូកែ ដើម្បីឱ្យសិស្សខិតខំរៀនទាំងអស់គ្នា ទី៣គ្រូបង្រៀនដោយប្រើវិធីចោទឆ្លើយ ទី៤គ្រូបង្រៀនតាមបែបគ្រូមជ្ឈមណ្ឌល ទី៥គ្រូបង្រៀនដោយបង្កើតសំណួរឱ្យបានច្រើន ទី៦គ្រូបង្រៀនដោយដាក់បញ្ហាឱ្យសិស្សដោះស្រាយហើយហៅឈ្មោះសិស្សឱ្យឆ្លើយម្នាក់ មួយចំណុចៗ។

*កង្វះសម្ភារឧបទេស និងឯកសារដែលពាក់ព័ន្ធសម្រាប់គ្រូ*

កន្លងមកគ្រូដោះស្រាយបញ្ហាកង្វះខាតសម្ភារដូចជា ទី១ ទិញសម្ភារនៅទីផ្សារដោយខ្លួនឯង។ ទី២ ចំពោះខ្លឹមសារ និងពាក្យគន្លឹះដែលពិបាកយល់ គឺពួកគាត់ដោះស្រាយតាមខ្លឹមសារនៃអត្ថបទ ឬសិក្សាបន្ថែមពីគ្រូចាស់ៗដែលមានបទពិសោធន៍ ឬតាមការប្រជុំក្រុមការងារបច្ចេកទេស ឬស្រាវជ្រាវដោយខ្លួនឯងតាមរយៈឯកសារផ្សេងៗដូចជាវចនានុក្រម ទស្សនាវដ្តី កាសែត ទូរទស្សន៍។ល។ ទី៣ គ្រូខំផលិតសម្ភារមួយឆ្នាំបន្តិចៗដោយខ្លួនឯង ឬគ្រូឱ្យសិស្សស្វែងរកសម្ភារឧបទេសដែលសិស្ស អាចរកបាន ឬគ្រូខ្ចីសម្ភារគ្នាទៅវិញទៅមក ឬគ្រូឱ្យសិស្សគូររូបភាព ឬបង្កើតសម្ភារជាក្រុម ដែលគ្រូឱ្យកំណត់តាមលទ្ធភាពរបស់សិស្ស។

*កង្វះសៀវភៅសិក្សាគោលសម្រាប់សិស្ស*

កន្លងមកគ្រូដោះស្រាយបញ្ហាកង្វះសៀវភៅសិក្សាគោលសម្រាប់សិស្សដូចជា៖ ទី១គ្រូឱ្យសិស្សទិញសៀវភៅសិក្សាគោលដោយខ្លួនឯង ទី២គ្រូឱ្យសិស្សអានសៀវភៅ រីឯសិស្សដទៃទៀតស្តាប់ និងកត់ត្រាចំណុចសំខាន់ៗ ទី៣គ្រូឱ្យសិស្សខ្ចីសៀវភៅគោលពីថ្នាក់ផ្សេងៗទៀត ដែលរៀនម៉ោងខុសគ្នា ទី៤គ្រូត្រូវរៀបចំខ្លឹមសារមេរៀនសំខាន់ៗដោយខ្លួនឯងសម្រាប់កត់ត្រាលើក្តារខៀនឬចតចម្លងឱ្យសិស្ស ទី៥គ្រូអានអត្ថបទឱ្យសិស្សស្តាប់ឬហៅមេរៀនឱ្យសិស្សកត់ត្រា ទី៦គ្រូផ្តល់មេរៀនឱ្យ

សិស្ស ឬឱ្យសិស្សដោះស្រាយរកមេរៀនដោយខ្លួនឯង ទី៧គ្រូជំរុញឱ្យសិស្សខ្ចីសៀវភៅពីបណ្ណាល័យក្នុងមួយតុ១ក្បាល ទី៨គ្រូឱ្យសិស្សខ្ចីសៀវភៅសិក្សាគោលពីសាលារៀនរាល់ម៉ោងដែលគ្រូមុខវិជ្ជារួចយកទៅសងសាលាវិញពេលចប់ម៉ោងសិក្សា ដោយមិនឱ្យសិស្សខ្ចីយកទៅផ្ទះ។ ទី៩គ្រូឱ្យសិស្សស្តាប់ការពន្យល់ចំណុចសំខាន់ៗលើក្តារខៀនតាមប្លង់មេរៀន និងសរសេរលើក្តារខៀន រួចឱ្យសិស្សចម្លងតាម។

*សិស្សអសកម្ម និងពិបាកគ្រប់គ្រង*

កន្លងមកគ្រូបានដោះស្រាយបញ្ហាសិស្សអសកម្មដូចជា ទី១ គ្រូឱ្យសិស្សអានបណ្តាក់គ្នាអានពីរ ឬបីនាក់ ដាក់សំណួរឱ្យពិភាក្សាតាមក្រុម គ្រូចុះពិនិត្យតាមតុ ឱ្យតំណាងក្រុមនីមួយៗឡើងរាយការណ៍ រួចសរសេរលើក្តារខៀន គ្រូជួយសម្របសម្រួល បន្ទាប់មកឱ្យសិស្សផ្សេងៗទៀតចម្លងទុកក្នុងសៀវភៅសរសេរ ទី២ គ្រូបង្រៀនតាមបែបចោទឆ្លើយជាបុគ្គល ឬគ្រូមជ្ឈមណ្ឌល ឬឱ្យសិស្សឡើងឆ្លើយដាក់ពិន្ទុ ទី៣ ដាក់បទបញ្ជាតឹងរ៉ឹង និងពន្យល់ពីសារៈប្រយោជន៍នៃការសិក្សា។

*៨.១.៨. កត្តាប្រឈមក្នុងការអនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌល*

គ្រូដែលបានសម្ភាសន៍បង្ហាញថា មានកត្តាសំខាន់ៗបីដែលប្រឈមក្នុងការអនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌល៖

*ទី១ សម្ភារសម្រាប់គ្រូ និងសិស្ស(៩៩%)*

សម្រាប់គ្រូ សម្ភារឧបទេសជួយសម្រួលដល់ការបង្រៀនសិស្ស ចេញពីទ្រឹស្តីទៅការអនុវត្តជាក់ស្តែង ពីអរូបិយទៅរូបិយ ដើម្បីឱ្យសិស្សងាយយល់ពីខ្លឹមសារមេរៀននិងចេះវិភាគ សំយោគ និងវាយតម្លៃបាតុភូតនានា។ សម្រាប់គ្រូដើម្បីបង្រៀនសិស្សឱ្យមានគុណភាពឯកសារសម្បូរបែប មានសារៈសំខាន់ណាស់ក្នុងការស្រាវជ្រាវបង្កើនចំណេះដឹងបន្ថែមឱ្យទូលំទូលាយ។ ប៉ុន្តែគ្រូមានតែសៀវភៅគោលរបស់ក្រសួងអប់រំប៉ុណ្ណោះ។

សម្រាប់សិស្សវិញ ពួកគេក៏ត្រូវការស្រាវជ្រាវបន្ថែមដែរ។ ប៉ុន្តែ ពួកគេភាគច្រើនគ្មានទាំងសៀវភៅសិក្សាគោលទៀតផង កុំថាឡើយដល់ទៅមានសម្ភារសម្រាប់អនុវត្ត។ ដូច្នេះ គ្រូនិងសិស្សបង្រៀននិងរៀនជាអរូបិយ និងខ្វះខាតឯកសារជាកត្តាប្រឈមដែលធ្វើឱ្យការអនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌលមិនទទួលបានផលល្អ។

*ទី២ ជីវភាពគ្រូបង្រៀន(៩៩%)*

ប្រាក់ខែចាយមិនគ្រប់ធ្វើឱ្យគ្រូប្រកបមុខរបរបន្ថែម ឬបង្រៀន៣ទៅ៤មុខវិជ្ជាម្នាក់ឯង ដើម្បីបានប្រាក់ម៉ោងបន្ថែម។ ដូច្នេះ នេះជាបញ្ហាធំមួយដែលជះឥទ្ធិពលដល់ការស្រាវជ្រាវដើម្បី

បង្រៀនសិស្ស ឬធ្វើឱ្យគ្រូធ្វើគំរូមិនល្អដល់សិស្ស ជាពិសេសនៅពេលប្រឡង។

*ទី៣ សកម្មភាពអវិជ្ជមាន(៩១%)*

សិស្សមិនគោរពវិន័យឬមិនស្តាប់គ្រូឬបង្កបាតុភាពផ្សេងៗ នៅពេលគ្រូកំពុងបង្រៀន។ នៅឯសាលាមួយចំនួន គ្រូឱ្យសិស្សបង់លុយសម្រាប់មេរៀន, ការបើកវគ្គបំប៉នក្រៅម៉ោងសិក្សា, បញ្ហាអវត្តមាននិងពិន្ទុរបស់សិស្សនិងបាតុភាពផ្សេងៗដែលបានកើតមានពេលប្រឡងនានា។

*៨.១.៩. ការយល់ឃើញរបស់គ្រូចំពោះគោលវិធីសិស្សមជ្ឈមណ្ឌល*

គ្រូដែលត្រូវបានសម្ភាសន៍ ពួកគេយល់ឃើញថា ការបង្រៀន និងរៀនតាមបែបសិស្សមជ្ឈមណ្ឌលពិតជាផ្តល់ចំណេះដឹងពិតប្រាកដដល់សិស្ស ព្រោះមានទ្រឹស្តីផ្សារភ្ជាប់នឹងការអនុវត្ត។សិស្សមានលទ្ធភាពកសាងសមត្ថភាពដោយខ្លួនឯង ក្លាហានក្នុងការបញ្ចេញមតិ មានទំនួលខុសត្រូវ ចំពោះរាល់ទង្វើរបស់ខ្លួន សិស្សមានសកម្មភាពរស់រវើក ការអប់រំសម្រេចបាននូវគោលដៅអប់រំសម្រាប់ទាំងអស់គ្នា សម្រេចបាននូវចតុស្តម្ភទាំង៤ គឺរៀនដើម្បីចេះ រៀនដើម្បីធ្វើ រៀនដើម្បីក្លាយ ជាមនុស្ស រៀនដើម្បីរស់នៅជាមួយគ្នា។ វិធីនេះបានបណ្តុះស្មារតីឃោគយល់គ្នា គោរពសិទ្ធិក្នុងការសំដែងមតិ ចេះស្តាប់មតិយោបល់គ្នា សិស្សមានឱកាសបង្កើតគំនិតច្នៃប្រឌិតថ្មីៗ សិស្សឆាប់យល់ខ្លឹមសារមេរៀន និងចាំបានយូរ ពីព្រោះសិស្សបានសិក្សាស្រាវជ្រាវដោយខ្លួនឯង និងសិក្សាស្រាវជ្រាវបានច្រើន កសាងលទ្ធិប្រជាធិបតេយ្យនៅក្នុងថ្នាក់រៀន ចេះធ្វើការងារតាមក្រុម ចេះចែករំលែកចំណេះដឹងគ្នាទៅវិញទៅមក សាមគ្គីគ្នានិងសហការគ្នា។ សិស្សមានបំណិនទៅថ្ងៃអនាគត មានចំណេះដឹងចំណេះធ្វើ អាចអភិវឌ្ឍន៍គ្រួសារ និងសង្គមបាន ធ្វើឱ្យសិស្សចេះគិតពិចារណារក ហេតុផល និងដោះស្រាយបញ្ហាដោយខ្លួនឯង ម្ចាស់ការលើខ្លួនឯង។

គ្រូធ្វើសកម្មភាពតិច សិស្សធ្វើសកម្មភាពច្រើន។ ការស្រាវជ្រាវរបស់គ្រូកាន់តែច្រើនជាងមុន និងមានទំនាក់ទំនងល្អជាមួយសិស្ស។

ក្រៅពីនោះ ក៏មានគ្រូមួយចំនួនតូច(១៧សម្លេង) បានលើកឡើងថា នៅក្នុងប្រទេសយើង មិនអាចអនុវត្តបានទេ ដោយសារឆន្ទៈសិស្ស និងឆន្ទៈគ្រូ ខ្វះសម្ភារ សៀវភៅសិក្សាគោលសម្រាប់សិស្ស និងអនុវត្តបានមួយចំនួនតូចប៉ុណ្ណោះ។

*៨.១.១០. សំណើដើម្បីអនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌលឱ្យបានប្រសើរជាងមុន*

១-ក្រសួងអប់រំ យុវជន និងកីឡាត្រូវផ្តល់សម្ភារឧបទេស ឯកសារគ្រូ ឯកសារសិស្សឱ្យបានគ្រប់គ្រាន់ និងត្រូវ មានថវិកាសម្រាប់ទិញសម្ភារឧបទេស និងឯកសារផ្សេងៗ។

៣-ចំនួនសិស្សក្នុងថ្នាក់រៀនយ៉ាងច្រើនត្រឹម២៥ទៅ៣០នាក់ និងមានបន្ទប់រៀនឱ្យសមស្រប

ទៅនឹងនិយាមគរុកោសល្យ។

៤-ក្រសួងអប់រំ យុវជន និងកីឡាត្រូវមានកម្មវិធីច្បាស់លាស់មានកម្មវិធីទស្សនៈកិច្ចសិស្ស ដើម្បីផ្លាស់ប្តូរបទពិសោធន៍ និងមានវគ្គបំប៉នថ្មីៗបន្ថែមទៀត។ ពិសេសត្រូវឱ្យអធិការមុខវិជ្ជាចុះទៅពិនិត្យញឹកញាប់នៅតំបន់ដាច់ស្រយាល និងជួបការលំបាក។

៥- ត្រូវលុបបំបាត់ភាពអសកម្មទាំងឡាយនៅពេលប្រឡង និងភាពអយុត្តិធម៌ ផ្សេងៗ។

៦-រៀបចំកម្មវិធីសិស្សឱ្យសមស្របទាំងពេលវេលា និងខ្លឹមសារ។



រូបទី៣ ការពិភាក្សាក្រុមតូច



រូបទី៤ តំណាងក្រុមឡើងរាយការណ៍

## ៤.២. ការសម្ភាសជាមួយសិស្ស

*៤.២.១. លក្ខណៈអ្នកឆ្លើយ*

សិស្ស៧២នាក់ត្រូវបានជ្រើសរើសសម្រាប់ធ្វើសម្ភាសន៍ ក្នុងនោះស្រីមាន៥៨% ។សិស្សទាំងនោះត្រូវបានជ្រើសរើសពីថ្នាក់ទី១០ចំនួន៣៥% ថ្នាក់ទី១១ចំនួន៣៣% និងសិស្សថ្នាក់ទី១២ចំនួន ៣២%។



រូបទី៥សម្ភាសសិស្សដោយបំពេញកម្រងសំណួរ



រូបទី៦ សម្ភាសសិស្សជាបុគ្គល

*៤.២.២. សកម្មភាពបង្រៀនរបស់គ្រូ(ចម្លើយរបស់សិស្ស)*

៣៧,៥%នៃសិស្សមិនស្គាល់ពីគោលវិធីសិស្សមជ្ឈមណ្ឌល និង៦២,៥%ទៀតស្គាល់។ តាម

ទិន្នន័យប្រមូលបានពីសិស្សវិទ្យាល័យ ស្តីពីសកម្មភាពនានា ដែលគ្រូបានអនុវត្តក្នុងពេលបង្រៀនកន្លងមកគឺបានតែ៨១% នេះដោយផ្អែកលើចំណុចមួយចំនួនដូចជា ទី១ គ្រូអនុវត្តជំហានទី១ (ត្រួតពិនិត្យវត្តមាន អនាម័យ សណ្តាប់ធ្នាប់ សំណេះសំណាលជាមួយសិស្ស) ទី២ គ្រូអនុវត្តជំហានទី២ រំលឹកមេរៀនចាស់(កែកិច្ចការផ្ទះ ឬសួរសំណួររំលឹក) ទី៣គ្រូអនុវត្ត ជំហានទី៣ ចំណេះដឹងថ្មី(ដាក់បញ្ហាឬសំណួរ ជួយណែនាំសិស្ស សម្របសម្រួល បំផុសគំនិតឱ្យសិស្សបូកសរុបខ្លឹមសារ ទី៤គ្រូឱ្យសិស្សដោះស្រាយមេរៀនជាដៃគូ ជាក្រុមតូចៗ ជាក្រុមធំ ការពារមតិយោបល់ និងរបកគំហើញដោយខ្លួនឯង ទី៥ ចំពោះការពិភាក្សាក្រុម គ្រូឱ្យសិស្សអនុវត្តការពិភាក្សាក្រុមធំដែលមានសមាជិកលើសពី១០នាក់ ក្រុមដែលមានសមាជិកចន្លោះពី៥-១០នាក់ ក្រុមដែលមានសមាជិកពី៣-៥នាក់, ការពិភាក្សាគ្នាជាដៃគូ និងគ្រូប្រើវិធីសាស្ត្រចោទឆ្លើយជាបុគ្គល។

ប៉ុន្តែមានចំណុចពីរទៀតគឺ ទី១ ចំនួនសិស្សមានសៀវភៅសិក្សាគោលគ្រប់គ្រាន់គ្រប់មុខវិជ្ជាមាន១៨% និង៨២%មានមិនគ្រប់គ្រាន់ ឬ គ្មាន ទី២ គ្រូបង្រៀនចំនួន៧៦%មកបង្រៀនទៀងទាត់ ១៥%មកទៀងទាត់ខ្លះមិនទៀងទាត់ខ្លះ និងគ្រូ៨%ទៀតមកបង្រៀនមិនទៀងទាត់។

ដោយផ្អែកលើចំណុចខាងលើរបស់សិស្សបានបង្ហាញថា លោកគ្រូអ្នកគ្រូអនុវត្តការបង្រៀនតាមបែបគោលវិធីសិស្សមជ្ឈមណ្ឌលបាន៥៩%។ ចំណែកឯសកម្មភាពពិភាក្សាដែលគ្រូនិយមប្រើជាងគេគឺវិធីចោទឆ្លើយជាបុគ្គល៨៧,៥%។




**រូបទី៣ ទិន្នន័យសិស្សស្តីពីការអនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌលរបស់គ្រូ**

*៤.២.៣. ការអនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌលជះឥទ្ធិពលដល់សិស្ស*

៩២%នៃសិស្សវិទ្យាល័យដែលបានសម្ភាសន៍បង្ហាញថា ការបង្រៀនបែបសិស្សមជ្ឈមណ្ឌលពិតជាបានជះឥទ្ធិពលល្អប្រសើរដល់ការសិក្សារបស់ពួកគេ ដោយផ្អែកទៅលើចំណុចចំនួន៦ដូចជា

ទី១ ធ្វើឱ្យគេយល់ច្បាស់ខ្លឹមសារមេរៀន ទី២ ធ្វើឱ្យគេបង្កើនចំណេះដឹងតាមរយៈការពិភាក្សាផ្លាស់ប្តូរយោបល់គ្នា ទី៣ ពួកគេទទួលចំណេះដឹងពីមិត្តរួមថ្នាក់ ទី៤ ពួកគេពិភាក្សាទទួលចំណេះដឹងបានដោយខ្លួនឯង ទី៥ពួកគេមានការប្រឡងប្រណាំងក្នុងការសិក្សា និងទី៦ពួកគេមានភាពឯករាជ្យក្នុងការសិក្សា។

### *៤.២.៤. សម្ភារប្រើប្រាស់របស់គ្រូបង្រៀនផ្នែកសង្គម*

សម្ភារបង្រៀនរបស់លោកគ្រូអ្នកគ្រូដែលបានប្រើប្រាស់ជាក់ស្តែងមាន ផែនទី ភូគោល សៀវភៅសិក្សាគោលរបស់គ្រូ ឯកសារមេរៀនផ្សេងៗរបស់គ្រូសម្រាប់ចែកឱ្យសិស្ស បន្ទាត់ ប្រដាប់លុបក្តារខៀន ហ្វឺតសរសេរ(ខៀវឬក្រហម)ដីស រុក្ខជាតិ រូបភាព សម្ភារដេរប៉ាក់ក្រណាត់ ចេស ម្ជុល កន្ត្រៃ សម្ភារសម្រាប់ធ្វើម្ហូបអាហារ រូបក្រាហ្វ រូបបដិមា ឯកសារសិលាចារិក របាក្សត្រ និងសៀវភៅសិក្សា។ ហើយក៏មានគ្រូគ្មានសម្ភារសម្រាប់បង្រៀនផងដែរ វិធីបង្រៀនរបស់គាត់គឺហៅឱ្យកត់ត្រានិងពន្យល់។

### *២.៥. ការលំបាករបស់សិស្សក្នុងការអនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌល*

***សម្ភារ*** ការលំបាករបស់សិស្សក្នុងការអនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌលគឺ ខ្វះខាតសម្ភារឧបទេសសៀវភៅគោល និងឯកសារមិនគ្រប់គ្រាន់ មិនសម្បូរបែប និងខ្វះឯកសារផ្សេងៗសម្រាប់ស្រាវជ្រាវបន្ថែម។

***សិស្ស*** សិស្សនៅក្នុងថ្នាក់រៀនគ្មានសណ្តាប់ធ្នាប់ឡូឡារំខានដល់សិស្សដទៃ មិនសាមគ្គីគ្នាមានការរើសអើង មិនបញ្ចេញមតិយោបល់ឱ្យបានគ្រប់គ្នា ប្រចាំគ្នា។ សិស្សមួយចំនួនមានការភ័យខ្លាចពេលឡើងធ្វើ ឬឆ្លើយសំណួរ។ ការងារជាក្រុមប្រើពេលច្រើនក្នុងការពន្យល់គ្នាទៅវិញទៅមក។ គ្រូដាក់កិច្ចការឱ្យសិស្សច្រើនពេក ចំនួនសិស្សច្រើន ពិបាករៀបចំតុកៅអី។

***គ្រូបង្រៀន*** គ្រូមិនពិនិត្យកិច្ចការផ្ទះរបស់សិស្ស ខ្វះគ្រូបង្រៀន គ្រូបង្រៀនលឿន ឈប់ច្រើនមានចង្ងល់ពុំអាចសួរគ្រូបាន ពុំមានសិទ្ធិបញ្ចេញមតិយោបល់ យល់ខ្លឹមសារមេរៀនមិនច្បាស់លាស់។

### *៤.២.៦. កត្តាប្រឈមដែលធ្វើឱ្យសិស្សមិនអាចអនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌលបាន*

សិស្សច្រើន ពេលវេលាខ្លី ក្នុងក្រុមមានសិស្សខ្លាំង និងខ្សោយប្រើពេលច្រើនក្នុងការពន្យល់គ្នា។ ការពិភាក្សាក្រុមមានតែសមាជិកក្រុមមួយចំនួនដែលធ្វើ ជាពិសេសសិស្សពូកែ។ ការងារក្រុមខ្លះចម្លងតែពីឯកសារកំណែ។ សិស្សស្រាវជ្រាវច្រើននៅផ្ទះ មានកិច្ចការគ្រូដាក់ឱ្យច្រើនពេក។ សិស្សខ្មាស់អៀន ឬខ្វះសេចក្តីក្លាហាន ខ្លាចឆ្លើយខុសសិស្សរួមថ្នាក់សើចចំអក។ សិស្សខ្ជិលមិនចង់អនុវត្តន៍។ សិស្សមិនខ្លាចគ្រូ បង្កឱ្យមានភាពរញ៉េរញ៉ៃក្នុងថ្នាក់រៀន។ សិស្សមិនសូវមានពេលច្រើនធ្វើសកម្មភាព សិស្សមិនសូវយល់មេរៀនពាក្យគន្លឹះ រវល់ច្រើនក្នុងការស្រាវជ្រាវមិនសូវចាំមេរៀន។

ពិបាករកគំនិតរួមគ្នាក្នុងការពិភាក្សា ។ ខ្វះខាតសម្ភារ និងសៀវភៅសិក្សាគោល។

គ្រូនិយាយតិចពេក សិស្សពិបាកយល់មេរៀនដោយខ្លួនឯង គ្រូមិនផ្តល់ឱកាសឱ្យសិស្ស ពិភាក្សា ឬធ្វើការជាក្រុម គ្រូមិនមានទេពកោសល្យគ្រប់គ្រាន់ក្នុងការបង្រៀន គ្រូបង្រៀនដោយមិនបានរៀបចំទុកជាមុន គ្រូមកបង្រៀនយឺតម៉ោង និងមិនបង្រៀន គ្រូបង្ខំឱ្យរៀន គ្រូពន្យល់មេរៀនមិនច្បាស់លាស់ សិស្សសួរសំណួរមិនឆ្លើយ សិស្សសួរគ្រូមិនចេះ គ្រូពុំអនុវត្តវិធីបង្រៀនបានល្អ ហើយគ្រូបង្រៀនឱ្យតែចប់ម៉ោង។ គ្រូហៅឱ្យកត់ត្រា ខ្វះគ្រូបង្រៀន កម្មវិធីថ្មីគ្រូមិនសូវចេះ។

កម្មវិធីមេរៀនខ្លះវែងពេក និងកម្មវិធីជ្រៅធ្វើឱ្យពិបាកយល់។ មានការបង្រៀនរំលងមេរៀន គ្រូមកបង្រៀនមិនទៀងទាត់ និងបង្រៀនមិនទាន់កម្មវិធី។

*៤.២.៧. សំណើរបស់សិស្សដើម្បីអនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌលឱ្យមានភាពប្រសើរជាងមុន*

១-ដើម្បីអនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌលឱ្យប្រព្រឹត្តទៅបានល្អ ត្រូវមានសម្ភារគ្រប់គ្រាន់សម្រាប់សិស្ស មានឯកសារសំបូរបែបសម្រាប់ការស្រាវជ្រាវ ឬ ផ្តល់ឯកសារសម្រាប់សិក្សាជាមុន។ ការបង្រៀនត្រូវមានសម្ភារឧបទេស ដែលធ្វើឱ្យសិស្សឆាប់ចាប់បានខ្លឹមសារមេរៀន ផ្តល់សំណួរ សម្ភារ និងលំហាត់ឱ្យបានច្រើនដើម្បីស្រាវជ្រាវ។

២-គ្រូចាំជួយសិស្ស ក្នុងពេលពិភាក្សាក្រុម។ សូមឱ្យគ្រូបែងចែកពេល វេលាឱ្យសមស្រប ពង្រឹងវិន័យ ពន្យល់មេរៀនឱ្យបានហ្មត់ចត់ ចែកក្រុមសមាជិកពិភាក្សាត្រឹម៥នាក់ក្នុងមួយក្រុម។ គ្រូមិនត្រូវដាក់ទណ្ឌកម្មសិស្ស ប្រើពាក្យសំដីឱ្យបានសមរម្យ និងត្រូវបង្កើនសមត្ថភាពលើមុខវិជ្ជាឯកទេសបន្ថែម។

៣-ដើម្បីធ្វើការងារជាក្រុម ត្រូវចូលរួមផ្លាស់ប្តូរយោបល់គ្នា សាមគ្គីគ្នា រួមគ្នាដោះស្រាយបញ្ហាដែលគ្រូដាក់ឱ្យ និងត្រូវចេះអធ្យាស្រ័យគ្នាទៅវិញទៅមក។

*៤.២.៨. ការយល់ឃើញរបស់សិស្សចំពោះគោលវិធីសិស្សមជ្ឈមណ្ឌល*

សិស្សវិទ្យាល័យដែលបានសម្ភាសន៍ បង្ហាញការយល់ឃើញរបស់ពួកគេ ចំពោះការបង្រៀន និងរៀនតាមបែបគោលវិធីសិស្សមជ្ឈមណ្ឌលដូចជា ៖

១-ធ្វើឱ្យសិស្សចង់រៀន, ចង់ស្រាវជ្រាវស្វែងយល់ដោយខ្លួនឯង, មានគំនិតច្រើន, ងាយស្រួលក្នុងការទទួលចំណេះដឹងពីមិត្តភ័ក្តិ បានបញ្ចេញមតិយោបល់ផ្ទាល់ខ្លួន ទទួលចំណេះដឹងរហ័សជាងរៀនម្នាក់ឯង ចេះសាមគ្គីគ្នា ចងចាំបានយូរ រៀនឆាប់ចេះ ជំរុញស្មារតីព្យាយាមរៀនសូត្រ និងចេះឯករាជ្យលើខ្លួនឯង ចេះអំណត់ ស្គាល់ពីតម្លៃនៃការសិក្សា ចេះពិតប្រាកដ និងមានការអភិវឌ្ឍខ្លួនឯង មានភាពម្ចាស់ការខ្លួនឯង មានគំនិតទូលំទូលាយចេះវិភាគនិងពិចារណាបញ្ហា ចេះកំណត់គោល

ជៅក្នុងជីវិតទៅថ្ងៃអនាគត មានទំនុកចិត្តក្លាហាន មានចំណេះដឹងនិងបទពិសោធន៍កាន់តែច្រើនធ្វើឱ្យមានការប្រឡងប្រណាំងគ្នានៅក្នុងថ្នាក់រៀន រៀនមិនធុញទ្រាន់ ចេះបែកគំនិតមាន យោបល់ល្អៗ ចេះមានគំនិតស្វែងរកចម្លើយថ្មីៗ និងមានការផ្លាស់ប្តូរមតិយោបល់គ្នាជាក្រុម។

២-ក្រៅពីនោះ ក៏មានសិស្សមួយចំនួនតូច(៥សម្លេង) បានលើកឡើងថា សិស្សមិនអាចទទួលយកបាន និងមិនអាចយល់ពីអត្ថន័យមេរៀនបានល្អ ពីព្រោះខ្វះសម្ភារ, ធ្វើឱ្យខាតពេលវេលា, មេរៀនវែងពេក, ធ្វើឱ្យមានភាពរញ៉េរញ៉ៃពេលម៉ោងសិក្សា។

## ៨.៣. ការសង្កេតថ្នាក់រៀននៅវិទ្យាល័យ

### *៨.៣.១. លក្ខណៈថ្នាក់រៀន*

ថ្នាក់រៀនចំនួនបីក្នុងមួយសាលាត្រូវបានជ្រើសរើស ដើម្បីធ្វើការសង្កេត គឺថ្នាក់ទី១០ ទី១១ និងទី១២។ គ្រូមុខវិជ្ជាសង្គមត្រូវបានជ្រើសរើសយកដោយចៃដន្យសម្រាប់ធ្វើជាសំណាក។ ការសង្កេតធ្វើនៅទីក្រុងភ្នំពេញបាន៧ថ្នាក់ស្មើនឹង២២% ខេត្តបាត់ដំបងបាន៩ថ្នាក់ស្មើនឹង២៨% ខេត្តតាកែវបាន៨ថ្នាក់ស្មើនឹង២៥% និងខេត្តព្រះវិហារបាន៨ថ្នាក់ស្មើនឹង២៥% ។ **ភេទ** ដែលបានធ្វើសម្ភាសន៍ មានប្រុស ៦៦% និងស្រី៣៤%។ **មុខវិជ្ជា**ដែលបានសង្កេតមានភូមិវិទ្យា២៨% អក្សរសាស្ត្រ៤១% សីលធម៌ពលរដ្ឋ៦% ប្រវត្តិវិទ្យា១៦% សេដ្ឋកិច្ច៣% ក្រៅពីនេះមានគេហកិច្ច និងភាសាអង់គ្លេស៦%។

**ចំនួនសិស្ស**ដែលបានធ្វើការសង្កេត នៅក្នុងថ្នាក់រៀនមានពី២៥នាក់ទៅ៥០នាក់មាន៦៩% ចន្លោះពី៥០នាក់ទៅ១០០នាក់មាន៣១%។ ថ្នាក់រៀនដែលសមស្របជាមួយសិស្សមានចំនួន៧៩% និងចង្អៀតមាន២២%។ ថ្នាក់រៀនដែលមានតុកៅអីគ្រប់គ្រាន់មាន៧៥% និងថ្នាក់រៀនដែលមានការខ្វះខាតមាន២៥%។

### *៨.៣.២. ឯកសារនិងសម្ភារគ្រូ-សិស្ស*

សិស្សមានសៀវភៅសិក្សាគោល ប្រើប្រាស់គ្រប់គ្រាន់ក្នុងម៉ោងសិក្សាមាន២៨% និង៧២% មានមិនគ្រប់គ្រាន់ ឬគ្មាន(១តុមានមួយក្បាល ឬ២ក្បាល)។

សម្ភារឧបទេសរបស់គ្រូក្នុងពេលបង្រៀន មានដូចជាសៀវភៅគ្រូ កម្រងសំណួរ រូបភាពក្នុងសៀវភៅក្រសួង ឯកសារសង្ខេបមេរៀន ផែនទី រូបថតផ្សេងៗមាន៩% និង៩១% គ្មានសម្ភារ ឬមានតិចតួច ឬមានតែសៀវភៅគ្រូសម្រាប់បង្រៀន។ សរុបសម្ភារឧបទេសគ្រូ និងសៀវភៅសិក្សាគោលរបស់សិស្សមាន៣៧%។

### *៨.៣.៣. សកម្មភាពពិភាក្សាក្រុម*

៦២,៥%នៃគ្រូបង្រៀនមានសំណួរឱ្យសិស្សសម្រាប់ពិភាក្សាក្រុម និង៣៧,៥%គ្មាន ឬមានតិចតួចបំផុត។

គ្រូដាក់សំណួរឱ្យសិស្សធ្វើការពិភាក្សាក្រុមធំ ដែលមានសមាជិកលើសពី១០នាក់មាន៩% ពី៥ទៅ៨នាក់មាន១៣% ធ្វើការជាដៃគូមាន៣% ចោទសួរជាបុគ្គលមាន៦៩% ធ្វើការក្រុមពី៥ទៅ៨នាក់និងចោទសួរជាបុគ្គលមាន៣% ធ្វើការជាក្រុមធំលើសពី១០នាក់ និងធ្វើការចោទឆ្លើយជាបុគ្គលមាន៣%។

៤៧%នៃក្រុមពិភាក្សារបស់សិស្សមានពេលគ្រប់គ្រាន់ដើម្បីពិភាក្សា ចំណែក៥៣%នៃក្រុមមានពេលមិនគ្រប់គ្រាន់។ ពេលវេលាគ្រប់គ្រាន់សម្រាប់តំណាងក្រុមឡើងរាយការណ៍ និងឆ្លើយបកស្រាយជាមួយមិត្តរួមថ្នាក់មាន៣៧,៥% និង៦២,៥%គ្មាន ឬមានតិចតួច។

ការងារក្រុមពិភាក្សាគោរពទៅតាមនិយាម(សមាជិក អ្នកកត់ត្រា អ្នកបកស្រាយ និង អ្នកដឹកនាំក្រុម)មាន២២% និង៧៨%មិនបានគោរព។ សមាជិកក្រុមពិភាក្សាមានចំនួនតិចតួចបំផុត ពី១ទៅ២នាក់ចូលរួមបញ្ចេញមតិយ៉ាងផុលផុសក្នុងក្រុមមាន១៩%, សមាជិកពាក់កណ្តាលនៃក្រុមបានចូលរួមយ៉ាងសកម្មមាន២៨%, និង៥៣%នៃសមាជិកក្រុមចាំតែឯកភាព។ សរុប សកម្មភាពពិភាក្សាក្រុមអនុវត្តបាន២៦%។ សកម្មភាពពិភាក្សាក្រុមដែលលោកគ្រូអ្នកគ្រូ និយមប្រើប្រាស់ជាងគេ គឺការចោទសួរជាបុគ្គលមាន៦៩%។

*៨.៣.៤. សកម្មភាពសម្របសម្រួល*

គ្រូបង្រៀន៦៦%ពន្យល់បន្ថែមឱ្យសិស្សចាប់ខ្លឹមសារមេរៀនបាន។ លោកគ្រូអ្នកគ្រូ១៦% បានជួយជំរុញលើកទឹកចិត្តសិស្សឱ្យខិតខំរៀនសូត្រ, ១%បានធ្វើកិច្ចការវាយតម្លៃសិស្ស និង ១៦%ទៀតមិនធ្វើសកម្មភាពទាំង៣ខាងលើ។

លោកគ្រូ អ្នកគ្រូ២២% បង្រៀនចប់តាមកិច្ចតែងការដែលបានគ្រោងទុក និង៧៨%បង្រៀនមិនចប់។

គ្រូបង្រៀន៣៧,៥%មានកិច្ចតែងការក្នុងពេលបង្រៀននិង៦២,៥%គ្មានកិច្ចតែងការ។

គ្រូបង្រៀន២២%បានអនុវត្តគ្រប់ជំហានទាំង៥នៃដំណើរការបង្រៀន និង៧៨%បានអនុវត្តមិនគ្រប់ជំហាន។ សរុប សកម្មភាពសម្របសម្រួលរបស់គ្រូអនុវត្តបាន២៧%។

យោងទៅលើឯកសារនិងសម្ភារគ្រូ-សិស្ស, សកម្មភាពពិភាក្សាក្រុម, និងសកម្មភាពសម្របសម្រួល លោកគ្រូអ្នកគ្រូអនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌលបាន៤៤%។




គំនូសតាងទី ៤ ទិន្នន័យសង្កេតថ្នាក់ស្តីពីការអនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌលរបស់គ្រូ

*៤.៣.៤. អនុវត្តជាក់ស្តែងនៃដំណើរការបង្រៀន*

*ជំហានទី១*

១. ពិនិត្យថ្នាក់រៀន

២. រដ្ឋបាលថ្នាក់រៀន គ្រូសួរប្រធានថ្នាក់ឱ្យឡើងរាយការណ៍ពីវត្តមាន។

*ជំហានទី២*

១. គ្រូសួរសិស្សរំលឹកមេរៀន (សួរជាបុគ្គលទៅសិស្ស២-៣នាក់)

២. កែ ឬសួរសំណួរកិច្ចការផ្ទះ

*ជំហានទី៣*

១.ចំណងជើងមេរៀន, សិក្សាមេរៀន(សិស្សអានសៀវភៅសិក្សាគោល), គ្រូដាក់សំណួរ, សិស្សស្រាវជ្រាវជាបុគ្គល, រួចឆ្លើយនិងគ្រូពន្យល់បន្ថែម, សិស្សកត់ត្រាចំណុចសំខាន់ៗដាក់សៀវភៅដោយខ្លួនឯង។

២.កត់ចំណងជើង, ចំណងជើងរង, ចំណុចសំខាន់ៗនីមួយៗនៃមេរៀនដាក់លើក្តារខៀន។ សិស្សកត់ត្រាចូលសៀវភៅសរសេរ។

៣.ចំណងជើងមេរៀន ពន្យល់មេរៀននិងលើកឧទាហរណ៍ពាក់ព័ន្ធទៅមេរៀន ស្តាប់គ្រូពន្យល់។

៤.ចំណងជើងមេរៀន និងហៅឱ្យសិស្សកត់ត្រាមេរៀន។

៥.ចំណងជើងមេរៀន ពន្យល់ពាក្យគន្លឹះ សិស្សអានខ្លឹមសារសំខាន់ៗនៃមេរៀន ដាក់សំណួរនិងចែកក្រុមពិភាក្សា តំណាងក្រុមរាយការណ៍ដោយសរសេរលើក្តារខៀន គ្រូបកស្រាយ

ចំណុចសំខាន់ៗបន្ថែម។

៦.ចំណាងជើងមេរៀន, សិស្សអានបណ្តាក់គ្នា៣ទៅ៤នាក់, គ្រូពន្យល់ពាក្យគន្លឹះ, សិស្សបែងចែកក្រុមពិភាក្សា, តំណាងក្រុមនីមួយៗឡើងរាយការណ៍, សិស្សកត់ត្រាលើក្តារខៀន, គ្រូពន្យល់បន្ថែម។

៧.ចំណាងជើងមេរៀន, សិស្សម្នាក់អានសៀវភៅពន្យល់ពាក្យគន្លឹះ, ពន្យល់និងសរសេរដាក់លើក្តារខៀន, សិស្សអានអត្ថបទមេរៀន, ដាក់សំណួរឱ្យសិស្សគិតនិងស្រាវជ្រាវ, គ្រូបន្ថែម, ហៅមេរៀនឱ្យសិស្សកត់ត្រា និងពន្យល់បន្ថែមចំណុចសំខាន់ៗ។

៨.ចំណាងជើងមេរៀន, ពន្យល់និងសរសេរលើក្តារខៀនឱ្យសិស្សកត់ត្រា, ឱ្យសិស្សអានបន្តចំណុចផ្សេងទៀត រួចពន្យល់និងឱ្យសិស្សកត់ត្រាតាម, ដាក់សំណួរឱ្យសិស្សពិភាក្សាចែកជាប្រាំក្រុមក្នុងមួយក្រុមមួយសំណួរ, តំណាងក្រុមឡើងសរសេរលើក្តារខៀន, គ្រូសម្របសម្រួល រួចឱ្យសិស្សកត់ត្រាចូលសៀវភៅ។

៩.ចំណាងជើងមេរៀន, ដាក់សំណួរសរសេរលើក្តារខៀន, សិស្សអានសៀវភៅសិក្សាគោល, ចែកក្រុមពិភាក្សា៤ក្រុម ក្នុងមួយក្រុមមួយសំណួរ, សិស្សឡើងសរសេរតាមក្រុម រួចគ្រូសរុបបន្ថែម, និងសិស្សចម្លងចូលសៀវភៅសរសេរ។

១០.ចំណាងជើងមេរៀន, សួរសំណួរទៅសិស្ស, សិស្សឆ្លើយ, គ្រូពន្យល់បន្ថែម, សិស្សអានសៀវភៅគោល, គ្រូឱ្យសិស្សស្រាវជ្រាវពាក្យគន្លឹះដោយខ្លួនឯង, គ្រូសួរទៅសិស្ស, គ្រូជួយពន្យល់បន្ថែមនិងហៅឱ្យសិស្សកត់ត្រា, ដាក់សំណួរពិភាក្សា, ចែកសិស្សជា៤ក្រុម ក្នុងមួយក្រុមមួយសំណួរ, សិស្សឡើងឆ្លើយតាមក្រុមនីមួយៗ, គ្រូពន្យល់បន្ថែមនិងឱ្យសិស្សកត់ត្រាដាក់លើក្តារខៀន។

១១.ចំណាងជើងមេរៀន, ចែកក្រុមពិភាក្សា, ចោទឆ្លើយជាបុគ្គល, គ្រូបូកសរុបមេរៀន។

១២.ចំណាងជើងមេរៀន, ពន្យល់មេរៀនពាក្យគន្លឹះ, ចែកសិស្សជាក្រុមពិភាក្សា, តំណាងក្រុមឡើងរាយការណ៍, បន្ថែមយោបល់ និងបូកសរុបមេរៀន, ឱ្យសង្ខេបមេរៀន និងកត់ត្រាចូលសៀវភៅ។

១៣.ចំណាងជើងមេរៀន, ចោទឆ្លើយជាបុគ្គល និងពន្យល់។

១៤.ចំណាងជើងមេរៀន, ពន្យល់មេរៀននិងពាក្យគន្លឹះ, ចោទឆ្លើយជាបុគ្គល។

១៥.ចំណាងជើងមេរៀន, ពន្យល់មេរៀន, ចែកសិស្សជាក្រុមពិភាក្សា, តំណាងក្រុមឡើងរាយការណ៍, គ្រូសង្ខេបមេរៀន។

១៦.ចំណាងជើងមេរៀន, ប្រើប្រាស់រូបភាពដើម្បីឱ្យសិស្សទស្សន៍ទាយមេរៀន, ពន្យល់មេរៀននិងពាក្យគន្លឹះ, ចោទឆ្លើយ, ដាក់សំណួរឱ្យពិភាក្សាដើម្បីសង្ខេបមេរៀន។

១៧.ចំណងជើងមេរៀន, ពន្យល់ពាក្យគន្លឹះ, ចោទឆ្លើយជាបុគ្គល។

១៨.ចំណងជើងមេរៀន, ឱ្យសិស្សអានមេរៀន, ពន្យល់ពាក្យគន្លឹះ, ចែកក្រុមពិភាក្សា, តំណាងក្រុមឡើងរាយការណ៍។

១៩.ចំណងជើងមេរៀន, សិស្សអានមេរៀន, ពន្យល់មេរៀននិងពាក្យគន្លឹះ, ចោទឆ្លើយជាបុគ្គល។

២០.ចំណងជើងមេរៀន, សិស្សអានមេរៀន, ពន្យល់មេរៀននិងពាក្យគន្លឹះ, ចោទឆ្លើយជាបុគ្គល, ចែកជាក្រុមតូចពិភាក្សា, គ្រូពន្យល់មេរៀន( រួចឱ្យសិស្សសង្ខេបមេរៀនខ្លួនឯងនៅជំហានទី៤)។

២១.ចំណងជើងមេរៀន, សិស្សអានមេរៀន, ពន្យល់មេរៀននិងពាក្យគន្លឹះ, ចោទឆ្លើយជាបុគ្គល, គ្រូបូកសរុប។

២២.ចំណងជើងមេរៀននិងចំណងជើងរង, ពន្យល់ពីខ្លឹមសារមេរៀន, សិស្សសួរសំណួរគ្រូ សិស្សចម្លងមេរៀនដែលគ្រូកត់ត្រាលើក្ដារខៀន។

២៣.កត់ត្រាចំណងជើង, សិស្សអានមេរៀន, គ្រូពន្យល់ខ្លឹមសារមេរៀននិងកត់ត្រាលើក្ដារខៀន, សិស្សកត់ត្រាចូលសៀវភៅ។

២៤.ចំណងជើងមេរៀន, កត់ត្រាខ្លឹមសារមេរៀននៅលើក្ដារខៀន, សិស្សកត់ត្រាចូលសៀវភៅ, គ្រូពន្យល់បន្ថែមលើខ្លឹមសារមេរៀន។

២៥.ចំណងជើងមេរៀន, គ្រូហៅមេរៀនឱ្យសិស្សកត់ត្រា, គ្រូពន្យល់ម្ដងមួយចំណុចៗ និងកត់ត្រាខ្លឹមសារមេរៀនលើក្ដារខៀន។

២៦.ចំណងជើងមេរៀន, ហៅមេរៀនឱ្យសិស្សកត់ត្រា, ដាក់សំណួរពិភាក្សាតាមក្រុម, តំណាងក្រុមឡើងសរសេរចម្លើយលើក្ដារខៀន, គ្រូកែសម្រួល, សិស្សចម្លងចូលសៀវភៅ។

២៧.ចំណងជើងមេរៀន, សិស្សអានមេរៀន, សិស្សបិទសៀវភៅរួចឆ្លើយសំណួរគ្រូជាបុគ្គល, គ្រូកត់ត្រាចម្លើយខ្លីៗលើក្ដារខៀន, គ្រូផ្ដល់យោបល់បន្ថែម។

២៨.ចំណងជើងមេរៀន, កត់ត្រាមេរៀនសង្ខេបលើក្ដារខៀន, សិស្សកត់ត្រាចូលសៀវភៅ។

២៩.ចំណងជើងមេរៀននិងចំណងជើងរង, បង្ហាញគោលបំណងសំខាន់ៗរបស់មេរៀន, ពន្យល់ពីខ្លឹមសារមេរៀន, ចោទឆ្លើយជាបុគ្គល, គ្រូពន្យល់បន្ថែម, សិស្សចម្លងមេរៀនដែលគ្រូកត់ត្រាលើក្ដារខៀន។

***ជំហានទី៤***

១.គ្រូចោទសួររំលឹកមេរៀនឡើងវិញឱ្យសិស្សបិទសៀវភៅ និងប្រើវិធីចោទឆ្លើយជាបុគ្គល។

២.សិស្សសង្ខេបមេរៀនខ្លួនឯង

*ជំហានទី៥*

១.បណ្តាំផ្ញើ



រូបទី៧ សកម្មភាពគ្រូឱ្យសិស្សអាន



រូបទី៨ សកម្មភាពគ្រូហៅឱ្យសិស្សកត់ត្រានូវចំណុចសំខាន់ៗ

# ៩. ការវិភាគ និងការបកស្រាយ

## ៩.១. របកគំហើញនិងការបកស្រាយទៅលើលទ្ធផល

### *៩.១.១. ទស្សនៈរបស់គ្រូនិងសិស្សចំពោះគោលវិធីសិស្សមជ្ឈមណ្ឌល*

*លោកគ្រូអ្នកគ្រូ:* យល់ឃើញថា ការបង្រៀន និងរៀនតាមបែបសិស្សមជ្ឈមណ្ឌលពិតជាផ្តល់ចំណេះដឹងដល់សិស្ស និងធ្វើឱ្យសិស្សអាចអភិវឌ្ឍន៍គ្រួសារនិងសង្គមបាន ។ ដូច្នេះបញ្ជាក់ថាការអប់រំបែបនេះ ធ្វើឱ្យសិស្សទទួលបាននូវការអប់រំមួយដ៏ល្អប្រសើរ។

*សិស្ស:* យល់ឃើញថា ការបង្រៀន និងរៀនតាមបែបគោលវិធីសិស្សមជ្ឈមណ្ឌលធ្វើឱ្យពួកគេមានចំណេះដឹងពិតប្រាកដ, ពួកគេមានការអភិវឌ្ឍខ្លួន។ ដូច្នេះបញ្ជាក់ថា ការអប់រំបែបនេះធ្វើឱ្យពួកគេបាននូវការអប់រំដ៏ល្អប្រសើរ។

### *៩.១.២. ចំណេះដឹង*

លទ្ធផលនៃការសិក្សាបង្ហាញថា លោកគ្រូអ្នកគ្រូដែលបានផ្តល់សម្ភាសន៍មានចំណេះដឹង ស្តីពីការបង្រៀន និងរៀនបែបគោលវិធីសិស្សមជ្ឈមណ្ឌល៩៨%។ នេះបញ្ជាក់ថា ពួកគេភាគច្រើនលើសលប់មានចំណេះដឹងច្បាស់លាស់ស្តីពីគោលវិធីសិស្សមជ្ឈមណ្ឌល។

### ៩.១.៣. ការអនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌល

លទ្ធផលនៃការសិក្សាបង្ហាញថា លោកគ្រូអ្នកគ្រូចំនួន១៩% បានអនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌលជាប្រចាំ និង៨១%អនុវត្តបានខ្លះនិងមិនបានខ្លះ។ ជារួមគឺអនុវត្តបាន៦៨% ក្នុងកម្រិតល្អបង្គួរ។ សកម្មភាពពិភាក្សាដែលគ្រូនិយមអនុវត្តជាងគេ គឺការចោទឆ្លើយជាបុគ្គល ៩៨%។ នេះបញ្ជាក់ឱ្យឃើញថា ការអនុវត្តរបស់គ្រូមិនបានល្អប្រសើរនៅឡើយទេ ដោយសារបញ្ហាប្រឈមមួយចំនួនដូចជា ចំនួនសិស្សច្រើន, ខ្វះសម្ភារឧបទេសនិងឯកសារពាក់ព័ន្ធសម្រាប់គ្រូ, សិស្សអសកម្មនិងពិបាកគ្រប់គ្រង, សមត្ថភាពនិងកង្វះគ្រូបង្រៀនមុខវិជ្ជាឯកទេស, កម្មវិធីសិក្សា ថ្នាក់រៀន, និងជីវភាពរបស់គ្រូបង្រៀន។

យោងតាមលទ្ធផលនៃការសិក្សាស្រាវជ្រាវពីសិស្សបង្ហាញថា គ្រូរបស់ពួកគេអនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌលបាន៥៩%។ សកម្មភាពពិភាក្សាដែលគ្រូនិយមប្រើជាងគេ គឺវិធីចោទឆ្លើយជាបុគ្គល៨៨% ។ នេះបញ្ជាក់ថា គ្រូរបស់ពួកគេអនុវត្តបានក្នុងកម្រិតមធ្យម គឺមិនបានល្អប្រសើរនៅឡើយទេ។ ហើយពួកគេក៏មានបញ្ហាប្រឈមមួយចំនួន ក្នុងការអនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌលដូចជា ខ្វះខាតសម្ភារ សិស្សមិនចង់សិក្សា គ្រូមិនគោរពសីលធម៌វិជ្ជាជីវៈជាដើម។

លទ្ធផលនៃការសង្កេតថ្នាក់បង្ហាញថា គ្រូអនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌលបាន៤៩%។ សកម្មភាពពិភាក្សាដែលពួកគេនិយមអនុវត្តជាងគេ គឺការចោទឆ្លើយជាបុគ្គលមាន៦៩%។ ក្នុងការអនុវត្តជាក់ស្តែង ការអនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌល តួលេខអាចទាបជាងនេះ ពីព្រោះគ្រូខ្លះបានដឹងមុន ហើយគ្រូខ្លះទៀតអនុវត្តក្នុងអំឡុងពេលមានអធិការកិច្ច ឬ មានភ្ញៀវទៅមើលតែប៉ុណ្ណោះ។ នេះបញ្ជាក់ថា នៅក្នុងការបង្រៀនជាក់ស្តែង គ្រូអនុវត្តបានកម្រិតទាបនៅឡើយ។

### ៩.១.៤. បញ្ហាប្រឈមនៃការអនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌល

#### ក. ចំនួនសិស្សច្រើន

យោងតាមស្ថិតិ និងសូចនាករអប់រំ២០១០/២០១១ របស់ការិយាល័យប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំនៃនាយកដ្ឋានផែនការ :

- វិទ្យាល័យ(ថ្នាក់ទី១០-១២)មានចំនួន២៣ ថ្នាក់រៀនមានចំនួន៣៨៣ ចំនួនសិស្សសរុប ២០២៨៥នាក់ បុគ្គលិកបង្រៀនសរុប៦០៧នាក់។
- វិទ្យាល័យ(ថ្នាក់ទី៧-១២)មានចំនួន៣៨៤ ថ្នាក់រៀនមានចំនួន១១៥២៩ សិស្សសរុបមានចំនួន៥៥៦៥៨១នាក់ និងបុគ្គលិកបង្រៀនសរុប២០៧៥៦នាក់។

យោងតាមទិន្នន័យសន្និបាតបូកសរុបលទ្ធផលការងារអប់រំ យុវជន និងកីឡាឆ្នាំសិក្សា២០០៩-

២០១០ នាថ្ងៃទី២២-២៤ ខែមីនា ឆ្នាំ២០១១ :

- ការងារប្រឡងឈមនៅមធ្យមសិក្សាបង្ហាញថា វិទ្យាល័យទូទាំងប្រទេសមាន៤០៧ក្នុងនោះ មានវិទ្យាល័យចំនួន២០៨រៀនពីរវេន គឺបណ្តាលមកពីខ្វះបន្ទប់រៀន និងខ្វះគ្រូឯកទេស។

- គ្រូកម្រិតឧត្តមមានចំនួន៩២៨២នាក់ និងសិស្សវិទ្យាល័យសរុប៥៧៦៨៦៦នាក់។ នៅមធ្យមសិក្សាទុតិយភូមិ ផលធៀបសិស្ស/គ្រូមាន៣៦ និងផលធៀបសិស្ស/ថ្នាក់មាន ៤៩,១។ ព័ត៌មាននេះបង្ហាញថា នៅវិទ្យាល័យខ្វះគ្រូកម្រិតឧត្តម និងខ្វះបន្ទប់រៀន។

តាមរយៈការសង្កេតបង្ហាញថា ថ្នាក់រៀនដែលមានសិស្សពី២៥-៥០នាក់មាន៦៩% និងពី ៥០-១០០នាក់មាន៣១%។ នៅក្នុងបញ្ហា ដែលលោកគ្រូអ្នកគ្រូបានលើកមានការខ្វះគ្រូបង្រៀន ដែលធ្វើឱ្យមានគ្រូម្នាក់បង្រៀន ៣ ឬ ៤ មុខវិជ្ជានិង ជ្រើសរើសគ្រូអនុវិទ្យាល័យមកបំពេញកង្វះគ្រូនៅវិទ្យាល័យ។

តាមនិយាមគរុកោសល្យនៅវិទ្យាស្ថានជាតិអប់រំ ផលធៀបសិស្ស/គ្រូ ២៥នាក់។

ជាសរុបតាមទិន្នន័យខាងលើបង្ហាញថា ចំនួនសិស្សច្រើនបណ្តាលមកពីខ្វះបន្ទប់រៀន និងខ្វះគ្រូមុខវិជ្ជាឯកទេស។

### *ខ. ខ្វះសម្ភារឧបទេស និងឯកសារពាក់ព័ន្ធសម្រាប់គ្រូ*

តាមទិន្នន័យសង្កេតថ្នាក់រៀនបានបង្ហាញថា សម្ភារឧបទេសរបស់គ្រូក្នុងពេលបង្រៀន ដូចជាសៀវភៅគ្រូ កម្រងសំណួរ រូបភាពក្នុងសៀវភៅក្រសួង ឯកសារសង្ខេបមេរៀន ផែនទី រូបថតផ្សេងៗមាន៩% និង៩១%គ្មានសម្ភារ ឬមានតិចតួច ឬមានតែសៀវភៅគ្រូសម្រាប់បង្រៀន។ នេះបង្ហាញថាគ្រូបង្រៀនជាង៩០%ខ្វះខាតសម្ភារសម្រាប់បង្រៀន គឺមានតែសៀវភៅគោលប៉ុណ្ណោះ។ បើយោងតាមការសម្ភាសជាមួយគ្រូបង្រៀនបង្ហាញថា មូលហេតុដែលធ្វើឱ្យគ្រូផ្នែកសង្គមខ្វះសម្ភារបណ្តាលមកពីសាលាគ្មានថវិកាសម្រាប់ចំណាយទិញ ឬបង្កើតសម្ភារ។ ចំពោះគ្រូបង្រៀនវិញ ភាគច្រើនពួកគាត់មិនបានផលិតសម្ភារសម្រាប់បង្រៀនខ្លួនឯងទេ ដោយបញ្ហាជីវភាព។ពួកគាត់បានប្រើប្រាស់ពេលសម្រាប់ការងារទី២ ដើម្បីរកថវិកាបន្ថែមសម្រាប់ចិញ្ចឹមគ្រួសារ។

ចំពោះបណ្ណាល័យសាលារៀននៅមធ្យមសិក្សា គឺមានតែសៀវភៅគោល និងវចនានុក្រមសម្តេចជួនណាតប៉ុណ្ណោះ។

យោងតាមសន្និបាតបូកសរុបលទ្ធផលការងារអប់រំ យុវជន និងកីឡាឆ្នាំសិក្សា២០០៩-២០១០ និងលើកទិសដៅឆ្នាំសិក្សា២០១០-២០១១ នាថ្ងៃទី២២ដល់២៤ ខែមីនា ឆ្នាំ២០១១ ស្តីពីបញ្ហាប្រឡងឈម

របស់ការងារមធ្យមសិក្សា មានបញ្ហាប្រឈមមួយក្នុងបញ្ហាប្រឈមទាំង៤ គឺខ្វះសៀវភៅសិក្សាពិសេសសៀវភៅសិក្សាគោលសម្រាប់កម្មវិធីសិក្សាថ្មី។

យោងតាមទិន្នន័យ ស្ដីពីការងារអភិវឌ្ឍន៍កម្មវិធីសិក្សាលទ្ធផលធៀបទៅនឹងទិសដៅឆ្នាំសិក្សា ២០០៩-២០១០បង្ហាញថា នាយកដ្ឋានបានផ្គត់ផ្គង់សៀវភៅសិក្សាគោលផ្នែកសង្គមថ្នាក់ទី១០ និងទី១១ គ្រប់មុខវិជ្ជា។ ប៉ុន្តែនៅក្នុងបញ្ហាប្រឈមបង្ហាញថា ការផ្គត់ផ្គង់សៀវភៅមិនគ្រប់គ្រាន់ និងមិនទាន់ពេលវេលា។

យោងតាមទិន្នន័យសន្និបាតខាងលើ ស្ដីពីលទ្ធផលធៀបទៅនឹងទិសដៅឆ្នាំសិក្សា២០០៩-២០១០ ការងារបោះពុម្ព និងចែកសៀវភៅ បង្ហាញថាអង្គភាពនេះបានអភិវឌ្ឍសៀវភៅសម្រាប់សិស្សថ្នាក់ទី១០ មុខវិជ្ជាភាសាខ្មែរ និងសិក្សាសង្គម បានអភិវឌ្ឍសៀវភៅសិស្សថ្នាក់ទី១១ មុខវិជ្ជាភាសាខ្មែរ ភូមិវិទ្យា ប្រវត្តិវិទ្យា សីលធម៌-ពលរដ្ឋវិជ្ជា និងសេដ្ឋកិច្ច កំពុងអភិវឌ្ឍសៀវភៅសិក្សាថ្នាក់ទី១២ មុខវិជ្ជាភាសាខ្មែរ ភូមិវិទ្យា ប្រវត្តិវិទ្យា សីលធម៌-ពលរដ្ឋវិជ្ជា និងសេដ្ឋកិច្ច និងបានដឹកជញ្ជូនសៀវភៅសិក្សាគោល៤០៦៣១៤០ច្បាប់ជូនសាលារៀនទូទាំងប្រទេស ព្រមទាំងបានបោះពុម្ពសៀវភៅសិស្សគោល៦៦៦ ៣០០ច្បាប់សម្រាប់លក់ជូនអតិជនទូទៅ។

បញ្ហាប្រឈមដែលបណ្ដាលឱ្យការផ្គត់ផ្គង់សៀវភៅយឺត គឺនីតិវិធីដេញថ្លៃបោះពុម្ពសៀវភៅសិក្សាមានការយឺតយ៉ាវ។

យោងតាមលទ្ធផលនៃការសង្កេតបង្ហាញថា សិស្សដែលមានសៀវភៅសិក្សាគោលគ្រប់គ្រាន់ (គ្រប់មុខវិជ្ជា, សៀវភៅកម្មវិធីចាស់និងថ្មី)មាន២៨% និងមិនបានគ្រប់គ្រាន់ឬគ្មានមានចំនួន៧២% ។

សរុបមកមូលហេតុនៃការខ្វះខាតសៀវភៅសិក្សាគោលបណ្ដាលមកពីនាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សាផ្គត់ផ្គង់សៀវភៅមិនគ្រប់គ្រាន់ មិនទាន់ពេលវេលា នីតិវិធីដេញថ្លៃបោះពុម្ពសៀវភៅសិក្សា និងការងារបោះពុម្ព និងចែកផ្សាយមានការយឺតយ៉ាវ ។

### *គ. សិស្សអសកម្ម និងពិបាកគ្រប់គ្រង*

យោងតាមបញ្ហាប្រឈមរបស់គ្រូ-សិស្ស លទ្ធផលស្រាវជ្រាវរកឃើញថា មូលហេតុនៃសិស្សអសកម្ម និងពិបាកគ្រប់គ្រងបណ្ដាលមកពី :

ទី១ វិន័យ និងគណៈគ្រប់គ្រងវិទ្យាល័យមិនអនុវត្តវិន័យឱ្យបានតឹងរ៉ឹង ឬមានចំណុចខ្សោយមួយចំនួនដែលធ្វើឱ្យសិស្សមិនគោរពវិន័យ។ឧទាហរណ៍ នៅវិទ្យាល័យព្រះមុនីវង្សខេត្តបាត់ដំបងសិស្ស មានវិន័យបណ្ដាលមកពីគណៈគ្រប់គ្រងមានភាពជាអ្នកដឹកនាំ និងមានការចូលរួមពីគ្រូ។

ទី២ គ្រូមានចំណុចខ្សោយមួយចំនួន ដូចជាគ្រូមិនពិនិត្យកិច្ចការផ្ទះរបស់សិស្ស គ្រូឈប់ច្រើន

គ្រូយល់ខ្លឹមសារមេរៀនមិនច្បាស់លាស់ គ្រូមិនសូវមានទេពកោសល្យគ្រប់គ្រាន់ក្នុងការបង្រៀន គ្រូបង្រៀនដោយមិនបានរៀបចំទុកជាមុន និងគ្រូបង្រៀនឱ្យចប់តែម៉ោង។ តាមទិន្នន័យសង្កេតបង្ហាញថា គ្រូដែលបង្រៀនមានកិច្ចតែងការមានតែ២២% និងគ្រូអនុវត្តបានគ្រប់ជំហានទាំង៥បាន៣៧,៥%

ក្រៅពីនេះ នៅមានមូលហេតុមួយចំនួនទៀតដូចជា គ្រូឱ្យសិស្សបង់លុយសម្រាប់មេរៀនបញ្ហាវត្តមានសិស្សនិងពិន្ទុ។ល។បាតុភាពដែលកើតមានពេលប្រឡងនានា និងមុខវិជ្ជាសង្គម សិស្សមិនយកចិត្តទុកដាក់ដោយសារនៅពេលប្រឡង ពួកគេអាចបើកចម្លងបាន។ ម៉្យាងទៀត មុខវិជ្ជាសង្គមមានពិន្ទុតិចពេក។គ្រូមួយចំនួនបានបើកវគ្គបំប៉នក្រៅម៉ោងសិក្សា ដោយចង់បានប្រជាប្រិយភាពនិងយកចិត្តសិស្ស។ គ្រូមួយចំនួន គឺមិនហ៊ានណែនាំសិស្សទេក្នុងម៉ោងបង្រៀនរដ្ឋ ពីព្រោះខ្លាចសិស្សរត់ទៅរៀនជាមួយគ្រូផ្សេងទៀត ដែលធ្វើឱ្យពួកគាត់បាត់ចំណូល។

ទី៣ សិស្សខ្លះខ្មាស់អៀនមិនផ្លាស់ប្តូរទម្លាប់បាន សិស្សមិនយកចិត្តទុកដាក់នឹងការសិក្សា មិនស្រឡាញ់ការសិក្សា សិស្សមិនចង់អភិវឌ្ឍខ្លួន សិស្សអាងលើអាណាព្យាបាល និងភ្លើតភ្លើនតាមសង្គមហួសហេតុ។ តាមទិន្នន័យសង្កេតបង្ហាញថា ក្នុងការពិភាក្សាជាក្រុម សិស្សចំនួន៥៣% ចាំតែឯកភាព។

សរុបមក សិស្សអសកម្ម និងពិបាកគ្រប់គ្រងបណ្តាលមកពីវិន័យ និងគណៈគ្រប់គ្រងធូរលុង គ្រូមានចំណុចខ្សោយ និងសិស្សមិនចង់រៀនដោយខ្លួនឯង។

***ឃ. សមត្ថភាព និងកង្វះគ្រូបង្រៀនមុខវិជ្ជាឯកទេស***

***១. កង្វះគ្រូបង្រៀនមុខវិជ្ជាឯកទេស***

ទី១ ក្រសួងផ្តល់គ្រូកម្រិតឧត្តមទៅឱ្យវិទ្យាល័យមួយចំនួនមិនគ្រប់គ្រាន់ ឧទាហរណ៍នៅវិទ្យាល័យ ជាំក្សាន្តមានគ្រូកម្រិតឧត្តមតែ៤នាក់ប៉ុណ្ណោះ។

ទី២ ក្រសួងជ្រើសរើសគ្រូបង្រៀន១ឆ្នាំ៥០០០នាក់ ប៉ុន្តែបើគិតពីបុគ្គលិកអប់រំ លំហែមាតុភាព (២៧២៦នាក់) បុគ្គលិកព្យាបាលជំងឺ(៥៨៨នាក់) ច្បាប់ទៅបរទេស(៦៦នាក់) ព្យួរការងារ(៨១៤នាក់) លុបឈ្មោះ(១១៧៦នាក់) មរណភាព(៣៤៩នាក់) បោះបង់ការងារ(៦៦៨នាក់) ប្តូរទៅក្រសួងផ្សេង (៦៩នាក់) បុគ្គលិកចូលនិវត្តន៍(១៩៨៨នាក់) សរុបមាន(៨៤៤៤នាក់)។ ក្រៅពីនោះ គ្រូមានតែឈ្មោះ ប៉ុន្តែមនុស្សជាក់ស្តែងទៅធ្វើការងារផ្សេង នេះមិនទាំងរាប់បញ្ចូលចំនួនគ្រូថ្មីជ្រើសរើសមិនគ្រប់ចំនួន និងមិនទៅបម្រើការជាគ្រូបង្រៀនផង។

ដូច្នេះ កង្វះគ្រូនៅវិទ្យាល័យ បណ្តាលមកពីក្រសួងផ្តល់មិនគ្រប់គ្រាន់, ការជ្រើសរើសគ្រូប្រចាំឆ្នាំមិនគ្រប់តាមតម្រូវការជាក់ស្តែង, ចំនួនគ្រូកម្រិតឧត្តមមានតិច សិស្សមានចំនួនច្រើន និង

ចំនួនជាតួលេខនៃបុគ្គលិកមានចំនួនច្រើន ប៉ុន្តែអ្នកបំពេញការងារជាក់ស្តែងមានចំនួនតិច។

*២. សមត្ថភាពគ្រូ*

យោងតាមការងារបោះពុម្ព និងចែកផ្សាយនាឆ្នាំសិក្សា២០០៩-២០១០ បានបង្ហាញថា មុខវិជ្ជាផ្នែកសង្គមទើបតែមានសៀវភៅសិក្សាគោលសម្រាប់សិស្សថ្នាក់ទី១០ និងទី១១។ លើមុខវិជ្ជាភាសាខ្មែរ និងសិក្សាសង្គម កំពុងអភិវឌ្ឍន៍សៀវភៅសិស្សថ្នាក់ទី១២មុខវិជ្ជាភាសាខ្មែរ ភូមិវិទ្យា ប្រវត្តិវិទ្យា សីលធម៌-ពលរដ្ឋ សេដ្ឋកិច្ច។ នេះមានន័យថា សៀវភៅសិក្សាគោលសម្រាប់សិស្សគឺមាន ប៉ុន្តែសៀវភៅគ្រូមិនទាន់មាននៅឡើយ។ យោងតាមបញ្ហាប្រឈមនៃការងារមធ្យមសិក្សាបង្ហាញថា គ្រូមិនទាន់បានតម្រង់ទិសការប្រើប្រាស់កម្មវិធីសិក្សាថ្មីនៅឡើយ។

ដោយសារគ្មានសៀវភៅគ្រូ និងគ្មានការតម្រង់ទិស ការប្រើប្រាស់កម្មវិធីថ្មីនេះធ្វើឱ្យគ្រូជួបប្រទះបញ្ហាពាក្យគន្លឹះ និងខ្លឹមសារថ្មីមួយចំនួននៅក្នុងសៀវភៅសិក្សាថ្មី។

បញ្ហាសមត្ថភាពគ្រូ បណ្តាលមកពីកម្រិតយល់ដឹងរបស់គ្រូអនុវិទ្យាល័យមួយចំនួនទៅបង្រៀននៅវិទ្យាល័យនៅមានកម្រិត ដូច្នេះកម្រិតយល់ដឹងរបស់គាត់មិនបានឆ្លងកាត់ការរៀនសូត្រដល់កម្រិតឧត្តមសិក្សា។

ដូច្នេះបញ្ហាសមត្ថភាពគ្រូនៅមានកម្រិត បណ្តាលមកពីលោកគ្រូអ្នកគ្រូអនុវត្តកម្មវិធីសិក្សាថ្មីគ្មានសៀវភៅគោលសម្រាប់គ្រូ គ្មានការតម្រង់ទិសការប្រើប្រាស់កម្មវិធីថ្មី និងការយល់ដឹងមុខវិជ្ជាឯកទេសរបស់គ្រូអនុវិទ្យាល័យមួយចំនួន ទៅបង្រៀននៅវិទ្យាល័យនៅមានកម្រិតនៅឡើយ។

*ង. កម្មវិធីសិក្សា និងថ្នាក់រៀន*

*១. កម្មវិធីសិក្សា*

យោងតាមលទ្ធផលនៃការស្រាវជ្រាវជាមួយសិស្សបានបង្ហាញឱ្យឃើញថា មានមេរៀនខ្លះវែងពេក និងជ្រៅ ធ្វើឱ្យសិស្សពិបាកយល់ នេះបណ្តាលមកពីឆ្នាំ ដែលចុះទៅធ្វើការសិក្សា គឺជាឆ្នាំដំបូងនៃការអនុវត្តកម្មវិធីថ្មី ដែលមានការបែងចែកមុខវិជ្ជាវិទ្យាសាស្ត្រ និងមុខវិជ្ជាសង្គម ហើយខ្វះខាតសៀវភៅសិក្សាគោលសម្រាប់សិស្សជាច្រើន, គ្រូមិនទាន់មានសៀវភៅគោលសម្រាប់គ្រូ គ្រូមិនទាន់យល់ពីកម្មវិធី និងអនុវត្តកម្មវិធីថ្មីមិនទាន់បានល្អ និងនៅជួបប្រទះបញ្ហានានា។ ដូច្នេះកម្មវិធីថ្មីទើបតែអនុវត្ត កម្មវិធីសិក្សាអនុវត្តមិនទាន់រលូនទាំងស្រុងនៅឡើយ ក្រសួងអប់រំយុវជន និងកីឡាកំពុងតែកែ លម្អឡើងវិញ ។

យោងតាមសន្និបាតអប់រំ២០១១បង្ហាញថា កម្មវិធីសិក្សាថ្នាក់ទី១១ និងទី១២ផ្នែកវិទ្យាសាស្ត្រ និងវិទ្យាសាស្ត្រសង្គមកំពុងកែសម្រួល។

*២. ថ្នាក់រៀន*

យោងតាមលទ្ធផលនៃការស្រាវជ្រាវខាងលើ លោកគ្រូអ្នកគ្រូបង្ហាញថាមានថ្នាក់រៀនខ្លះទ្រុឌទ្រោម និងតុកៅអីវែងៗមិនសមស្របតាមការបង្រៀនបែបគោលវិធីសិស្សមជ្ឈមណ្ឌល។

យោងតាមលទ្ធផលនៃការសង្កេតថ្នាក់រៀន ថ្នាក់រៀនចង្អៀតមាន២២% និងថ្នាក់រៀនដែលខ្វះតុកៅអីមាន២៥%។

យោងតាមទិន្នន័យខាងលើ ថ្នាក់រៀន តុកៅអី ចំនួនសិស្ស នៅវិទ្យាល័យមួយចំនួន មិនសមស្របទៅនឹងការបង្រៀនបែបគោលវិធីសិស្សមជ្ឈមណ្ឌល។

សរុប បញ្ហាកម្មវិធីសិក្សាដែលលោកគ្រូអ្នកគ្រូបានលើកឡើង បណ្តាលមកពីឆ្នាំដំបូងនៃការអនុវត្តកម្មវិធីថ្មី, ការចែកមុខវិជ្ជាវិទ្យាសាស្ត្រនិងមុខវិជ្ជាសង្គម, ខ្វះខាតសៀវភៅគោលសម្រាប់សិស្ស, គ្មានសៀវភៅគោលសម្រាប់គ្រូ និងកម្មវិធីសិក្សាមួយចំនួនត្រូវកែសម្រួលឡើងវិញ។ ចំពោះបញ្ហាថ្នាក់រៀនវិញ បណ្តាលមកពីបន្ទប់ខ្លះចាស់ពេក តុកៅអីមិនសមស្រប និងមានចំនួនសិស្សច្រើនក្នុងថ្នាក់រៀន។

*៣. ជីវភាពគ្រូបង្រៀន*

យោងតាមលទ្ធផលនៃការស្រាវជ្រាវបង្ហាញថា ប្រាក់ខែគ្រូបង្រៀនចាយមិនគ្រប់គ្រាន់ ដែលជំរុញឱ្យគ្រូបង្រៀនជ្រើសមុខវិជ្ជា និងប្រកបមុខរបរទី២ ដូចជាបង្រៀនតាមសាលាឯកជន ជួយរកស៊ីប្រពន្ធកូន ធ្វើស្រែចំការ បម្រើការងារក្រុមហ៊ុន ឬអង្គការនានា បង្កើតគម្រោងខ្លួនឯង។ល។ ដែលជះឥទ្ធិពលដល់គុណភាពបង្រៀនរបស់ពួកគាត់ដល់សិស្សវិទ្យាល័យ។

យោងតាមបញ្ហាប្រឈមគ្រូ-សិស្សលទ្ធផលស្រាវជ្រាវបង្ហាញថា នៅសាលាមួយចំនួនគ្រូឱ្យសិស្សបង់លុយសម្រាប់មេរៀន, គ្រូបើកវគ្គបំប៉នក្រៅម៉ោងសិក្សា, បញ្ហាអវត្តមាន និងពិន្ទុរបស់សិស្ស និងបាតុភាពផ្សេងៗដែលបានកើតមានពេលប្រឡងនានា។ គ្រូបង្រៀនមិនបានរៀបចំទុកជាមុន គ្រូមកបង្រៀនយឺតម៉ោងនិងមិនមកបង្រៀន គ្រូបង្រៀនឱ្យតែចប់ម៉ោង។ នេះបង្ហាញថាមានគ្រូមួយចំនួនឆ្លៀតឱកាសប្រើប្រាស់អាជីព ដើម្បីរកកម្រៃបន្ថែមនៅក្នុងសាលារៀន និងនៅពេលប្រឡងម្តងៗ។ ទាំងនេះធ្វើឱ្យប៉ះពាល់ដល់សីលធម៌វិជ្ជាជីវៈគ្រូបង្រៀន ដែលធ្វើឱ្យសង្គមមើលគ្រូក្នុងខ្សែភ្នែកមិនល្អ។

សរុបមក បញ្ហាជីវភាពខ្វះខាតនេះបានបង្ខំចិត្តឱ្យគ្រូបង្រៀនប្រកបមុខរបរទី២ និងហ៊ានធ្វើសកម្មភាពមួយចំនួនខុសពីអាជីពជាគ្រូបង្រៀន ដែលធ្វើឱ្យប៉ះពាល់ដល់ការសិក្សារបស់សិស្ស។

***សម្គាល់:*** ការសង្កេតថ្នាក់មិនធ្វើសុពលកម្មទៅលើចម្លើយនៃការអនុវត្តរបស់សិស្សនិងគ្រូឡើយ។

## ១០. កំហិតភាពនៃការស្រាវជ្រាវ និងចំណុចដែលត្រូវសិក្សាបន្ត

*កំហិតភាពនៃការស្រាវជ្រាវ*

- សំណួរស្រាវជ្រាវនៅមានចំណុចខ្វះខាត និងកន្លែងខ្លះពិបាកវិភាគ។
- សំណាកនៃការស្រាវជ្រាវតិចជាង១០%។
- ខ្វះខាតឯកសារយោងជាច្រើនដូចជា ទិន្នន័យចំនួនគ្រូកម្រិតឧត្តមមុខវិជ្ជាសង្គម, ចំនួនសិស្សវិទ្យាល័យថ្នាក់ទី១០ ទី១១ និងទី១២, ស្តង់ដាផលធៀបសិស្ស/គ្រូនៅវិទ្យាល័យ, ចំនួនគ្រូកម្រិតឧត្តមផ្នែកសង្គមដែលបង្រៀននៅវិទ្យាល័យ ហើយបោះបង់ ព្យួរការងារ ចូលនិវត្តន៍ មរណភាព និងតម្រូវការគ្រូកម្រិតឧត្តមផ្នែកសង្គម, ចំនួនថ្នាក់រៀនដែលទ្រុឌទ្រោម និងតុកៅអីដែលមិនសមស្រប។ល។
- គ្មានករណីសិក្សាលើបញ្ហាមួយចំនួន

*ចំណុចដែលត្រូវសិក្សាបន្ត*

- ការចំណាយថវិកាសម្រាប់សាលារៀននីមួយៗសម្រាប់ទិញសម្ភារ។
- កម្មវិធីថ្មី និងការកែលម្អកម្មវិធីថ្មី។
- ទំហំនៃការខ្វះខាតសៀវភៅសិក្សាគោលជាក់ស្តែង។
- ថវិកា សម្ភារ និងឯកសារសម្រាប់បណ្ណាល័យ។
- ចំនួនគ្រូកម្រិតឧត្តមមានអាជីពចាប់ពីពីរឡើងទៅនិងផលប៉ះពាល់។
- គម្រោងសាកល្បង សម្រាប់សេវាឯកជនចំពោះវិស័យអប់រំ(វិទ្យាល័យ)។

## ១០. សន្និដ្ឋាន

លោកគ្រូអ្នកគ្រូនិងសិស្សយល់ថា ការបង្រៀន និងរៀនតាមបែបគោលវិធីសិស្សមជ្ឈមណ្ឌលធ្វើឱ្យសិស្សទទួលបាននូវការអប់រំដ៏ល្អប្រសើរ។

លោកគ្រូអ្នកគ្រូភាគច្រើនលើសលប់មានចំណេះដឹងស្តីពីគោលវិធីសិស្សមជ្ឈមណ្ឌល ប៉ុន្តែការអនុវត្តជាក់ស្តែងនៅមានកម្រិតទាបនៅឡើយ ដោយសារមានបញ្ហាប្រឈមជាច្រើន។ បញ្ហាប្រឈមទាំងនោះរួមមាន ចំនួនសិស្សច្រើននៅក្នុងថ្នាក់រៀន ខ្វះសម្ភារឧបទេសនិងឯកសារពាក់ព័ន្ធសម្រាប់គ្រូ ខ្វះសៀវភៅគោលសម្រាប់សិស្ស សិស្សមួយចំនួនអសកម្មនិងពិបាកក្នុងការគ្រប់គ្រងសមត្ថភាពគ្រូនៅមានកម្រិតដោយសារគ្រូមួយចំនួននៅអនុវិទ្យាល័យត្រូវបង្រៀននៅវិទ្យាល័យ ហើយវិទ្យាល័យខ្លះខ្វះគ្រូមុខវិជ្ជាឯកទេស ការអនុវត្តកម្មវិធីសិក្សាជួបប្រទះបញ្ហាខ្លះៗ បន្ទប់រៀនខ្លះទ្រុឌទ្រោម តុកៅអីមិនសមស្រប និងមានសម្ពាធជីវភាពគ្រូបង្រៀន។

## ១១. អនុសាសន៍

នៅវិទ្យាល័យនៃប្រទេសកម្ពុជា ដើម្បីឱ្យការអនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌលបានប្រសើរជាងមុន ត្រូវយកចិត្តទុកដាក់ចំណុចមួយចំនួនដូចខាងក្រោម ៖

ទី១ ពិនិត្យ ឬធានាការអនុវត្តគោលនយោបាយ និយាមគរុកោសល្យ និងផលធៀបសិស្ស/ថ្នាក់រៀន។

ទី២ ផ្គត់ផ្គង់សម្ភារឧបទេសសម្រាប់គ្រូឱ្យបានគ្រប់គ្រាន់ ព្រមទាំងបំប៉នគាត់ឱ្យចេះប្រើប្រាស់ឧបករណ៍ទាំងនោះ។

ទី៣ ផ្គត់ផ្គង់សៀវភៅគោលឱ្យបានគ្រប់គ្រាន់ និងទាន់ពេលវេលាសម្រាប់សិស្ស-គ្រូ។

ទី៤ ផ្តល់ឱ្យបណ្ណាល័យនូវសៀវភៅសិក្សាគ្រប់គ្រាន់ និង ឯកសារផ្សេងៗបន្ថែមសម្រាប់ការរៀនសូត្ររបស់សិស្ស និងការស្រាវជ្រាវរបស់គ្រូ ។

ទី៥ ផ្តល់សេវា Internet នៅបណ្ណាល័យសាលារៀនមធ្យមសិក្សាសម្រាប់កិច្ចការស្រាវជ្រាវ និងបញ្ចូលការបង្រៀនពីរបៀបប្រើប្រាស់ Internet ក្នុងកម្មវិធីបណ្តុះបណ្តាលគរុនិស្សិតនៅវិទ្យាស្ថានជាតិអប់រំ ។

ទី៦ លើកទឹកចិត្តគ្រូរកវិធីសាស្រ្តថ្មី ដើម្បីសិស្សចូលរួមក្នុងដំណើរការសិក្សា។

ទី៧ បង្កើនការជ្រើសរើសគ្រូកម្រិតឧត្តមប្រកបដោយសមត្ថភាពគ្រប់មុខវិជ្ជា។

ទី៨ បង្កើនប្រាក់បៀវត្សគ្រូឱ្យដល់កម្រិតមួយសមស្រប ដោយផ្សារភ្ជាប់ជាមួយអតិថរណា។

ទី៩ រៀបចំ និងបណ្តុះបណ្តាលគ្រូតាមមុខវិជ្ជា មុនអនុវត្តកម្មវិធីថ្មី ។

ទី១០ បង្កើនការត្រួតពិនិត្យ និងការគាំទ្រដល់គ្រូនៅតាមថ្នាក់រៀន។

**ឯកសារយោង**


១. ទ្រឹស្តីរបស់ចិត្តវិទូមនុស្សនិយម និងគោលវិធីសិស្សមជ្ឈមណ្ឌល ដោយបណ្ឌិត អ៊ឹម កុច ឆ្នាំ១៩៩៩ ។

២. ឯកសារជំនួយស្មារតីដល់គ្រូបង្រៀនមធ្យមសិក្សា ស្តីពីវិធីសាស្ត្របង្រៀន ដោយ ហាប់ ផល្លី និង ឯម សូត្រ ឆ្នាំ២០០៣ ។

៣. គរុកោសល្យសម្រាប់បណ្តុះបណ្តាលសាស្ត្រាចារ្យឧត្តមសិក្សា មធ្យមសិក្សា អធិការបឋម អធិការមធ្យមសិក្សា និងមន្ត្រីអប់រំ ដោយបណ្ឌិត ចាន់ រដ្ឋសុជា ឆ្នាំ២០០៥ ។

៤. ផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ២០០៩/២០១៣, ឆ្នាំ២០១០ ។

៥. ស្ថិតិ និងសូចនាករអប់រំ ២០១០/២០១១, ការិយាល័យប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ, នាយកដ្ឋានផែនការ ។

៦. កម្មវិធីសិក្សាគោលសម្រាប់មធ្យមសិក្សាទុតិយភូមិ, នាយកដ្ឋានស្រាវជ្រាវគរុកោសល្យ ឆ្នាំ២០០៨ ។

៧. សន្និបាតបូកសរុបលទ្ធផលការងារអប់រំ យុវជន និងកីឡាឆ្នាំសិក្សា២០០៩-២០១០ ។